ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំស្តីពី
# មគ្គុទ្ទេសក៍អាជីព
# និងការផ្តល់ប្រឹក្សាណែនាំ
# សម្រាប់មធ្យមសិក្សាទុតិយភូមិ

ព.ស.២៥៦២ គ.ស.២០១៨

# បុព្វកថា

ស្ថិតក្នុងបរិការណ៍នៃសាកលភាវូបនីយកម្ម ការកសាងមូលធនមនុស្សគឺជាលក្ខខណ្ឌចាំបាច់មួយដែលមិនអាចខ្វះបានសម្រាប់កម្ពុជា។ ការអប់រំ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃការកសាងធនធានមនុស្សប្រកបដោយគុណភាព ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅនៃការអភិវឌ្ឍជាតិលើគ្រប់វិស័យ ឱ្យទទួលបានជោគជ័យដ៏ត្រចះត្រចង់។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំនានា សំដៅគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សតាមរយៈការងាររៀន និងបង្រៀនឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរ។ ក្នុងស្មារតីនេះ សៀវភៅណែនាំស្ដីពី **«មគ្គុទ្ទេសក៍អាជីព និងការផ្ដល់ប្រឹក្សាណែនាំ សម្រាប់មធ្យមសិក្សាទុតិយភូមិ»** គឺជាឯកសារថ្មីមួយ ត្រូវបានរៀបចំចងក្រងឡើង ដើម្បីជាផ្នែកមួយនៃការជួយគាំទ្រសិស្សានុសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ឱ្យមានស្មារតីស្រឡាញ់ការសិក្សា ចំណេះដឹង និងមានជំនាញគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈទទួលយករបត់នៃការផ្លាស់ប្ដូរស្ថានភាពក្នុងជីវិត នាពេលអនាគត។

សៀវភៅនេះ បានរៀបចំឡើងដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់បង្រៀនមេរៀនប្រឹក្សាអាជីព និងផ្ដល់ការប្រឹក្សាយោបល់ដល់សិស្សានុសិស្សជាលក្ខណៈឯកជនផងដែរ។ ខ្លឹមសារសំខាន់ៗនៅក្នុងសៀវភៅណែនាំនេះ ចែកចេញជា ៤ ផ្នែកគឺ៖ ផ្នែកទី១ ជំនាញក្នុងការសិក្សា (ថ្នាក់ទី១០) ផ្នែកទី២ ការរៀបចំផែនការអាជីព (ថ្នាក់ទី១១) ផ្នែកទី៣ ជំនាញក្នុងជីវិតការងារ (ថ្នាក់ទី១២) និងផ្នែកទី៤ ឧបសម្ព័ន្ធ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា លោកគ្រូ អ្នកគ្រូផ្ដល់ប្រឹក្សាអាជីព និងសិស្សានុសិស្សទាំងអស់ នឹងយកចិត្តទុកដាក់ប្រើប្រាស់សៀវភៅណែនាំនេះ ដើម្បីបានជាប្រយោជន៍ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីទទួលបានជោគជ័យថ្មីៗបន្ថែមទៀតក្នុងភារកិច្ចការងារ និងការសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីជំនាញនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ជាពិសេសអង្គការជំនួយព្រះវិហារនៃប្រទេសហ្វាំងឡង់ និងអ្នកស្ម័គ្រចិត្ត ដែលបានរួមចំណែកផ្ដល់កិច្ចសហការគាំទ្រលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដែលបានធ្វើឱ្យសៀវភៅដ៏មានសារៈសំខាន់នេះ លេចរូបរាងឡើង។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

# មាតិកា


បុព្វកថា.......................................................................................................ii
មាតិកា ..........................................................................................................iii
ផ្នែកទី១ ជំនាញក្នុងការសិក្សា (ថ្នាក់ទី១០) ............................................................ ១
មេរៀនទី១ ស្វាគមន៍មកកាន់ថ្នាក់ទី១០ ឬឆ្នាំទី១ ............................................ ២
មេរៀនទី២ ស្វាគមន៍មកកាន់ថ្នាក់ទី១០ (តចប់)............................................... ៦
មេរៀនទី៣ ការរៀបចំសណ្ដាប់ធ្នាប់ ១.......................................................... ៩
មេរៀនទី៤ ការរៀបចំសណ្ដាប់ធ្នាប់ ២ .........................................................១១
មេរៀនទី៥ ការរៀបចំសណ្ដាប់ធ្នាប់ ៣.......................................................... ១៣
មេរៀនទី៦ ការគ្រប់គ្រងពេលវេលា ..............................................................១៥
មេរៀនទី៧ ក្លឹបមុខវិជ្ជា .............................................................................១៨
មេរៀនទី៨ ការងារគម្រោង ១ ....................................................................១៩
មេរៀនទី៩ ការងារគម្រោង ២.....................................................................២១
មេរៀនទី១០ ការងារគម្រោង ៣................................................................... ២២
មេរៀនទី១១ ការងារគម្រោង ៤ .................................................................. ២២
មេរៀនទី១២ ការកំណត់ និងសម្រេចគោលដៅ..................................................២៣
មេរៀនទី១៣ ការប៉ាន់ស្មាន និងការដាក់ពិន្ទុ....................................................២៦
មេរៀនទី១៤ ការវាយតម្លៃអំពីជំនាញសិក្សា.....................................................២៩
មេរៀនទី១៥ វិធីសាស្ត្ររៀនដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា ១ .......................... ៣១
មេរៀនទី១៦ វិធីសាស្ត្ររៀនដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា ២ .......................... ៣៧
មេរៀនទី១៧ ការជំរុញទឹកចិត្ត ឥរិយាបថ សមត្ថភាព ១ .......................................៤១
មេរៀនទី១៨ ការជំរុញទឹកចិត្ត ឥរិយាបថ សមត្ថភាព ២.........................................៤៤
មេរៀនទី១៩ ជំនាញធ្វើឱ្យការចងចាំប្រសើរឡើង................................................៤៦
មេរៀនទី២០ ការអាន ................................................................................៥០
មេរៀនទី២១ ការធ្វើកំណត់ត្រា ....................................................................៥២
មេរៀនទី២២ ការស្ដាប់ ...............................................................................៥៥
មេរៀនទី២៣ ការប្រឡង ............................................................................. ៥៧
មេរៀនទី២៤ ការធ្វើបទបង្ហាញ ....................................................................៥៩
មេរៀនទី២៥ ការសរសេរ ............................................................................៦១
មេរៀនទី២៦ កំណត់ហេតុសិក្សា .................................................................. ៦៣
មេរៀនទី២៧ ការស្រាវជ្រាវព័ត៌មាន...............................................................៦៥
មេរៀនទី២៨ បញ្ហាប្រឈមក្នុងការសិក្សា..........................................................៦៦
មេរៀនទី២៩ ការដោះស្រាយបញ្ហាសម្ភាធ ១ .....................................................៦៨
មេរៀនទី៣០ ការដោះស្រាយបញ្ហាសម្ពាធ ២ .................................................... ៧៣
មេរៀនទី៣១ កត្តាប៉ះពាល់ដល់ការរៀនសូត្រ .................................................... ៧៥
មេរៀនទី៣២ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ១ ................................................ ៧៨
មេរៀនទី៣៣ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ២ .................................................៨០
មេរៀនទី៣៤ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ៣..................................................៨២

មេរៀនទី៣៥ ការវិភាគពីភាពជោគជ័យ និងការងារល្អ ......................................................៨៩
មេរៀនទី៣៦ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ទី១០ ឬឆ្នាំទី ១ ..........................................៩០
ផ្នែកទី២ ការរៀបចំផែនការអាជីព (ថ្នាក់ទី១១)............................................................... ៩២
មេរៀនទី១ ស្វាគមន៍មកកាន់ថ្នាក់ទី១១ ឬឆ្នាំទី២ ............................................................ ៩៣
មេរៀនទី២ ការតម្រង់ទិសដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា.............................................៩៤
មេរៀនទី៣ ការធ្វើផែនការ...................................................................................................៩៥
មេរៀនទី៤ ការពន្យល់បកស្រាយ .......................................................................................... ៩៧
មេរៀនទី៥ ការរៀបចំត្រៀមធ្វើបទបង្ហាញ..............................................................................៩៨
មេរៀនទី៦ ការធ្វើបទបង្ហាញ ១ ..........................................................................................៩៩
មេរៀនទី៧ ការធ្វើបទបង្ហាញ ២ ........................................................................................ ១០០
មេរៀនទី៨ ការធ្វើបទបង្ហាញ ៣........................................................................................... ១០១
មេរៀនទី៩ ការធ្វើបទបង្ហាញ ៤ ..........................................................................................១០២
មេរៀនទី១០ ការសង្ខេបខ្លឹមសារ....................................................................................... ១០៣
មេរៀនទី១១ ការដោះស្រាយបញ្ហា ..................................................................................... ១០៤
មេរៀនទី១២ ការត្រិះរិះពិចារណា ...................................................................................... ១០៦
មេរៀនទី១៣ ការតម្រង់ទិសអាជីពការងារ ........................................................................... ១០៩
មេរៀនទី១៤ ការស្វះស្វែងរកអាជីពការងារដ៏សក្តិសម ........................................................ ១១៣
មេរៀនទី១៥ ការរៀបចំផែនការសម្ភាសប្រមូលព័ត៌មាន ......................................................... ១១៥
មេរៀនទី១៦ ការរៀបចំត្រៀមធ្វើបទបង្ហាញ.......................................................................... ១១៧
មេរៀនទី១៧ បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ១ ....................................................... ១១៨
មេរៀនទី១៨ បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ២......................................................... ១១៨
មេរៀនទី១៩ បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ៣ ....................................................... ១១៨
មេរៀនទី២០ ការសង្ខេបខ្លឹមសារ ...................................................................................... ១១៩
មេរៀនទី២១ ការរៀបចំផែនការអាជីព ដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា.................................. ១២០
មេរៀនទី២២ យុថ្កាអាជីព ................................................................................................ ១២១
មេរៀនទី២៣ ការរៀបចំផែនការអាជីព ដោយប្រើតេស្ត RIASEC 1............................................ ១២៥
មេរៀនទី២៤ ការរៀបចំផែនការអាជីព ដោយប្រើតេស្ត RIASEC 2........................................... ១៣២
មេរៀនទី២៥ ល្បែងសិក្សាអំពីគុណតម្លៃ ............................................................................១៣៣
មេរៀនទី២៦ ជម្រើសនៃការអប់រំបន្ត ១.............................................................................. ១៣៥
មេរៀនទី២៧ ជម្រើសនៃការអប់រំបន្ត ២ .............................................................................១៣៧
មេរៀនទី២៨ ដំណើរការសិក្សាខ្ញុំ .......................................................................................១៤០
មេរៀនទី២៩ ក្លឹបមុខវិជ្ជា................................................................................................. ១៤២
មេរៀនទី៣០ កងរង្វង់នៃអាជីព.......................................................................................... ១៤៤
មេរៀនទី៣១ លំហារនៃជីវិត ............................................................................................ ១៤៥
មេរៀនទី៣២ បាតដៃទេពកោសល្យ..................................................................................... ១៤៧
មេរៀនទី៣៣ ការគិតអំពីជីវិតការងារ.................................................................................. ១៤៨
មេរៀនទី៣៤ ផែនការអាជីព និងការអប់រំរបស់ខ្ញុំ................................................................... ១៤៩
មេរៀនទី៣៥ យោបល់វិជ្ជមានទៅកាន់មិត្តរួមថ្នាក់ ................................................................ ១៥៣

មេរៀនទី៣៦ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ទី១១ ឬឆ្នាំទី២ ..... ១៥៤
ផ្នែកទី៣ ជំនាញក្នុងជីវិតការងារ (ថ្នាក់ទី១២) ..... ១៥៥
មេរៀនទី១ ស្វាគមន៍មកកាន់ថ្នាក់ទី១២ ឬឆ្នាំទី៣ ..... ១៥៦
មេរៀនទី២ ការសម្រេចចិត្ត ..... ១៥៧
មេរៀនទី៣ ការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព ..... ១៥៩
មេរៀនទី៤ ការដោះស្រាយបញ្ហា ..... ១៦១
មេរៀនទី៥ ភាពជាអ្នកដឹកនាំ ..... ១៦២
មេរៀនទី៦ សុខុមាលភាព ..... ១៦៥
មេរៀនទី៧ ការបង្កើតបណ្តាញ ..... ១៦៧
មេរៀនទី៨ ការធ្វើការងារជាក្រុម ..... ១៧០
មេរៀនទី៩ ការទទួលខុសត្រូវ ..... ១៧១
មេរៀនទី១០ ក្រមសីលធម៌ការងារ ..... ១៧៣
មេរៀនទី១១ ជំនាញក្នុងការបំពេញការងារ ..... ១៧៤
មេរៀនទី១២ ទីផ្សារការងារក្នុងមូលដ្ឋាន ១ ..... ១៧៥
មេរៀនទី១៣ ទីផ្សារការងារក្នុងមូលដ្ឋាន ២ ..... ១៧៧
មេរៀនទី១៤ តើនិយោជកចង់បានអ្វី? ១ ..... ១៧៨
មេរៀនទី១៥ តើនិយោជកចង់បានអ្វី? ២ ..... ១៧៩
មេរៀនទី១៦ ការវិភាគព័ត៌មានអំពីការងារ ..... ១៨២
មេរៀនទី១៧ ជម្រើសការងាររបស់ខ្ញុំ ..... ១៨៣
មេរៀនទី១៨ ក្លឹបមុខវិជ្ជា ..... ១៨៤
មេរៀនទី១៩ ជំនាញក្នុងការស្វែងរកការងារ ..... ១៨៥
មេរៀនទី២០ ការវាយតម្លៃខ្លួនឯង ..... ១៨៧
មេរៀនទី២១ ការស្វែងរកការងារ និងបង្កើតបណ្តាញ ..... ១៨៩
មេរៀនទី២២ ពាក្យស្នើសុំចូលបម្រើការងារ ..... ១៩០
មេរៀនទី២៣ ការរៀបចំឯកសារប្រវត្តិរូបសង្ខេប ..... ១៩២
មេរៀនទី២៤ ការហៅទូរសព្ទទៅនិយោជក និងការសម្ភាសការងារ ..... ១៩៤
មេរៀនទី២៥ សហគ្រិនភាព ..... ១៩៨
មេរៀនទី២៦ ការរៀបចំផែនការ ..... ២០០
មេរៀនទី២៧ ការពន្យល់បកស្រាយ ..... ២០១
មេរៀនទី២៨ ការរៀបចំត្រៀមធ្វើបទបង្ហាញ ..... ២០២
មេរៀនទី២៩ ការធ្វើបទបង្ហាញ ១ ..... ២០៣
មេរៀនទី៣០ ការធ្វើបទបង្ហាញ ២ ..... ២០៤
មេរៀនទី៣១ ការធ្វើបទបង្ហាញ ៣ ..... ២០៥
មេរៀនទី៣២ ការសង្ខេបខ្លឹមសារ ..... ២០៦
មេរៀនទី៣៣ ការអប់រំបន្ត ..... ២០៧
មេរៀនទី៣៤ សង្ខេបមេរៀនមគ្គុទ្ទេសក៍ និងប្រឹក្សាអាជីព ..... ២០៩
មេរៀនទី៣៥ ក្លឹបមុខវិជ្ជា ..... ២១០
មេរៀនទី៣៦ លាហើយមធ្យមសិក្សាទុតិយភូមិ ..... ២១១

ផ្នែកទី៤ ឧបសម្ព័ន្ធសម្រាប់អ្នកផ្តល់ប្រឹក្សាអាជីព ........ ២១៣
១.វិធីសាស្ត្រផ្សេងៗនៃការផ្តល់ប្រឹក្សាអាជីព ........ ២១៣
២.ទ្រឹស្តីនៃការប្រឹក្សាអាជីព ........ ២១៦
៣.ទស្សនាទាន ........ ២១៩
៤.ក្របខណ្ឌកម្មវិធីសិក្សា និងការរំពឹងទុក ........ ២២៥
៥.ការប្រឹក្សាទល់មុខ ........ ២២៦
៦.ឧបករណ៍សម្រាប់ការប្រឹក្សាទល់មុខ ........ ២៣៣
៧.មគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន ........ ២៣៧
៨.កម្មវិធីជួបជុំមាតាបិតា ........ ២៤១

# ផ្នែកទី១
# ជំនាញក្នុងការសិក្សា (ថ្នាក់ទី១០)

នៅក្នុងឆ្នាំសិក្សាសម្រាប់ថ្នាក់ទី១០ សិស្សានុសិស្សនឹងត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការសិក្សាមុខវិជ្ជាផ្សេងៗ ដើម្បីឱ្យមានភាពបន្សុីគ្នាទៅនឹងគោលការណ៍អប់រំបែបសិស្សមជ្ឈមណ្ឌល ដោយរួមបញ្ចូលនូវសកម្មភាពស្វ័យសិក្សា និងស្មារតីស្រឡាញ់ការសិក្សាពេញមួយជីវិត ប្រកបដោយការទទួលខុសត្រូវ។

នៅក្នុងឆ្នាំសិក្សានេះ តម្រូវឱ្យបង្រៀនរយៈពេល ៣៦ ម៉ោង (៤៥ នាទី សម្រាប់ម៉ោងសិក្សានិង ១៥ នាទី សម្រាក)។ សិស្សានុសិស្ស នឹងត្រូវអនុវត្តគម្រោងសិក្សា (ការងារជាក្រុម) មួយមួយចំនួន ព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដែលជាផ្នែកមួយសម្រួលដល់ការរៀន និងបង្រៀនមេរៀនប្រឹក្សាអាជីព។ ក្នុងម៉ោងសិក្សា សិស្សត្រូវមានសៀវភៅកត់ត្រា និងប៊ិកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

**ខ្លឹមសារមេរៀន ត្រូវបានបែងចែកដូចខាងក្រោម៖**

| | |
|---|---|
| មេរៀនទី១ ដល់ទី៧៖ | ខ្លឹមសារផ្តោតលើការតម្រង់ទិសសិស្សថ្នាក់ទី១០ នៃឆ្នាំសិក្សាថ្មី |
| មេរៀនទី៨ ដល់ទី១១៖ | បំណិនការងារគម្រោង |
| មេរៀនទី១២ ដល់១៤ ៖ | បំណិនក្នុងការកំណត់គោលដៅ និងឆ្លុះបញ្ចាំងនូវជំនាញផ្ទាល់ខ្លួន |
| មេរៀនទី១៥ ដល់ ១៦ ៖ | ការស្វែងយល់ពីរបៀបរៀន ដោយផ្សារភ្ជាប់នឹង ICT |
| មេរៀនទី១៧ ដល់ ១៨ ៖ | ការជំរុញទឹកចិត្ត |
| មេរៀនទី១៩ ដល់ ២៧ ៖ | បំណិនក្នុងការសិក្សា |
| មេរៀនទី២៨ ដល់ ៣១ ៖ | បញ្ហាប្រឈមក្នុងការសិក្សា និងដំណោះស្រាយ |
| មេរៀនទី៣២ ដល់ ៣៤ ៖ | ជំនាញ និងភាពខ្លាំង |
| មេរៀនទី៣៥ ដល់ ៣៦ ៖ | ការឆ្លុះបញ្ចាំង និងវាយតម្លៃការសិក្សាពេញ១ឆ្នាំ |

## មេរៀនទី ១ ស្វាគមន៍មកកាន់ថ្នាក់ទី១០ ឬឆ្នាំទី១

វត្ថុបំណងក្នុងឆ្នាំសិក្សាដំបូងនៃមេរៀនមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាណែនាំគឺ៖

- ជួយឱ្យសិស្សស្គាល់គ្នាទៅវិញទៅមក
- ផ្តល់ជំនួយដល់សិស្សអំឡុងពេលអន្តរកាលនៃការផ្លាស់ចេញពីមធ្យមសិក្សាបឋមភូមិមកមធ្យមសិក្សាទុតិយភូមិ

វាពិតជាមានសារៈសំខាន់ណាស់ដែលសិស្សានុសិស្សជាទូទៅ ត្រូវទទួលបានការគាំទ្រ និងការណែនាំចង្អុលបង្ហាញផ្សេងៗ ក្នុងដំណាក់កាលនៃការរំកិលខ្លួនពីមួយដំណាក់ទៅមួយដំណាក់លើមាគ៌ាសិក្សាអប់រំរបស់ពួកគេ។ ស្ថិតក្នុងដំណាក់កាលនៃការឆ្លងកាត់ពីកម្រិតមធ្យមសិក្សាបឋមភូមិ ឈានចូលមកមធ្យមសិក្សាទុតិយភូមិ សិស្សអាចមានអារម្មណ៍ខុសប្លែកគ្នាពាក់ព័ន្ធនឹងភាពរំភើបរីករាយ ក្តីកង្វល់ផ្សេងៗ ឬភាពឯកាក្នុងចិត្ត។ល។ នៅក្នុងសប្តាហ៍ដំបូងនៃការចាប់ផ្តើមភូមិសិក្សាថ្មីនេះ សិស្សមួយចំនួនអាចសម្រេចចិត្តបោះបង់ចោលការសិក្សាដោយសារតែអារម្មណ៍អវិជ្ជមាន ខ្វះការគាំទ្រ។

ពិតណាស់ មធ្យមសិក្សាទុតិយភូមិគឺមានទីតាំងធំជាង ឬអាចនៅឆ្ងាយពីផ្ទះ និងមានមុខវិជ្ជាសិក្សាថ្មីៗបន្ថែមពីលើអ្វីដែលសិស្សធ្លាប់ឆ្លងកាត់ នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពពីមធ្យមសិក្សាបឋមភូមិ ទៅមធ្យមសិក្សាទុតិយភូមិ ទាមទារឱ្យមានការគាំទ្រពីគ្រូផ្តល់ប្រឹក្សាអាជីព និងសហការយ៉ាងជិតស្និទ្ធជាមួយនាយកសាលា ក៏ដូចជាគ្រូដទៃទៀត។ ដើម្បីធានាបាននូវការផ្លាស់ប្តូរភូមិសិក្សានេះប្រកបដោយសុវត្ថិភាព គ្រូផ្តល់ប្រឹក្សាអាជីពគួរដាក់កម្មវិធីចុះណែនាំដោយផ្ទាល់ដល់សិស្សដែលកំពុងសិក្សានៅថ្នាក់ទី៩ ក្នុងគោលបំណងផ្តល់ការណែនាំជាបឋមនូវអ្វីដែលសិស្សត្រូវឆ្លងកាត់ បន្ទាប់ពីពួកគេឡើងមកដល់ថ្នាក់ទី១០នៅឆ្នាំក្រោយ។ វេទិកាផ្សព្វផ្សាយបើកទូលាយមួយសម្រាប់សិស្សានុសិស្ស ដែលត្រៀមនឹងឆ្លងភូមិសិក្សាមកកាន់ថ្នាក់ទី១០ គួរត្រូវបានរៀបចំឡើងដោយមានកិច្ចសហការចូលរួមពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូតាមមុខវិជ្ជានីមួយៗដែលបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ក្រោមការសម្របសម្រួលពីគ្រូផ្តល់ប្រឹក្សាអាជីព ដើម្បីណែនាំចង្អុលបង្ហាញពីអ្វីដែលសិស្សត្រូវឆ្លងកាត់ ក្នុងដំណើរការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិទុកជាមុន។ បន្ថែមលើនេះ កិច្ចសហការផ្ទាល់ជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស ឬអាជ្ញាធរដែនដី (ក្នុងករណីចាំបាច់) ដើម្បីចែករំលែកព័ត៌មានរបស់សិស្សទៅកាន់គ្នាទៅវិញទៅមកជាមួយគ្រូផ្តល់ប្រឹក្សាអាជីព គឺជាកត្តាមួយដែលមិនអាចខ្វះបានក្នុងការជំរុញឱ្យសិស្សមានទស្សនៈវិជ្ជមានចំពោះការសិក្សា។

ក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍ដំបូងនៃការចូលរៀននៅថ្នាក់ទី១០ សិស្សានុសិស្សត្រូវការការពន្យល់ណែនាំ ពីរបៀបនៃការសម្របខ្លួននៅមធ្យមសិក្សាទុយភូមិ ដោយហេតុថា ការងារមួយចំនួនមានភាពខុសគ្នាពីអ្វីដែលពួកគេ ធ្លាប់បានឆ្លងកាត់នៅថ្នាក់ទី៩។ នៅពេលដែលមានការយល់ដឹងពីភាពបត់បែននៅមធ្យមសិក្សាទុតិយភូមិខ្លះៗហើយ វាអាចជួយឱ្យសិស្សមានភាពងាយស្រួលក្នុងការសម្របខ្លួនទៅនឹងបរិបទនៃការផ្លាស់ប្តូរភូមិសិក្សានេះ។ ប្រធានបទក្នុងការជជែក ដែលនឹងត្រូវផ្តល់ឱ្យនៅដើមឆ្នាំសិក្សាមួយចំនួនខាងក្រោមនេះ មានសារៈសំខាន់ណាស់សម្រាប់សិស្ស ដើម្បីធានាបាននូវការផ្លាស់ប្តូរប្រកបដោយសុវត្ថិភាពនៅមធ្យមសិក្សាទុតិយភូមិ និងជួយសម្រួលដល់គន្លងផ្លូវសិក្សារបស់ពួកគេ នោះគឺ៖

- ការបង្ហាញអារម្មណ៍ និងចំណាប់អារម្មណ៍ដំបូង
- ការផ្លាស់ប្តូរ និងបញ្ហាប្រឈម
- ការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងការដោះស្រាយបញ្ហាប្រឈម

ការពិភាក្សានិងការចែករំលែកនូវលទ្ធផលនៃសកម្មភាពរបស់សិស្សជាមួយគ្នាទៅវិញទៅមក ជាផ្នែកមួយនៃការកសាងទំនុកចិត្ត និងពង្រឹងការប្តេជ្ញាចិត្តក្នុងការសិក្សា។

### សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

សួរសិស្សម្នាក់ម្តងៗ ឱ្យបង្ហាញពីចំណាប់អារម្មណ៍ដំបូងក្នុងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ អ្នកត្រូវផ្តល់ការគាំទ្រយ៉ាងកក់ក្តៅដល់សិស្សដែលមានភាពខ្មាសអៀន ឬភ័យខ្លាច មិនហ៊ានឆ្លើយ ដើម្បីឱ្យពួកគេមានអារម្មណ៍ធូរស្រាលអាចសន្ទនាបាន។

### សកម្មភាពសិស្សទី២ (រយៈពេល ៣៥ នាទី)

ចែកសន្លឹកកិច្ចការទៅឱ្យសិស្សម្នាក់ៗ ឬក៏សរសេរសំណួរនៅលើក្តារខៀន។ (សន្លឹកកិច្ចការ៖ ស្វាគមន៍មកកាន់មធ្យមសិក្សាទុតិយភូមិ)

#### *ជំហានទី១៖ ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល (រយៈពេល ៥ នាទី)*

ប្រាប់សិស្សឱ្យគិតពិចារណាលើសំណួរឱ្យបានហ្មត់ចត់ បន្ទាប់មកសរសេរចម្លើយរបស់ពួកគេនៅក្នុងសន្លឹកកិច្ចការ ឬសៀវភៅកត់ត្រា។ សូមផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីឱ្យពួកគេបញ្ចប់លំហាត់នេះ។ សម្រាប់សិស្សមួយចំនួន ប្រហែលជាពិបាកក្នុងការបង្ហាញចំណាប់អារម្មណ៍ដំបូងរបស់ពួកគេភ្លាមៗ។

#### *ជំហានទី២៖ ធ្វើការជាគូ (រយៈពេល ១០ នាទី)*

ប្រាប់សិស្សឱ្យធ្វើការជាដៃគូ ដើម្បីចែករំលែក និងពិភាក្សាពីអារម្មណ៍ និងបទពិសោធន៍របស់ពួកគេ។

#### *ជំហានទី៣៖ ចែករំលែកលទ្ធផលក្នុងថ្នាក់ (រយៈពេល ១០ នាទី)*

បន្ទាប់មក ឱ្យសិស្សចែករំលែកអារម្មណ៍ បទពិសោធន៍ និងការយល់ឃើញរបស់ពួកគេជាមួយគ្នាទៅវិញទៅមកនៅក្នុងថ្នាក់។ អ្នកអាចចាត់តំណាងសិស្សណាម្នាក់ ឱ្យធ្វើជាអ្នកដឹកនាំការពិភាក្សានេះ។ បន្ទាប់មក អ្នកត្រូវធ្វើការសំយោគគំនិតល្អៗ រួចសរសេរលើក្តារខៀន ដោយបែងចែកជាតារាងចម្លើយសម្រាប់សំណួរនីមួយៗ។



**សន្លឹកកិច្ចការ៖ ស្វាគមន៍មកកាន់ថ្នាក់ទី១០ ឬឆ្នាំទី១ (រយៈពេល ១០ នាទី)**

សូមស្វាគមន៍ការមកដល់មធ្យមសិក្សាទុតិយភូមិ! ប្អូនៗបានរៀនមុខវិជ្ជាជាច្រើន និងបានទទួលចំណេះដឹងជាច្រើននៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ឥឡូវនេះប្អូនមានឱកាសសិក្សាបន្ថែមទៀត។ ប្អូនក៏នឹងមានមិត្តភក្តិថ្មី និងចែករំលែកការរៀនសូត្រជាមួយពួកគេផងដែរ។

នៅដំណាក់កាលដំបូង ប្អូនប្រហែលជាមានអារម្មណ៍រំភើប ព្រួយបារម្ភ ឬមានភាពឯកាជាមួយនឹងការរំពឹងទុកជាច្រើន ក្នុងការរៀននៅថ្នាក់វិទ្យាល័យនេះ។ ជាមួយគ្នានេះ ប្អូននឹងត្រូវទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀតទៅលើមុខវិជ្ជានានាដែលនឹងត្រូវរៀន។ វាជារឿងប្រសើរមួយ ប្រសិនបើប្អូនអាចចែករំលែក ឬបង្ហាញពីការយល់ឃើញរបស់ប្អូនជាមួយមិត្តរួមថ្នាក់។

**សាកល្បងគិតពីសំណួរខាងក្រោមនេះឱ្យបានហ្មត់ចត់ រួចសរសេរចម្លើយរបស់ប្អូន៖**

អំឡុងពេលដែលប្អូនបានផ្លាស់ចេញពីការសិក្សានៅមធ្យមសិក្សាបឋមភូមិ មកកាន់មធ្យមសិក្សាទុតិយភូមិនេះ តើប្អូនមានអារម្មណ៍ដូចម្តេចដែរ?

______________________________________________

______________________________________________

តើភាពខុសគ្នាអ្វីខ្លះដែលប្អូនអាចមើលឃើញរវាងការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ?

______________________________________________

______________________________________________

តើការផ្លាស់ភូមិសិក្សានេះ មានការប្រែប្រួលជាវិជ្ជមានសម្រាប់ប្អូនដែរឬទេ? សូមបញ្ជាក់។

______________________________________________

______________________________________________

តើការប្រែប្រួលអ្វីខ្លះ ដែលប្អូនកំពុងជួបបញ្ហាពិបាកដោះស្រាយ?

______________________________________________

______________________________________________

តើប្អូនត្រូវដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយវិធីណា?

______________________________________________

______________________________________________

ហេតុអ្វីបានជាប្អូនត្រូវទៅរៀន? តើការរៀនសូត្រ មានសារៈសំខាន់អ្វីខ្លះសម្រាប់ប្អូន?

______________________________________________

______________________________________________

ក្នុងនាមជាអ្នកសិក្សា តើប្អូនត្រូវមានទំនួលខុសត្រូវអ្វីខ្លះ?

______________________________________________

______________________________________________

បន្ទាប់ពីសិស្សឆ្លើយសំណួរខាងលើនេះរួច ក្នុងនាមគ្រូផ្តល់ប្រឹក្សាអាជីព អ្នកត្រូវប្រាកដថា សិស្សទាំងអស់ នឹងទទួលបានអារម្មណ៍វិជ្ជមានចំពោះការសិក្សារបស់ពួកគេនៅកម្រិតវិទ្យាល័យ។ អ្នកអាចចាប់ផ្តើមណែនាំពួកគេដូចជា៖

- លួងលោមអារម្មណ៍សិស្សថា ការរៀននៅថ្នាក់វិទ្យាល័យ វាមិនមានអីដែលប្លែកពីមុនប៉ុន្មាននោះទេ
- បង្ហាញត្រួសៗនូវអ្វីដែលជាបទពិសោធន៍ថ្មី និងការទទួលខុសត្រូវដែលពួកគេត្រូវឆ្លងកាត់
- ផ្តល់ដំបូន្មានខ្លះៗអំពីរបៀបដោះស្រាយបញ្ហាជុំវិញរបត់ថ្មីនៃការសិក្សា
- សង្កត់ធ្ងន់លើគុណតម្លៃនៃការសិក្សា និងចំណេះដឹងដែលពួកគេនឹងទទួលបាន។



## មេរៀនទី ២ ស្វាគមន៍មកកាន់ថ្នាក់ទី១០ (តចប់)

វត្ថុបំណងនៃមេរៀននេះគឺៈ

- បន្តការឆ្លុះបញ្ចាំងអំពីដំណើរអន្តរកាលទៅកាន់មធ្យមសិក្សាទុតិយភូមិ
- បន្សាំការយល់ដឹងរបស់សិស្សជុំវិញការងារផ្តល់មគ្គុទ្ទេសក៍ និងការប្រឹក្សាអាជីព
- ណែនាំសិស្សពីមាតិកាមេរៀនមគ្គុទ្ទេសក៍ និងការប្រឹក្សាអាជីពសម្រាប់ឆ្នាំទី១

### សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

អ្នកត្រូវចាប់ផ្តើមដោយពិភាក្សាសួរនាំពីចំណាប់អារម្មណ៍សិស្ស បន្ទាប់ពីបានឆ្លងកាត់សប្តាហ៍ទី១។ សិស្សអាចបង្ហាញអារម្មណ៍របស់ពួកគេតាមការយល់ឃើញរៀងៗខ្លួន។ ដើម្បីជាជំនួយ អ្នកអាចដឹកនាំការពិភាក្សាខាងលើ ដោយប្រើប្រាស់ប្រធានបទដូចខាងក្រោមៈ

- តើប្អូនអាចបន្សាំទៅនឹងការប្រែប្រួល និងដោះស្រាយបញ្ហាប្រឈមបានដោយរបៀបណា?
- តើអ្នកណាខ្លះជាអ្នកគាំទ្រដល់ការសិក្សា និងជីវិតនៅសាលារៀនរបស់ប្អូន?
- តើប្អូនមើលឃើញអំពីសារៈសំខាន់អ្វីខ្លះចេញពីការសិក្សានៅទីនេះ?

ការពិភាក្សា និងការចែករំលែកលទ្ធផលសិស្សទៅវិញទៅមក ជាការកសាងទំនុកចិត្ត និងពង្រឹងការប្តេជ្ញាក្នុងការសិក្សារបស់ពួកគេ។

### សកម្មភាពសិស្សទី២

ចែកសន្លឹកកិច្ចការទៅសិស្សម្នាក់ៗ (សន្លឹកកិច្ចការទី២ៈ ស្វាគមន៍មកកាន់មធ្យមសិក្សាទុតិយភូមិ)។ អ្នកអាចសរសេរប្រធានបទដាក់លើក្តារខៀន ឬអានឮៗឱ្យសិស្សកត់ត្រាទុក។ ឱ្យសិស្សយកក្រដាសម្នាក់មួយសន្លឹក រួចគូររូបក្រុមមនុស្សមួយក្រុមឈរជារង្វង់ ដោយមានម្នាក់ស្ថិតនៅចំកណ្តាលរង្វង់នោះ (តំណាងឱ្យខ្លួនគេផ្ទាល់)។

*ជំហានទី១ៈ ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល*

ផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យសិស្សចាប់ផ្តើមគិតពីមនុស្សនៅក្នុងរង្វង់នោះ ហើយសាកល្បងដាក់ឈ្មោះ តួនាទី ដែលពួកគេគិតថា គេអាចពឹងពាក់បាននៅពេលមានបញ្ហាទាក់ទងនឹងការសិក្សានៅថ្នាក់វិទ្យាល័យនេះ។

*ជំហានទី២ៈ ធ្វើការជាគូ*

ឱ្យសិស្សចាប់ដៃគូ រួចសិក្សាប្រៀបធៀបចម្លើយគ្នាទៅវិញទៅមក។ អ្នកអាចដើរពិនិត្យមើលដើម្បីឱ្យដឹងថា តើមានសិស្សប៉ុន្មាននាក់ដែលមានការគិតប្រហាក់ប្រហែលគ្នា។

*ជំហានទី៣ៈ ចែករំលែកលទ្ធផលក្នុងក្រុមពិភាក្សាធំ*

បន្ទាប់មក ចែករំលែកលទ្ធផលនៃសកម្មភាពនេះនៅក្នុងថ្នាក់។ ឱ្យតំណាងសិស្សមួយចំនួនឡើងផ្តល់ចម្លើយរបស់ពួកគេ ហើយសរសេរនៅលើក្តារខៀន។

### *ជំហានទី៤៖ ការបំពេញបន្ថែមដោយគ្រូ*

បន្ទាប់ពីបានចម្លើយចេញពីការពិភាក្សារួមរបស់សិស្សក្នុងថ្នាក់រួចមក អ្នកត្រូវបំពេញបន្ថែមនូវសមាសភាពអ្នកដែលអាចជួយសិស្សបាននៅពេលពួកគេត្រូវការជំនួយដូចជា អ្នកប្រឹក្សាអាជីព នាយក សាលា លោកគ្រូ អ្នកគ្រូ អាណាព្យាបាល មិត្តភក្តិ អ្នកជិតខាង អាជ្ញាធរជាដើម។ ជាចុងក្រោយ អ្នកត្រូវ បង្ហាញឱ្យពួកគេឃើញថា អ្នកមានតួនាទីក្នុងការគាំទ្រ ផ្តល់ដំបូន្មាន និងជំនួយផ្សេងៗដល់ពួកគេ នៅពេលដែលមានបញ្ហាដោះស្រាយខ្លួនឯងមិនបាន។



### សន្លឹកកិច្ចការ៖ ការគាំទ្រការសិក្សានៅមធ្យមសិក្សាទុតិយភូមិ

ជាទូទៅ មនុស្សយើងម្នាក់ៗមានវិធីក្នុងការសម្របខ្លួនផ្សេងៗគ្នាទៅនឹងការចរន្តនៃបម្រែបម្រួលអ្វីមួយដែលយើងឆ្លងកាត់។ អ្នកខ្លះមានស្មារតីរឹងមាំអាចសម្របខ្លួនបានយ៉ាងល្អ ខណៈអ្នកខ្លះទៀតត្រូវការជំនួយពីអ្នកដទៃទើបអាចបន្តដំណើរទៅមុខបាន។ ក្នុងន័យនេះ ការសិក្សារបស់អ្នកនៅសាលាក៏មិនខុសគ្នាដែរ។ សិស្សខ្លះអាចសម្របខ្លួនទៅនឹងបរិកាសថ្មីនៃថ្នាក់រៀន ឬខ្លឹមសារមេរៀនបាន ប៉ុន្តែសិស្សខ្លះទៀត ត្រូវការការយកចិត្តទុកដាក់ខ្ពស់ពីគ្រូ ឬការជួយជ្រោមជ្រែងពីមិត្តភក្តិ អាណាព្យាបាល។ល។ ទើបអាចទទួលបានជោគជ័យក្នុងការសិក្សារបស់ខ្លួន។

សាកល្បងស្វែងរកចម្លើយនៃសំណួរខាងក្រោម រួចសរសេរវាជុំវិញរូបភាពដែលបង្ហាញនេះ៖

តើនរណាអាចជួយជ្រោមជ្រែងការសិក្សារៀនសូត្ររបស់អ្នកនៅសាលារៀនបានខ្លះ?



### សកម្មភាពសិស្សទី៣

បែងចែកសិស្សជាក្រុមតូចៗដែលមានគ្នា ៣ នាក់ក្នុងមួយក្រុម។ ឱ្យក្រុមនីមួយៗធ្វើការពិភាក្សាស្វែងរកអត្ថន័យនៃពាក្យ «មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាណែនាំ»។ ឱ្យតំណាងក្រុមនីមួយៗ ឡើងបញ្ចេញយោបល់។ បន្ទាប់មក អ្នកធ្វើការសំយោគគំនិតរបស់សិស្ស និងបង្ហាញឱ្យពួកគេយល់ថា មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាណែនាំ គឺជាការផ្តល់ការណែនាំត្រួសត្រាយផ្លូវ និងគាំទ្រផ្នែកស្មារតីដល់សិស្ស ដើម្បីឱ្យការសិក្សាពួកគេទទួលបានជោគជ័យ។ សិស្សគ្រប់រូប អាចស្វែងរកជំនួយ នេះពីអ្នកបាននៅរាល់ពេលពេលពួកគេមានបញ្ហាទាក់ទងនឹងការសិក្សានៅកម្រិតវិទ្យាល័យ។

បន្ទាប់មក បង្ហាញអំពីមាតិកាមេរៀននៃការប្រឹក្សាយោបល់ និងមគ្គុទ្ទេសក៍អាជីព ដែលអ្នកគ្រោងនឹងបង្រៀនដល់ពួកគេក្នុងឆ្នាំទី១នេះ។



## មេរៀនទី ៣ ការរៀបចំសណ្ដាប់ធ្នាប់ ១

មេរៀននេះ និងមេរៀនពីរបន្ទាប់ទៀត ស្ថិតក្នុងប្រធានបទដូចគ្នា ដែលមានវត្ថុបំណងៈ

- បង្កើតបរិយាកាសវិជ្ជមាននៅក្នុងក្រុម
- បង្កើតបទបញ្ជាផ្ទៃក្នុង ដើម្បីរៀនជាមួយគ្នា។

***ចែករំលែកការណែនាំខាងក្រោមទៅលើប្រធានបទជាមួយសិស្សរបស់អ្នក!***

សាលារៀន គឺជាទីតាំងមួយសម្រាប់គ្រូ និងសិស្ស ធ្វើការជាមួយគ្នា។ គ្រប់គ្នានៅក្នុងសាលារៀន មានសិទ្ធិស្មើៗគ្នាក្នុងការបង្កើតនូវភាពរីករាយស្និទ្ធស្នាល មានសន្តិភាព សុវត្ថិភាពផ្លូវចិត្ត គាំទ្រគ្នាទៅវិញទៅមក គោរពសិទ្ធិគ្នា សាមគ្គីភាព សហការគ្នា ជួយយកអាសារគ្នា ចូលរួមរក្សាប្រយោជន៍រួមរបស់សាលា និងប្រយោជន៍បុគ្គលម្នាក់ៗ។ល។ ដើម្បីឱ្យបរិយាកាសនៃការសិក្សាមានភាពល្អប្រសើរដើរលើ ផ្លូវវិជ្ជមាន ទាំងគ្រូទាំងសិស្សជោគជ័យទាំងអស់គ្នា។ មូលដ្ឋានខាងលើនេះ អាចសម្រេចទៅបានក៏ អាស្រ័យដោយសាលារៀនមានបទបញ្ជាផ្ទៃក្នុង មានវិន័យច្បាស់លាស់ សម្រាប់ឱ្យគ្រប់គ្នាអនុវត្តតាម តួនាទី ភារកិច្ចរៀងៗខ្លួន។

នៅក្នុងថ្នាក់រៀន ការផ្ដោតការយកចិត្តទុកដាក់ ការរក្សាភាពស្ងៀមស្ងាត់ ការចូលរួមសកម្មភាពពិភាក្សាក្រុម ឬឆ្លើយសំណួរគ្រូជាដើម ជាការបង្ហាញនូវការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ ក្នុងការចូលរួមធ្វើឱ្យបរិយាកាសសិក្សាមានភាពដំណើរការទៅដោយរលូន។ នៅក្នុងមេរៀននេះ នឹងផ្ដោតលើការណែនាំសិស្សឱ្យរៀនធ្វើការក្រុមជាមួយគ្នា ចេះជួយគ្នា ចេះចែករំលែកគ្នា និងទទួលខុសត្រូវរួមគ្នា ចំពោះការសម្រេចចិត្តរបស់ក្រុម។

### សកម្មភាពសិស្សទី១

បែងចែកសិស្សជាក្រុមតូចដែលមានគ្នា ៤–៥នាក់។ ឱ្យក្រុមនីមួយៗ ពិភាក្សាចែករំលែកគំនិត និងអារម្មណ៍របស់ពួកគេអំពីបរិយាកាសសន្តិភាពនៅក្នុងសាលារៀន។

***សំណួរពិភាក្សា***

- តើថ្នាក់រៀនរបស់អ្នកមានបរិយាកាសប្រកបដោយសន្តិភាពដែរឬទេ? ចូរបញ្ជាក់។
- តើអ្នកអាចចូលរួមបង្កើតបរិយាកាសសន្តិភាពនៅក្នុងថ្នាក់ ក៏ដូចជាសាលារៀនបាន ដោយ វិធីណាខ្លះ?
- តើនៅពេលណាដែលអ្នកគួរនិយាយលឺៗនៅក្នុងថ្នាក់រៀន?
- តើអ្នកគួរធ្វើយ៉ាងណានៅពេលដែលមិត្តរបស់អ្នកចង់និយាយជាមួយអ្នក អំឡុងពេលដែលអ្នកកំពុងផ្ដោតការយកចិត្តទុកដាក់លើការពន្យល់មេរៀនរបស់គ្រូ?
- ប្រធានបទពាក់ព័ន្ធដទៃទៀត...



### សកម្មភាពសិស្សទី២

បែងចែកសិស្សជាក្រុមតូចៗ រួចផ្ដល់ការណែនាំ និងបំផុសគំនិតឱ្យសិស្សគិតអំពីវិធីជួយឱ្យសាលារៀនរបស់ពួកគេមានបរិយាកាសសន្តិភាព (អាចជាការបង្កើតបទបញ្ជាផ្ទៃក្នុង)។ រៀបចំរចនាជាផ្ទាំងរូបភាព ហើយសរសេរនូវអ្វីដែលសិស្សគិតឃើញចូល រួចព្យួរវានៅលើជញ្ជាំងថ្នាក់រៀន ដើម្បីអនុវត្តទាំងអស់គ្នា។

**បទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់របស់យើង៖**

- ✓
- ✓
- ✓
- ✓

# មេរៀនទី ៤ ការរៀបចំសណ្តាប់ធ្នាប់ ២

ប្រធានបទនេះបន្តពីមេរៀនមុន នឹងផ្តោតលើការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ។

ចែករំលែកការណែនាំខាងក្រោមទៅលើប្រធានបទជាមួយសិស្សរបស់អ្នក៖ នៅពេលដែលចាប់ផ្តើមចូលរៀនឆ្នាំសិក្សាថ្មី នៅសាលារៀនថ្មី សិស្សក៏អាចជួបជាមួយមិត្តរួមថ្នាក់ថ្មីៗ និងក្លាយជាសមាជិករបស់ក្រុមថ្មីមួយ។ ទិដ្ឋភាពចម្រុះក្នុងក្រុមថ្មីមានជាអាទិ៍ អត្តចរិត ជំនាញ ជីវប្រវត្តិ ចំណូលចិត្ត ទំនោរក្រុម...។ សកម្មភាពចូលរួមនៅក្នុងក្រុមតម្រូវឱ្យមានជំនាញសង្គម និងយកចិត្តទុកដាក់ជាមួយអ្នកដទៃ។ បន្ថែមពីលើនេះ អ្នកគួរតែចេះស្វែងរកជំនួយ និងពឹងពាក់គ្នាទៅវិញទៅមក។

## សកម្មភាពសិស្សទី១៖ សំណោរវិជ្ជមានអំពីមិត្តរួមថ្នាក់

រៀបសិស្សឱ្យឈរជារង្វង់នៅក្នុងថ្នាក់រៀន (សិស្សច្រើនបំផុតត្រឹម ១៥ នាក់ក្នុងមួយរង្វង់)។ ចែកក្រដាសពណ៌លឿង ទៅឱ្យសិស្សម្នាក់មួយសន្លឹកៗ។ ឱ្យពួកគេគូររូបព្រះអាទិត្យនៅចំកណ្តាលទំព័រ រួចដាក់ឈ្មោះរបស់គេនៅលើនោះ។ បន្ទាប់មក ប្រាប់សិស្សឱ្យហុចក្រដាសដែលបានគូររួចទៅសិស្សម្នាក់ទៀតដែលឈរនៅខាងឆ្វេងដៃ។ សិស្សម្នាក់ៗត្រូវសរសេរចំណុចវិជ្ជមានមួយ (អត្តចរិត រូបរាង ជំនាញ ទេពកោសល្យ ។ល។) អំពីសិស្សដែលមានឈ្មោះនៅលើគំនូរនោះ រួចហុចបន្តទៅសិស្សម្នាក់ទៀត។ ធ្វើដូចនេះរហូតទាល់តែក្រដាសនីមួយៗមានយោបល់របស់សិស្សគ្រប់គ្នាដែលឈរនៅក្នុងរង្វង់នោះ។ ចុងក្រោយ ប្រគល់ក្រដាសនោះទៅឱ្យម្ចាស់ដើមវិញ។ ដូចនេះម្នាក់ៗបានទទួលនូវសំណោរវិជ្ជមានអំពីខ្លួនគេ តាមរយៈមិត្តរួមថ្នាក់ដែលឈរនៅក្នុងរង្វង់។

## សកម្មភាពសិស្សទី២៖ ការទទួលខុសត្រូវរបស់សមាជិកក្រុម

បែងចែកសិស្សជាបួនក្រុម ដើម្បីឱ្យពួកគេបង្កើតសំឡេងតន្ត្រី។ ក្រុមមួយត្រូវទះដៃ ក្រុមមួយទៀតគោះកៅអី និងគោះវត្ថុផ្សេងៗបន្តទៀត។ ក្រុមនីមួយៗ ត្រូវបង្កើតសំឡេងតន្ត្រីរៀងៗខ្លួននៅពេលដែលអ្នកចង្អុលទៅក្រុមនោះ។ គោលបំណងនៃសកម្មភាពនេះ គឺចង់ឱ្យក្រុមនីមួយៗចេះសម្របសម្រួលគ្នាដើម្បីបង្កើតឱ្យមានសំឡេងពីរោះឡើង។ ដើម្បីសម្រេចបានចំណុចនេះ ពួកគេត្រូវចេះស្តាប់នូវអ្វីដែលសមាជិកក្រុមកំពុងធ្វើ ហើយធ្វើឱ្យមានភាពស៊ីសង្វាក់គ្នា។ អ្នកត្រូវចង្អុលម្តងមួយក្រុមៗ ដើម្បីឱ្យពួកគេធ្វើសកម្មភាព។ បន្ទាប់មក បញ្ចូលក្រុមពីរចូលគ្នាតែមួយដោយទុកពេលឱ្យពួកគេរៀនសមជាមួយគ្នារហូតទាល់តែពួកគេអាចបង្កើតសំឡេងតន្ត្រីពីរោះមួយ។ ជាចុងក្រោយ អ្នកនឹងបញ្ចូលក្រុមទាំងអស់ចូលគ្នាក្នុងពេលតែមួយ ដែលអាចមានកិច្ចសហការគ្នាដ៏ល្អមួយ។ នៅពេលការប្រគំតន្ត្រីត្រូវបានបញ្ចប់ អ្នកត្រូវសួរទៅកាន់សិស្សថា ហេតុអ្វីបានជាត្រូវការកិច្ចសហការគ្នាដើម្បីឱ្យសម្រេចសកម្មភាពនេះ? តើអ្វីដែលអាចជួយឱ្យសកម្មភាពនេះ ធ្វើបានប្រសើរជាងមុន? ប្រសិនបើអ្នកធ្វើមិនបានជោគជ័យ តើបណ្តាលមកពីមូលហេតុអ្វី? ផ្អែកលើសំណួរទាំងអស់នេះ ឱ្យសិស្សរបស់អ្នកធ្វើការជាក្រុមដដែល រួចចែករំលែកគំនិត និងអារម្មណ៍របស់ពួកគេ។

***សំណួរសម្រាប់ពិភាក្សា (អាស្រ័យទៅលើពេលវេលាដែលមាន)***

- តើអ្វីដែលនាំឱ្យការធ្វើការជាក្រុមរបស់អ្នកមានភាពរីករាយ?
- តើអ្វីដែលនាំឱ្យការធ្វើការជាក្រុមរបស់អ្នកមិនមានភាពរីករាយ?
- តើអ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍ថា អ្នកជាផ្នែកមួយដ៏សំខាន់របស់ក្រុម?

- តើពាក្យថា «សហការ» មានន័យយ៉ាងដូម្តេច?
- តើអ្វីទៅជាភាពខុសគ្នារវាងការសហការ និងការគ្រាន់តែធ្វើតាមៗគ្នានៅក្នុងក្រុម?
- តើធ្វើយ៉ាងដូម្តេចដើម្បីក្លាយជាមនុស្សដែលមានការសហការល្អ?
- ចូរអ្នករៀបរាប់ពីសកម្មភាពនៅសាលារៀន ឬនៅផ្ទះ ដែលទាមទារឱ្យមានកិច្ចសហការ។
- ហេតុអ្វីបានជាមានការលំបាកមួយចំនួន នៅពេលដែលធ្វើការសហការជាមួយមិត្តភក្តិ?
- ចូររៀបរាប់ពីផលលំបាកនានា នៅពេលអ្នកធ្វើការសហការជាមួយនរណាម្នាក់។ តើអ្នកអាចដោះស្រាយវាបានដែរឬទេ?
- តើការសហការគ្នាមានផលប្រយោជន៍អ្វីខ្លះ?



## មេរៀនទី ៥ ការរៀបចំសណ្ដាប់ធ្នាប់ ៣

### សកម្មភាពសិស្សទី១៖ ការស្ដាប់អ្នកដទៃ

ឱ្យសិស្សចាប់ដៃគូ បន្ទាប់មកឱ្យពួកគេអង្គុយទល់ខ្នងគ្នា។ ផ្ដល់រូបគំនូរសាមញ្ញមួយដល់សិស្សម្នាក់ក្នុងចំណោមដៃគូនេះ (សិស្ស ក) ហើយផ្ដល់ក្រដាសមួយសន្លឹកដល់សិស្សម្នាក់ទៀត (សិស្ស ខ)។ សិស្ស ក ចាប់ផ្ដើមពណ៌នាពីរូបគំនូរដែលអ្នកផ្ដល់ឱ្យ ហើយសិស្ស ខ ចាប់ផ្ដើមគូររូបតាមការពណ៌នា នោះមួយជំហានម្ដងៗ។ បន្ទាប់ពីរូបភាពត្រូវបានគូររួច ឱ្យសិស្ស ក និង ខ ប្រៀបធៀបរូបជាមួយគ្នា តើរូបភាពទាំងពីរនេះ ស្រដៀងគ្នាទេ? តើមានភាពខុសគ្នាដ៏គួរឱ្យអស់សំណើចទេ?

បន្ទាប់មក ពួកគេត្រូវប្ដូរតួនាទីដោយប្រើប្រាស់រូបភាពថ្មី។ ពេលនេះសិស្ស ខ ពន្យល់ទៅកាន់សិស្ស ក នូវអ្វីដែលត្រូវគូរមួយជំហានម្ដងៗ។ បន្តការពិភាក្សាជាក្រុមតូចៗ។

### សំណួរសម្រាប់ពិភាក្សា

- តើមានរឿងអ្វីកើតឡើងនៅពេលដែលនរណាម្នាក់និយាយហើយអ្នកមិនបានស្ដាប់?
- តើវាមានភាពខុសគ្នាទេរវាងការឮ និងការស្ដាប់? តើវាមានភាពខុសគ្នាដូចម្ដេចខ្លះ?
- តើអ្នកធ្លាប់មានការយល់ច្រលំខ្លាំងទេ នៅពេលដែលអ្នកមិនបានស្ដាប់ដោយប្រុងប្រយ័ត្ន ឬនរណាម្នាក់មិនបានស្ដាប់អ្នកដោយយកចិត្តទុកដាក់?
- តើការស្ដាប់ដោយយកចិត្តទុកដាក់ ជួយអ្នកក្នុងការរៀនបានសូត្របានយ៉ាងដូម្ដេច?
- តើអ្នកមានអារម្មណ៍បែបណានៅពេលដែលនរណាម្នាក់មិនបានស្ដាប់គំនិត ឬយោបល់របស់អ្នក?

### សកម្មភាពសិស្សទី២៖ ការធ្វើការជាក្រុម

បែងចែកសិស្សជាក្រុមតូចៗ (មានគ្នា ៥-៦ នាក់ក្នុងមួយក្រុម)។ ចែកសន្លឹកកិច្ចការទៅឱ្យសិស្សម្នាក់ៗ ឬឱ្យពួកគេប្រើប្រាស់សៀវភៅកត់ត្រារបស់ពួកគេ។ ឱ្យសិស្សធ្វើការពិភាក្សាស្វែងរកវិធីសាស្ត្រ ចាំបាច់ផ្សេងៗដែលត្រូវប្រើក្នុងការបំពេញការងារជាក្រុម។ ត្រូវផ្ដល់ពេលវេលាសមស្របដល់ពួកគេ រួចអ្នកត្រូវផ្ដល់ជំនួយដល់ពួកគេក្នុងករណីចាំបាច់។

បន្ទាប់ពីបានលទ្ធផលក្នុងក្រុមហើយ អ្នកត្រូវឱ្យសិស្សបញ្ចូលគ្នាពីរៗក្រុម ដើម្បីចែករំលែកលទ្ធផលដល់គ្នាទៅវិញទៅមក។ អ្នកត្រូវបំពេញបន្ថែម និងសង្ខេបប្រាប់សិស្សនូវជំនាញ និងសមត្ថភាពសំខាន់ៗខាងក្រោម ដែលត្រូវប្រើក្នុងពេលបំពេញការងារជាក្រុម៖

- ការយល់ពីអារម្មណ៍ផ្ទាល់ខ្លួន និងអារម្មណ៍អ្នកដទៃ
- ការចេះសុំអធ្យាស្រ័យពីអ្នកដទៃ
- ការបង្កើតចំណងមិត្តភាព
- ជំនាញប្រាស្រ័យទាក់ទង
- ជំនាញសម្ដែងចេញ (ភាពបើកទូលាយ ភាពច្បាស់លាស់ ភាពស្មោះត្រង់ ការវិនិច្ឆ័យ)
- ជំនាញដោះស្រាយបញ្ហា

បន្ទាប់មក ឱ្យសិស្សជ្រើសរើសជំនាញសំខាន់ជាងគេចំនួនបី ចេញពីតារាងរបស់ពួកគេ រួចសរសេរនៅលើសៀវភៅកត់ត្រារបស់ពួកគេ។ ឱ្យពួកគេពន្យល់ហេតុអ្វីបានជាគេយល់ថាជំនាញទាំងនេះមានសារៈសំខាន់។

### សន្លឹកកិច្ចការ៖ ធ្វើការជាក្រុម

*បន្ថែមពីលើកិច្ចសហការ ការស្តាប់អ្នកដទៃ និងការទទួលខុសត្រូវ ក៏មានជំនាញសំខាន់ៗផ្សេងទៀតដែលត្រូវការនៅពេលដែលធ្វើការក្នុងក្រុម។*

សរសេរជំនាញដែលត្រូវការនៅពេលដែលអ្នកធ្វើការជាក្រុម នៅក្នុងតារាងខាងក្រោម។

មើលតារាងខាងក្រោម រួចជ្រើសរើសជំនាញចំនួនបី ដែលអ្នកគិតថាសំខាន់៖

| ជំនាញសំខាន់ៗរួមមាន៖ | ជំនាញទាំងនេះមានសារៈសំខាន់ដោយសារតែ៖ |
|---|---|
| | |
| | |
| | |

## មេរៀនទី ៦ ការគ្រប់គ្រងពេលវេលា

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សរៀនក្នុងការគ្រប់គ្រងពេលវេលារៀនរបស់ពួកគេឱ្យមានប្រសិទ្ធភាព

នៅពេលដែលសិស្សបង្កើតផែនការ និងកាលវិភាគសម្រាប់គ្រប់គ្រងពេលវេលារបស់ខ្លួនដំបូង ពួកគេត្រូវសង្កេតថា តើពួកគេប្រើប្រាស់ពេលវេលាក្នុងមួយថ្ងៃៗយ៉ាងដូចម្ដេច? អ្នកត្រូវធ្វើឱ្យសិស្សចាប់ផ្ដើមស្រមៃរូបភាពដែលអាចមើលឃើញ ឧទាហរណ៍គេងតិចពេក ឬច្រើនពេក ប្រើប្រាស់ពេលវេលាមើលទូរទស្សន៍ច្រើនពេក ឬប្រើប្រាស់ពេលវេលាតិចតួចក្នុងការធ្វើកិច្ចការផ្ទះ។ អ្នកអាចចែកសន្លឹកកិច្ចការទៅឱ្យសិស្សសម្រាប់ធ្វើផែនការពេលវេលា ឬឱ្យពួកគេគូសតារាងកាលវិភាគក្នុងសៀវភៅរបស់ពួកគេ។

អ្នកអាចចែករំលែកការណែនាំទៅកាន់សិស្ស៖ ការសិក្សា ត្រូវការការធ្វើផែនការពេលវេលាច្បាស់លាស់ ដើម្បីឱ្យដឹងថាពេលណាអ្នកត្រូវធ្វើលំហាត់នៅផ្ទះ ឬលំហាត់ផ្សេងៗ ពេលវេលាប៉ុន្មានដែលអ្នកត្រូវចាត់ចែងមេរៀនត្រៀមប្រលង ពេលម៉ោងណាដែលអ្នកមានថាមពលសកម្មសម្រាប់សិក្សា ពេលណាដែលអ្នកត្រូវសម្រាក។ល។ សិស្សមួយចំនួនទទួលផលបានច្រើនក្នុងការភ្ញាក់ពីដំណេកនៅព្រឹកព្រលឹមស្រាងៗដើម្បីរំលឹកមេរៀន ធ្វើលំហាត់ផ្សេងៗ ខណៈសិស្សមួយចំនួនទៀតអនុវត្តការងាររៀនសូត្របន្ថែមនៅពេលយប់មុនចូលដំណេក។ មិនមានជាកំហុសឆ្គងនោះទេ ដ្បិតនេះជាទម្លាប់ ឬថាជាការសម្របខ្លួនដោយឡែកៗពីគ្នារបស់សិស្សម្នាក់ៗ។ ជាមួយគ្នានេះ អ្វីដែលត្រូវហ្មត់ចត់នោះគឺ ពេលវេលាដែលដាក់ក្នុងកាលវិភាគ គួរតែជាក់លាក់ ហើយអាចអនុវត្តបាន។ ឧទាហរណ៍ អ្នកត្រូវពិចារណាអំពីពេលវេលានៅសាលា ពេលវេលាជាមួយគ្រួសារ ពេលវេលាធ្វើភារកិច្ចដទៃទៀត ពេលវេលាធ្វើការងារផ្ទះ (ចម្អិនម្ហូប បោកគក់) ពេលវេលាសម្រាប់ហាត់ប្រាណ (មើលថែរក្សាខ្លួនអ្នក)។

ការធ្វើផែនការពេលវេលាសម្រាប់ការសិក្សាគឺផ្អែកលើគោលដៅរបស់សិស្ស។ ដើម្បីអាចសិក្សាត្រឹមត្រូវ សិស្សត្រូវថែរក្សាសុខភាពខ្លួនឯង (គេង ញ៉ាំឱ្យបានគ្រប់គ្រាន់ និងហាត់ប្រាណ)។ សិស្សនឹងទទួលបានលទ្ធផលល្អបំផុតពីការសិក្សា លុះត្រាណាអ្នកចេះចាប់យកគុណប្រយោជន៍ពីពេលវេលាតូចតាចទៅ។ វាជាការប្រសើរចំពោះសិស្សក្នុងការចាប់ផ្ដើមរៀនបន្តិចម្ដងៗជារៀងរាល់ថ្ងៃ ជាជាងចំណាយពេលពេញមួយថ្ងៃសម្រាប់រៀនមេរៀនយ៉ាងច្រើន។ ពួកគេត្រូវយកចិត្តទុកដាក់លើសុខភាពរាងកាយដូចជា ពេលណាអស់កម្លាំង ឃ្លាន ឬឆ្អែត ឬពិសាគ្រឿងស្រវឹងបីម៉ោងមុនការសិក្សា នោះពួកគេនឹង**រៀនមិនចេះ**នោះទេ។

### សកម្មភាពសិស្សទី១

ចូរសង្កេតពីរបៀបប្រើប្រាស់ពេលវេលារបស់អ្នក។ ពេលណាដែលអ្នកនៅសាលា ពេលវេលាប៉ុន្មានដែលត្រូវធ្វើដំណើរ ពេលវេលាប៉ុន្មានដែលត្រូវធ្វើលំហាត់នៅផ្ទះ។ល។ តើអ្នករកឃើញថាមានអ្វីត្រូវរៀបចំ ឬកែប្រែដែរឬទេ? តើអ្នកគេងបានគ្រប់គ្រាន់ដែរឬទេ? តើអ្នកបានចំណាយពេលសម្រាប់អ្វីដែលសមរម្យដែរឬទេ? អ្នកមិនអាចរកពេលរៀនសូត្របន្ថែមនៅផ្ទះ?

### សកម្មភាពសិស្សទី២

បង្កើតផែនការមួយសម្រាប់ការគ្រប់គ្រងពេលវេលាដ៏ល្អ! ប្រើសន្លឹកកិច្ចការ ឬគូរនៅក្នុងសៀវភៅកិច្ចការរបស់អ្នក។

ឧទាហរណ៍៖

| ម៉ោង | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ៧-៨ | | | ត្រៀប្រលង ឬលំហាត់នៅផ្ទះ | | ហាត់ប្រាណ | | |
| | | | | | | | |
| ៩-១៥ | រៀននៅសាលា | រៀននៅសាលា | រៀននៅសាលា | រៀននៅសាលា | រៀននៅសាលា | | |
| | | | | ហាត់ប្រាណ | | | |
| ១៦-១៧ | | ធ្វើការផ្ទះ | | | | ធ្វើការផ្ទះ | ហាត់ប្រាណ |
| ១៧-១៨ | ត្រៀម ប្រលង ឬ កិច្ចការផ្ទះ | ត្រៀម ប្រលង ឬ កិច្ចការផ្ទះ | ធ្វើការផ្ទះ | ត្រៀម ប្រលង ឬ កិច្ចការផ្ទះ | ធ្វើការផ្ទះ | ត្រៀម ប្រលង ឬ កិច្ចការផ្ទះ | ធ្វើការផ្ទះ |
| ១៨-១៩ | | ហាត់ប្រាណ | | ធ្វើការផ្ទះ | | | |
| ១៩-២០ | ធ្វើការផ្ទះ | | | | | | ត្រៀម ប្រលង ឬ កិច្ចការផ្ទះ |
| | ចូលគេង! | ចូលគេង! | ចូលគេង! | ចូលគេង! | ចូលគេង! | ចូលគេង! | ចូលគេង! |

### សន្លឹកកិច្ចការ៖ ផែនការពេលវេលារបស់ខ្ញុំ

ដើម្បីធ្វើផែនការពេលវេលាបានល្អ អ្នកត្រូវគិតពី៖

- ពេលវេលានៅសាលា
- ពេលវេលាសម្រាប់ធ្វើដំណើរទៅសាលា
- អាហារថ្ងៃត្រង់ និងអាហារពេលល្ងាច
- កិច្ចការផ្ទះ
- ការងារផ្ទះ
- ភារកិច្ចចាំបាច់ដទៃទៀត
- ហាត់ប្រាណ
- ពេលវេលាជាមួយគ្រួសារ និងមិត្តភក្តិ ឬអ្នកផ្សេងទៀត
- ពេលសំរាក
- ។ល។

| ម៉ោង | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# មេរៀនទី ៧ ក្លឹបមុខវិជ្ជា

មកដល់ពេលនេះ សិស្សរបស់អ្នកឈានជិតដល់ពាក់កណ្ដាលឆមាសហើយ។ ពួកគេអាចប្រើប្រាស់មេរៀននេះ ដើម្បីបូកសរុបអំពីថ្នាក់រៀនដំបូងនៃមេរៀនប្រឹក្សាអាជីព។ ថ្វីដ្បិតតែនេះមិនមែនជាទម្លាប់ក្នុងការមាន ក្លឹបមុខវិជ្ជា វាជាគំនិតល្អក្នុងការបូកសរុបអំពីមេរៀនទាំង ៦ របស់ការប្រឹក្សាអាជីព។ វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សរៀនឆ្លុះបញ្ចាំងអំពីធាតុចូលរបស់មេរៀនប្រឹក្សាអាជីព ទៅក្នុងការសិក្សាប្រចាំថ្ងៃរបស់ពួកគេ។

## សកម្មភាពសិស្សទី១

ឱ្យសិស្សចូលជាក្រុមដែលមានគ្នា៦នាក់ រួចឱ្យក្រុមនីមួយៗនូវកិច្ចការខុសៗគ្នា។ ក្រុមនីមួយៗត្រូវធ្វើបទបង្ហាញតូចមួយអំពីមាតិកានៃមេរៀន។ ពួកគេអាចប្រើសៀវភៅរបស់ពួកគេដើម្បីរំលឹកអ្វីដែលបានរៀន។

អ្នកអាចប្រមូលចម្លើយរបស់ពួកគេសរសេរលើក្ដារខៀន ឬឱ្យសិស្សម្នាក់ៗនូវសន្លឹកកិច្ចការនេះដែលពួកគេអាចសរសេរនូវចម្លើយសរុបរបស់គេ។

## សន្លឹកកិច្ចការ

| មាតិកាមេរៀនប្រឹក្សាអាជីព | តើខ្ញុំបានរៀនអ្វី? | តើខ្ញុំអាចយកមេរៀននេះទៅអនុវត្តន៍ក្នុងសាលាបានយ៉ាងដូម្ដេច? |
|---|---|---|
| មេរៀនទី ១ | | |
| មេរៀនទី ២ | | |
| មេរៀនទី ៣ | | |
| មេរៀនទី ៤ | | |
| មេរៀនទី ៥ | | |
| មេរៀនទី ៦ | | |

## មេរៀនទី ៨ ការងារគម្រោង ១

ពេលនេះ សិស្សនឹងចាប់ផ្តើមការងារគម្រោងទី១ នៃមេរៀនប្រឹក្សាអាជីព។ មេរៀនចំនួន ៤ បន្ទាប់ទៀត នឹងត្រូវបានប្រើប្រាស់ក្នុងគម្រោងសិក្សា។ សេចក្តីណែនាំអំពីគម្រោងសិក្សានឹងត្រូវបានបង្ហាញនៅក្នុងមេរៀននេះ ហើយសិស្សនឹងត្រូវធ្វើការជាក្រុម ដើម្បីរៀបចំផែនការគម្រោងរបស់ពួកគេ។ មេរៀនបន្ទាប់ ពួកគេនឹងត្រូវពន្យល់បកស្រាយអំពីលទ្ធផលការងារគម្រោងរបស់ខ្លួន។ វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សរៀនធ្វើការងារគម្រោងដោយឯករាជ្យនៅក្នុងក្រុមតូច ប្រកបដោយការទទួលខុសត្រូវ និងធ្វើបទបង្ហាញអំពីលទ្ធផលរបស់គម្រោង

### សកម្មភាពសិស្សទី១៖ ការរៀបចំផែនការការងារគម្រោង

បែងចែកសិស្សជា ១០ ក្រុម ឬ ១០ គូ សម្រាប់ប្រធានបទចំនួន ១០ នៅក្នុងកម្មវិធីសិក្សា។ ក្រុមនីមួយៗនឹងចាប់ផ្តើមធ្វើការលើប្រធានបទ ១ ។ វត្ថុបំណងគឺ សិស្សនឹងកំណត់រកលទ្ធផលរំពឹងទុកពីការរៀនសូត្រទៅលើប្រធានបទនីមួយៗ ក្នុងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងរបៀបវាយតម្លៃទៅលើប្រធានបទទាំងនេះ (សម្ភាសគ្រូដែលបង្រៀនមុខវិជ្ជាទាំងនេះ) ស្វែងយល់ថាតើសិស្សផ្សេងទៀតគិតបែបណាអំពីប្រធានបទ (សម្ភាសមិត្តរួមថ្នាក់របស់ពួកគេ) និងស្វែងយល់អំពីថាតើទេពកោសល្យនេះ នឹងត្រូវបានប្រើប្រាស់បែបណានៅក្នុងជីវិតការងារ (សម្ភាសឪពុកម្តាយ ឬសាច់ញាតិ ឬមនុស្សពេញវ័យ)។ ធ្វើដូចនេះ នឹងជំរុញឱ្យសិស្សមានការយល់ដឹងស៊ីជម្រៅអំពីវត្ថុបំណងរបស់មធ្យមសិក្សាទុតិយភូមិ និងជួយឱ្យសិស្សមានការជំរុញទឹកចិត្ត និងប្តេជ្ញាដោយខ្លួនឯង ហើយមើលឃើញអំពីទំនាក់ទំនងទៅនឹងជីវិតការងារជាក់ស្តែង។ ខាងក្រោមនេះ ជាប្រធានបទដែលពួកគេត្រូវធ្វើការងារជាក្រុម៖

- អក្សរសាស្ត្រខ្មែរ
- គណិតវិទ្យា
- សិក្សាសង្គម
- វិទ្យាសាស្ត្រ
- ព័ត៌មានវិទ្យា និងទូរគមនាគមន៍(ICT)
- ភាសាបរទេស (ភាសាអង់គ្លេស និង/ឬភាសាបារាំង)
- កីឡា និងកាយវិទ្យា
- ការអប់រំសុខភាព
- ការអប់រំសិល្បៈ
- បំណិនជីវិតមូលដ្ឋាន

សិស្សចំណាយពេលក្នុងមេរៀននេះដើម្បីរៀបចំផែនការការងារគម្រោងជាក្រុម ដោយប្រើសន្លឹកកិច្ចការ ឬសៀវភៅរបស់ពួកគេ។ ពួកគេនឹងរៀបសំណួរសម្រាប់ធ្វើកិច្ចសម្ភាសជាមួយគ្នា និងបែងចែកភារកិច្ចគ្នា (នរណាជាអ្នកសម្ភាស ឬសម្ភាសទាំងអស់គ្នា - អ្នកត្រូវឱ្យពួកគេជាអ្នកសម្រេច)។

មុននឹងមេរៀនប្រឹក្សាអាជីពបន្ទាប់ត្រូវបានចាប់ផ្ដើម ពួកគេត្រូវធ្វើកិច្ចសម្ភាសឱ្យរួចរាល់។ សម្រាប់មេរៀនបន្ទាប់ ឱ្យពួកគេយកមកជាមួយនូវ ឧ. គំរូកាសែត ឬសម្ភារៈផ្សេងទៀតដូចជា រូបភាព កាតប៉ុស្ដាល់ ដែលទាក់ទងនឹងប្រធានបទគម្រោងរបស់ពួកគេ។

**សន្លឹកកិច្ចការ៖ រៀបចំផែនការគម្រោង**

| ភារកិច្ចដែលត្រូវធ្វើ | កាលវិភាគ/កាលបរិច្ឆេទ | ការទទួលខុសត្រូវ (ដែលសិស្សក្រុមត្រូវធ្វើ) | រៀបចំសំណួរចំនួន២-៣ ដើម្បីសម្ភាស |
|---|---|---|---|
| សម្ភាសគ្រូមុខវិជ្ជា ដែលនឹងត្រូវធ្វើសម្ភាស | | | |
| សម្ភាសមិត្តរួមសាលា ២ នាក់ ដែលនឹងត្រូវធ្វើសម្ភាស | | | |
| សម្ភាសមនុស្សពេញវ័យ ២ នាក់ ដែលនឹងត្រូវធ្វើសម្ភាស | | | |

## មេរៀនទី ៩ ការខារគម្រោង ២

### សកម្មភាពសិស្ស៖ រៀបចំបទបង្ហាញ

សិស្សត្រូវពន្យល់បង្ហាញអំពីលទ្ធផលនៃការធ្វើសម្ភាសរបស់ពួកគេ និងរៀបចំបទបង្ហាញប្រធានបទរបស់ពួកគេសម្រាប់ពេលបន្ទាប់។ រយៈពេលធ្វើបទបង្ហាញចាប់ពី ៥ ទៅ១០នាទី។ សិស្សត្រូវបន្តធ្វើការនៅក្នុងក្រុមដដែល។ បទបង្ហាញអាចធ្វើលើផ្ទាំងក្រដាសដែលពួកគេតុបតែងដោយកាតប៉ុស្តាល់ គូរគំនូរ រូបថត ឬគំរូកាសែតដែលទាក់ទងនឹងប្រធានបទរបស់ពួកគេ។ នៅក្នុងបទបង្ហាញ ចំណុចសំខាន់ចំនួន ៣ គួរតែត្រូវលើកឡើង៖

១.តើអ្វីខ្លះជាវត្ថុបំណងនៃការរៀនមេរៀននេះ? (ឧ. ភាសាខ្មែរ ឬគណិតវិទ្យា....។ល។ យោងតាមចម្លើយដែលបានពីការសម្ភាសគ្រូ)

២.តើសិស្សដទៃទៀតគិតបែបណាចំពោះប្រធានបទនេះ? (យោងតាមចម្លើយដែលបានពីការសម្ភាសមិត្តរួមថ្នាក់)

៣.តើហេតុអ្វីបានជាប្រធានបទនេះមានសារៈសំខាន់នៅក្នុងជីវិតការងារ? (យោងតាមចម្លើយដែលបានពីការសម្ភាសមនុស្សពេញវ័យ)

អ្នកអាចដើរមើលតាមក្រុមនីមួយៗ ប្រសិនបើគេជួបការលំបាក ក្នុងការកំណត់រកវត្ថុបំណងរបស់កម្មវិធីសិក្សា អ្នកអាចជួយពួកគេ (លទ្ធផលរំពឹងទុករបស់ប្រធានបទនីមួយៗ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៤.៥ ដូចដែលដាក់នៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ)។ ក្នុងករណី សិស្សមិនជោគជ័យក្នុងការសម្ភាសមិត្តរួមថ្នាក់ អ្នកត្រូវឱ្យពួកគេបញ្ចប់ការសម្ភាសនេះឱ្យលឿន ដើម្បីទុកពេលស្នើសុំការសម្ភាសជាមួយអ្នកដែលមានបទពិសោធន៍ជុំវិញប្រធានបទរបស់ពួកគេ ឬអ្នកអាចជួយពួកគេតាមលទ្ធភាព។

មេរៀន ២ បន្ទាប់ទៀតគឺការធ្វើបទបង្ហាញ។ ពេលនេះអ្នកគួរប្រាប់សិស្សថាតើ ៥ ក្រុមណាទៀតដែលត្រូវធ្វើបទបង្ហាញនៅមេរៀនបន្ទាប់។ (ឧ. ប្រាប់ឱ្យក្រុម ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT) ត្រៀមធ្វើបទបង្ហាញ។)



## មេរៀនទី ១០ ការងារគម្រោង ៣

### សកម្មភាពសិស្ស

នៅក្នុងមេរៀននេះ គម្រោង ៥ ដំបូងត្រូវបានបង្ហាញដោយសិស្ស។ ដោយសារតែរយៈពេលមេរៀននេះមានតែ ៤៥ នាទី ក្រុមនីមួយៗមានពេលពី ៥-១០ នាទីដើម្បីបង្ហាញការងាររបស់គេ ដូចនេះអ្នកត្រូវពិនិត្យមើលពេលវេលាសម្រាប់បទបង្ហាញនីមួយៗ។ បទបង្ហាញខ្លីកាន់តែល្អ ដូចនេះអ្នកនឹងមានពេលផ្តល់មតិយោបល់ ឬសួរសំណួរបន្ថែមពេលបង្ហាញនីមួយៗ។ បទបង្ហាញនីមួយៗគួរតែឱ្យតម្លៃ និងផ្តល់យោបល់ជាវិជ្ជមាន និងទះដៃសាទរ ដូចនេះសិស្សនឹងមានទឹកចិត្តក្នុងការធ្វើការងារគម្រោង និងបង្ហាញដោយឯករាជ្យ។

## មេរៀនទី ១១ ការងារគម្រោង ៤

### សកម្មភាពសិស្ស៖

នៅក្នុងមេរៀននេះ គម្រោង៥ដំបូងត្រូវបានបង្ហាញដោយសិស្ស។ ដោយសារតែរយៈពេលមេរៀននេះមានតែ ៥០នាទី ក្រុមនីមួយៗមានពេលពី ៥-១០នាទីដើម្បីបង្ហាញការងាររបស់គេ ដូចនេះអ្នកត្រូវពិនិត្យមើលពេលវេលាសម្រាប់បទបង្ហាញនីមួយៗ។ បទបង្ហាញខ្លីកាន់តែល្អ ដូចនេះអ្នកនឹងមានពេល ផ្តល់មតិយោបល់ ឬសួរសំណួរបន្ថែមពេលបង្ហាញនីមួយៗ។ បទបង្ហាញនីមួយៗគួរតែឱ្យតម្លៃ និងផ្តល់យោបល់ជាវិជ្ជមាន និងទះដៃសាទរ ដូចនេះសិស្សនឹងមានទឹកចិត្តក្នុងការធ្វើការងារគម្រោង និងបង្ហាញដោយឯករាជ្យ។



## មេរៀនទី ១២ ការកំណត់ និងសម្រេចគោលដៅ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សក្នុងការកំណត់គោលដៅ។

នៅពេលដែលពួកគេកំពុងធ្វើការងារគម្រោង ពួកគេត្រូវឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងមុខវិជ្ជាដែលបានរៀននៅសាលា និងពិភពពិតខាងក្រៅ។ ពួកគេគួរតែយល់ថា អ្វីទៅជាការសិក្សាដែលផ្ដោតលើគោលដៅ។ ការសិក្សាដែលផ្ដោតលើគោលដៅ គឺខុសពីការសិក្សាដែលគ្មានគោលដៅពិតប្រាកដ (ឧ. សិស្សនឹងទទួលបានជោគជ័យ ពេលដែលគេមានគោលដៅជាក់លាក់)។

### សកម្មភាពសិស្សទី១

សិស្សអាចចាប់ផ្ដើមចេញពីការពិភាក្សាទូទៅអំពីការងារគម្រោង។ តើសិស្សមានអារម្មណ៍យ៉ាងដូចម្ដេចនៅពេលកំពុងអនុវត្តគម្រោង? តើការសម្ភាសប្រព្រឹត្តទៅយ៉ាងដូម្ដេច? តើការងារជាក្រុមដំណើរការយ៉ាងដូម្ដេចដែរ? តើជួបបញ្ហាប្រឈមអ្វីខ្លះ? បរិយាយអំពីអ្វីដែលគេមានមោទនភាព? ។ល។ បន្ទាប់ពីធ្វើការងារគម្រោង ពួកគេបានយល់ច្បាស់អំពីវត្ថុបំណងរបស់មុខវិជ្ជានីមួយៗដែលបានសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ពួកគេអាចទាយស្មានបានអំពីអាជីពទៅអនាគតនៅពេលដែលបានរៀនមុខវិជ្ជាដែលគេចូលចិត្ត។ អ្នកអាចសួរសិស្សមួយចំនួន ដើម្បីឱ្យដឹងថា តើពួកគេមានការផ្លាស់ប្ដូរទស្សនៈអំពីប្រធានបទ ឬដូរមុខវិជ្ជាដែលគេចូលចិត្ត នៅពេលដែលកំពុងអនុវត្តការងារគម្រោង និងបានស្ដាប់ក្រុមផ្សេងៗធ្វើបទបង្ហាញដែរឬទេ?

### សកម្មភាពសិស្សទី២

បែងចែកសិស្សជាក្រុមតូចៗ ដែលមានគ្នា ៤–៥ នាក់ រួចចែករំលែកបទពិសោធន៍ និងអារម្មណ៍របស់ពួកគេពីការកំណត់ និងសម្រេចគោលដៅជាមួយគ្នា។

### *សំណួរពិភាក្សា*

- តើភាពខុសគ្នារវាងបំណងប្រាថ្នា និងគោលដៅមានអ្វីខ្លះ? តើអ្នកធ្លាប់បានកំណត់គោលដៅសម្រាប់ខ្លួនឯងដែរឬទេ? (បំណងប្រាថ្នាមិនមែនសុទ្ធតែគោលដៅនោះទេ។ គោលដៅ គឺមានភាពពិតប្រាកដជាង។)
- តើអ្នកមានគោលដៅអ្វីខ្លះនៅពេលនេះ (រយៈពេលខ្លី និងរយៈពេលវែង)? តើអ្នកកំណត់គោលបំណងរបស់អ្នកយ៉ាងដូម្ដេច?

### របៀបកំណត់គោលដៅ

១. កំណត់គោលដៅ

២. គ្រោងជំហានដែលត្រូវការដើម្បីសម្រេចគោលដៅ

៣. ពិចារណាអំពីកត្តាប្រឈម និងមធ្យោបាយដើម្បីដោះស្រាយ

៤. កំណត់ពេលវេលា។

### សកម្មភាពសិស្សទី៣

អ្នកត្រូវឱ្យសិស្សអនុវត្តលំហាត់ ដើម្បីរៀនបង្កើតគោលដៅ។ នៅក្នុងសម្មតិកម្មនីមួយៗ ឱ្យសិស្សបង្កើតគោលដៅដោយអនុវត្តតាមជំហានទាំង ៤ ខាងលើ។

**ឧទាហរណ៍៖**

*លំហាត់បង្កើតគោលដៅទី១៖* រកប្រាក់ទិញកុំព្យូទ័រថ្មីមួយ ឬសៀវភៅសម្រាប់ទៅរៀន។

*លំហាត់បង្កើតគោលដៅទី២៖* រៀបចំបង្កើតដាំបន្លែ/ផ្លែឈើ មួយនៅសាលារៀន។

## សកម្មភាពសិស្សទី៨

ចែកសន្លឹកកិច្ចការមួយច្បាប់ (ជណ្ដើរនៃក្ដីសុបិន) ទៅឱ្យសិស្សម្នាក់ៗ ឬសរសេរកិច្ចការលើក្ដារខៀន។ ឱ្យពួកគេកំណត់គោលដៅរយៈពេលខ្លីមួយ ដែលអាចសម្រេចបានក្នុងកំឡុងពេលឆ្នាំសិក្សា។ ឧទាហរណ៍ ពួកគេអាចប្រលងបានបានពិន្ទុមធ្យមណាមួយ ឬពួកគេអាចកំណត់គោលដៅសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន ឬជំនាញដូចជា ចំណាយពេលសម្រាប់ធ្វើលំហាត់នៅផ្ទះឱ្យបានច្រើន ឬជួយសិស្សផ្សេងទៀតក្នុងការសិក្សា។ ពួកគេអាចកំណត់គោលដៅរយៈពេលវែង សម្រាប់រៀនជំនាញវិជ្ជាជីវៈ ឬអាជីពនាពេលអនាគត ដោយកំណត់ពីជំហាន ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន។

*ប្រសិនបើមានពេល៖* ឱ្យសិស្សបង្ហាញគោលដៅរបស់ពួកគេទៅកាន់មិត្តរួមថ្នាក់ រួមទាំងផែនការ ពេលវេលា និងសារៈសំខាន់។



## សន្លឹកកិច្ចការ៖ ជណ្ដើរនៃក្ដីសុបិន



# មេរៀនទី ១៣ ការប៉ាន់ស្មាន និងការដាក់ពិន្ទុ

បន្ទាប់ពីបញ្ចប់ការងារគម្រោង សិស្សមានការយល់ដឹងច្បាស់ជាងមុនអំពីលទ្ធផលរំពឹងទុករបស់ប្រធានបទនីមួយៗដែលបានបង្រៀននៅសាលា។ នៅមេរៀនចុងក្រោយ ពួកគេអាចកំណត់គោលដៅដូចជា ទាក់ទងនឹងការទទួលបានពិន្ទុមធ្យមជាក់លាក់ណាមួយ...។ វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សឱ្យមានការយល់ដឹងអំពីរបៀបប៉ាន់ស្មានសមិទ្ធផលរបស់ពួកគេ។

## សកម្មភាពសិស្សទី១

ឱ្យសិស្សធ្វើការពិភាក្សាក្រុមធំ ដោយផ្តល់នូវព័ត៌មានអំពីការប៉ាន់ស្មានសម្រាប់ប្រើប្រាស់ នៅមធ្យមសិក្សាទុតិយភូមិ។ ផ្តល់ការណែនាំក្នុងការប៉ាន់ស្មាន និងដាក់ពិន្ទុដែលជារឿយៗត្រូវបានប្រើនៅសាលារបស់អ្នក៖

- របៀបប៉ាន់ស្មានកិច្ចការសាលា៖ ពិន្ទុ ឬចំណាត់ថ្នាក់ ការប៉ាន់ស្មានដោយផ្ទាល់មាត់?
- តើមានប្រភេទនៃការប៉ាន់ស្មានក្រៅពីការប្រលង និងតេស្តឬទេ? ឧទាហរណ៍ កិច្ចការធ្វើនៅផ្ទះ បទបង្ហាញនៅក្នុងថ្នាក់រៀន និងកិច្ចការអនុវត្តផ្ទាល់។
- តើពេលណាទើបការប្រលងផ្លូវការត្រូវបានកំណត់កាលបរិច្ឆេទ?
- ប្រភេទពិន្ទុ (ពិន្ទុជាប់ និងពិន្ទុធ្លាក់)
- តើមានអ្វីកើតឡើងប្រសិនបើអ្នកប្រឡងធ្លាក់/ធ្លាក់មុខវិជ្ជាណាមួយ?
- វិញ្ញាបនបត្រ ឬសញ្ញាបត្រនៅពេលរៀនចប់ និងតម្រូវការសម្រាប់បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ហើយទទួលបានវិញ្ញាបនបត្រ។

ការប៉ាន់ស្មានដោយខ្លួនឯង គឺជាទិដ្ឋភាពដ៏សំខាន់សម្រាប់ការរៀនសូត្រ។ សិស្សគួរតែត្រូវបានលើកទឹកចិត្ត ដើម្បីឆ្លុះបញ្ចាំងទៅលើការរីកចម្រើន និងការវិវឌ្ឍខ្លួន ប្រៀបធៀបការងារបច្ចុប្បន្នរបស់ពួកគេទៅនឹងពេលកន្លងមក និងប្រៀបធៀបជាមួយនឹងទិសដៅផ្ទាល់ខ្លួនរបស់ពួកគេ។ ការប៉ាន់ស្មានការងារផ្ទាល់ខ្លួន អាចជួយឱ្យសិស្សអភិវឌ្ឍការយល់ដឹងរបស់ពួកគេទៅលើគោលបំណងនៃការរៀនសូត្រ និងកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកគេ ហើយពិនិត្យមើលថាតើពួកគេអាចធ្វើឱ្យប្រសើរឡើងបានដោយរបៀបណា។

## សកម្មភាពសិស្សទី២

ចែកសន្លឹកកិច្ចការមួយច្បាប់ (ការប៉ាន់ស្មាន និងការដាក់ពិន្ទុ) ទៅឱ្យសិស្សម្នាក់ៗ ឬសរសេរសំណួរនៅលើក្តារខៀន។ នេះគឺជាកិច្ចការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ដូចនេះឱ្យសិស្សធ្វើដោយផ្ទាល់ខ្លួនឯងរៀងៗខ្លួន។ ឱ្យពួកគេអានសំណួរ និងគិតដោយយកចិត្តទុកដាក់មុននឹងសរសេរចម្លើយរបស់គេ។ ទុកពេលឱ្យគ្រប់គ្រាន់សម្រាប់ពួកគេបញ្ចប់កិច្ចការនេះ។

### សន្លឹកកិច្ចការ៖ ការប៉ាន់ប្រមាណ និងការដាក់ពិន្ទុ ១

អានសំណួរខាងក្រោម រួចពិចារណាដោយយកចិត្តទុកដាក់ទៅលើប្រធានបទនីមួយៗ បន្ទាប់មកសរសេរចម្លើយរបស់អ្នក។

ហេតុអ្វីបានជាត្រូវវាយតម្លៃសិស្សនៅសាលារៀន?

ហេតុអ្វីវាមានសារៈសំខាន់ក្នុងការធ្វើលំហាត់នៅផ្ទះ? សូមបញ្ជាក់មូលហេតុយ៉ាងតិចបី។

ហេតុអ្វីការចូលរួមពិភាក្សាក្នុងថ្នាក់រៀន មានសារៈសំខាន់? សូមបញ្ជាក់មូលហេតុយ៉ាងតិចបី។

តើគ្រូរបស់អ្នកផ្តល់នូវមតិត្រលប់នៅពេលណា ហើយដោយរបៀបណា?

តើអ្នកមានអារម្មណ៍បែបណានៅពេលទទួលបានមតិត្រឡប់ល្អៗ ទៅលើការងារសាលារបស់អ្នក?

តើហេតុអ្វីបានជាការឆ្លុះបញ្ចាំង និងប៉ាន់ប្រមាណដោយទៀងទាត់ទៅលើការអភិវឌ្ឍ និងការរីកចម្រើនរបស់អ្នក មានសារៈសំខាន់?

តើអ្នកមានគោលដៅយ៉ាងណាសម្រាប់ការងារសាលា និងពិន្ទុរបស់អ្នក?

តើវិញ្ញាបនបត្រពេលបញ្ចប់ការសិក្សាមានសារៈសំខាន់បែបណាខ្លះ? ហេតុអ្វី?

## សកម្មភាពសិស្សទី៣

ចែកសន្លឹកកិច្ចការមួយច្បាប់ (ការប៉ាន់ប្រមាណ និងការដាក់ពិន្ទុ ទី២) ទៅឱ្យសិស្សម្នាក់ៗ ឬសរសេរសំណួរនៅលើក្តារខៀន។ ឱ្យសិស្សធ្វើម្នាក់ឯង រួចបំពុសគំនិតសិស្សលើចំណុចទាំង ៣ ខាងក្រោម៖ ១) សរសេរនូវអ្វីដែលអ្នកពូកែ (មុខវិជ្ជាសាលា ជំនាញសិក្សាដូចជា ការអាន និងការសរសេរ ការប្រគំតន្ត្រី។ល។) ២) សរសេរនូវអ្វីដែលអ្នកគិតថាពិបាកធ្វើ និង ៣)សរសេរនូវអ្វីដែលអ្នកអាចធ្វើឱ្យការអនុវត្ត និងអភិវឌ្ឍន៍ជំនាញរបស់អ្នកបានប្រសើរជាងមុន។ នៅដំណាច់ឆ្នាំ យក

សន្លឹកកិច្ចការដែលសិស្សបានបំពេញនោះមកមើលឡើងវិញ ហើយពិនិត្យមើលថាមានអ្វីបានអនុវត្តប្រសើរជាងមុន។

### សន្លឹកកិច្ចការ៖ ការប៉ាន់ប្រមាណ និងការដាក់ពិន្ទុ ២

បំផុសគំនិតសិស្សលើចំណុចទាំង ៣ ខាងក្រោម៖ ១) សរសេរនូវអ្វីដែលអ្នកពូកែ (មុខវិជ្ជាសាលា ជំនាញសិក្សាដូចជា ការអាន និងការសរសេរ សរសេរបទចម្រៀង។ល។) ២) សរសេរនូវអ្វីដែលអ្នកគិតថាពិបាកធ្វើ និង ៣)សរសេរនូវអ្វីដែលអ្នកអាចធ្វើឱ្យការអនុវត្ត និងអភិវឌ្ឍជំនាញរបស់អ្នកបានប្រសើរជាងមុន។



# មេរៀនទី ១៤ ការវាយតម្លៃអំពីជំនាញសិក្សា

ពេលនេះ សិស្សកំពុងតែឈានដល់ជំនាញនៅក្នុងការសិក្សា។ ជាការចាប់ផ្ដើម សិស្សនឹងវាយតម្លៃពីជំនាញក្នុងការសិក្សារបស់ពួកគេ។ វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយសិស្សឱ្យឆ្លុះបញ្ចាំង និងវាយតម្លៃជំនាញក្នុងការសិក្សារបស់ពួកគេ ដើម្បីយល់ដឹងថាជំនាញនៅក្នុងការសិក្សា គឺដូចគ្នាទៅនឹងទេពកោសល្យផ្សេងៗទៀតដែលអាចធ្វើការប៉ាន់ស្មាន និងធ្វើឱ្យប្រសើរឡើង។

## សកម្មភាពសិស្សទី១ៈ ការវាយតម្លៃអំពីជំនាញសិក្សា

ចែកសន្លឹកកិច្ចការមួយច្បាប់ ទៅឱ្យសិស្សម្នាក់ៗ ឬសរសេរសំណួរនៅលើក្ដារខៀនសម្រាប់ឱ្យសិស្សចម្លងចូលសៀវភៅ។ នេះគឺជាលំហាត់សម្រាប់សិស្សម្នាក់ៗធ្វើដោយខ្លួនឯង។

## សន្លឹកកិច្ចការៈ ជំនាញនៃការសិក្សា

| តើអ្នកដាក់ពិន្ទុជំនាញសិក្សារបស់អ្នកយ៉ាងដូចម្ដេចពី ១ ទៅ ១០? | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
|---|---|---|---|---|---|---|---|---|---|---|
| ១. ខ្ញុំដឹងវិធីសិក្សាប្រកបដោយប្រសិទ្ធភាព | | | | | | | | | | |
| ២. ខ្ញុំដឹងពីរបៀបរៀនសូត្ររបស់ខ្ញុំ | | | | | | | | | | |
| ៣. ខ្ញុំមានអាកប្បកិរិយាវិជ្ជមានក្នុងការសិក្សា | | | | | | | | | | |
| ៤. ខ្ញុំមានគោលដៅច្បាស់លាស់សម្រាប់ការសិក្សារបស់ខ្ញុំ | | | | | | | | | | |
| ៥. ខ្ញុំមានការជំរុញទឹកចិត្តល្អក្នុងការសិក្សា | | | | | | | | | | |
| ៦. ខ្ញុំដឹងពីរបៀបរៀបចំពេលវេលាសិក្សា | | | | | | | | | | |
| ៧. ខ្ញុំដឹងពីរបៀបរៀបចំខ្លួនឯងឱ្យត្រូវនឹងការសិក្សា | | | | | | | | | | |
| ៨. វាមានភាពងាយស្រួលសម្រាប់ខ្ញុំក្នុងការស្ដាប់ និងកត់ត្រាពេលម៉ោងរៀន | | | | | | | | | | |
| ៩. វាមានភាពងាយស្រួលសម្រាប់ខ្ញុំ ក្នុងការរៀនដោយស្ដាប់គ្រូ | | | | | | | | | | |
| ១០. វាមានភាពងាយស្រួលសម្រាប់ខ្ញុំ ក្នុងការរៀនដោយការអានអត្ថបទ រួចកត់ត្រានូវចំណុចសំខាន់ៗ | | | | | | | | | | |
| ១១. ខ្ញុំមានការចងចាំល្អ | | | | | | | | | | |
| ១២. វាមានភាពងាយស្រួលសម្រាប់ខ្ញុំ ក្នុងការផ្ដោតអារម្មណ៍លើការសិក្សា | | | | | | | | | | |

តើអ្នកពិពណ៌នាអំពីខ្លួនអ្នកយ៉ាងដូចម្ដេចក្នុងនាមជាសិស្ស?

|   |
|---|
|   |

### សកម្មភាពសិស្សទី២៖ ការពិភាក្សាជាគូ

ឱ្យសិស្សចាប់ដៃគូ រួចប្រៀបធៀបសន្លឹកកិច្ចការរបស់ពួកគេ ឆ្លើយចម្លើយ និងពិភាក្សាអំពីប្រធានបទទាំងនេះ។ វាជាការប្រសើរ ប្រសិនបើពួកគេអាចចាប់ដៃគូជាមួយអ្នកដែលគេស្គាល់ ដូចនេះពួកគេក៏អាចផ្ដល់មតិលើចម្លើយរបស់គ្នាទៅវិញទៅមក។ តើពួកគេយល់ស្របតាមចម្លើយរបស់គ្នាទៅវិញទៅមកឬទេ? តើពួកគេអាចវាយតម្លៃផ្សេងពីគ្នាឬទេ?

### សកម្មភាពសិស្សទី៣៖ ការពិភាក្សាជាក្រុម

ឱ្យសិស្សដាក់ពិន្ទុថាតើមុខវិជ្ជាមួយណាក្នុងចំណោមមុខវិជ្ជាដែលពួកគេកំពុងសិក្សា ដើម្បីរកឱ្យឃើញថា មុខវិជ្ជាណាពិបាកជាងគេ និងមុខវិជ្ជាណាស្រួលជាងគេ។ អ្នកអាចសរសេរនៅលើក្ដារខៀន ដើម្បីឱ្យសិស្សដទៃផ្សេងទៀតអាចមើលបាន។



## មេរៀនទី ១៥   វិធីសាស្ត្ររៀនដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា ១

វត្ថុបំណងនៃមេរៀននេះ និងមេរៀនបន្ទាប់ទៀតគឺ៖

- ជួយឱ្យសិស្សស៊ាំទៅនឹងវិធីសាស្ត្ររៀនផ្សេងៗគ្នា
- កំណត់រកវិធីសាស្ត្ររៀនរបស់សិស្សម្នាក់ៗ។

### សកម្មភាពសិស្សទី១

តើវិធីសាស្ត្ររៀនមួយណាដែលអ្នកចូលចិត្ត? មានតេស្តជាច្រើនសម្រាប់ស្វែងយល់ពីវិធីសាស្ត្ររៀនរបស់បុគ្គលម្នាក់ៗ។ ខាងក្រោមគឺជាតេស្តខ្លីមួយចំនួន ដែលអាចផ្តល់ជាគម្រូយខ្លះៗ។

**តេស្តខ្លី ១៖** ចលនាភ្នែក ជាពិសេសនៅពេលដែលគិត ឬឆ្លើយសំណួរ។ សួរទៅកាន់សិស្សក្នុងចំណោមចំណុចទាំង៣ខាងក្រោម តើពួកគេចូលចិត្តធ្វើមួយណានៅពេលគិត?

- អ្នកគិតដោយប្រើ**ចក្ខុ** មានទំនោរមើលឡើងលើ (រូបភាព!)
- អ្នកគិតដោយប្រើ**ការស្តាប់** មានទំនោរមើលត្រង់ទៅមុខ
- អ្នកគិតដោយប្រើ**ការអនុវត្ត** មានទំនោរមើលចុះក្រោម

**តេស្តខ្លី ២៖** វាក្យសព្ទ (អាស្រ័យតាមភាសា និងវប្បធម៌)។ សួរសិស្សតើកិរិយាសព្ទ ឬពាក្យមួយណាដែលពួកគេប្រើ?

- អ្នកគិតដោយប្រើ**ចក្ខុ៖** «ខ្ញុំចាប់រូបភាពបានហើយ!» «ខ្ញុំមើលឃើញហើយ!» «តាមទស្សនៈរបស់ខ្ញុំ!» «តើអ្នកមានទស្សនៈបែបណា?»
- អ្នកគិតដោយប្រើ**ការស្តាប់៖** «ខ្ញុំទទួលបានសារហើយ!» «វាជាសំឡេងគោះកណ្តឹង!» «សំឡេងនេះខ្ញុំអាចទទួលយកបាន!»
- អ្នកគិតដោយប្រើ**ការអនុវត្ត៖** «អំពី...» «វាពិតជាមានអារម្មណ៍ត្រឹមត្រូវហើយ!» «ខ្ញុំអាចភ្ជាប់ខ្លួនឯងទៅនឹងរឿងហ្នឹងបាន!»

### សកម្មភាពសិស្សទី២៖ តេស្តលើវិធីសាស្ត្ររៀន

ចែកសន្លឹកកិច្ចការឱ្យសិស្សគ្រប់គ្នា (តេស្តលើរបៀបរៀន) រួចឱ្យពួកគេបំពេញ។



### សន្លឹកកិច្ចការៈ តេស្តលើរបៀបរៀន

តើរបៀបរៀនមួយណាដែលអ្នកចូលចិត្ត? អានសំណេរខាងក្រោម រួចគូសលើចម្លើយដែលអ្នកពេញចិត្ត «ញឹកញាប់» «ម្តងម្កាល» ឬ «ដោយកម្រ»

| | ញឹកញាប់ | ម្តងម្កាល | ដោយកម្រ |
|---|---|---|---|
| ១. ខ្ញុំអាចចងចាំមេរៀនយ៉ាងល្អ ដោយការស្តាប់គ្រូបង្រៀនដែលមានព័ត៌មាន ការពន្យល់ និងការពិភាក្សា | | | |
| ២. ខ្ញុំចូលចិត្តមើលការសរសេរព័ត៌មាននៅលើក្តារខៀន ឬតាមរយៈ ឧបករណ៍ឧបទ្ទេស និងលំហាត់សម្រាប់អាន | | | |
| ៣. ខ្ញុំចូលចិត្តសរសេរ ឬកត់ត្រាសម្រាប់មើលម្តងទៀតនៅពេលក្រោយ | | | |
| ៤. ខ្ញុំចូលចិត្តប្រើផ្ទាំងក្រដាស ឧបករណ៍គំរូ ឬសកម្មភាពអនុវត្តផ្សេងៗក្នុងថ្នាក់ | | | |
| ៥. ខ្ញុំត្រូវការការពន្យល់អំពីដ្យាក្រាម ខ្សែកោង ឬទិសដៅដោយប្រើរូបភាព | | | |
| ៦. ខ្ញុំចូលចិត្តធ្វើការងារ ឬផលិតវត្ថុដោយប្រើដៃរបស់ខ្ញុំ | | | |
| ៧. ខ្ញុំមានជំនាញ និងចូលចិត្តបង្កើតក្រាហ្វិច និងគំនូសតាង | | | |
| ៨. ខ្ញុំអាចដឹងប្រសិនបើសំឡេងត្រូវបានភ្ជាប់គ្នា | | | |
| ៩. ខ្ញុំអាចចងចាំបានយ៉ាងល្អ ដោយការសរសេរឱ្យច្រើនដង | | | |
| ១០. ខ្ញុំអាចយល់ និងដើរតាមទិសដៅក្នុងផែនទីដោយងាយស្រួល | | | |
| ១១. ខ្ញុំអាចរៀនមុខវិជ្ជាបានយ៉ាងល្អដោយស្តាប់គ្រូ និងស្តាប់កាសែតចាក់សំឡេង | | | |
| ១២. ខ្ញុំចូលចិត្តលេងជាមួយលុយកាក់ ឬកូនសោរដែលមាននៅក្នុងហោប៉ៅរបស់ខ្ញុំ | | | |
| ១៣. ខ្ញុំរៀនប្រកបបានល្អដោយ ថាតាមពាក្យនោះម្តងហើយម្តងទៀតឱ្យឮៗ ជាជាងការសរសេរពាក្យលើក្រដាស | | | |
| ១៤. ខ្ញុំអាចយល់អត្ថបទព័ត៌មានដោយការអាន ជាងការស្តាប់ព័ត៌មានផ្សាយតាមវិទ្យុ | | | |
| ១៥. ខ្ញុំទំពាស្ករកៅស៊ូ ឬញ៉ាំនំពេលកំពុងរៀន | | | |
| ១៦. ខ្ញុំគិតថាមធ្យោបាយដ៏ល្អបំផុតដើម្បីចងចាំអ្វីមួយ គឺបង្កើតជារូបភាពនៅក្នុងខួរក្បាលរបស់អ្នក | | | |
| ១៧. ខ្ញុំរៀនប្រកបពាក្យ ដោយប្រើ «ម្រាមដៃប្រកប» | | | |
| ១៨. ខ្ញុំចូលចិត្តស្តាប់ការបង្រៀន ឬការនិយាយដ៏ល្អ ជាជាងអានមេរៀនដូចគ្នានេះនៅក្នុងសៀវភៅ | | | |
| ១៩. ខ្ញុំពូកែដោះស្រាយ និងលេងល្បែងផ្គុំរូប និងល្បែងរកច្រកចេញ | | | |
| ២០. ខ្ញុំក្តាប់វត្ថុក្នុងដៃក្នុងពេលកំពុងរៀន | | | |
| ២១. ខ្ញុំចូលចិត្តស្តាប់ព័ត៌មានតាមវិទ្យុ ជាជាងអានតាមកាសែត | | | |
| ២២. ខ្ញុំចូលចិត្តទទួលព័ត៌មានអំពីប្រធានបទដែលចាប់អារម្មណ៍ដោយការអានវា | | | |

| | | | |
|---|---|---|---|
| ២៣. ខ្ញុំមានអារម្មណ៍សុខស្រួលដោយការប៉ះ ឱប និងចាប់ដៃអ្នកដទៃ... | | | |
| ២៤. ខ្ញុំអាចធ្វើតាមការប្រាប់ដោយផ្ទាល់មាត់ បានល្អជាងការសរសេរ | | | |

### នីតិវិធីនៅក្នុងការដាក់ពិន្ទុ

ញឹកញាប់ = ៥ ពិន្ទុ

ម្តងម្កាល = ៣ ពិន្ទុ

ដោយកម្រ = ១ ពិន្ទុ

ដាក់លេខពិន្ទុ (៥ ៣ ១) នៅលើបន្ទាត់ដែលនៅក្បែរលេខសំណួរខាងក្រោម។ បូកពិន្ទុតាមក្រឡោន នីមួយៗ ដើម្បីទទួលបានពិន្ទុសរុបក្រោមផ្នែកនីមួយៗ។

| ប្រើចក្ខុ | | ប្រើ**ការស្តាប់** | | ប្រើ**ការអនុវត្ត** | |
|---|---|---|---|---|---|
| ២ | _______ | ១ | _______ | ៤ | _______ |
| ៣ | _______ | ៥ | _______ | ៦ | _______ |
| ៧ | _______ | ៨ | _______ | ៩ | _______ |
| ១០ | _______ | ១១ | _______ | ១២ | _______ |
| ១៤ | _______ | ១៣ | _______ | ១៥ | _______ |
| ១៦ | _______ | ១៨ | _______ | ១៧ | _______ |
| ១៩ | _______ | ២១ | _______ | ២០ | _______ |
| ២២ | _______ | ២៤ | _______ | ២៣ | _______ |
| សរុប | _______ | សរុប | _______ | សរុប | _______ |

*បង្កើតដោយ៖* *Brandeis.edu* *http://www.study-tips-today.com/Study-Skills-Activities/Learning-Styles-Assessment-worksheet.html*

### សកម្មភាពសិស្សទី៣៖

ឱ្យសិស្សសរសេរឈ្មោះរបស់គេនៅលើក្តារខៀន។



### សកម្មភាពសិស្សទី៤៖ បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT)

អ្នកអាចរួមបញ្ចូលប្រធានបទនេះជាមួយ បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT) រួចឱ្យសិស្សស្វែងរកព័ត៌មានអំពីប្រធានបទនេះ ឬក៏ធ្វើតេស្តតាមអ៊ិនធឺណេត។ អ្នកអាចសហការជាមួយគ្រូផ្នែកព័ត៌មានវិទ្យា និងទូរគមនាគមន៍ សិស្សអាចធ្វើលំហាត់នេះនៅថ្នាក់កុំព្យូទ័រ ឬពួកគេអាចធ្វើលំហាត់នៅផ្ទះដោយប្រើទូរស័ព្ទឆ្លាតវៃ (Smart phone) ប្រសិនបើមាន។ ពួកគេអាចធ្វើលំហាត់នេះជាគូ ឬជាក្រុមក៏បានប្រសិនបើនរណាម្នាក់មិនអាចភ្ជាប់អ៊ិនធឺណេតបាន។

ពួកគេអាចប្រើទម្រង់ឯកសារតាមគេហទំព័រទាំងនេះ ឬធ្វើការស្រាវជ្រាវតាមទំព័របើកចំហរ។

https://www.oercommons.org/courses/learning-styles-2/view

http://www.educationplanner.org/students/self-assessments/learning-styles-quiz.shtml

### សម្រាប់អ្នកប្រឹក្សាយោបល់

អ្នកប្រើសារតាព័ត៌មាននេះដើម្បីពន្យល់ពីប្រធានបទស្តីពីវិធីសាស្ត្ររៀនដល់សិស្ស៖

**វិធីសាស្ត្ររៀន(VAK[1]) – ហេតុការណ៍**

វិធីសាស្ត្ររៀន គឺជាធម្មជាតិនៃការទទួលបាន និងយល់ដឹងពីអ្វីមួយ។ មនុស្សយើងម្នាក់ៗសុទ្ធតែមានវិធីសាស្ត្ររៀនរៀងៗខ្លួន។ សិស្សខ្លះ ចងចាំច្បាស់នូវអ្វីដែលគេបានឃើញ សិស្សខ្លះចងចាំច្បាស់នូវអ្វីដែលគេបានឮ និងសិស្សខ្លះទៀតចាំច្បាស់នូវអ្វីដែលគេឆ្លងកាត់បទពិសោធន៍។ វិធីសាស្ត្ររៀន អាចត្រូវបានចែកចំណាត់ថ្នាក់បានតាមវិធីសាស្ត្រផ្សេងៗគ្នា។

វិធីដ៏សាមញ្ញបំផុតក្នុងចំណោមវិធីដទៃទៀតនោះគឺ VAK = Visual (ការមើល) – Auditory (ការស្តាប់) – Kinaesthetic/Tactile (ការអនុវត្ត)។ វិធីរៀនទាំងបីនេះ គឺទាក់ទងទៅនឹងវិញ្ញាណទាំង ៥ របស់យើង។ ប៉ុន្តែ ឃានវិញ្ញាណ និងជីវហាវិញ្ញាណ មិនត្រូវបានរាប់បញ្ចូលក្នុងវិធីសាស្ត្ររៀននេះទេ ដោយសារតែវាមិនសំខាន់សម្រាប់ការប្រាស្រ័យទាក់ទង។

ពេលខ្លះ ការអាន(Reading) និងការសរសេរ (Writing - R) ត្រូវបានដាក់បញ្ចូល ជាវិធីសាស្ត្រនៃការរៀនមួយបែបទៀតគឺ VARK ហើយពេលខ្លះ Kinaesthetic (ចលនា) និង Tactile (ការអនុវត្ត) ត្រូវបានបំបែកចេញពីគ្នា។ នៅក្នុងឯកសារនេះ យើងនឹងប្រើប្រព័ន្ធ VAK ។

ជាការលំបាកក្នុងការកំណត់តួរលេខជាក់លាក់ អំពីភាពជាតំណាងនៃវិធីសាស្ត្ររៀននីមួយៗ។ បញ្ហានេះ វាប្រហែលជាអាស្រ័យលើវប្បធម៌ និងប្រព័ន្ធនៃការបង្រៀន។ ជាទូទៅ អ្នករៀនដោយប្រើការស្តាប់ មានចំនួនតិចជាងគេមាន ២៥% បន្ទាប់មក អ្នករៀនដោយប្រើចក្ខុមាន ៣៥% ខណ: ដែលអ្នករៀនដោយការអនុវត្តមាន ៤០%។ យើងទាំងអស់គ្នា សុទ្ធតែមានគ្រប់ប្រភេទនៃវិធីរៀនទាំងអស់ គ្រាន់តែតិច ឬច្រើន។ វិធីពន្យល់ម្យ៉ាងទៀតគឺ យើងចងចាំ ២០% នូវអ្វីដែលយើងបានឮ ៤០% នូវអ្វីដែលយើងបានឃើញ និង៨០% នូវអ្វីដែលយើងបានអនុវត្ត។

### អ្នករៀនដោយប្រើចក្ខុ

ពាក្យចាស់និយាយថា «រូបភាពមួយមានអត្ថន័យជាងមួយពាន់ពាក្យ» គឺពិតជាត្រឹមត្រូវសម្រាប់អ្នករៀនដោយប្រើចក្ខុ។ ពួកគេតែងតែគិតពីរូបភាព និងសាច់រឿង។ ពួកគេត្រូវការមើលកាយវិការ

[1] VAK៖ រូបភាព សម្លេង និងចលនា

និងទឹកមុខរបស់គ្រូ ដើម្បីយល់ពីអត្ថន័យពេញលេញអំពីមាតិកានៃមេរៀន។ ហេតុនេះហើយបានជាពួកគេ តែងតែចង់អង្គុយនៅជួរខាងមុខគេ។ ពួកគេរៀនបានយ៉ាងល្អតាមរយៈ ការបង្ហាញរូបភាពដែលមានដូចជា៖ ដ្យាក្រាម រូបភាព ផ្ទាំងរូបភាព និងឯកសារ មេរៀន។ អ្នករៀនដោយប្រើចក្ខុ តែងតែចូលចិត្តកត់ត្រាយ៉ាងលំអិត។

អ្នករៀនដោយប្រើចក្ខុ អាចទទួលប្រយោជន៍ពី......

- ផែនទី ផែនទីគំនិត តារាង គំនូសតាងលំហូរ ដ្យាក្រាម
- រូបភាព គំនូរ គំនូរជីវចល កាតដែលប្រើពន្លឺ
- បង្កើតគ្រោងគំនិត
- ចម្លងអ្វីដែលបានសរសេរនៅលើក្តារខៀន កត់ត្រាទុក
- មើលការបង្រៀនជាវីដេអូ
- គូសពណ៌ចំណាំ គូសរង្វង់ គូសបន្ទាត់ពីក្រោម ឬហាយឡាយពាក្យ និងល្បះ

## អ្នករៀនដោយប្រើការស្តាប់

អ្នករៀនដោយប្រើការស្តាប់ ចូលចិត្តរៀនដោយការស្តាប់ និងតែងតែនឹកឃើញពាក្យដែលគេធ្លាប់ឮនៅក្នុងអារម្មណ៍ជានិច្ច។ ពួកគេរៀនបានយ៉ាងល្អតាមរយៈការបង្រៀនដោយផ្ទាល់មាត់ ការពិភាក្សា ការជជែកគ្នា និងការស្តាប់។ ពួកគេស្តាប់តាមការលើកដាក់សំឡេង កម្ពស់សំឡេង ល្បឿន និងប្រភេទសំឡេងដទៃទៀត។ ព័ត៌មានជាលាយលក្ខណ៍អក្សរ ប្រហែលជាអាចមានអត្ថន័យតិចតួច រហូតទាល់តែពួកគេបានស្តាប់ឮវា។

អ្នករៀនដោយប្រើការស្តាប់ អាចទទួលប្រយោជន៍ពី......

- ការប្រើប្រាស់ពាក្យដែលទាក់ទងនឹងការចងចាំហេតុការណ៍ និងព័ត៌មានជាក់ស្តែង
- បង្កើតខ្សែអាត់សំឡេងសម្រាប់កំណត់ត្រា បន្ទាប់ពីសរសេររួច
- ថតសំឡេងរបស់មេរៀន ឬការបង្រៀន
- មើលការបង្រៀនជាវីដេអូ
- រៀនសាឡើងវិញនូវហេតុការណ៍ ដោយបិទភ្នែក
- ចូលរួមក្នុងក្រុម ឬថ្នាក់ពិភាក្សា
- ពន្យល់នូវអ្វីដែលគេបានរៀនទៅកាន់អ្នកដទៃទៀត
- តន្ត្រី រ៉េប សំឡេងបទភ្លេង និងចម្រៀង
- អានឱ្យឮៗ

## អ្នករៀនដោយការអនុវត្ត

អ្នករៀនដោយការអនុវត្ត រៀនបានយ៉ាងល្អតាមរយៈវិធីសាស្ត្រអនុវត្តផ្ទាល់ និងដោយរិះរកយ៉ាងសកម្មអំពីរូបធាតុពិភពលោកដែលនៅជុំវិញពួកគេ។ ពួកគេអាចនឹងមានអារម្មណ៍ពិបាក ប្រសិនបើឱ្យអង្គុយនៅស្ងៀមរយៈពេលយូរ ហើយនឹងអាចមានស្មារតីមិនមូលដោយសារតែត្រូវការធ្វើសកម្មភាព និងចូលចិត្តការរិះរក។

អ្នករៀនដោយប្រើការអនុវត្ត អាចទទួលប្រយោជន៍ពី......

- សិក្សាដោយប្រើរយៈពេលខ្លី

- ជ្រើសយកថ្នាក់មន្ទីរពិសោធន៍ និងធ្វើពិសោធន៍
- ដើរតួសម្តែង និងបំលែងជាសាច់រឿងល្ខោន
- ជ្រើសយកទស្សនៈកិច្ចសិក្សា ទស្សនៈកិច្ចសារៈមន្ទីរ
- រៀនសូត្រជាមួយអ្នកផ្សេងទៀត ហើយប្រើល្បែងចងចាំ
- ប្រើប្រាស់កាតដែលប្រើពន្លឺ សម្រាប់ការចងចាំ
- បង្កើតគម្រោងដើម្បីអំពីពន្យល់មេរៀន ឬហេតុការណ៍
- លទ្ធភាពដើម្បីធ្វើបំលាស់ទី
- បង្កើតវត្ថុដោយដៃរបស់គេ

ប្រភព៖http://www.brainboxx.co.uk/a3_aspects/pages/VAK.htm
កែសម្រួលចេញពី Sandberg ២០១៥។



## មេរៀនទី ១៦ វិធីសាស្ត្ររៀនដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា ២

សិស្សបន្តសិក្សាប្រធានបទដដែល។ អ្នកត្រូវណែនាំសិស្សឱ្យធ្វើចំណាត់ថ្នាក់វិធីសាស្ត្ររៀន ដោយផ្អែកលើទ្រឹស្ដីពិសោធន៍លើការរៀនសូត្ររបស់ David A. Kolb ។

### សកម្មភាពសិស្សទី១៖ តេស្តលើរបៀបរៀន

គ្រូចែកសន្លឹកកិច្ចការឱ្យសិស្សគ្រប់គ្នា (តេស្តលើវិធីសាស្ត្ររៀន ) រួចឱ្យពួកគេបំពេញ។

### សន្លឹកកិច្ចការ៖ តេស្តលើវិធីសាស្ត្ររៀន

តើវិធីសាស្ត្ររៀនមួយណាដែលអ្នកចូលចិត្ត?

វិធីសាស្ត្ររៀន គឺជាធម្មជាតិនៃការចូលចិត្តពីរបៀបដែលយើងរៀនសូត្រ និងសិក្សា។ អ្នកស្ថិតក្នុងចំណែកនៃរបៀបរៀនទាំងអស់នេះ ប៉ុន្តែគ្រាន់តែមានរបៀបរៀនមួយខ្លាំងជាងប្រភេទមួយទៀត។

វិធីសាស្ត្ររៀន អាចត្រូវបានចែកចំណាត់ថ្នាក់បានតាមវិធីសាស្ត្រផ្សេងៗគ្នា។ មួយក្នុងចំណោមនោះគឺផ្អែកតាមទ្រឹស្ដីពិសោធន៍លើការរៀនសូត្រ ដែលជាលទ្ធផលអង្កេតរបស់ David A. Kolb Peter Honey's និង Alan Mumford។

**ពិនិត្យមើលទាំងអស់គ្នា ថាតើរបៀបរៀនរបស់អ្នកគឺអ្វី៖**

អានល្បះខាងក្រោម ពិចារណារួចសរសេរពាក្យ ចាស/បាទ នៅប្រអប់ខាងចុងនៃល្បះនីមួយៗ

| វិធីសាស្ត្របំបែក ឬចម្លាស់គំនិត (Diverging) | ចាស/បាទ |
|---|---|
| ខ្ញុំចូលចិត្តប្រើការស្រមៃ និងគំនិតផ្ទាល់ខ្លួន ក្នុងការដោះស្រាយបញ្ហា និងប្រមូលព័ត៌មាន | |
| ខ្ញុំចូលចិត្តមើល ជាជាងការធ្វើ | |
| ខ្ញុំចូលចិត្តរៀនជាក្រុម ជាងរៀនម្នាក់ឯង | |
| ខ្ញុំចូលចិត្តមើលអ្វីមួយជាមួយនឹងទស្សនៈផ្សេងពីគេ | |
| ខ្ញុំមានចំណាប់អារម្មណ៍ជាមួយមនុស្ស ជាងហេតុការណ៍ | |
| ពិន្ទុផ្អែកវិធីសាស្ត្របំបែក ឬចម្លាស់គំនិត តើមាន ចាស/បាទ ប៉ុន្មាន? | |

| វិធីសាស្ត្របន្សុំគំនិត(Assimilating) | ចាស/បាទ |
|---|---|
| ខ្ញុំចូលចិត្តមើលអ្វីដែលថ្មី ជាមួយនឹងអភិក្រមដែលសមហេតុសមផល | |
| ខ្ញុំចូលចិត្តទ្រឹស្ដីដែលសមហេតុសមផល ជាជាងផ្អែកលើគុណតម្លៃជាក់ស្ដែង | |
| ខ្ញុំចូលចិត្តការពន្យល់ច្បាស់លាស់ ជាជាងឱកាសជាក់ស្ដែង | |
| គំនិត និងទស្សនាទាន គឺគួរឱ្យចាប់អារម្មណ៍ជាងមនុស្ស | |
| ខ្ញុំចូលចិត្តសិក្សាដោយ ការអាន ការបង្រៀន ស្វែងរកគំរូ/ម៉ូដែលបែបវិភាគ និងមានពេលរិះគិតអំពីអ្វីមួយដោយប្រុងប្រយ័ត្ន | |
| ពិន្ទុផ្អែកវិធីសាស្ត្របន្សុំគំនិត តើមាន ចាស/បាទ ប៉ុន្មាន? | |

| វិធីសាស្ត្របង្រួម ឬបញ្ចូលគំនិត (Converging) | ចាស/បាទ |
|---|---|
| ខ្ញុំចូលចិត្តដោះស្រាយបញ្ហាជាក់ស្ដែង | |

| | |
|---|---|
| ខ្ញុំចូលចិត្តភារកិច្ចបែបបច្ចេកទេស ជាងបញ្ហាសង្គម និងបញ្ហាផ្ទាល់ខ្លួន | |
| ខ្ញុំចូលចិត្តកម្មវិធីជាក់ស្តែង និងការបំលែងកម្មវិធី | |
| ខ្ញុំចូលចិត្តស្វែងរកការអនុវត្តជាក់ស្តែងសម្រាប់គំនិត សំណួរ និងទ្រឹស្តី | |
| ខ្ញុំមិនសូវចាប់អារម្មណ៍នឹងទ្រឹស្តីតែមួយមុខនោះទេ | |
| ពិន្ទុផ្នែកវិធីសាស្រ្តបង្រួមឬបញ្ចូលគំនិត តើមាន ចាស/បាទ ប៉ុន្មាន? | |

| វិធីសាស្រ្តបំពេញគំនិត (Accommodating) | ចាស/បាទ |
|---|---|
| ខ្ញុំជឿជាក់លើ អព្ភន្តរញាណ ជាងតក្ក (logic) | |
| ខ្ញុំចូលចិត្តរៀនដោយសាកល្បងអនុវត្ត និងអនុវត្តផ្ទាល់ | |
| ខ្ញុំចូលចិត្តកិច្ចការដែលអនុវត្ត និងពិសោធន៍ជាក់ស្តែងដែលលទ្ធផលបានមកពីព័ត៌មាន និងការវិភាគរបស់អ្នកផ្សេង | |
| ខ្ញុំចូលចិត្តការសាកល្បង និងបទពិសោធដែលថ្មី ហើយខ្ញុំចូលចិត្តបន្តអនុវត្តផែនការ | |
| ខ្ញុំមិនសូវចាប់អារម្មណ៍នឹងការវិភាគ និងទ្រឹស្តីទេ | |
| ពិន្ទុផ្នែកវិធីសាស្រ្តបំពេញគំនិត តើមាន ចាស/បាទ ប៉ុន្មាន? | |

- Diverging student ចូលចិត្តផ្តោតលើអារម្មណ៍ និងការមើល
- Assimilating student ចូលចិត្តការគិត និងការមើល
- Converging student ចូលចិត្តការគិត និងការអនុវត្ត
- Accommodating student ចូលចិត្តផ្តោតលើអារម្មណ៍ និងការអនុវត្ត

តើផ្នែកណាដែលអ្នកទទួលបាន ចាស/បាទ ច្រើនជាងគេ?

______________________________

## សកម្មភាពសិស្សទី២

ឱ្យសិស្សសរសេរឈ្មោះរបស់គេនៅលើក្តារខៀន។



## សកម្មភាពសិស្សទី៣៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT)

អ្នកអាចរួមបញ្ចូលប្រធានបទនេះដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ រួចឱ្យសិស្សស្វែងរកព័ត៌មានអំពីប្រធានបទនេះ ឬក៏ធ្វើតេស្តតាមអ៊ីនធឺណេត នៅក្នុងមេរៀនស្ដីពីវិធីសាស្ត្ររៀន។ ប្រសិនជាអ្នកអាចសហការជាមួយគ្រូខាងព័ត៌មានវិទ្យានិងទូរគមនាគមន៍ សិស្សអាចធ្វើលំហាត់នេះនៅថ្នាក់កុំព្យូទ័រ ឬពួកគេអាចធ្វើជាលំហាត់នៅផ្ទះដោយប្រើទូរសព្ទឆ្លាតវៃប្រសិនបើមាន។ ពួកគេក៏អាចធ្វើលំហាត់នេះជាគូ ឬជាក្រុមក៏បានប្រសិនបើនរណាម្នាក់មិនអាចភ្ជាប់អ៊ីនធឺណេតបាន។

សិស្សអាចប្រើទម្រង់ឯកសារខាងលើតាមតំណភ្ជាប់ទៅគេហទំព័រខាងក្រោម ឬធ្វើការស្រាវជ្រាវតាមទំព័របើកចំហរ។

https://www.oercommons.org/authoring/18965-kolb-s-learning-styles/view

## សម្រាប់អ្នកប្រឹក្សាយោបល់

ខាងក្រោមនេះ គឺជាសារតានៃទ្រឹស្ដីក្នុងការរៀនរបស់ Kolb ។ ដូចនេះ អ្នកអាចពន្យល់ទៅកាន់សិស្សនូវសារតានៃតេស្តនេះ។ ពន្យល់អំពីវដ្តនៃការរៀនសូត្រដោយសង្ខេប ប្រើប្រាស់រូបភាពខាងក្រោម ឬគូរឡើងវិញនៅលើក្ដារខៀន។ បញ្ចប់មេរៀននេះ ដោយបញ្ជាក់បន្ថែមថា គ្រប់របៀបរៀនសុទ្ធតែល្អដូចៗគ្នា វាគ្រាន់តែប្រាប់យើងថាតើពួកយើងមានរបៀបរៀនសូត្រខុសពីគ្នាបែបណាខ្លះ។ អ្នកចូលរួមអាចយកចំណេះដឹងអំពីរបៀបរៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេទៅប្រើនៅក្នុងការសិក្សាដើម្បីងាយស្រួលទទួលបានលទ្ធផលល្អ។







អ្នកជំនាញទ្រឹស្ដីការអប់រំតាមបែបកសាង បានអភិវឌ្ឍទ្រឹស្ដីនៃការរៀនសូត្របន្ថែមទៀត។ ពួកគេបានដាក់បញ្ចូលអភិញ្ញាណចូលជាដំណើរការមួយនៃការកសាង ដែលជាការកំណត់យកដោយបុគ្គល។ មូលដ្ឋានគ្រឹះនៃគំនិតនេះ គឺថាអ្នករៀនបង្កើតនិយមន័យដោយខ្លួនឯង តាមរយៈបទពិសោធន៍ខ្លួនផ្ទាល់។

ចំណុចនេះមានន័យថា គ្រូមិនបានប្រាប់ និងឱ្យព័ត៌មានទាំងអស់ដល់សិស្សនោះទេ ប៉ុន្តែទុកឱ្យសិស្សស្វែងរកដោយខ្លួនឯង។ សិស្សត្រូវបានលើកទឹកចិត្ត ក្នុងការរៀនពីគោលគំនិតគន្លឹះដោយខ្លួនឯងតាមរយៈការរៀនស្វែងរក។ ចំណុចចាប់ផ្ដើមគឺ ចេញពីអ្វីដែលសិស្សបានដឹងរួចហើយ។

សិស្សអាចរៀនបានយ៉ាងល្អនៅពេលដែលគេចូលរួមក្នុងការងារគម្រោង ដែលទាក់ទងទៅនឹងបញ្ហា ឬស្ថានភាពជីវិតពិត។ ការរៀនសូត្រ ជាដំណើរការកសាងឡើងវិញ ជាជាងការបញ្ជូនចំណេះដឹង។ អ្នកត្រូវប្រើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។ ការរៀនសូត្រ អាចកើតឡើងដោយមានប្រសិទ្ធភាពបំផុតនៅពេលដែលមនុស្សសកម្មក្នុងការបង្កើតកម្មវត្ថុជាក់ស្តែង នៅក្នុងពិភពពិតប្រាកដ។

តួនាទីរបស់គ្រូ គឺជួយលើកទឹកចិត្តអ្នករៀនក្នុងការស្វែងរកគោលការណ៍សម្រាប់ខ្លួនឯង និងដើម្បីកសាងចំណេះដោយធ្វើការឆ្លើយសំណួរបើកទូលាយ និងដោះស្រាយបញ្ហានៃពិភពពិតប្រាកដ។ គ្រូគួរតែជំរុញឱ្យមានការចង់ដឹង ចង់ឮ និងការពិភាក្សា។ ពួកគេអាចផ្តល់ទិន្នន័យដើម និងសម្ភារៈរូបវន្តឱ្យដល់សិស្សយកទៅអនុវត្ត និងវិភាគ។ ជាទូទៅ មនុស្សអាចរៀនបានយ៉ាងល្អនៅក្នុងអន្តរកម្មសកម្ម ការងារជាក្រុម ការងារហាត់ការ។ល។ ឧទាហរណ៍រួមមាន ការរៀនអំពីកន្សោមពាក្យដោយលេងគ្រលាស់ពាក្យ ឬរៀនអំពីសមត្ថភាព តាមរយៈការធ្វើពិសោធន៍ជាមួយនឹងវត្ថុដែលមានទំហំខុសៗគ្នា។ យុទ្ធសាស្ត្រក្នុងការបង្រៀន ក៏បានដាក់បញ្ចូលការបង្ហាញមតិរបស់អ្នកដទៃ ជំរុញឱ្យមានកិច្ចសន្ទនា និងសង្កត់ធ្ងន់លើការយល់ដឹងពីទស្សនាទាន។ គ្រូប្រើប្រាស់ការណែនាំច្រើនជាងការបង្រៀន ឬការណែនាំជាដំណាក់កាល។

អ្នកទ្រឹស្តីនិយមសំខាន់នៅក្នុងវិស័យនេះ គឺ David A. Kolb និង John Dewey ដែលបានបង្កើតទ្រឹស្តីពិសោធន៍លើការរៀនសូត្រ។ ទ្រឹស្តីការអប់រំតាមបែបកសាង មានប្រជាប្រិយភាពនៅក្នុងវិស័យអប់រំតាំងពីឆ្នាំ ១៩៨០ រហូតមកដល់បច្ចុប្បន្ន ហើយវានៅតែមានកម្មវិធីថ្មីៗគ្រប់សម័យកាល ឧ. ការរៀនសូត្រផ្អែកលើដំណោះស្រាយបញ្ហា (Problem-based learning-PBL) និងទ្រឹស្តីរៀនសូត្រដោយការស្រាវជ្រាវស្វែងរក។




*ប្រភពរូបភាពនៃការរៀនសូត្រដោយការស្រាវជ្រាវស្វែងរក៖ Hakkarainen, Lonka, Lipponen & Raami, 1999* http://mlab.taik.fi/polut/Yhteisollinen/teoria_tutkiva_oppiminen.html

## មេរៀនទី១៧ ការជំរុញទឹកចិត្ត ឥរិយាបថ សមត្ថភាព ១

វត្ថុបំណងនៃមេរៀននេះ និងមេរៀនខាងមុខបន្ទាប់ទៀតគឺ៖

- ជួយឱ្យសិស្សយល់ពីអត្ថន័យនៃការជំរុញទឹកចិត្តក្នុងការសិក្សា
- ជួយគាំទ្រសិស្សក្នុងការរក្សាការជំរុញទឹកចិត្ត

ការជំរុញទឹកចិត្តក្នុងការរៀនសូត្រមានន័យថា ការផ្តល់ក្តីសង្ឃឹម ប្រើប្រាស់ឱកាស និងបោះបង់ភាពគ្មានប្រយោជន៍ចោល។ ការជំរុញទឹកចិត្ត មានន័យថាការប៉ងប្រាថ្នា ការទទួលស្គាល់ភាពដែលអាចធ្វើបាន អនុវត្តដោយសកម្ម និងទទួលយកការឆ្លើយតប និងយោបល់ត្រលប់។

ការជំរុញទឹកចិត្តរួមមាន ការកំណត់គោលដៅដ៏សមហេតុផល អាកប្បកិរិយាវិជ្ជមាន និងជឿជាក់លើសមត្ថភាពក្នុងការរៀនសូត្រ។ អ្នកអាចគូររូបភាពខាងក្រោមនេះនៅលើក្តារខៀន បន្ទាប់មកចែកសន្លឹកកិច្ចការឱ្យសិស្សធ្វើជាលក្ខណៈបុគ្គល ឬសរសេរសំណួរនៅលើក្តារខៀន។




### សកម្មភាពសិស្សទី១

ឱ្យសិស្សបំពេញអ្វីដែលពួកគេគិតឃើញនៅក្នុងសន្លឹកកិច្ចការរៀងខ្លួនៗ។

### សន្លឹកកិច្ចការ៖ ការជំរុញទឹកចិត្ត

### គោលដៅ

ហេតុអ្វីបានជាអ្នកសិក្សា? តើអ្នកចង់រៀនអ្វីខ្លះ? តើអ្នកចង់សម្រេចបានអ្វីខ្លះ? តើអ្នកមានការប៉ងប្រាថ្នាអ្វីខ្លះ?

**គោលដៅរបស់អ្នក៖**

| |
|---|
| |

តើគោលដៅមានសារៈសំខាន់បែបណាសម្រាប់អ្នក? ប៉ាន់ស្មានពី ១-១០។

គោលដៅមានសារៈសំខាន់តិចតួចសម្រាប់ខ្ញុំ ⟷ មានសារៈសំខាន់ច្រើនសម្រាប់ខ្ញុំ

គោលដៅរបស់ខ្ញុំខ្ពស់ពេក ⟷ អាចសម្រេចបាន

តើអ្នកត្រូវការជំនួយអ្វីខ្លះ? តើអ្នកណាអាចជួយអ្នកបាន?

---

## ឥរិយាបថ

តើការសិក្សាមានសារៈសំខាន់បែបណាសម្រាប់អ្នក? ប៉ាន់ស្មានពី ១-១០។

ការសិក្សារបស់ខ្ញុំមិនចាំបាច់ ⟷ ចាំបាច់

ការសិក្សារបស់ខ្ញុំគ្មានតម្លៃ ⟷ មានតម្លៃខ្ពស់

សាច់ញាតិរបស់ខ្ញុំមិនយល់ថាហេតុអ្វីខ្ញុំចាំបាច់សិក្សា ⟷ សាច់ញាតិរបស់ខ្ញុំមានមោទនភាពចំពោះការសិក្សារបស់ខ្ញុំ

ការសិក្សាខ្ញុំគឺជាការទទួលខុសត្រូវរបស់គ្រូខ្ញុំ ⟷ ការសិក្សាខ្ញុំគឺជាការទទួលខុសត្រូវរបស់ខ្ញុំ

## សមត្ថភាព

តើអ្នកពូកែរៀនសូត្រទេ? តើអ្នកមានជំនាញនៅក្នុងការសិក្សាទេ? ប៉ាន់ស្មានពី ១-១០។

ខ្ញុំគិតថាការសិក្សាគឺ៖

មិនអាចទៅរួចទេសម្រាប់ខ្ញុំ ⟷ អាចទៅរួចហើយងាយស្រួលសម្រាប់ខ្ញុំ

ខ្ញុំមិនប្រាកដទេថា ខ្ញុំនឹងអាចរៀនចេះ ⟷ ខ្ញុំដឹងថាខ្ញុំរៀនចេះ

## សកម្មភាពសិស្សទី២៖ ក្រុមពិភាក្សា

ដំណាច់ឆមាសជិតមកដល់ ការជំរុញទឹកចិត្តរបស់សិស្សអាចនឹងមានការប្រែប្រួលដោយសារការនឿយហត់នឹងកិច្ចការសាលាពេញមួយឆមាស។ អ្នកអាចបំផុសសិស្សឱ្យពិភាក្សាអំពី មូលហេតុដែលធ្វើឱ្យសិស្សមានការលំបាកក្នុងការរក្សាការជំរុញទឹកចិត្តឱ្យបានល្អក្នុងពេលសិក្សា។ វាជាការល្អក្នុងការប្រាប់សិស្សថា ការប្រែប្រួលនៃការជំរុញទឹកចិត្តជារឿងធម្មតា ហើយពួកគេមិនគួរ ឧ. ពិចារណាឈប់រៀនដោយសារអារម្មណ៍បរាជ័យ ឬខ្វះការជំរុញទឹកចិត្តនោះទេ។ សួរពួកគេអំពីសកម្មភាពល្អៗដែលពួកគេដឹង ឬយោបល់ល្អៗដែលពួកគេចង់លើកឡើងក្នុងការរក្សាការជំរុញទឹកចិត្ត។ អ្នកត្រូវសរសេរចំណុចដែលសិស្សលើកឡើងនៅលើក្តារខៀន រួចប្រាប់ឱ្យសិស្សទាំងអស់គ្នាសរសេរចូលក្នុងសៀវភៅរបស់ពួកគេ ដើម្បីអាចមើលដំបូន្មានទាំងនោះ នៅពេលដែលគេមានអារម្មណ៍ថា ត្រូវការជំនួយសម្រាប់ការជំរុញទឹកចិត្តរបស់ពួកគេ។

### សកម្មភាពសិស្សទី៣៖ លំហាត់នៅផ្ទះ

ឱ្យសិស្សពិភាក្សាអំពីខ្លឹមសារនៃសន្លឹកកិច្ចការខាងលើនៅផ្ទះ។ វាជាការសំខាន់ណាស់សម្រាប់សិស្សដែលមានអារម្មណ៍ថា ពួកគេត្រូវបានជួយគាំទ្រ។

### សម្រាប់អ្នកប្រឹក្សាអាជីព៖

ប្រសិនបើសិស្សមករកអ្នកដើម្បីសុំការណែនាំជាលក្ខណៈបុគ្គល អ្នកអាចស្នើឱ្យពួកគេបង្ហាញសន្លឹកកិច្ចការដែលធ្វើពាក់ព័ន្ធអំពីការលើកទឹកចិត្ត ដើម្បីចាប់ផ្តើមការពិភាក្សាអំពីប្រធានបទទាំងនេះ។ ជាច្រើនករណី បញ្ហាដែលសិស្សប្រឈមគឺកើតឡើងដោយសារកត្តា៖ ពួកគេបានភ្លេចអំពីគោលដៅ ឥរិយាបថរបស់ពួកគេក្នុងការសិក្សា ឬពួកគេមិនជឿជាក់លើសមត្ថភាពខ្លួនឯង។ ចំណុចទាំងអស់នេះហើយដែលអាចបង្កឱ្យមានការបាត់បង់ការជំរុញទឹកចិត្ត។ ភារកិច្ចរបស់អ្នកដែលជាអ្នកប្រឹក្សាអាជីព គឺត្រូវគាំទ្រសិស្សឱ្យមានក្តីសង្ឃឹម និងឱ្យកម្លាំងចិត្តដល់សិស្ស បង្ហាញពីចំណាប់អារម្មណ៍ និងការជឿជាក់លើសមត្ថភាពរបស់គេក្នុងការបន្តដំណើរទៅមុខទៀតប្រកបដោយភាពជោគជ័យ។



# មេរៀនទី ១៨ ការជំរុញទឹកចិត្ត ឥរិយាបថ សមត្ថភាព ២

## សកម្មភាពសិស្សទី១

ចែកសន្លឹកកិច្ចការឱ្យសិស្ស (តេស្តស្តីពី ការជំរុញទឹកចិត្ត) រួចឱ្យសិស្សធ្វើជាលក្ខណៈបុគ្គល។

## សន្លឹកកិច្ចការៈ តេស្តស្តីពី ការជំរុញទឹកចិត្តរបស់សិស្ស

ឆ្លើយសំណួរឱ្យលឿន និងដោយស្មោះត្រង់តាមដែលអាចធ្វើបាន។ ជ្រើសរើសជម្រើសដែលពិពណ៌នាពីអ្នក។

| | ពិត | ពិតមួយចំនួន | មិនពិត |
|---|---|---|---|
| ១. ជាទូទៅខ្ញុំតែងតែដឹងអំពីភារកិច្ច និងលំហាត់នៅផ្ទះ | | | |
| ២. ខ្ញុំអាចបន្តរៀនរហូតដល់ចប់ ទោះបីជាឯកសារមេរៀនគួរឱ្យធុញទ្រាន់យ៉ាងណាក៏ដោយ | | | |
| ៣. ខ្ញុំមិនមើលមេរៀនទុកមុនទេ ប្រសិនបើមិនចាំបាច់ | | | |
| ៤. ខ្ញុំប្រឹងប្រែងធ្វើកិច្ចការសាលា ដើម្បីបានចំណាត់ថ្នាក់ល្អ ទោះបីជាខ្ញុំមិនចូលចិត្តមុខវិជ្ជានោះក៏ដោយ | | | |
| ៥. ខ្ញុំយកលេសផ្ទាល់ខ្លួនថា ហេតុអ្វីខ្ញុំមិនបានធ្វើកិច្ចការសាលា | | | |
| ៦. ខ្ញុំដាក់គោលដៅច្បាស់លាស់ និងខ្ពស់ក្នុងការសិក្សា | | | |
| ៧. មានកិច្ចការមួយចំនួន ខ្ញុំរៀនតែចំណុចណាដែលស្រួលទេ | | | |
| ៨. ខ្ញុំអានលំហាត់នៅផ្ទះ និងធ្វើលំហាត់ជាច្រើនមេរៀន | | | |
| ៩. ខ្ញុំមិនចាប់អារម្មណ៍នឹងមេរៀនដែលគេបង្រៀននោះទេ | | | |
| ១០. អ្វីដែលខ្ញុំរៀន សុទ្ធតែគួរឱ្យចាប់អារម្មណ៍សម្រាប់ខ្ញុំ មិនមែនដោយសារតែត្រូវប្រលង ឬវាយតម្លៃនោះទេ | | | |

ពេលនេះបង្ហាញពួកគេ ឬសរសេរនៅលើក្ដារខៀន ថាតើពួកគេបានពិន្ទុប៉ុន្មាន អាស្រ័យទៅតាមការគូសរបស់គេ (សូមមើលតារាងខាងក្រោម)។

| | ពិត | ពិតមួយចំនួន | មិនពិត |
|---|---|---|---|
| ១. ជាទូទៅខ្ញុំតែងតែដឹងអំពីភារកិច្ច និងលំហាត់នៅផ្ទះ | ២ | ១ | ០ |
| ២. ខ្ញុំអាចបន្តរៀនរហូតដល់ចប់ ទោះបីជាឯកសារមេរៀនគួរឱ្យធុញទ្រាន់យ៉ាងណាក៏ដោយ | ២ | ១ | ០ |
| ៣. ខ្ញុំមិនមើលមេរៀនទុកមុនទេ ប្រសិនបើមិនចាំបាច់ | ០ | ១ | ២ |
| ៤. ខ្ញុំប្រឹងប្រែងធ្វើកិច្ចការសាលា ដើម្បីបានចំណាត់ថ្នាក់ល្អ ទោះបីជាខ្ញុំមិនចូលចិត្តមុខវិជ្ជានោះក៏ដោយ | ២ | ១ | ០ |

| | | | |
|---|---|---|---|
| ៥. ខ្ញុំយកលេសផ្ទាល់ខ្លួនថា ហេតុអ្វីខ្ញុំមិនបានធ្វើកិច្ចការសាលា | ០ | ១ | ២ |
| ៦. ខ្ញុំដាក់គោលដៅច្បាស់លាស់ និងខ្ពស់ក្នុងការសិក្សា | ១ | ១ | ០ |
| ៧. មានកិច្ចការមួយចំនួន ខ្ញុំរៀនតែចំណុចណាដែលស្រួលទេ | ០ | ១ | ២ |
| ៨. ខ្ញុំអានលំហាត់នៅផ្ទះ និងធ្វើលំហាត់ជាច្រើនមេរៀន | ២ | ១ | ០ |
| ៩. ខ្ញុំមិនចាប់អារម្មណ៍នឹងមេរៀនដែលគេបង្រៀននោះទេ | ០ | ១ | ២ |
| ១០. អ្វីដែលខ្ញុំរៀន សុទ្ធតែគួរឱ្យចាប់អារម្មណ៍សម្រាប់ខ្ញុំ មិនមែនដោយសារតែត្រូវប្រលង ឬវាយតម្លៃនោះទេ | ២ | ១ | ០ |

ឱ្យសិស្សគណនាពិន្ទុផ្ទាល់ខ្លួនរបស់ពួកគេ។

ការពន្យល់បកស្រាយលើលទ្ធផលតេស្តៈ

២០-១៦ ពិន្ទុ= មានការតាំងចិត្តខ្ពស់

១០-១៥ ពិន្ទុ = មានការតាំងចិត្តល្អ

តិចជាង ១០ពិន្ទុ = ការតាំងចិត្តត្រូវការជំនួយ

*ប្រភពដើមរបស់គំរូនេះបានមកពីៈKauppila, Reijo A. 2004. Opi ja opeta tehokkaasti. P-kustannus. WS Bookwell Oy. Juva.*

## សកម្មភាពសិស្សទី២ៈ ការពិភាក្សាជាគូ

ឱ្យសិស្សពិភាក្សាជាមួយដៃគូនូវប្រធានបទខាងក្រោមៈ

- គិតអំពីអ្វីដែលអ្នកអាចធ្វើបាន ដើម្បីជំរុញការលើកទឹកចិត្តរបស់អ្នក
- តើគ្រូ ឬមិត្តរួមថ្នាក់អ្នក អាចធ្វើអ្វីបាន ដើម្បីឱ្យការលើកទឹកចិត្តរបស់អ្នកកាន់តែប្រសើរ?
- សួរដៃគូរបស់អ្នកអំពីរបៀបជំរុញទឹកចិត្តរបស់ពួកគេ
- ពិភាក្សាជាមួយដៃគូរបស់អ្នក ថាតើសមាជិកក្រុម អាចជួយគាំទ្រឱ្យមានការលើកទឹកចិត្តដោយរបៀបណា។

## សកម្មភាពសិស្ស ៣ៈ ការពិភាក្សាជាក្រុម

ឱ្យសិស្សចែករំលែកអំពី ការពិភាក្សាដែលពួកគេមានជាមួយគ្រួសារនៅឯផ្ទះ ទៅនឹងលំហាត់កាលពីវគ្គមុន។

# មេរៀនទី ១៩ ជំនាញធ្វើឱ្យការចងចាំប្រសើរឡើង

ចាប់ពីមេរៀននេះ និងមេរៀនបន្ទាប់ចំនួន ៨ ទៀត គឺនឹងធ្វើការសិក្សាពីយុទ្ធសាស្ត្រក្នុងការរៀនសូត្រ។ វត្ថុបំណងរបស់មេរៀនទាំង ៩ នេះគឺ ជួយឱ្យវិធីសាស្ត្ររៀនសូត្ររបស់សិស្សកាន់តែមានលក្ខណៈល្អប្រសើរ មានប្រសិទ្ធភាពជាងមុន មានសមត្ថភាពខ្ពស់ក្នុងការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និងសម្រាប់ជាទុនបន្តការសិក្សាទៅថ្ងៃក្រោយទៀត។ វត្ថុបំណងនៃមេរៀនទាំងនេះគឺៈ

- វិធីសាស្ត្រធ្វើឱ្យការចងចាំប្រសើរឡើង

អ្នកនឹងត្រូវការនាឡិកាសម្រាប់កំណត់ម៉ោង និងការងារត្រៀមទុកជាមុនមួយចំនួន។ សរសេរអក្សរចំនួន ១០ ពាក្យទៅលើក្រដាសផ្សេងៗគ្នា។ សូមមើលផ្នែកសម្រាប់អ្នកប្រឹក្សាអាជីពនៅទំព័រក្រោយ។

## សកម្មភាពសិស្សទី១

ឱ្យសិស្សត្រៀមក្រដាស ៤ សន្លឹក ឬប្រើសៀវភៅកិច្ចការរបស់ខ្លួន។ បង្ហាញសិស្សនូវពាក្យទាំង ១០ ម្តងមួយៗ (ប្រហែល៣នាទីក្នុងមួយពាក្យ)។ បន្ទាប់មក ឱ្យពេលពួកគេ ១ នាទី ៣០ វិនាទីដើម្បីសរសេរពាក្យទាំងនោះតាមលទ្ធភាពដែលអាចចងចាំបាន រួចហើយឱ្យគេផ្កាប់ក្រដាស ឬសៀវភៅចុះ។

បង្ហាញពាក្យដដែលនោះតាមលំដាប់ខុសពីមុន (ប្រហែល២-៣នាទីក្នុងមួយពាក្យ)។ ពួកគេមានពេល ១ នាទី ៣០ វិនាទី ក្នុងការសរសេរពាក្យ។ ពួកគេត្រូវប្រើក្រដាសផ្សេង ហើយមិនត្រូវមើលតាមក្រដាសដែលសរសេរលើកទី១នោះទេ (ធ្វើបែបនេះ ៣ ដងទៀត)។

ពេលនេះអាចធ្វើការប្រៀបធៀបជាគូ ថាតើគេអាចចាំបានប៉ុន្មានពាក្យ។ (៨ ក្នុងចំណោម ១០ គឺជាលទ្ធផលល្អ)។

អ្នកអាចបង្ហាញវិធីសាស្ត្រសម្រាប់ការចងចាំ តាមរយៈការបង្រៀនខ្លី (សូមមើល សម្រាប់អ្នកប្រឹក្សាអាជីព)។

## សកម្មភាពសិស្សទី២

១. សរសេរសាច់រឿងខ្លី ដោយប្រើប្រាស់ពាក្យដែលអ្នកត្រូវចាំៈ

| |
|---|
| |

### សកម្មភាពសិស្សទី៣

២. គូររូបភាពនៃពាក្យ ដែលអ្នកត្រូវចាំ៖

| |
|---|
| |

### សកម្មភាពសិស្សទី៤

៣. ចាត់ចំណាត់ថ្នាក់នៃពាក្យ ដែលអ្នកត្រូវចាំ៖

| | | | |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

### សម្រាប់អ្នកប្រឹក្សាអាជីព៖

សរសេរពាក្យទាំងនេះទៅក្នុងក្រដាសផ្សេងៗគ្នា និងប្រើប្រាស់នៅក្នុងសកម្មភាពសិស្ស ១។

| | | | | |
|---|---|---|---|---|
| រាំងនន | ស្លាប | កញ្ចក់ | ខ្យល់ | កាបូបស្ពាយ |
| រ៉ូប | ភ្លើង | ជញ្ជាំង | សន្លឹកបៀរ | នំខេក |

**សម្រាប់មេរៀនខ្លី អ្នកអាចប្រើប្រាស់ព័ត៌មាននេះ៖**

អ្នកតែងតែត្រូវការការចងចាំក្នុងការសិក្សា។ អ្វីដែលអាចជួយដល់ការចងចាំរបស់អ្នកគឺ៖

- ការយកចិត្តទុកដាក់
- ការចង់ដឹងចង់ឮ
- ការសម្រាកលំហែ
- បរិយាកាសវិជ្ជមាន
- មានពេលគ្រប់គ្រាន់សម្រាប់រៀន
- ភ្ជាប់ចំណេះដឹងថ្មីៗទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយ
- ប្រើប្រាស់វិធីសាស្រ្តសកម្មនៅក្នុងការទន្ទេញ

អ្វីដែលធ្វើឱ្យការចងចាំរបស់អ្នកចុះខ្សោយ៖

- ការប្រញាប់ប្រញាល់
- ភាពភ័យខ្លាច
- ការខ្វល់ខ្វាយ
- ការនឿយហត់ អស់កម្លាំង

- ប្រសិនបើអ្នកមិនបានផ្តោតអារម្មណ៍
- ប្រសិនបើអ្នកព្យាយាមចងចាំដោយមិនបានរៀបចំត្រឹមត្រូវ ព័ត៌មានលម្អិតពេក

**តិចនិចទន្ទេញឱ្យឆាប់ចាំ៖**

### ១. វិធីសាស្ត្រជាសាច់រឿង

សិស្សអាចបង្កើតជាសាច់រឿងដែលទាក់ទងនឹងពាក្យ។ វាមានភាពងាយស្រួលក្នុងការចងចាំសាច់រឿងជាងពាក្យមួយៗ។ ឧ. ពាក្យទាំង ១០ នេះអាចបង្កើតជាសាច់រឿងដូចនេះ៖ នាងក្រលេកមើលរូបរបស់នាងតាមរយៈកញ្ចក់ដែលព្យួរនៅលើជញ្ជាំង។ ស្លាបខ្យល់បក់ហោះហើររាំងនន ហើយពន្លត់ភ្លើងដែលឆេះ។ នាងដាក់សន្លឹកបៀរទៅក្នុងកាបូបស្ពាយរបស់នាង ហើយចាប់ផ្តើមញ៉ាំនំខេក។

### ២. បែបបង្កើតរូបភាព

1. ការបង្កើតរូបភាព មានន័យថាអ្នកព្យាយាមភ្ជាប់ពាក្យទៅនឹងរូបភាពនៅក្នុងចិត្តអ្នក។ រូបភាពគួរតែច្បាស់លាស់ ហើយសាមញ្ញ។














### ៣. បែបភ្ជាប់ពាក្យចូលគ្នា

ការភ្ជាប់មានន័យថា អ្នកភ្ជាប់ពាក្យពីរបញ្ចូលគ្នា ជាមួយនឹងរូបភាព៖

កញ្ចក់+ ជញ្ជាំង



ខ្យល់+ស្លាប



## ៤. ការរៀបចំព័ត៌មាន

| ដោយសមាសធាតុ | សម្លៀកបំពាក់ | ចំណីអាហារ | វត្ថុ | ផ្នែកខាងក្នុង |
|---|---|---|---|---|
| ភ្លើង | រ៉ូប | នំខេក | សន្លឹកបៀរ | ជញ្ជាំង |
| ខ្យល់ | | | វាំងនន | កញ្ចក់ |
| | | | កាបូបស្ពាយ | |
| | | | ស្លាប | |

## ៥. ការនិយាយត្រាប់ឡើងវិញ

វាំងនន ស្លាប កញ្ចក់ ខ្យល់ កាបូបស្ពាយ រ៉ូប ភ្លើង ជញ្ជាំង សន្លឹកបៀរ នំខេក វាំងនន ស្លាប កញ្ចក់ ខ្យល់ កាបូបស្ពាយ រ៉ូប ភ្លើង ជញ្ជាំង សន្លឹកបៀរ នំខេក វាំងនន ស្លាប កញ្ចក់ ខ្យល់ កាបូបស្ពាយ រ៉ូប ភ្លើង ជញ្ជាំង សន្លឹកបៀរ នំខេក វាំងនន ស្លាប កញ្ចក់ ខ្យល់ កាបូបស្ពាយ រ៉ូប ភ្លើង ជញ្ជាំង សន្លឹកបៀរ នំខេក វាំងនន ស្លាប កញ្ចក់ ខ្យល់ កាបូបស្ពាយ រ៉ូប ភ្លើង ជញ្ជាំង សន្លឹកបៀរ នំខេក... (នេះគឺជាវិធីសាស្ត្រដែលគ្មានប្រសិទ្ធភាពងាយឱ្យឆាប់ចងចាំទេ។)



# មេរៀនទី ២០  ការអាន

វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យទម្លាប់ក្នុងការអានរបស់សិស្សមានភាពប្រសើរឡើង

អ្នកត្រូវយកអត្ថបទមួយទំព័រសម្រាប់ឱ្យសិស្សអាន ឬឱ្យពួកគេប្រើសៀវភៅពុម្ពមុខវិជ្ជាផ្សេងៗដែលមាន។ សិស្សគ្រប់គ្នា ត្រូវតែអានអត្ថបទតែមួយដូចគ្នា។

## សកម្មភាពសិស្សទី១

ឱ្យសិស្សអានអត្ថបទដែលអ្នកណែនាំ បន្ទាប់មកធ្វើលំហាត់នៅក្នុងសន្លឹកកិច្ចការ។

## សន្លឹកកិច្ចការៈ សេចក្ដីណែនាំសម្រាប់ការអាន

អានអត្ថបទដែលគ្រូបានផ្ដល់ឱ្យៈ

១. ផ្ដោត និងយកចិត្តទុកដាក់លើការអាន។

២. ដាក់ផែនការ ថាតើអ្នកអានយូរប៉ុណ្ណា រយៈពេលប៉ុន្មានដែលអ្នកមាន។ កុំអានយឺតពេក អានអត្ថបទបន្តពីមួយទៅមួយ។

៣. ដំបូងត្រូវមើលអត្ថបទទាំងមូលសិន (វែងប៉ុណ្ណា មានប៉ុន្មានល្បះ ប្រធានបទអ្វី)។

៤. បន្ទាប់មក គិតថាតើអ្វីដែលអ្នកបានដឹងរួចហើយអំពីប្រធានបទ។

៥. អំឡុងពេលអាន អ្នកត្រូវមានសំណួរដូចជាៈ

ក. នរណាធ្វើអ្វី មានរឿងអ្វីកើតឡើង នៅទីណា ពេលណា ហេតុអ្វី របៀបណា?

ខ. តើវាមានន័យយ៉ាងដូចម្ដេច?

គ. មួយណាជាចំណុចគន្លឹះ?

ឃ. តើសាច់រឿងតភ្ជាប់គ្នាយ៉ាងដូចម្ដេច?

ង. សួរខ្លួនឯង ថាតើអ្នកយល់ស្រប ឬមិនយល់ស្របជាមួយអត្ថបទ?

ច. ហេតុអ្វីបានជាប្រធានបទនេះមានសារៈសំខាន់សម្រាប់អ្នក? តើអ្នកអាចប្រើប្រាស់ព័ត៌មាននេះយ៉ាងដូចម្ដេច?

៦. ប្រសិនបើពិបាកផ្ដោតអារម្មណ៍ អ្នកអាចអានឮៗបាន។

៧. បន្ទាប់ពីអានរួច អានអត្ថបទម្ដងទៀតឱ្យលឿន រួចហើយសង្ខេបចូលប្រអប់ខាងក្រោម។

## សកម្មភាពសិស្សទី២

បែងចែកសិស្សជាក្រុមដែលមានគ្នា ៣នាក់ រួចប្រៀបធៀបការសង្ខេបរបស់ពួកគេ។ ឱ្យពួកគេពិភាក្សា៖ មានចំណុចខុសគ្នារវាងការកត់ត្រា និងការសង្ខេបរបស់ពួកគេទេ? តើមានចំណុចណាខ្លះដែលមានការយល់ឃើញខុសគ្នា? អ្វីដែលធ្វើឱ្យការអានលំបាក? អ្វីដែលធ្វើឱ្យការអានងាយស្រួល? ពួកគេក៏អាចចែករំលែកដំបូន្មានល្អៗសម្រាប់ការអានឱ្យមានប្រសិទ្ធភាព បន្ទាប់មកអ្នកអាចសំយោគគំនិតរួមមួយនៅលើក្តារខៀនអំពីរបៀបអានដ៏ល្អ។



## មេរៀនទី ២១ ការធ្វើកំណត់ត្រា

វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យជំនាញក្នុងការកត់ត្រារបស់សិស្សមានភាពប្រសើរឡើង

អ្នកគួរតែរៀបចំជាមុននូវការបង្រៀនរយៈពេល ១០ នាទី អំពីប្រធានបទមួយចំនួនដែលអ្នកអាចប្រើសម្រាប់ឱ្យសិស្សធ្វើលំហាត់ អាចជាប្រធានបទដែលបានបង្រៀនពីពេលមុន ឬអត្ថបទដែលដកស្រង់ពីកាសែត។ល។ (មាតិកាមិនសំខាន់ទេ ដ្បិតយើងចង់ឱ្យសិស្សអនុវត្តការធ្វើកំណត់ត្រា មិនមែនសំដៅលើការសិក្សាខ្លឹមសារប្រធានបទនោះទេ)។

### សកម្មភាពសិស្សទី១ៈ លំហាត់ការធ្វើកំណត់ត្រា

ចែកសន្លឹកកិច្ចការឱ្យសិស្សគ្រប់គ្នា រួចតម្រង់ទិសសិស្សជាមុនក្នុងការធ្វើកំណត់ត្រាដោយប្រើប្រាស់អត្ថបទដកស្រង់ចេញពីទំព័រតែមួយ។ សិស្សត្រូវធ្វើកំណត់ត្រាអំពីលំហាត់ ២ បន្ទាប់ទៀតដោយប្រើគំនិតដែលអ្នកបានពន្យល់ទៅកាន់សិស្ស។ ពេលនេះបង្រៀនរយៈពេល ១០ នាទី ហើយឱ្យសិស្សកត់ត្រានៅពេលដែលអ្នកនិយាយ។

### សន្លឹកកិច្ចការៈ ការធ្វើកំណត់ត្រា

នៅពេលធ្វើកំណត់ត្រា អ្នកត្រូវណែនាំសិស្សឱ្យកត់ត្រានូវព័ត៌មានសំខាន់ និងមិនត្រូវសរសេរគ្រប់ពាក្យដែលអ្នកបានឮ ឬអាននោះទេ។

សរសេរតែចំណុចគន្លឹះៈ

ក. នរណាធ្វើអ្វី មានរឿងអ្វីកើតឡើង នៅទីណា ពេលណា ហេតុអ្វី ដោយរបៀបណា?

ខ. តើវាមានន័យយ៉ាងដូចម្តេច?

គ. តើសាច់រឿងតភ្ជាប់គ្នាយ៉ាងដូចម្តេច?

ឃ. សួរខ្លួនឯង ថាតើអ្នកយល់ស្រប ឬមិនយល់ស្របជាមួយអត្ថបទ?

ង. ហេតុអ្វីបានជាប្រធានបទនេះមានសារៈសំខាន់សម្រាប់អ្នក? តើអ្នកអាចប្រើប្រាស់ព័ត៌មាននេះនៅឯណា និងដោយរបៀបណា?ហេតុអ្វីបានជាខ្ញុំត្រូវការវា?

**រៀបចំការសរសេររបស់អ្នកៈ**

ក. ប្រើប្រាស់ពាក្យគន្លឹះ

ខ. ប្រើលេខ

គ. ប្រើជួរអក្សរ

ឃ. ប្រើគំនូរ និងសញ្ញា

ង. ប្រើតិចនិចផែនទីគំនិត

បន្ទាប់ពីសរសេររួចហើយ អ្នកត្រូវពិនិត្យមើលសំណេររបស់អ្នកម្តងទៀត រួចកែសម្រួលចំណុចដែលមិនសូវច្បាស់ ដើម្បីពេលក្រោយអ្នកអាចនៅតែមើលយល់។ ការសង្ខេបដោយខ្លួនឯងគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការចងចាំ!

### គំនូសផែនទីគំនិត

ការធ្វើផែនទីគំនិត មានន័យថាអ្នករៀបចំកំណត់ត្រារបស់អ្នកក្នុងទម្រង់ជារូបភាព មិនមែនជាជួរអក្សរ។ អ្នកសរសេរប្រធានបទគន្លឹះនៅចំកណ្តាល បន្ទាប់មកមាតិកាសំខាន់ៗនៅក្បែរនោះ ហើយព័ត៌មានលម្អិតនៅចុងក្រោយគេ។



ប្រភព៖http://cdn-media-1.lifehack.org/wp-content/files/2012/09/Mind-Map-Structure.png

ទីនេះអ្នកអាចអនុវត្តផែនទីគំនិតរបស់អ្នក៖



### សកម្មភាពសិស្សទី២

ឱ្យសិស្សចាប់ដៃគូ ហើយឱ្យពួកគេពិភាក្សានូវប្រធានបទខាងក្រោម៖ ប្រៀបធៀបកំណត់ត្រារបស់អ្នក ការសង្ខេប និងផែនទីគំនិតជាមួយដៃគូរបស់អ្នក។ តើអ្នកកត់បានចំណុចដូចគ្នាដែរឬទេ? តើមានចំណុចណាខ្លះដែលខុសគ្នា? តើកត្តាអ្វីខ្លះដែលប៉ះពាល់ដល់ការកត់ត្រា? តើអ្នកយល់

យ៉ាងណាចំពោះតិចនិចផែនទីគំនិត? តើអ្នកជាទូទៅកត់ត្រាដោយរបៀបណា? តើអ្នកអាចកែលម្អកំណត់ត្រារបស់អ្នកបានដោយរបៀបណា? ពួកគេក៏អាចចែករំលែកដំបូន្មានល្អៗសម្រាប់ការកត់ត្រាដ៏មានប្រសិទ្ធភាព រួចអ្នកអាចសំយោគគំនិតរួមសរសេរលើក្ដារខៀនអំពីរបៀបអនុវត្តដ៏ល្អ។

## សម្រាប់អ្នកប្រឹក្សាយោបល់៖

អ្នកមានឧទាហរណ៍ ដោយប្រើប្រាស់ «ការសិក្សា» ជាប្រធានបទ និងមាតិកាបង្រៀន៖



# មេរៀនទី ២២ ការស្ដាប់

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យទម្លាប់ក្នុងការស្ដាប់របស់សិស្សមានភាពប្រសើរឡើង

អ្នកគួរតែរៀបចំជាមុន នូវការនិយាយប្រហែល ១០នាទី ទៅកាន់សិស្សរបស់អ្នក។

## សកម្មភាពសិស្សទី១

អាននូវអ្វីដែលអ្នកបានត្រៀមខាងលើឱ្យសិស្សស្ដាប់។ អំឡុងពេលនេះ សិស្សចាប់ផ្ដើមកត់ត្រានូវអ្វីដែលពួកគេបានឮចូលក្នុងសៀវភៅរបស់គេ។ ក្រោយពេលអ្នកអានចប់ សិស្សអាចពិភាក្សាជាក្រុម ឬជាបុគ្គលម្នាក់ៗ ដើម្បីពិនិត្យមើលកំណត់ត្រារបស់គេ ថាតើប្រាសចាកពីខ្លឹមសារដើមដែលអ្នកបានអានឬទេ។ អ្នកអាចឱ្យសិស្សឡើងសង្ខេបនូវអ្វីដែលអ្នកបាននិយាយទៅកាន់ថ្នាក់រៀនទាំងមូល រួចបំពេញបន្ថែមចំណុចខ្វះខាត។

## សន្លឹកកិច្ចការ៖ ការស្ដាប់

ស្ដាប់ការបង្រៀនរបស់គ្រូអ្នកដោយអនុវត្តតាមការណែនាំខាងក្រោម៖

១. ផ្ដោតនិងយកចិត្តទុកដាក់លើការស្ដាប់

២. សរសេរកម្មវត្ថុ និងប្រធានបទនៃមេរៀន។ បន្ទាប់មកគិតថា តើអ្វីដែលអ្នកបានដឹងរួចហើយអំពីប្រធានបទ។

៣. ការស្ដាប់គឺជាកិច្ចការមួយដែលពិបាក។ គ្រប់ពេលដែលអ្នកគិតដល់រឿងផ្សេង អ្នកត្រូវទាញអារម្មណ៍មកផ្ដោតលើការស្ដាប់វិញ។

៤. កត់ត្រាគ្រប់ពេល ព្រោះវាជួយឱ្យអ្នកផ្ដោតអារម្មណ៍បាន។ អ្នកអាចគូររូប ឬសញ្ញាផ្សេងៗ។

៥. សួរសំណួរ វាក៏ជួយអ្នកផ្ដោតអារម្មណ៍បាន។

៦. កុំសរសេរគ្រប់ពាក្យ វាគ្មានពេលនោះទេ។ សរសេរតែចំណុចគន្លឹះ៖

ក. នរណាធ្វើអ្វី មានរឿងអ្វីកើតឡើង នៅទីណា ពេលណា ហេតុអ្វី របៀបណា?

ខ. តើវាមានន័យយ៉ាងដូចម្ដេច?

គ. តើសាច់រឿងតភ្ជាប់គ្នាយ៉ាងដូចម្ដេច?

ឃ. សួរខ្លួនឯង ថាតើអ្នកយល់ស្រប ឬមិនយល់ស្របជាមួយអត្ថបទ?

ង. ហេតុអ្វីបានជាប្រធានបទនេះមានសារៈសំខាន់សម្រាប់អ្នក? តើអ្នកអាចប្រើប្រាស់ព័ត៌មាននេះយ៉ាងដូចម្ដេច?

៧. អ្វីដែលគ្រូរបស់អ្នកអាចធ្វើបានគឺបង្រៀន អ្នកខ្លួនឯងទេដែលត្រូវធ្វើការជាមួយព័ត៌មានដែលអ្នកទទួលបាន។ បន្ទាប់ពីគ្រូបង្រៀនចប់ អ្នកត្រូវសរសេរសង្ខេបយ៉ាងខ្លី ដោយប្រើប្រាស់កំណត់ត្រារបស់អ្នក។

សរសេរកំណត់ត្រារបស់អ្នកនៅទីនេះ៖

| |
|---|
| |

សរសេរការសង្ខេបរបស់អ្នកនៅទីនេះ (ចំណុចសំខាន់បំផុតនៃខ្លឹមសារ ដែលអ្នកបានយល់)៖

| |
|---|
| |

### សកម្មភាពសិស្សទី២

ឱ្យសិស្សចាប់ដៃគូ ហើយឱ្យពួកគេពិភាក្សានូវប្រធានបទខាងក្រោម៖ ប្រៀបធៀបកំណត់ត្រា ការសង្ខេប និងផែនទីគំនិតជាមួយដៃគូរបស់ពួកគេ។ តើអ្នកកត់បានចំណុចដូចគ្នាដែរឬទេ? តើមានចំណុចណាខ្លះដែលខុសគ្នា? តើកត្តាអ្វីខ្លះដែលប៉ះពាល់ដល់ការស្តាប់? តើអ្វីដែលធ្វើឱ្យការស្តាប់ងាយស្រួល? អ្វីដែលធ្វើឱ្យការស្តាប់លំបាក? តើអ្នកអាចកែលម្អការស្តាប់របស់អ្នកបានដោយរបៀបណា? ពួកគេក៏អាចចែករំលែកដំបូន្មានល្អៗសម្រាប់ការកត់ត្រាដ៏មានប្រសិទ្ធភាព រួចអ្នកអាចធ្វើការសំយោគគំនិតរួមសរសេរលើក្តារខៀនអំពីរបៀបអនុវត្តដ៏ល្អ។



## មេរៀនទី ២៣ ការប្រឡង

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យទម្លាប់ក្នុងការត្រៀមប្រឡងរបស់សិស្សមានភាពប្រសើរឡើង

### សកម្មភាពសិស្សទី១៖ ការរៀនសូត្រតាមវិធីសាស្ត្រតុកាហ្វេ

បែងចែកសិស្សជាក្រុមតូចៗមានគ្នាពី ៤-៥នាក់ រួចចែកផ្ទាំងក្រដាសធំឱ្យក្រុមនីមួយៗ។ ឱ្យពួកគេសរសេរលើផ្ទាំងក្រដាសនូវដំបូន្មានល្អៗដើម្បីត្រៀមសម្រាប់ការប្រឡង។ ឱ្យពួកគេពិភាក្សាពី ៥-១០នាទី។ បន្ទាប់មក ឱ្យក្រុមចល័តទៅតុបន្ទាប់ តែទុកផ្ទាំងក្រដាស និងសមាជិកម្នាក់នៅចាំតុទី១។ ក្រុមនីមួយៗ នឹងត្រូវចល័តទៅកាន់តុបន្ទាប់ លើកលែងតែសមាជិកម្នាក់និងផ្ទាំងក្រដាស។ នៅតុថ្មី ក្រុមនឹងអានអ្វីៗដែលក្រុមមុនបានសរសេរទៅលើផ្ទាំងក្រដាស បន្ទាប់មកពួកគេអាចបន្ថែមចំណុចដែលគេគិតថានៅខ្វះខាត។ ពេលវេលាសម្រាប់សកម្មភាពនេះមានពី ៥-១០ នាទី។ (តួនាទីរបស់សមាជិកដែលនៅចាំតុជាមួយនឹងផ្ទាំងក្រដាស គឺដើម្បីបញ្ជាក់បន្ថែមអំពីនូវអ្វីដែលបានពិភាក្សា ប្រសិនបើមានសំណួរ)។ បន្ទាប់មក ក្រុមចល័តទៅតុបន្ទាប់ម្តងទៀត ដែលក្រុមពីរមុនបានបំពេញបន្ថែម។ (ប្រសិនបើអ្នកមានពេល អ្នកអាចឱ្យក្រុមចល័តម្តងទៀត)។

### សកម្មភាពសិស្សទី២

បន្ទាប់មក សមាជិកដែលនៅចាំជាមួយនឹងផ្ទាំងក្រដាសនឹងត្រូវបង្ហាញផ្ទាំងក្រដាសទៅកាន់ក្រុមទាំងមូល រួចប្រាប់សង្ខេបអំពីចំណុចសំខាន់ៗ។ គ្រប់ក្រដាសទាំងអស់ នឹងត្រូវបង្ហាញ ២-៣ នាទីម្តង។ អ្នកអាចបន្ថែមចំណុចមួយចំនួនពីបញ្ជីខាងក្រោម ប្រសិនបើសិស្សមិនទាន់បានលើកមកនិយាយ។

### សម្រាប់អ្នកប្រឹក្សាយោបល់៖

**មុនពេលប្រឡង៖**

- អានគ្រប់កំណត់ត្រាដែលអ្នកបានកត់ពេលគ្រូបង្រៀន ឬកត់ចេញពីអត្ថបទ។ ប្រសិនបើមានកំណត់ត្រាច្រើន អ្នកអាចសរសេរសង្ខេបឡើងវិញ។ ការសរសេរជួយឱ្យអ្នកចងចាំ។
- ចែកមេរៀនដែលអ្នកត្រូវអាន(សម្រាប់អានច្រើនថ្ងៃ)។ អានបន្តិចម្តងៗជារៀងរាល់ថ្ងៃ កុំអានច្រើន ឬអានទាំងអស់នៅថ្ងៃចុងក្រោយ។
- ប្រសិនបើអ្នកមិនយល់ចំណុចអ្វីមួយ សួរគ្រូទុកឱ្យហើយ។
- គិតថាអ្នកនឹងសួរពីអ្វី ប្រសិនបើអ្នកជាគ្រូ។
- គេង ញ៉ាំ និងសម្រាក៖ វាជួយដល់ការចងចាំរបស់អ្នក។

**ពេលប្រឡង៖**

- មកឱ្យទាន់ពេល ហើយរៀបចំសម្ភារៈរបស់អ្នកឱ្យរួចរាល់
- សម្រាកឱ្យគ្រប់គ្រាន់។ ការសម្រាកជួយឱ្យអ្នកទទួលបានលទ្ធផលល្អ និងជួយដល់ការចងចាំ និងការគិតរបស់អ្នក។
- ផ្តោតអារម្មណ៍។ សម្រេចចិត្តថាអ្នកអាចធ្វើវាបាន។
- ធ្វើតាមការណែនាំ និងអានសំណួរដោយប្រុងប្រយ័ត្ន។

- ប្រសិនបើអ្នកមិនយល់អ្វីមួយ សួរគ្រូ។ ឆ្លើយសំណួរដែលអ្នកចេះមុនគេ។ រំលងសំណួរណាដែលអ្នកមិនចេះ ពីព្រោះបើសិនជាអ្នកឈប់ត្រឹមចម្លើយនោះ ហើយប្រើពេលគិតយូរពេកទៅលើអ្វីដែលអ្នកមិនចេះ នោះអ្នកនឹងគ្មានពេលគ្រប់គ្រាន់សម្រាប់សំណួរដែលនៅសល់នោះទេ។
- បន្ទាប់មក ឆ្លើយសំណួរដែលអ្នកមិនសូវចេះច្បាស់។ ព្យាយាមឆ្លើយ។ សរសេរបន្តិចបន្តួច គ្រាន់បើជាងគ្មានអ្វីទាំងអស់។
- ប្រសិនបើអ្នកអាច សរសេរចម្លើយឱ្យមានរបៀប ហើយស្អាត។
- កុំលួចមើលចម្លើយរបស់សិស្សផ្សេង ពីព្រោះប្រហែលជាគេចេះតិចជាងអ្នក។ អ្នកនឹងអាចមានកំហុសដូចពួកគេដែរ។
- កុំភ្លេចដាក់ឈ្មោះអ្នកលើក្រដាសប្រឡង។ ប្រគល់ឱ្យគ្រូ ឬអនុរក្សឱ្យបានទាន់ពេល។

**ក្រោយពេលប្រឡង៖**

- ពិនិត្យមើលកំណត់ត្រារបស់អ្នកម្តងទៀត អ្វីខ្លះត្រូវ និងអ្វីខ្លះខុស។
- សួរចម្លើយដែលត្រឹមត្រូវពីគ្រូ។
- សម្រាក។



## មេរៀនទី ២៤ ការធ្វើបទបង្ហាញ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យជំនាញក្នុងការរៀបចំ និងការធ្វើបទបង្ហាញរបស់សិស្សមានភាពប្រសើរឡើង

### សកម្មភាពសិស្សទី១

ឱ្យសិស្សបង្ហាញទៅកាន់ក្រុមធំ នូវបទពិសោធន៍របស់ពួកគេអំពីការធ្វើបទបង្ហាញ។ តើពួកគេបានធ្វើបទបង្ហាញអំពីអ្វី (នៅសាលា ឬនៅកន្លែងផ្សេង)? តើគេមានបទពិសោធល្អអ្វីខ្លះ? តើបទពិសោធមិនសូវល្អអ្វីខ្លះដែលគេមាន? តើពួកគេគិតថាអ្វីខ្លះ ជាលក្ខណៈសំគាល់របស់បទបង្ហាញដែលល្អ? តើពួកគេអាចនៅចាំបានអំពីបទបង្ហាញដែលល្អណាមួយទេ? ហេតុអ្វីបានជាបទបង្ហាញនោះជោគជ័យ? ចុះចំណែកបទបង្ហាញដែលមិនល្អដែលគេនៅចាំ អ្វីខ្លះដែលធ្វើឱ្យបទបង្ហាញនោះមិនល្អ? ការពិភាក្សាគួរប្រើពេលប្រហែល១០-១៥នាទី។

គ្រូត្រូវណែនាំសិស្ស ឱ្យត្រៀមសម្រាប់ការធ្វើបទបង្ហាញពីលំហាត់ ឬគម្រោងផ្សេងទៀតទៅកាន់ថ្នាក់រៀនទាំងមូល។ ខាងក្រោមនេះ គឺជាអ្វីដែលពួកគេត្រូវធ្វើ៖

**មុនពេលធ្វើបទបង្ហាញ៖**

- រៀបចំបទបង្ហាញ (ប្រើផែនទីគំនិត ឬវិធីសាស្ត្រផ្សេងទៀត)៖
    - តើអ្នកនឹងនិយាយ ឬបង្ហាញពីអ្វី
    - តើគោលបំណង ឬសារគន្លឹះនៃបទបង្ហាញរបស់អ្នកជាអ្វី
    - រៀបចំមាតិកា ដូចនេះបទបង្ហាញរបស់អ្នកនឹងដំណើរការតាមលំដាប់ត្រឹមត្រូវ
    - សរសេរនៅលើសន្លឹកក្រដាសសម្រាប់ទន្ទេញ ដូចនេះអ្នកនឹងចាំពីអ្វីដែលអ្នកត្រូវនិយាយ ឬធ្វើ
- ប្រសិនបើអ្នកត្រូវបង្ហាញវត្ថុជាក់លាក់ណាមួយ ត្រូវរៀបចំវាឱ្យរួចរាល់
- ប្រសិនបើអ្នកត្រូវសម្ភារៈបច្ចេកទេស ត្រូវធានាថាវាមានដំណើរការល្អ
- គិតពីអ្វីដែលត្រូវមានសំណួរ ប្រសិនបើអ្នកជាគ្រូ ឬអ្នកចូលរួម

**ពេលធ្វើបទបង្ហាញ៖**

- មកឱ្យទាន់ពេល ហើយរៀបចំសម្ភារៈរបស់អ្នកឱ្យរួចរាល់
- សម្រាក។ ការសម្រាកជួយឱ្យអ្នកទទួលបានលទ្ធផលល្អ
- ផ្តោតអារម្មណ៍។ សម្រេចចិត្តថាអ្នកអាចធ្វើវាបាន!
- ធ្វើបទបង្ហាញរបស់អ្នកតាមសម្រួល និងឱ្យច្បាស់ៗ
- សួរមើលថា តើមាននរណាមានសំណួរអំពីបទបង្ហាញរបស់អ្នកដែរឬទេ

**ក្រោយពេលធ្វើបទបង្ហាញ៖**

- សុំយោបល់ត្រលប់ពីគ្រូរបស់អ្នក និងពីអ្នកចូលរួមផ្សេងទៀត ដើម្បីកែលំអរបទបង្ហាញនៅពេលអនាគត។

បន្ទាប់មក បែងចែកសិស្សចែកជា ២ក្រុមធំៗ។

### សកម្មភាពសិស្សទី២

ក្រុមមួយមានប្រធានបទអំពីការរៀបចំបទបង្ហាញ និងក្រុមមួយទៀតមានប្រធានបទអំពីការធ្វើបទបង្ហាញ។ ពេលនេះពួកគេមានពេល ៥នាទីក្នុងមួយក្រុម ដើម្បីរៀបចំការសម្តែង។ ពួកគេអាចជ្រើសយកជាការសម្តែងត្រាប់តាមកាយវិការ ឬសម្តែងនិយាយ ហើយគ្រប់សមាជិកនៅក្នុងក្រុមត្រូវតែចូលរួមសម្តែងម្តងមួយក្រុមៗ។

គោលគំនិតសំខាន់ចំណុចនេះ ដើម្បីឱ្យសិស្សមានការអនុវត្តជាក់ស្តែង បង្កើតបាននូវលក្ខណៈលឿនរហ័ស ហើយរីករាយ និងកាត់បន្ថយភាពភ័យខ្លាចចំពោះការឡើងសម្តែង ដែលពេលខ្លះអាចទាក់ទងនឹងការធ្វើបទបង្ហាញ។

សម្រាប់មេរៀនលើកក្រោយ ឱ្យសិស្សយកមកជាមួយនូវសំណេរ ឬកិច្ចការសរសេរដែលគេបានធ្វើរួចកាលពីមុខវិជ្ជាផ្សេង។ អត្ថបទ មិនត្រូវវែងពេកទេ វែងបំផុត ១ទំព័រ។



## មេរៀនទី ២៥ ការសរសេរ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យទម្លាប់ក្នុងការសរសេររបស់សិស្សមានភាពប្រសើរឡើង

ផ្តល់ព័ត៌មានខាងក្រោម អំពីភារកិច្ចរបស់អ្នកសរសេរ ទៅកាន់សិស្សដូចខាងក្រោម៖

### សន្លឹកកិច្ចការ៖ អនុសាសន៍សម្រាប់ការសរសេរ

**មុននឹងសរសេរ៖**

- ដាក់ផែនការ អំពីពេលវេលាចំនួនប៉ុន្មានដែលអ្នកនឹងប្រើប្រាស់
- ដាក់ផែនការ ពេលណាដែលអ្នកនឹងធ្វើលំហាត់នៅផ្ទះ អំពីការសរសេរ
- គិតពីអ្វីដែលអ្នកបានដឹងអំពីប្រធានបទ
- ដាក់ផែនការ ពីរបៀបដែលអ្នកត្រូវរកព័ត៌មានបន្ថែម មើលការណែនាំដែលគ្រូអ្នកបានឱ្យ (ប្រវែងអត្ថបទដែលអ្នកត្រូវសរសេរ។ល។)

**ពេលសរសេរ៖**

- រៀបចំអត្ថបទរបស់អ្នក (ប្រើផែនទីគំនិត ឬវិធីសាស្ត្រផ្សេងទៀត) រួចរៀបវា៖
    - តើអ្នកចាប់ផ្តើមដោយរបៀបណា?
    - តើមានប៉ុន្មានជំពូកដែលអ្នកត្រូវសរសេរ?
    - តើជំពូកនីមួយៗមានមាតិកាអ្វីខ្លះ?
    - តើចុងក្រោយ អ្នកសង្ខេបដោយរបៀបណា?
- សរសេរនូវអ្វីដែលស្ថិតនៅក្នុងប្រធានបទតែមួយ នៅក្នុងជំពូកតែមួយ
- ផ្តោតលើសរសេរ
- នៅពេលដែលអ្នកសរសេររួចរាល់ហើយ ពិនិត្យមើលថាតើអ្នកបានឆ្លើយនូវគ្រប់សំណួរ ឬធ្វើតាមការណែនាំរបស់គ្រូអ្នកហើយឬនៅ កែអក្ខរាវិរុទ្ធ ឬកំហុសផ្សេងទៀត និងចម្លងអត្ថបទរបស់អ្នក។

**ពេលសរសេររួច៖**

- កុំភ្លេចដាក់ឈ្មោះអ្នកលើក្រដាសកិច្ចការ។ ប្រគល់ជូនគ្រូអ្នកឱ្យបានទាន់ពេល។
- រក្សាទុកមួយច្បាប់។ វានឹងមានប្រយោជន៍ ពេលដែលអ្នកត្រូវការត្រៀមសម្រាប់ប្រឡង។

### សកម្មភាពសិស្សទី១

ឱ្យសិស្សចាប់ដៃគូ ឬចូលជាក្រុម (មានគ្នា ៣ នាក់)។ ឱ្យពួកគេ ត្រួតពិនិត្យមើលអត្ថបទសំណេររបស់ពួកគេជាមួយគ្នា។ (អត្ថបទ អាចជាអត្ថបទអ្វីក៏បាន ឬសំណេរដែលពួកគេបានធ្វើសម្រាប់មុខវិជ្ជាផ្សេង)។ សិស្សម្នាក់ៗនឹងត្រូវបង្ហាញអត្ថបទរបស់ខ្លួនទៅកាន់គ្នាទៅវិញទៅមក។ ភារកិច្ចរបស់ក្រុមគឺពិនិត្យអត្ថបទនីមួយៗ ហើយផ្ទៀតផ្ទាត់ទៅនឹងការណែនាំ ឬសួរសំណួរទៅកាន់អ្នកសរសេរ។ ឧ. តើអ្នករៀបចំអត្ថបទរបស់អ្នកដោយរបៀបណា? តើអ្នកចំណាយពេលអស់ប៉ុន្មាន? តើមានគំនិត ឬយោបល់ខ្លួនឯងដែរឬទេ ឬជាការចម្លង? តើអ្នកចាប់ផ្តើមសរសេរដោយរបៀបណា? តើអ្នករៀបចំជំពូកនីមួយៗដោយរបៀបណា? តើមានការសង្ខេបអ្វី?។ល។ (មិនគួរលើសពី ១០នាទី)

### សកម្មភាពសិស្សទី២

បន្ទាប់ពីការពិភាក្សា ពួកគេត្រូវបន្តក្នុងក្រុមដដែល។ ពួកគេត្រូវធ្វើការកែសម្រួលអត្ថបទរបស់ខ្លួនឡើងវិញ។ ក្នុងករណីទទួលបានសំណើពីសមាជិកក្រុម និងស្របតាមការណែនាំខាងលើ។ ការផ្តល់យោបល់ផ្សេងៗរបស់សមាជិកក្រុម ត្រូវតែជាយោបល់វិជ្ជមាន មិនមែនដើម្បីគ្រាន់តែជាការរិះគន់នោះទេ។ ពួកគេមានពេលតែ ៥-១០ នាទីប៉ុណ្ណោះសម្រាប់អត្ថបទនីមួយៗ។

ឱ្យសិស្សយកសៀវភៅថ្មីមកជាមួយ សម្រាប់មេរៀនលើកក្រោយ ប្រសិនបើមាន។



## មេរៀនទី ២៦ កំណត់ហេតុសិក្សា

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យជំនាញក្នុងការឆ្លុះបញ្ចាំង និងការគិតបែបវិភាគរបស់សិស្សមានភាពប្រសើរឡើង។

ដំបូង អ្នកអាចពន្យល់អំពីអត្ថន័យនៃការរៀន៖ ការរៀនមិនមែនគ្រាន់តែចម្លង ឬទន្ទេញឱ្យចាំមាត់នោះទេ។ ការរៀនមានន័យថា អ្នកអាចបង្កើត និងប្រើប្រាស់ព័ត៌មាន។ នេះមានន័យថា អ្នកត្រូវតែច្នៃព័ត៌មានយ៉ាងសកម្ម មិនគ្រាន់តែរក្សាទុក និងថាតាមនោះទេ។ ការរៀនពិតប្រាកដ គឺជាការយល់ និងចេះបំលែងព័ត៌មាននោះឱ្យកាន់តែមានភាពសំខាន់។ មធ្យោបាយមួយនៃការឆ្លុះបញ្ចាំង និងកែច្នៃព័ត៌មាន គឺកំណត់ហេតុនៃការរៀនសូត្រ។ អ្នកត្រូវមានសៀវភៅកត់ត្រាថ្មីមួយ ដើម្បីរៀនអនុវត្តពីរបៀបធ្វើកំណត់ហេតុនៃការរៀនសូត្រ។

ចែកសន្លឹកកិច្ចការទៅឱ្យសិស្ស ឬធ្វើការណែនាំដោយផ្ទាល់មាត់អំពីមាតិកា (អ្វីទៅជាកំណត់ហេតុសិក្សា ហើយវាមានមាតិកាអ្វីខ្លះ)។

### សន្លឹកកិច្ចការ៖ កំណត់ហេតុសិក្សា

សៀវភៅរបស់អ្នក!

ដូចដែលអ្នកបានឃើញស្រាប់ហើយ ការរៀនសូត្រមានន័យថា អ្នកត្រូវអនុវត្ត និងកែច្នៃព័ត៌មានគ្រប់ពេលវេលា។ ប្រសិនបើអ្នកគ្រាន់តែស្តាប់ដោយអសកម្ម នោះអ្នកមិនបានរៀនច្រើនទេ។ ប្រសិនបើអ្នកកែច្នៃ និងប្រើប្រាស់ព័ត៌មាន ការចងចាំរបស់អ្នកនឹងដំណើរការបានល្អជាងមុន។ កំណត់ហេតុសិក្សា គឺជាឧបករណ៍ដ៏ល្អ សម្រាប់រៀបចំចាត់ចែង និងចងចាំនូវអ្វីដែលថ្មី។ ខាងក្រោមនេះ គឺជាការណែនាំពីកិច្ចការដែលអ្នកត្រូវធ្វើ៖

**មុនថ្ងៃទៅសាលា៖**

១. សរសេរនូវអ្វីដែលអ្នករំពឹងទុកក្នុងពីថ្ងៃនេះ?

២. សរសេរនូវអ្វីដែលអ្នកចង់រៀន?

**ជារៀងរាល់ថ្ងៃ៖**

**នៅពេលព្រឹក៖**

១. សរសេរនូវអ្វីដែលអ្នករំពឹងទុកក្នុងពីថ្ងៃនេះ!

២. សរសេរនូវអ្វីដែលអ្នកចង់សួរគ្រូ?

**នៅពេលល្ងាច៖**

៣. តើអ្នកបានរៀនអ្វីខ្លះនៅថ្ងៃនេះ?

៤. តើអ្វីដែលអ្នកធ្វើមិនបានល្អ?

៥. តើអ្នកចូលចិត្តអ្វីជាងគេបំផុត?

៦. សរសេរបន្តិចម្តងៗ ជារៀងរាល់ថ្ងៃ!



**បន្ទាប់ពីសាលា៖**

១. រៀបរាប់ជំនាញ ៣ ដែលអ្នកបានរៀនច្រើនបំផុត!

២. តើជំនាញណាដែលត្រូវកែលម្អ?

៣. តើខ្ញុំអាចប្រើប្រាស់ចំណេះដឹង និងជំនាញនេះទៅអនាគតដោយរបៀបណា?



អ្វីគ្រប់យ៉ាងដែលអ្នកសរសេរ គឺសម្រាប់ខ្លួនអ្នក។ អ្នកអាច៖

- សរសេរហេតុការណ៍ពិត និងសំណួរ ចម្លល់ និងគំនិតផ្ទុយ
- គូរផែនទីគំនិត
- គូរ និងផាត់ពណ៌នូវអ្វីដែលអ្នកចង់ចាំ
- បិតអត្ថបទកាសែតខ្លី ឬរូបភាព
- រក្សាអ្វីៗដែលសំខាន់នៅក្នុងសៀវភៅរបស់អ្នក សារពីមិត្តភក្តិ កាតប៉ុស្តាល់ ឬរូបថត
- សរសេរពីចំណង់ចំណូលចិត្តខ្លួនឯង ជាមួយមិត្តភក្តិ និងគ្រួសារ...

លើសពីកំណត់ហេតុប្រចាំថ្ងៃ វាជាសៀវភៅឯកសារយោងរបស់អ្នក សៀវភៅបំផុសគំនិត និងជាសៀវភៅកែច្នៃ ព័ត៌មាន។ សរសេរចូលផងដែរ នូវអ្វីដែលអ្នកបានគិតរាល់ថ្ងៃ ឬអ្វីដែលរំខានអ្នក។ ការសរសេរជួយឱ្យអ្នកវិភាគបញ្ហារំខាន និងជួយក្នុងការរៀនសូត្រ និងចងចាំ។

## សកម្មភាពសិស្ស

ចាប់ផ្តើមធ្វើកំណត់ហេតុសិក្សារបស់អ្នក។ សិស្សអាចធ្វើផែនការ និងពិភាក្សាក្នុងក្រុមតូចអំពីរបៀបធ្វើកំណត់ហេតុ មាតិកាមានអ្វីខ្លះ តើវាសម្ងាត់ទេ តើវាអាចចែកចាយជាសាធារណៈបានទេ តើពួកគេនឹងដាក់រូបថតបន្ថែមទេ ធ្វើឱ្យដូចសៀវភៅសិល្បៈ ឬសៀវភៅប្រលោមលោក ឬសៀវភៅពីបុរាណ សរសេរអក្សរច្រើន ឬគូររូប។ល។ អ្នកអាចប្រើពេលសម្រាប់មេរៀនទាំងមូលសម្រាប់រៀបចំផែនការ ហើយពួកគេក៏អាចចាប់ផ្តើមសរសេរផងដែរ។ ការសរសេរដំបូង គួរតែសង្ខេប និងឆ្លុះបញ្ចាំងអំពីអ្វីៗដែលគេបានរៀននៅថ្នាក់ទី ១០រហូតមកដល់បច្ចុប្បន្ន។





# មេរៀនទី ២៧ ការស្រាវជ្រាវព័ត៌មាន

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យជំនាញក្នុងការស្រាវជ្រាវព័ត៌មានរបស់សិស្សមានភាពប្រសើរឡើង

ជំនាញក្នុងការស្រាវជ្រាវរកព័ត៌មាន គឺត្រូវការដើម្បីត្រៀមដោះស្រាយលំហាត់ ឬរៀបចំបទបង្ហាញលើប្រធានបទដែលគ្រូដាក់ឱ្យ។ សារៈសំខាន់នៃជំនាញក្នុងការស្រាវជ្រាវរកព័ត៌មាន និងការគិតពិចារណា នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយទាំងនៅពេលរៀនបច្ចុប្បន្ន ពេលបន្តការសិក្សា និងក្នុងជីវិតការងារនាថ្ងៃអនាគត។ ជំនាញក្នុងការស្រាវជ្រាវ និងសមត្ថភាពក្នុងការវែកញែកលទ្ធផលនៃការស្រាវជ្រាវ «រែងអង្កាមចេញពីអង្ករ» គឺជាជំនាញដ៏ចាំបាច់ដែលសិស្សត្រូវដឹង។

## សកម្មភាពសិស្សទី១៖ ជំនាញក្នុងការស្រាវជ្រាវរកព័ត៌មាន ១ (រយៈពេល ១០នាទី)

ឱ្យសិស្សបង្កើតការពិភាក្សាជាក្រុមធំ និងបំផុសគំនិតដល់សិស្ស ដើម្បីទទួលបានព័ត៌មានដែលអាចទុកចិត្តបានអំពី៖

- តារាងកាលវិភាគរបស់ឡានក្រុង
- របៀបជួសជុលម៉ូតូ
- ការសិក្សាបន្ត (ជំនាញវិជ្ជាជីវៈ ឬឧត្តមសិក្សា)

## សកម្មភាពសិស្សទី២៖ ជំនាញក្នុងការស្រាវជ្រាវរកព័ត៌មាន ២

បែងចែកសិស្សជាក្រុមតូចៗ ហើយផ្តល់ប្រធានបទមួយសម្រាប់ក្រុមនីមួយៗ (សត្វ ប្រទេស សកម្មភាពនៅពេលទំនេរ...) សម្រាប់ធ្វើបទបង្ហាញខ្លីមួយ។ ផ្តល់ពេល ១៥ នាទី ដើម្បីឱ្យសិស្សអនុវត្តជំហានទី១ ក្នុងការស្រាវជ្រាវខ្នាតតូច ឱ្យសិស្សបំផុសគំនិតក្នុងក្រុមតូច រួចកត់ត្រាអំពី៖

- តើយើងបានដឹងអ្វីខ្លះអំពីប្រធានបទ?
- តើព័ត៌មានប្រភេទណាដែលយើងត្រូវការបន្ថែម?
- តើយើងអាចរកព័ត៌មានដែលទាក់ទងនៅកន្លែងណា? តើប្រភពព័ត៌មានអ្វីខ្លះដែលមាននៅទីនោះ?
- តើយើងស្រាវជ្រាវរកព័ត៌មានបានដោយរបៀបណា?
- តើព័ត៌មានទាំងអស់អាចទុកចិត្តបានទេ មានបច្ចុប្បន្នភាពទេ និងត្រឹមត្រូវទេ? តើយើងអាចធានាបានដោយរបៀបណា?

## សកម្មភាពសិស្សទី៣

ពេលនេះក្រុមនីមួយៗ នឹងបង្ហាញអំពីលទ្ធផលដែលចេញពីការបំផុសគំនិត។ ក្រុមនីមួយៗអាចប្រើពេល ២-៣នាទី អាស្រ័យទៅលើចំនួនក្រុមដែលអ្នកមាន។ អ្នកអាចសង្ខេបលទ្ធផលសំខាន់ៗជា ២-៣ ល្បះ ដោយសង្កត់ធ្ងន់ថាវាមានសារៈសំខាន់បែបណាក្នុងការវិភាគឱ្យបានដិតដល់ពេលស្រាវជ្រាវរកព័ត៌មានថ្មីៗ ហើយមិនត្រូវជឿជាក់ដោយពេកទេទៅលើព័ត៌មានដែលអ្នកបានឃើញ ឬបានឮ។

# មេរៀនទី ២៨ បញ្ហាប្រឈមក្នុងការសិក្សា

វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យសិស្សយល់ដឹងពីភាពលំបាកផ្សេងៗក្នុងការរៀនសូត្រ។

ភាពលំបាកក្នុងការរៀនសូត្រ អាចធ្វើឱ្យសិស្សមានអារម្មណ៍ទន់ជ្រាយ មិនពេញចិត្ត ពិបាកចិត្ត ធុញថប់...។ ដូចនេះ វាសំខាន់ណាស់ដែលអ្នកត្រូវបញ្ជាក់ប្រាប់សិស្សថា ភាពលំបាកក្នុងការរៀនសូត្រអាចមានខុសៗគ្នា ហើយវាមិនមែនមានន័យថាអ្នកល្ងង់ ឬរៀនមិនចេះនោះទេ។

### សកម្មភាពសិស្សទី១ៈ ឱ្យសិស្សបំពេញសន្លឹកកិច្ចការ

### សន្លឹកកិច្ចការៈ បញ្ហាប្រឈមក្នុងការសិក្សា និងភាពពិបាកក្នុងការរៀនសូត្រ

| អានល្បះខាងក្រោម រួមជ្រើសយកពាក្យ ចាស/បាទ បំពេញក្នុងប្រលោះខាងស្តាំ | ចាស/បាទ |
|---|---|
| ១. ខ្ញុំតែងច្រលំរវាងខាងស្តាំ និងឆ្វេង ឬទិសខាងកើត និងខាងលិច | |
| ២. វាពិតជាពិបាកនៅក្នុងការអានផែនទី | |
| ៣. ខ្ញុំមិនចូលចិត្តអានដោយបញ្ចេញសំឡេងខ្លាំងៗនោះទេ | |
| ៤. ខ្ញុំអានយឺតជាងអ្នកផ្សេង | |
| ៥. វាពិតជាពិបាកនៅក្នុងការចងចាំនូវអ្វីដែលខ្ញុំបានអាន | |
| ៦. ខ្ញុំមិនចូលចិត្តអានទេ។ | |
| ៧. ខ្ញុំប្រកបអក្សរខុសច្រើន | |
| ៨. វាពិតជាពិបាកនៅក្នុងការអានអក្សរដែលខ្ញុំសរសេរដោយដៃ | |
| ៩. វាពិតជាពិបាកនៅក្នុងការទទួលសារ រួចបន្តឱ្យអ្នកផ្សេងទៀត | |
| ១០. ពាក្យវែងគឺពិបាកក្នុងការបញ្ចេញសំឡេង | |
| ១១. វាពិបាកនៅក្នុងការបំពេញទម្រង់បែបបទ | |
| ១២. នៅពេលខ្ញុំអាន តែងតែរំលងជួរអក្សរ | |
| ១៣. តួអក្សរតែងតែដូរកន្លែងនៅពេលដែលខ្ញុំអាន | |
| ១៤. ខ្ញុំសរសេរយឺត | |
| ១៥. វាពិបាកក្នុងការសម្រេច ថាតើខ្ញុំត្រូវសរសេរស្រៈ ឬព្យញ្ជនៈ វែង ឬខ្លី | |
| ១៦. ខ្ញុំប្រើម្រាមដៃក្នុងការគិតលេខ | |
| ១៧. ខ្ញុំមិនអាចចាំលេខទូរស័ព្ទដែលវែង រួចចុចលេខពីការចងចាំបានទេ | |
| ១៨. វាពិបាកក្នុងការចាំឈ្មោះខែតាមលំដាប់លេខរៀង | |
| ១៩. ខ្ញុំច្រលំរវាងថ្ងៃខែ និងម៉ោង ហើយតែងតែមើលម៉ោង និងថ្ងៃខែខុស | |

| | |
|---|---|
| ២០. លេខដូរកន្លែង ឧ. ៥៩ និង ៩៥ | |
| ២១. ខ្ញុំនៅតែមិនអាចទន្ទេញមេលេខចាំ | |
| ២២. វាពិបាកក្នុងការរៀនគណិតវិទ្យា ទោះបីជាខ្ញុំដឹងចម្លើយក៏ដោយ | |
| ២៣. វាពិបាកក្នុងការរៀនភាសានៅសាលា ទោះបីជាខ្ញុំអាចនិយាយភាសាផ្សេងក៏ដោយ | |
| ២៤.លេខមួយជួរ ដូចជាលេខទូរស័ព្ទគឺពិបាកក្នុងការចងចាំ | |
| ២៥. វាពិបាកក្នុងការផ្តោតអារម្មណ៍រៀន ឬធ្វើលំហាត់នៅផ្ទះ | |
| ២៦. ខ្ញុំតែងតែមានអារម្មណ៍អវត្តមាននៅក្នុងថ្នាក់ ហើយសំគាល់ឃើញថាខ្ញុំមិនអាចយកចិត្តទុកដាក់រៀនបានទេពេលចុងក្រោយនេះ | |
| ២៧. វាពិបាកក្នុងការចាំនូវអ្វីដែលខ្ញុំទើបតែរៀនហើយ | |
| ២៨. ខ្ញុំគិតថាខ្ញុំកាលពីមុនមានសមត្ថភាពជាង | |
| ២៨. ខ្ញុំតែងតែមានអារម្មណ៍ខឹងដោយគ្មានមូលហេតុ | |
| ៣០. វាពិបាកក្នុងការជឿជាក់លើអនាគត ជំនាញក្នុងការរៀនរបស់ខ្ញុំ ឬសមត្ថភាពរបស់ខ្ញុំ | |
| ពិន្ទុដែលឆ្លើយថា បាទ/ចាស៖ | |

ប្រសិនបើសិស្សមានចម្លើយ បាទ/ចាសច្រើនជាងពាក់កណ្តាល អ្នកអាចមានការពិបាកក្នុងការរៀនសូត្រ។ ការពិបាកគឺជាទូទៅបណ្តាលមកពី ខកខានមិនបានអនុវត្តរយៈពេលវែង ឬពេលខ្លះដោយសារតែកត្តាប្រព័ន្ធប្រសាទ ឬបទពិសោធធ្លាប់ស្មុគស្មាញ។ ជារឿយៗ សិស្សអាចដោះស្រាយការពិបាកបានដោយអនុវត្តសាឡើងវិញជាច្រើនដង ដោយប្រើប្រាស់យុទ្ធសាស្រ្តខុសៗគ្នានៅក្នុងការសិក្សា និងចំណុចខ្លាំង។ ពេលខ្លះ ការយកចិត្តទុកដាក់ជាពិសេសអាចនឹងមានប្រយោជន៍។

# មេរៀនទី ២៩ ការដោះស្រាយបញ្ហាសម្ពាធ ១

វត្ថុបំណងនៃមេរៀនទាំងនេះគឺ៖

- ជួយសិស្សទទួលស្គាល់ស្ត្រេស និងការងារលើសកម្រិត
- ជួយសិស្សដោះស្រាយបញ្ហាស្ត្រេស និងកាត់បន្ថយវា។

សិស្សភាគច្រើនតែងមានការរំពឹងទុក និងស្ត្រេសជាច្រើន ក្នុងអំឡុងឆ្នាំសិក្សានីមួយៗ ហើយជាពិសេសនៅចុងឆ្នាំ និងពេលជិតប្រឡងបញ្ចប់។

## សកម្មភាពសិស្សទី១



ឱ្យសិស្សសរសេរអត្ថបទខ្លីមួយទៅអ្នកអំពីប្រភេទសម្ពាធដែលគេមាន៖

- ពេលបច្ចុប្បន្ននៅសាលារៀន
- អ្នកដទៃដាក់សម្ពាធលើពួកគេ
- អំពីអនាគតរបស់ពួកគេ

ប្រមូលអត្ថបទនោះពីសិស្ស រួចអានវាម្តងមួយៗ និងមិនត្រូវចែកចាយជាសាធារណៈឡើយ។ អ្នកត្រូវចាប់ផ្តើមផ្តល់ប្រឹក្សាដោយផ្ទាល់ជាមួយសិស្សដែលត្រូវការជំនួយ។

## សកម្មភាពសិស្សទី២

បន្ទាប់មកពិភាក្សាគ្នា៖

- តើសម្ពាធខាងក្នុងខុសពីសម្ពាធខាងក្រៅយ៉ាងដូចម្តេច?
- តើសិស្សដាក់សម្ពាធខ្លាំងពេកសម្រាប់ខ្លួនឯង ពេលដែលពួកគេមិនរីករាយនូវអ្វីដែលគេកំពុងធ្វើ?
- តើសិស្សដាក់សម្ពាធខ្លាំងពេកសម្រាប់ខ្លួនឯង ពេលដែលពួកគេប្រៀបធៀបខ្លួនឯងនឹងអ្នកដទៃ? តើវាល្អដែរឬទេ?
- តើសិស្សគិតថាសម្ពាធអាចប៉ះពាល់ដល់ការធ្វើការសម្រេចចិត្តរបស់គេដែរឬទេ? ហេតុអ្វី? នៅពេលដែលសិស្សមានបញ្ហាធំៗ តើគេបានរកជំនួយដែរឬទេ?
- តើអ្វីខ្លះដែលមានសម្ពាធលើសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិ? ស្វែងរកប្រធានបទពី ៤-៥ ដោយសរសេរលើក្តារខៀន។



## សកម្មភាពសិស្សទី៣

ជាទូទៅ សម្ពាធគឺជាផ្នែកមួយនៃជីវិត។ ការសិក្សាមធ្យមសិក្សាទុតិយភូមិនាំមកនូវសម្ពាធថ្មីៗមួយចំនួន។ អ្វីដែលជាបញ្ហានោះ មិនមែនទំហំសម្ពាធដែលសិស្សមាននោះទេ ប៉ុន្តែនៅត្រង់ថាសិស្សមើលវាក្នុងទស្សនៈបែបណា ហើយដោះស្រាយវាយ៉ាងដូចម្តេច។

បែងចែកសិស្សជា ៤-៥ ក្រុម (ទៅតាមចំនួនប្រធានបទដែលអ្នកមាននៅលើក្តារខៀន)។ ក្រុមនីមួយៗ ត្រូវពិភាក្សាស្វែងរកវិធីកាត់បន្ថយស្ត្រេសលើប្រធានបទ១ ដែលជ្រើសចេញពីក្តារខៀន។ ខាងក្រោមនេះ គឺជាមធ្យោបាយវិជ្ជមានមួយចំនួន សម្រាប់ដោះស្រាយបញ្ហាស្ត្រេស៖

- សំរាកបន្តិច
- ធ្វើរឿងសប្បាយមួយរយៈ អាចជួយឱ្យអ្នកបំភ្លេចសម្ពាធ
- និយាយជាមួយមិត្តភក្តិ ឪពុកម្តាយ ឬអ្នកប្រឹក្សាយោបល់ ឬសរសេរចូលក្នុងសៀវភៅកំណត់ហេតុ
- សុំជំនួយពីអ្នកដទៃ និងកុំស្តីបន្ទោសខ្លួនឯងខ្លាំងពេក
- ស្គាល់ពីកម្រិតខ្លួនឯង កុំដាក់លើសពីអ្វីដែលអ្នកអាចចាត់ចែងបាន។



## សម្រាប់អ្នកប្រឹក្សាអាជីព៖

### ព័ត៌មានសាវតាអំពីស្ត្រេស៖

ជារឿងធម្មតាក្នុងជីវភាពប្រចាំថ្ងៃ ដែលអ្នកតែងមានស្ត្រេស។ ស្ត្រេស ក៏អាចជារឿងល្អដែរ នៅពេលដែលវាមិនមានច្រើនពេក។ បរិមាណសមស្របនៃស្ត្រេស ផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកធ្វើការងារដោយប្រសិទ្ធភាព។ ប្រសិនបើអ្នកមានស្ត្រេសច្រើនពេក ជីវិតនឹងមានភាពតានតឹង និងហត់នឿយខ្លាំង។ អ្នកគួររៀនស្គាល់អំពីរោគសញ្ញានៃស្ត្រេស និងភាពនឿយហត់ជាមុន ហើយអនុវត្តវិធីផ្សេងៗ ក្នុងការបំបាត់ស្ត្រេស។ ស្ត្រេសកើតឡើងនៅពេលដែលអ្នកមានអារម្មណ៍ថាជំនាញ និងសមត្ថភាពមិនទាន់គ្រប់គ្រាន់ ឬអ្នកត្រូវតែបង្ខំខ្លួនឯងទៅដល់កម្រិតមួយដែលអ្នកទៅលែងរួច។

ចំណុចខាងក្រោមនេះ អាចជាប្រភពបង្កើតស្ត្រេស៖

- ប្រញាប់ប្រញាល់ជានិរន្តរ៍
- ការផ្លាស់ប្តូរក្នុងទំនាក់ទំនង និងស្ថានភាពរស់នៅ
- ខ្វះខាតទំនាក់ទំនងសង្គម និងភាពឯកកោ
- ខ្វះការជួយជ្រោមជ្រែង
- បញ្ហាហិរញ្ញវត្ថុ
- តម្រូវការដែលគ្មានហេតុផល និងការរវល់ច្រើន

- ជីវិតរស់នៅដែលមានបន្ទុកច្រើន

ជួនកាល សូម្បីតែរឿងវិជ្ជមានមួយចំនួនក៏អាចបង្កើតស្ត្រេសបានដែរតួយ៉ាងដូចជា ការបញ្ចប់ការសិក្សា ការទទួលបានការងារថ្មី ឬមានទំនាក់ទំនងថ្មី។ ស្ត្រេសគឺជារឿងបុគ្គល ដែលមានកម្រិតខុសៗគ្នាពីមនុស្សម្នាក់ទៅម្នាក់។ មនុស្សខ្លះឆាប់ទទួលភាពស្ត្រេស រហ័សជាងមនុស្សខ្លះទៀត។ បុគ្គលិកលក្ខណៈ ភាពឆេវឆាវ និងស្ថានភាពក្នុងជីវិត គឺជាអ្វីដែលប៉ះពាល់ដល់ស្ត្រេសដែលអ្នកនឹងទទួល។ ការរំពឹងទុក និងការទាមទារដ៏ហួសហេតុពីខ្លួនអ្នកផ្ទាល់ ឬអ្នកដទៃ ជាញឹកញាប់ក៏អាចបង្កើនកម្រិតស្ត្រេសដែរ។ អ្នកអាចប្រកបកិច្ចការបានយ៉ាងល្អបំផុតនៅពេលដែលអ្នកមានអារម្មណ៍រំភើប និងផ្តោតលើអ្វីដែលអ្នកកំពុងធ្វើ។ ស្ត្រេសវិជ្ជមាននឹងជំរុញឱ្យអ្នកសកម្មឡើង ផ្តល់ឱ្យអ្នកនូវថាមពល និងជួយឱ្យអ្នកផ្តោតអារម្មណ៍បានល្អ។ ប្រសិនបើអ្នកមិនដែលឆ្លងកាត់ពិសោធន៍ស្ត្រេសប្រភេទណាមួយទេ អ្នកក៏មិនអាចធ្វើអ្វីបានសម្រេចដែរ។ ស្ត្រេសក៏បានប្រាប់អ្នកនូវអ្វីដែលសំខាន់សម្រាប់អ្នក។ ហេតុនេះហើយបានជាវាអាចធ្វើឱ្យអ្នកស្ត្រេស! បញ្ហាសំខាន់គឺថា តើអ្នកមានស្ត្រេសជាលក្ខណៈបណ្តោះអាសន្ន ឬមានរហូត។ ស្ត្រេសរយៈពេលខ្លី ជាទូទៅមិនបានបង្កបញ្ហាអ្វីនោះទេ វាធ្វើឱ្យមនុស្សបញ្ចេញអស់នូវសមត្ថភាព។ ស្ត្រេសរយៈពេលវែង អាចបង្កហានិភ័យតាមមធ្យោបាយជាច្រើន។

អ្នកគួរតែយល់ដឹងពីរោគសញ្ញានៃស្ត្រេសដែលហួសកម្រិត។ បន្ទាប់មក អ្នកអាចធ្វើអ្វីម្យ៉ាងមុននឹងសម្ពាធឡើងខ្ពស់ពេក។ រៀនស្គាល់ពីរោគសញ្ញាស្ត្រេស ព្រោះវាមានលក្ខណៈខុសគ្នាពីមនុស្សម្នាក់ ទៅមនុស្សម្នាក់។ រោគសញ្ញាទូទៅមានដូចខាងក្រោម៖

- រោគសញ្ញារាងកាយផ្សេងៗ ដូចជា ឈឺក្បាល ឈឺចុករោយសាច់ដុំ ញ័របេះដូង វិលមុខ មិនស្រួលក្រពះ និងឈឺក្រពះ
- រោគសញ្ញាផ្លូវអារម្មណ៍ដូចជា ធុញថប់ ខ្វល់ខ្វាយ កំណើនការចង់យំច្រើន អារម្មណ៍មិនបិតបេរ និងមានអារម្មណ៍ស្រងេះស្រងោច
- រោគសញ្ញាកាយវិការដូចជា គេងមិនទៀងទាត់ អាក់ខានក្នុងការបំពេញតួនាទី មិនចេះអត់ធ្មត់ ភ័យខ្លាច អន្ទះអន្ទែង និងយឺតយ៉ាវ
- រោគសញ្ញាពាក់ព័ន្ធនឹងការគិតដូចជា មានបញ្ហាក្នុងការផ្តោតអារម្មណ៍ គិតទុទ្ទិដ្ឋិនិយម ពិបាកក្នុងការសម្រេចចិត្ត កំណើនការរិះគន់ខ្លួនឯង ការចងចាំមិនទៀងទាត់។

ស្ត្រេសរយៈពេលវែង អាចបង្កបញ្ហាសុខភាពធ្ងន់ធ្ងរដូចជា ជំងឺបេះដូង ជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ សម្ពាធឈាមឡើងខ្ពស់ រហិតរហៃ និងបញ្ហាក្នុងការគេងមិនលក់។ សូមប្រឹក្សាជាមួយនឹងអ្នកជំនាញសុខភាពក្នុងករណីចាំបាច់។

នៅពេលដែលអ្នករៀនអំពីការគ្រប់គ្រងស្ត្រេស អ្នកនឹងអាចរក្សាស្ត្រេសដោយមិនឱ្យមានផលអវិជ្ជមានមករំខានអ្នកនោះទេ។ ចំណុចដែលអ្នកអាចផ្តោតក្នុងការគ្រប់គ្រងស្ត្រេសរួមមាន៖

- ប៉ះពាល់ស្ថានភាពដែលបង្កស្ត្រេស
- ប៉ះពាល់នូវការការគិតរបស់អ្នក
- កាត់បន្ថយឥទ្ធិពលស្ត្រេស។

ចាប់ផ្តើមជាមួយអ្វីដែលងាយស្រួលមុនគេ។ ប្រសិនបើសម្រាកមិនបានគ្រប់គ្រាន់ ឬមិនបានធ្វើសកម្មភាពនៅខាងក្រៅគ្រប់គ្រាន់ អាចបណ្តាលឱ្យអ្នកស្ត្រេស ប្តូរទម្លាប់ប្រចាំថ្ងៃទាំងនេះចេញ។ ពេលខ្លះ ការផ្លាស់ប្តូរទាក់ទងនឹងកិច្ចការធំៗដូចជា ការប្តូរកន្លែងសិក្សា ឬមុខវិជ្ជាសិក្សាក៏អាចបណ្តាលឱ្យស្ត្រេសបានដែរ។ កត់ត្រានូវប្រភេទសកម្មភាពតាមភាពសំខាន់របស់វា ហើយពិចារណានូវវិធានការណ៍ណាមួយដែលចាំបាច់សម្រាប់ឱ្យមានការផ្លាស់ប្តូរកើតឡើង។

ស្ត្រេសតែងតែពាក់ព័ន្ធនឹងស្ថានភាពជាក់លាក់ណាមួយ ដូចជាការធ្វើបទបង្ហាញ។ ប្រឈមមុខនឹងស្ថានភាពដែលបង្កស្ត្រេសម្តងទៀត ហើយអ្នកនឹងទទួលបានបទពិសោធសំខាន់មួយក្នុងការបន្តរស់រានមានជីវិតជាមួយវា។ អ្នកក៏អាចរំលងស្ថានការណ៍ដែលបង្កស្ត្រេសដែលមិនចាំបាច់បាន។

អនុវត្តការគិតរបស់អ្នកដូចខាងក្រោម ដើម្បីកាត់បន្ថយកម្រិតស្ត្រេស៖

- មិនត្រូវគិតថាអ្នកអន់ជាងអ្នកដទៃនោះទេ
- ផ្អាក និងវាយតម្លៃដោយស្ងប់ពីស្ថានការណ៍ ទទួលស្គាល់កម្រិត និងធនធានរបស់អ្នក
- អត់ឱនឱ្យខ្លួនឯង និងពេញចិត្តនូវអ្វីដែលអ្នកសម្រេចបាន
- ទម្លាក់ចោលនូវតម្រូវការដែលហួសកម្រិត និងមានភាពទន់ភ្លន់សម្រាប់ខ្លួនឯង
- រកដំណោះស្រាយច្បាស់លាស់ឆ្លើយតបទៅនឹងស្ថានការណ៍នោះ ជាជាងព្រួយបារម្ភ និងស៊ូទ្រាំជាមួយវា
- ព្យាយាមទទួលស្គាល់ហេតុការណ៍ដែលកន្លងហួស ហើយសំឡឹងទៅមុខ
- ត្រូវចងចាំថា ការព្រួយបារម្ភតូចតាចមិនអាចឱ្យពិភពលោករលំរលាយនោះទេ។ រាល់កំហុសនឹងត្រូវបានយល់ ហើយទទួលយក។ ជឿជាក់លើសមត្ថភាពខ្លួនឯងក្នុងការគ្រប់គ្រងស្ត្រេស និងកំណត់ជីវិតផ្ទាល់ខ្លួនរបស់អ្នក។

## កាត់បន្ថយឥទ្ធិពលរបស់ស្ត្រេស

ការគ្រប់គ្រងពេលវេលា គឺជាមធ្យោបាយដ៏ល្អក្នុងការគ្រប់គ្រងស្ត្រេស។ សាកល្បងអនុវត្តនូវសេចក្តីណែនាំខ្លីៗដូចខាងក្រោម៖

- រៀបកាលវិភាគអ្នកដោយប្រុងប្រយ័ត្ន
- សួរខ្លួនអ្នកនូវអ្វីដែលសំខាន់ ហើយលំដាប់នៃសកម្មភាពដែលត្រូវធ្វើ
- បង្កើតគោលដៅរយៈពេលខ្លី រយៈពេលវែង និងជម្រុះចោលអ្វីដែលមិនសំខាន់
- រៀបចំជំហានខ្លីៗក្នុងការសម្រេចគោលបំណងនីមួយៗ និងធ្វើវាតាមលំដាប់លំដោយ
- ទុកពេលសម្រាប់ការងារដែលអ្នកចូលចិត្ត និងរកជំនួយពីអ្នកដទៃក្នុងករណីចាំបាច់។

ប្រើប្រាស់ទំនាក់ទំនងរបស់អ្នកនៅពេលដែលមានអារម្មណ៍ថាស្ត្រេស ផងដែរ៖

- ទទួលយកជំនួយពីអ្នកដទៃ
- ប្រាប់ពីបញ្ហារបស់អ្នកជាមួយមនុស្សដែលអ្នកស្រឡាញ់ និងមិត្តភក្តិ
- ស្វែងរកការកំដរពីអ្នកផ្សេង ទោះបីជាពេលខ្លះអ្នកមិនសូវចូលចិត្តក៏ដោយ
- មើលពីកម្រិតសមត្ថភាពរបស់អ្នក ហើយកុំឱ្យអ្នកដទៃដឹកនាំអ្នក
- ត្រូវតែម៉ឺងម៉ាត់។



រាល់ការចាប់ផ្តើមនៃអ្វីៗគ្រប់យ៉ាងគឺចេញពីការមើលថែ និងការស្រឡាញ់ខ្លួនអ្នក នៅក្នុងជីវិតប្រចាំថ្ងៃ៖

- រក្សារចង្វាក់ និងទម្លាប់ប្រហាក់ប្រហែលក្នុងជីវិតរបស់អ្នក
- ហាត់ប្រាណតាមលក្ខណៈដែលអ្នករីករាយ
- គេងឱ្យបានគ្រប់គ្រាន់
- ញុំាឱ្យទៀងទាត់ និងប្រកបដោយសុខភាព
- ប្រើប្រាស់ជាតិស្រវឹងបន្តិចបន្តួចបានហើយ
- ធ្វើនូវរឿងពេញចិត្ត ដែលនាំឱ្យអ្នករីករាយ
- បន្ថែមសមាសភាគធម្មជាតិទៅក្នុងជីវិតប្រចាំថ្ងៃ
- ផ្តល់នូវអំណោយសម្រាប់ខ្លួនអ្នក
- សម្រាកជារៀងរាល់ថ្ងៃ។

គន្លឹះសម្រាប់ការសម្រាក៖

- ស្វែងរកការកម្សាន្តដែលអ្នកចូលចិត្ត ដែលនាំឱ្យអ្នកអភិវឌ្ឍខ្លួនឯង៖ មើលឃើញការអភិវឌ្ឍខ្លួនឯងគឺជាការលើកទឹកចិត្ត និងអនុញ្ញាតឱ្យអ្នកផ្តោតលើស្រ្តេស
- ស្វែងរកអ្វីដែលធ្វើឱ្យអ្នកមានលំនឹងនៅក្នុងភារកិច្ចប្រចាំរបស់អ្នក
- ធ្វើរឿងខុសៗគ្នាឱ្យច្រើនជាងអ្វីដែលអ្នកធ្វើក្នុងពេលកំពុងសិក្សា៖ ប្រសិនបើអ្នកអានច្រើនដោយសារតែការសិក្សា ចូរធ្វើនូវអ្វីដែលខុសពីនេះទាំងស្រុងនៅពេលសម្រាក
- មិនត្រូវពន្យារពេលការសម្រេចចិត្តរបស់អ្នកទេ៖ ការសញ្ជឹងគិតហួសហេតុនឹងដាក់ទម្ងន់លើខួរក្បាលរបស់អ្នក
- កំណត់មូលហេតុនៃស្រ្តេស៖ តើជីវិតរបស់អ្នកមានបន្ទុកមនុស្ស ឬរឿងរ៉ាវដែលធ្ងន់ធ្ងរទេ ឬក៏អ្នកមានប្រតិកម្មទៅលើអ្វីមួយតឹងតែងពេក
- លំហាត់ប្រាណអាចជួយបាន ជាពិសេសគឺយោហ្គា។

អ្នកគួររកពេលសម្រាកឱ្យបានគ្រប់គ្រាន់។ ប្រសិនបើអ្នកសម្រាកពី ២០–៣០ នាទី ជារៀងរាល់ថ្ងៃ អ្នកប្រហែលជាមានអារម្មណ៍ធូរស្រាលបានច្រើន បន្ទាប់ពីអនុវត្តបាន ២ សប្តាហ៍។ អ៊ិនធឺណិត សម្បូរទៅដោយការណែនាំសម្រាប់លំហាត់សម្រាកជាច្រើន។ ចំណុចខាងក្រោមគឺជាវិធីសាស្រ្តដែលសាមញ្ញៗ៖



- បន្ធូរអារម្មណ៍ដោយការដកដង្ហើម
- សម្រាកសាច់ដុំ
- ហាត់ប្រាណដោយប្រើប្រាស់រូបភាពខួរក្បាល
- ហ្វឹកហាត់វត្តមាននៃវិចារណៈញ្ញាណ។

ជំពូកសម្រាប់អ្នកប្រឹក្សាយោបល់នេះត្រូវបានយកចេញពី៖

https://www.nyyti.fi/en/opiskelijoille/opi-elamantaitoa/sopivasti-stressia/

## មេរៀនទី ៣០ ការដោះស្រាយបញ្ហាសម្ពាធ ២

យើងបន្តប្រធានបទស្រ្តេសដដែលនេះមួយមេរៀនទៀត។ ជាការចាប់ផ្តើម អ្នកត្រូវសង្ខេបខ្លឹមសារមេរៀនមុន ដើម្បីរំឭកការចងចាំរបស់សិស្សប្រហែល ១០ នាទី។

### សកម្មភាពសិស្សទី១

អ្នកត្រូវបំផុតសិស្សឱ្យធ្វើការពិភាក្សាអំពីសារៈសំខាន់នៃការសំរាកលំហែកាយ។ ការសម្រាកបានទៀងទាត់គ្រប់គ្រាន់ អាចជួយឱ្យសិស្សមានថាមពលគ្រប់គ្រាន់សម្រាប់សិក្សា ធ្វើការ និងថែរក្សាសុខភាពប្រចាំថ្ងៃបានល្អ។ ជាងនេះទៅទៀត សិស្សអាចកាត់បន្ថយស្រ្តេស និងធ្វើឱ្យការគេងការផ្តោតអារម្មណ៍ និងមានផលិតភាពប្រសើរជាងមុន។ សម្រាប់អ្នកខ្លះ ការមើលខ្សែភាពយន្ត គឺជាការសម្រាកដ៏ល្អបំផុត ហើយអ្នកខ្លះសម្រាកលំហែដោយការចំណាយពេលនៅជាមួយមិត្តភក្តិ ឬរត់ហាត់ប្រាណ ឬលេងកីឡាផ្សេងទៀត។ មនុស្សគ្រប់គ្នា គួរតែចំណាយពេលសម្រាប់សម្រាកលំហែរាល់ថ្ងៃ។ ឱ្យសិស្ស ប្រាប់ពីវិធីនៃការសម្រាកលំហែដ៏ល្អសម្រាប់ពួកគេ។ សរសេរគំនិតទាំងនេះនៅលើក្តារខៀន។

### សកម្មភាពសិស្សទី២

អ្នកនឹងត្រូវធ្វើលំហាត់ខ្លីមួយអំពីការសម្រាកលំហែ។ ជាដំបូងឱ្យសិស្សអង្គុយឱ្យស្រួល រួចបិទភ្នែក ដកដង្ហើមមួយៗ និងស្តាប់តាមការណែនាំរបស់អ្នក។ ផ្តល់ការណែនាំរបស់អ្នកដោយទន់ភ្លន់ និងមានសំឡេងថេរល្អ ដូចនេះពួកគេអាចមានអារម្មណ៍ធូរស្រាល និងសុវត្ថិភាព។ នេះជាការផ្តល់ឧទាហរណ៍នៃលំហាត់បន្ធូរអារម្មណ៍សម្រាប់កាត់បន្ថយស្រ្តេស។

### ស្រមើស្រមៃដំណើរកម្សាន្តមួយទៅមាត់បឹង

ដកដង្ហើមស្ងប់ស្ងាត់ និងធ្វើអាកប្បកិរិយាសម្រាកលំហែ។ បិទភ្នែករបស់អ្នក ដកដង្ហើមវែងៗ និងស្ងប់អារម្មណ៍។ ដកដង្ហើមចូល ដង្ហើមចេញ និងទុកឱ្យខ្លួនប្រាណអ្នកសម្រាក។ ដៃ និងជើងចាប់ផ្តើម មានអារម្មណ៍ធ្ងន់។ បន្តិចម្តងៗ អ្នកនឹងមានអារម្មណ៍លង់ទៅក្នុងការសម្រាកដ៏ជ្រាលជ្រៅ។ ផ្តោតអារម្មណ៍លើចលនាដង្ហើមរបស់អ្នក។ ដកដង្ហើមចូលឱ្យជ្រៅតាមច្រមុះ និងចេញមកតាមមាត់ស្ងាត់ៗ។ ស្រមៃថាអ្នកកំពុងស្ថិតនៅលើផ្ទៃបឹង។ វាជាទិដ្ឋភាពដ៏ស្រស់ស្អាត មានខ្យល់ទន់ត្រជាក់ ហើយកក់ក្តៅ និងមានពន្លឺព្រះអាទិត្យដ៏ស្រទន់ជះលើផ្ទៃបឹង។ រស្មីព្រះអាទិត្យនឹងកំដៅក្បាល និងស្មារបស់អ្នក។ អ្នកនឹងមានអារម្មណ៍ថា ទឹកសន្សើមរាងត្រជាក់បន្តិចផាត់មកតាមខ្យល់បក់ដណ្តប់លើផ្ទៃមុខរបស់អ្នក។ ស្រមៃមើលទៅឆ្នេរសមុទ្រ និងវាលខ្សាច់លាតសន្ធឹងធំល្វឹងល្វើយនៅលើឆ្នេរ។ តើអ្នកមានអារម្មណ៍បែបណាពេលដើរជាន់វា? អ្នកកំពុងតែឈរនៅលើខ្សាច់ដែលស្ងួត ហើយទន់។ ដើរ ២ ទៅ ៣ ជំហាន។ តើអ្នកមានអារម្មណ៍បែបណានៅពេលដែលដើរលើខ្សាច់ដែលទន់ ហើយកក់ក្តៅ? ដើរសំដៅទៅកាន់បឹង ពេលនេះខ្សាច់រាងត្រជាក់បន្តិច។ កត់សម្គាល់ខ្សាច់តោងជើងអ្នកនៅពេលដែលអ្នកដើរចុះឡើង។ ក្រលេកមើលដានជើងខាងក្រោយអ្នក។ រលកមានភាពរលូនបក់បោកលើឆ្នេរ និងលុបស្នាមដានជើងរបស់អ្នក។ មើលផ្ទៃបឹង សម្គាល់ពណ៌ដែលមានពន្លឺស្រដៀងៗគ្នា។ រលកបក់ដល់ច្រាំងហើយត្រលប់ទៅវិញ ម្តងហើយម្តងទៀត។ ស្តាប់ចង្វាក់សំឡេងដែលបង្កើតឡើងដោយទឹករលក។ ក្រលេកមើលទៅត្រើយសមុទ្រ ហើយអ្នកនឹងសម្គាល់ថារលកពិតជាធ្វើដំណើរមកពីទីដ៏សែនឆ្ងាយ។ ពន្លឺព្រះអាទិត្យចែងចាំងដ៏ស្រស់ស្អាតនៅលើរលក។ ពន្លឺព្រៀកៗគឺ

កំពុងរាំនៅលើផ្ទៃទឹក។ សំឡឹងមើលទៅមេឃដ៏ស្រស់ថ្លា។ ដកដង្ហើមយកខ្យល់អាកាសដ៏បរិសុទ្ធ។ ដើរយឺតៗនៅលើឆ្នេរខ្សាច់។ ភ្នែករបស់អ្នកស្រទន់ កក់ក្ដៅហើយស្ងប់ស្ងាត់។ ឱ្យកំដៅបំពេញដួងអារម្មណ៍របស់អ្នក។ (ឈប់និយាយបន្តិច ឬប្រសិនបើអាច លេងតន្ត្រីក្លាសិចដែលស្រទន់រយៈពេល ២-៣ នាទី)។

អ្នកកំពុងតែត្រលប់ទៅកាន់ពេលវេលានេះដោយស្ងៀមស្ងាត់។ ភាពធូន់ធូរ/តឹងតែង ស្ថិតក្នុងកណ្ដាប់ដៃអ្នក ហើយជើងអ្នកចាប់ផ្ដើមសម្រួល អ្នកមានអារម្មណ៍ស្រស់ថ្លា។ លើកដៃ និងជើងអ្នកបន្តិច។ បង្វិលម្រាមដៃ រួចបន្ទាប់មកដៃរបស់អ្នក។ អ្នកអាចបើកភ្នែករបស់អ្នកយឺតៗ រួចត្រលប់មកស្ថានភាពនេះវិញ។ អ្នកអាចពត់ខ្លួនអ្នកដោយសម្រួល។ ពេលនេះអ្នកត្រូវបានធ្វើឱ្យស្រស់ថ្លា។ តើពេលនេះអ្នកមានអារម្មណ៍បែបណាហើយ?

(កែសម្រួលចេញពី Rantanen ២០១០)។

### សកម្មភាពសិស្សទី៣

រំឭកសិស្សនូវអត្ថបទដែលពួកគេបានសរសេរជូនអ្នកកាលពីមេរៀនមុន។ ពេលនេះពួកគេត្រូវសរសេរអត្ថបទមួយទៀត ដែលពួកគេត្រូវធ្វើផែនការ ឬធ្វើសំណើសម្រាប់ខ្លួនឯង ដោយប្រាប់អំពីរបៀបដោះស្រាយសម្ពាធរបស់ពួកគេ និងវិធីសាស្ត្រអ្វីដែលពួកគេនឹងប្រើក្នុងការពុះពារបញ្ហាស្ត្រេស។

### សម្រាប់អ្នកប្រឹក្សាអាជីព

បន្ទាប់ពីអានអត្ថបទរបស់សិស្សរួច អ្នកត្រូវប្រកាន់ខ្ជាប់នូវការរក្សាការសម្ងាត់ឯកជនរបស់សិស្សម្នាក់ៗ។ ជាការប្រសើរ អ្នកគួរប្រគល់អត្ថបទទាំងពីរ (មេរៀនមុនមួយ មេរៀននេះមួយ) ទៅឱ្យសិស្សវិញ បន្ទាប់ពីអានរួច ហើយអ្នកនឹងមានគំនិតថា តើសិស្សណាត្រូវការជំនួយ និងផ្ដល់ការប្រឹក្សាយោបល់ជាលក្ខណៈបុគ្គលដល់ពួកគេ។



## មេរៀនទី ៣១ ភ្ជាប់ទំនាក់ទំនងទៅការរៀនសូត្រ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សមានទម្លាប់ល្អក្នុងការរស់នៅ និងការសិក្សា

### សកម្មភាពសិស្សទី១

ចែកសន្លឹកកិច្ចការ ឱ្យសិស្សបំពេញ ឬសរសេរសំណួរនៅលើក្ដារខៀន ដូចនេះពួកគេអាចចម្លង និងសរសេរចម្លើយចូលសៀវភៅរបស់ពួកគេ។

### សន្លឹកកិច្ចការ

សូមអានសំណួរខាងក្រោមឱ្យបានល្អិតល្អន់ រួចសរសេរចម្លើយរបស់អ្នក។

តើអ្នកមានអារម្មណ៍បែបណានៅពេលដែលគេងមិនលក់ស្រួល ឬគេងមិនបានគ្រប់គ្រាន់?

តើអ្នកមានអារម្មណ៍បែបណា បន្ទាប់ពីបានធ្វើសកម្មភាពដែលអ្នកចូលចិត្តដូចជា លេងកីឡា ឬសកម្មភាពផ្សេងៗទៀត?

ហេតុអ្វីបានជាការជឿជាក់ថា អ្នកនឹងជោគជ័យ និងអាចគ្រប់គ្រងការសិក្សារបស់អ្នកបាន?

ហេតុអ្វីបានជាការកំណត់គោលដៅសម្រាប់ខ្លួនឯង ជារឿងសំខាន់?

ពិពណ៌នាអំពីបទពិសោធរីករាយដែលទាក់ទងនឹងការរៀនសូត្រ និងការសិក្សា?

តើអ្វីដែលបំផុស និងជំរុញទឹកចិត្តអ្នកក្នុងការសិក្សា?

តើអ្នកគួរតែមានប្រតិកម្មបែបណា ប្រសិនបើបានពិន្ទុប្រលងមិនល្អ?

ប្រសិនបើអ្នកមានបញ្ហាជាមួយនឹងការងារសាលា តើអ្នកអាចធ្វើអ្វីបានខ្លះ? តើអាចមានរឿងអ្វីកើតឡើងប្រសិនបើអ្នកមិនធ្វើអ្វីទាំងអស់?

ប្រសិនបើអ្នកត្រូវការជំនួយតែមិនហ៊ានសួររក តើវាអាចនាំឱ្យកើតបញ្ហាច្រើនជាងមុនឬទេ?

តើអ្នកអាចនិយាយ ឬធ្វើអ្វីនៅពេលមានមនុស្សដែលអ្នកស្គាល់ត្រូវការជំនួយ?



## សកម្មភាពសិស្សទី២

ឱ្យសិស្សឡើងនិយាយដោយសង្ខេបអំពីសារៈសំខាន់នៃការថែរក្សាសុខភាពរាងកាយ ដោយប្រើប្រាស់រូបភាពខាងក្រោម (អ្នកអាចគូរនៅលើក្ដារខៀន)។ ឱ្យពួកគេឆ្លើយសំណួរនៅក្នុងសន្លឹកកិច្ចការ។

## សន្លឹកកិច្ចការ

ថែរក្សាខួរក្បាលរបស់អ្នក! ខួរក្បាលអ្នកជាអ្នកបញ្ជារាល់កិច្ចការសិក្សារបស់អ្នក។ ត្រូវជួយខួរក្បាលរបស់អ្នកឱ្យបានល្អ ដោយធានាថាអ្នកគេង និងសម្រាកបានគ្រប់គ្រាន់ បរិភោគអាហារបានត្រឹមត្រូវ ធ្វើលំហាត់ប្រាណរាងកាយ និងប្រាជ្ញាបានល្អ នោះសមត្ថភាពដោះស្រាយបញ្ហា និងការចងចាំរបស់អ្នក នឹងមានភាពប្រសើរឡើង។



| | |
|---|---|
| ១. តើអ្នកគេងប៉ុន្មានម៉ោងក្នុងមួយថ្ងៃ? | |
| ២. តើអ្នកបរិភោគអាហារមានជីវជាតិគ្រប់គ្រាន់ដែរឬទេ? | |
| ៣. តើអ្នកធ្វើអ្វីដើម្បីបានសម្រាក និងកាត់បន្ថយស្ត្រេស? (តាំងសមាធិ ធ្វើលំហាត់លេង ។ល។) | |
| ៤. តើអ្នកថែរក្សាទំនាក់ទំនងសង្គមរបស់អ្នកយ៉ាងដូចម្តេច ចែករំលែក ឬចូលរួមជាមួយអ្នកដទៃ? | |
| ៥. តើអ្នកថែរក្សាសុខភាពខួរក្បាលរបស់អ្នកដោយរបៀបណា? (ធ្វើការសិក្សាផ្សេងៗ) | |
| ៦. តើអ្នកថែរក្សាសុខភាពរាងកាយអ្នកដោយរបៀបណា? | |

## មេរៀនទី ៣២ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ១

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សឱ្យស្គាល់ពីចំណុចខ្លាំងរបស់ខ្លួន

### សកម្មភាពសិស្ស

ចែករំលែកគំនិតផ្ទះសមត្ថភាព ដោយគូររូបនៅលើក្តារខៀន ឬចែកសន្លឹកកិច្ចការឱ្យសិស្សម្នាក់មួយច្បាប់។ អ្នកទាំងអស់គ្នាមានសមត្ថភាពជាច្រើន តែយើងមិនប្រាកដថាអ្នកបានដឹងនោះទេ។ ឧទាហរណ៍ របៀបបែងចែកសមត្ថភាពផ្សេងៗគ្នា៖

**ការជំរុញទឹកចិត្ត គុណតម្លៃ និងចំណាប់អារម្មណ៍របស់ខ្ញុំ = គោលដៅក្នុងជីវិត**

**ជំនាញវិជ្ជាជីវៈ**
- ការអប់រំ
- សញ្ញាបត្រ និងវិញ្ញាបនបត្រ
- បទពិសោធការងារ

**សមត្ថភាពបន្ទាប់បន្សំ**
- បរិស្ថានប្រតិបត្តិ
- លក្ខណៈទូទៅរបស់សាខា

**ជំនាញទូទៅ**
- ជំនាញភាសា
- ជំនាញកុំព្យូទ័រ
- ជំនាញសង្គម
- ជំនាញដោះស្រាយបញ្ហា
- ជំនាញទំនាក់ទំនង

**គុណភាពផ្ទាល់ខ្លួន**
- ត្រៀមរួចរាល់សម្រាប់ការផ្លាស់ប្តូរ
- ត្រៀមរួចរាល់សម្រាប់ការរៀនសូត្រ
- អាកប្បកិរិយា
- គួរឱ្យជឿជាក់បាន

**បទពិសោធន៍**
- បទពិសោធន៍ជីវិត
- ចំណង់ចំណូលចិត្ត
- សេវាសហគមន៍
- ស្ម័គ្រចិត្ត

**ទំនាក់ទំនង**
- បណ្តាញ
- មិត្តភ័ក្ត
- សាច់ញាតិ

## សន្លឹកកិច្ចការ

ឱ្យសិស្សបំពេញនូវសមត្ថភាពទាំងអស់ដែលពួកគេមាន។ ពួកគេអាចទទួលបានដោយបទពិសោធន៍ការងារ ការអប់រំ ចំណង់ចំណូលចិត្ត ឬបទពិសោធន៍ជីវិតផ្សេងទៀត។ សិស្សអាចធ្វើការងារម្នាក់ឯង ឬជាគូ ឬជាក្រុមដែលមានគ្នា ៣នាក់។ គ្រូអាចចំណាយពេលមេរៀនទាំងមូលសម្រាប់សកម្មភាពនេះ ព្រោះបង្កើតគំនិតសម្រាប់លំហាត់នេះ ពេលខ្លះមានការពិបាកសម្រាប់សិស្ស។



# មេរៀនទី ៣៣ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ២

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សឱ្យយល់ដឹងស៊ីជម្រៅពីចំណុចខ្លាំងរបស់គេ តាមរយៈការមើលឃើញរបស់អ្នកដទៃ

## សកម្មភាពសិស្ស

ស្វែងរកជំនាញរបស់ខ្ញុំតាមរយៈក្រសែភ្នែករបស់អ្នកដទៃ។ ឱ្យសិស្សធ្វើផ្នែកខ្លះនៃលំហាត់នេះ (សម្ភាស មិត្តភក្តិ) នៅថ្នាក់រៀន និងនៅផ្ទះ (សម្ភាសឪពុកម្តាយ និងជីដូនជីតា)។

## សន្លឹកកិច្ចការ

សម្ភាសឪពុកម្តាយ ជីដូនជីតា និងមិត្តភក្តិរបស់អ្នក។ សួរពួកគេនូវសំណួរខាងក្រោម៖ ក) តើខ្ញុំជាមនុស្សប្រភេទណា? ខ)តើខ្ញុំពូកែអ្វីខ្លះ? គ) តើអ្នកមើលឃើញថាខ្ញុំគួរតែមានមុខរបរ ឬអាជីពអ្វីនាពេលអនាគត?










(*សកម្មភាពនេះត្រូវបានកែសម្រួលចេញពីលំហាត់ដែលបានបង្កើតឡើងដោយHiekkataipale et al., ២០១៣*)

តើអ្នកមានអារម្មណ៍បែបណានៅពេលដែលបានសម្ភាសសមាជិកគ្រួសារ និងមិត្តភក្តិរបស់អ្នក?

________________________________________

________________________________________

តើចម្លើយរបស់ពួកគេធ្វើឱ្យអ្នកភ្ញាក់ផ្អើលទេ?

_______________________________________________

_______________________________________________

តើអ្នកបានដឹងអ្វីថ្មីអំពីចំណុចខ្លាំងរបស់អ្នកទេ?

_______________________________________________

_______________________________________________



### សន្លឹកកិច្ចការ ២៖ ជំនាញ និងចំណុចខ្លាំង

មើលឃើញចំណុចខ្លាំងរបស់ខ្ញុំតាមរយៈក្រសែភ្នែកអ្នកដទៃ។

ទូរសព្ទទៅរកមនុស្សពីរនាក់ដែលស្គាល់អ្នកច្បាស់ (ម្តាយរបស់អ្នក ឪពុក មិត្តភក្តិ...)។ សួរពួកគេនូវសំណួរខាងក្រោម៖

១) នៅពេលណាដែលខ្ញុំជោគជ័យ? តើអ្វីដែលខ្ញុំធ្វើបានល្អជាងគេ?

២) ហេតុអ្វីបានជាខ្ញុំជោគជ័យ? តើជំនាញ និងចរិកលក្ខណៈប្រភេទណាដែលជួយខ្ញុំឱ្យបានជោគជ័យ?

៣) តើអ្នកអាចឱ្យយោបល់ត្រលប់វិជ្ជមានផ្សេងទៀតបានទេ?





# មេរៀនទី ៣៤ ជំនាញ និងចំណុចខ្លាំងរបស់ខ្ញុំ ៣

នេះគឺជាមេរៀនចុងក្រោយនៃការកំណត់ពីចំណុចខ្លាំងរបស់សិស្ស។ មេរៀនដំបូង សិស្សធ្វើការប៉ាន់ស្មានដោយខ្លួនឯង បន្ទាប់មកពួកគេសួរយោបល់ឪពុកម្ដាយ និងមិត្តភក្តិ និងចុងក្រោយនេះ ពួកគេនឹងអាចស្វែងយល់បានដោយធ្វើតេស្ត។ វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សឱ្យយល់ដឹងស៊ីជម្រៅក្នុងការកំណត់រកចំណុចខ្លាំង។

## សកម្មភាពសិស្ស

ចំណុចខ្លាំងគឺជាភាពឈ្លាសវៃរបស់មនុស្សម្នាក់ៗ។ Howard Gardner នៃសកលវិទ្យាល័យ ហាវើដ បានកំណត់នូវភាពឈ្លាសវៃចំនួន ៧ប្រភេទ។ សិស្សរៀនចងចាំ អនុវត្ត និងយល់តាមរបៀបខុសៗគ្នា។ វិធីសាស្ត្រក្នុងការរៀនជាច្រើនត្រូវបានណែនាំ ក្នុងការជំរុញការរៀនសូត្រប្រកបដោយលទ្ធផល (Gardner, H. 1991)។ តេស្តខាងក្រោម នឹងជួយឱ្យសិស្សអាចវាយតម្លៃភាពឈ្លាសវៃ ចំណុចខ្លាំង និងវិធីសាស្ត្ររៀនរបស់ពួកគេ។ អ្នកត្រូវណែនាំឱ្យពួកគេមានការប្រុងប្រយ័ត្ននៅពេលដែលពួកគេធ្វើការបកស្រាយលទ្ធផលតេស្ត ពីព្រោះការសរុបជាលក្ខណៈសន្និដ្ឋាន មិនអាចផ្អែកលើតេស្តតែមួយមុខនេះទេ។



**សន្លឹកកិច្ចការ** តេស្តពហុបញ្ញា *Multiple Intelligences Test* (ដោយផ្អែកលើគំរូរបស់Howard Gardner's MI, ១៩៩១)

**១) តេស្តទម្រង់នៃបញ្ញារបស់អ្នក។** ដាក់ពិន្ទុលើប្រយោគខាងក្រោម (ដាក់ពិន្ទុនៅក្នុងប្រអប់ពណ៌ស)៖

១ = មិនយល់ស្របភាគច្រើន ២ = មិនយល់ស្របតិចតួច ៣ = យល់ស្របតិចតួច ៤= យល់ស្របភាគច្រើន

| ល្បះ | ពិន្ទុ | | | | | | |
|---|---|---|---|---|---|---|---|
| ខ្ញុំអាចលេងឧបករណ៍តន្ត្រី | | | | | | | |
| ខ្ញុំតែងតែមានបទចម្រៀង ឬផ្នែកមួយនៃតន្ត្រីក្នុងខួរក្បាលរបស់ខ្ញុំ | | | | | | | |
| ខ្ញុំអាចបង្កើតសាច់រឿងដោយងាយស្រួល | | | | | | | |
| ខ្ញុំតែងតែអាចបញ្ជារាងកាយបានដោយល្អ (រត់ លោត លំនឹង....) | | | | | | | |
| តន្ត្រីមានសារៈសំខាន់ណាស់ចំពោះខ្ញុំ | | | | | | | |
| ខ្ញុំពូកែកុហកណាស់ (ប្រសិនបើខ្ញុំចង់) | | | | | | | |
| ខ្ញុំលេងកីឡា ឬរាំ | | | | | | | |
| ខ្ញុំគឺជាមនុស្សម្នាក់ដែលរួសរាយ និងចូលចិត្តនៅជាមួយអ្នកដទៃ | | | | | | | |
| ខ្ញុំងាយយល់ក្រាហ្វ តារាង និងដ្យាក្រាម | | | | | | | |
| ខ្ញុំងាយចងចាំពាក្យស្លោក ឃ្លាល្បះ កំណាព្យ ឬប៉ារូលបទចម្រៀង | | | | | | | |
| ខ្ញុំតែងតែអាចស្គាល់ទីកន្លែងដែលខ្ញុំធ្លាប់បានទៅ | | | | | | | |
| នៅពេលដែលខ្ញុំផ្តោតអារម្មណ៍ ខ្ញុំចេះតែចង់គូសវាសគំនូរ | | | | | | | |
| ខ្ញុំមានភាពងាយស្រួលក្នុងការធ្វើលេខនព្វន្ត (បូកលេខក្នុងខួរក្បាល) | | | | | | | |
| នៅសាលា ក្នុងចំណោមមុខវិជ្ជាដែលខ្ញុំចូលចិត្តគឺភាសាខ្មែរ | | | | | | | |
| ខ្ញុំគិតអំពីបញ្ហាដោយប្រុងប្រយ័ត្ន ដោយពិចារណានូវរាល់ផលវិបាកទាំងឡាយ | | | | | | | |
| ខ្ញុំស្រឡាញ់កីឡាដែលប្រថុយគ្រោះថ្នាក់ខ្លាំង និងការជិះដែលគួរឱ្យខ្លាច | | | | | | | |
| ខ្ញុំចូលចិត្តកីឡាអត្តពលិកជាងគេ | | | | | | | |
| ខ្ញុំងាយចងចាំលេខទូរស័ព្ទ | | | | | | | |
| ខ្ញុំកំណត់គោលដៅ និងផែនការទៅអនាគតរបស់ខ្ញុំ | | | | | | | |
| ខ្ញុំអាចប្រាប់បានដោយងាយស្រួលថានរណាចូលចិត្ត ឬមិនចូលចិត្តខ្ញុំ | | | | | | | |
| ដើម្បីរៀនជិះអ្វីដែលថ្មី ខ្ញុំគ្រាន់តែត្រូវការឡើងជិះ និងសាកល្បងវា | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ខ្ញុំតែងតែមើលឃើញរូបភាពច្បាស់លាស់ នៅពេលដែលខ្ញុំបិទភ្នែក | | | | | | | |
| ខ្ញុំមិនប្រើម្រាមដៃរបស់ខ្ញុំទេ នៅពេលដែលខ្ញុំរាប់លេខ | | | | | | | |
| នៅសាលា ខ្ញុំស្រឡាញ់មេរៀនតន្ត្រី | | | | | | | |
| ខ្ញុំងាយស្រួលក្នុងការលេងល្បែងបាល់ និងរីករាយក្នុងការលេងវា | | | | | | | |
| មុខវិជ្ជាដែលខ្ញុំចូលចិត្តនៅសាលាគឺ គណិតវិទ្យា | | | | | | | |
| ខ្ញុំតែងតែដឹងថា ខ្ញុំមាននូវអារម្មណ៍បែបណា | | | | | | | |
| ខ្ញុំទុកសៀវភៅកំណត់ហេតុ | | | | | | | |
| មុខវិជ្ជាដែលខ្ញុំចូលចិត្តនៅសាលាគឺ សិល្បៈ | | | | | | | |
| ខ្ញុំពិតជាចូលចិត្តការអាន | | | | | | | |
| វាធ្វើឱ្យខ្ញុំមិនសប្បាយចិត្តនៅពេលដែលឃើញនរណាម្នាក់យំ និងមិនអាចជួយអ្វីបាន | | | | | | | |
| ខ្ញុំចូលចិត្តកីឡាដែលលេងជាក្រុម | | | | | | | |
| ការច្រៀងធ្វើឱ្យខ្ញុំសប្បាយចិត្ត | | | | | | | |
| ខ្ញុំរីករាយក្នុងការចំណាយពេលម្នាក់ឯង | | | | | | | |
| មិត្តភក្តិរបស់ខ្ញុំតែងតែមករកឱ្យខ្ញុំជួយផ្តល់ដំបូន្មាន និងគាំទ្រផ្នែកសតិអារម្មណ៍ | | | | | | | |
| **សរុប** | | | | | | | |

## ២) បូកសរុបតាមប្រអប់នីមួយៗ។

| ទម្រង់ការឈ្លាសវៃ / របៀបរៀន | ពិន្ទុសរុបរបស់អ្នក | | | | | | |
|---|---|---|---|---|---|---|---|
| ភាសា | | | | | | | |
| តក្ក-គណិតវិទ្យា | | | | | | | |
| តន្ត្រី | | | | | | | |
| កាយសម្ព័ន្ធ | | | | | | | |
| រូបភាពក្នុងលំហរ | | | | | | | |
| ការប្រាស្រ័យទាក់ទងអន្តរបុគ្គល | | | | | | | |
| ការប្រាស្រ័យទាក់ទងខាងក្នុង | | | | | | | |

*(តេស្តនេះ គឺត្រូវបានកែសម្រួលចេញពីតេស្តនៅឯគេហទំព័រ Businessballs.com)*

ពិន្ទុដែលខ្ពស់ជាងគេ បង្ហាញអំពីចំណុចខ្លាំងពីធម្មជាតិ សក្ដានុពល ភាពឈ្លាសវៃពីធម្មជាតិរបស់អ្នក !

## សម្រាប់អ្នកប្រឹក្សាអាជីព

ព័ត៌មានសារតាសម្រាប់ការចែករំលែកជាមួយសិស្ស។ ទម្រង់ផ្សេងៗនៃបញ្ញា មានបង្ហាញដូចខាងក្រោម៖

**ភាសាវិទ្យា៖** ពាក្យថា អ្នករៀនភាសាឆ្លាត បានអភិវឌ្ឍយ៉ាងខ្លាំងក្លានូវជំនាញត្រួតពិនិត្យ។ មនុស្ស ទាំងនេះប្រើប្រាស់ពាក្យយ៉ាងមានប្រសិទ្ធភាព ហើយតែងតែគិតពីអ្វីមួយចេញជាពាក្យ ជាជាងគិតអ្វីមួយចេញជារូបភាព។ អ្នករៀនភាសាវិទ្យា ជាប្រភេទមនុស្សដែលស្ងប់ និងមានហេតុផល ព្រមទាំងជាអ្នកដែលពូកែស្ដាប់គេនិយាយផងដែរ។ ពេលខ្លះពួកគេចូលចិត្តគិតអ្វីៗ និងអាចចូលចិត្តការលេងល្បែងល្បងប្រាជ្ញាដាក់ពាក្យ ឬល្បែងផ្គុំរូប។ អ្នករៀនភាសាវិទ្យាគឺជាអ្នកដែលមានភាពប៉ិនប្រសប់ក្នុងការរៀបរាប់ និងពន្យល់បង្ហាញអំពីបញ្ហាអ្វីមួយ ហើយពួកគេចូលចិត្តការអាន ការលេងការល្បែងប្រាជ្ញាដាក់ពាក្យ ការសរសេរ និងការបង្កើតសាច់រឿងផ្សេងៗ។ ការណែនាំសម្រាប់វិធីសាស្ត្ររៀន និងជំនួយនានាមានដូចជា ការអានសៀវភៅជុំគ្នា ការពិភាក្សា ការជជែកវែកញែក ការប្រើប្រាស់កុំព្យូទ័រ ការលេងហ្គេម ការប្រើប្រាស់ពហុព័ត៌មាន(multimedia) និងការធ្វើសុន្ទរកថាជាដើម។

**អាជីពដែលសក្ដិសម៖** អ្នកកាសែត បណ្ណារក្ស អ្នកធ្វើអត្ថាធិប្បាយ អ្នកធ្វើការរដ្ឋបាល អ្នកធ្វើការផ្នែកលក់ អ្នកប្រឹក្សាយោបល់ មេធាវី អ្នកតែងកំណាព្យ អ្នកនិពន្ធ អ្នកកែសម្រួលទស្សនាវដ្ដី ទីប្រឹក្សាខាងផ្សព្វផ្សាយ ពិធីករវិទ្យុ/ទូរទស្សន៍ អ្នកបកប្រែ ឬគ្រូបង្រៀន។

**គណិតសាស្ត្រ៖** ពាក្យថាអ្នករៀនគណិតវិទ្យាឆ្លាត ឬអ្នករៀនលេខឆ្លាត កើតចេញពីវិធីសិក្សារកហេតុផលចេញពីភាពទូទៅឆ្ពោះទៅភាពជាក់លាក់ គិតអ្វីមានលក្ខណៈអរូបី និងមានលទ្ធភាពរកឃើញពីគំរូនិងទំនាក់ទំនងអំពីអ្វីមួយ។ បញ្ញាពួកគេភាគច្រើនផ្សារភ្ជាប់ជាមួយវិទ្យាសាស្ត្រ និងការគិតបែបលេខនព្វន្ត។ អ្នករៀនគណិតវិទ្យាចូលចិត្តទុកដាក់របស់របរឱ្យស្អាត និងមានសណ្ដាប់ធ្នាប់ព្រមទាំង ចូលចិត្តកត់ត្រាចាំណាំអំពីជំហាននីមួយៗ មុនពេលគេធ្វើអ្វីមួយនៅពេលណាមួយ។ នេះមានន័យថាពួកគេគិតគូរពីលទ្ធផលតាមលំដាប់លំដោយ មុនពេលចាប់ផ្ដើមប្រើប្រាស់វិធីសាស្ត្រណាមួយ ដើម្បី អនុវត្ត។ មនុស្សប្រភេទនេះពូកែខាងស្វែងយល់ពីរបៀបដែលអ្វីមួយអាចធ្វើទៅបាន និងមានការគិតគូរបានល្អិតល្អន់។

**អ្នករៀនគណិតវិទ្យា៖** ឆ្លាតគឺសួរសំណួរច្រើន ហើយពួកគេពូកែខាងដោះស្រាយល្បែងរូបផ្គុំ។ ការបង្រៀនពួកគេអាចធ្វើឡើងតាមរយៈល្បែងដែលមានលក្ខណៈតក្កវិទ្យា ការស៊ើបអង្កេត និងការស្វែរកអាថ៌កំបាំង។ ពួកគេត្រូវការរៀនអំពីគំនិតនានា និងប្រមូលផ្ដុំគំនិត មុនពេលពួកគេដោះស្រាយបញ្ហាអ្វីមួយជាក់លាក់។

**អាជីពដែលសក្ដិសម៖** គណនេយ្យករ អ្នកស្ថិតិ អ្នកត្រួតពិនិត្យចរាចរជើងអាកាស អវកាសយានិក អ្នកស្រាវជ្រាវ អ្នកសរសេរកម្មវិធីកុំព្យូទ័រ អ្នកបង្កើតកម្មវិធីហ្គេមកុំព្យូទ័រ វិស្វករ ប៉ូលីសស៊ើបអង្កេត អ្នកវិទ្យាសាស្ត្រ ឬអ្នកធ្វើការធនាគារ។

**ដូរ្យតន្ត្រី៖** អ្នកឆ្លាតខាងដូរ្យតន្ត្រី ស្រឡាញ់តន្ត្រី និងមានភាពផ្សារភ្ជាប់ជាមួយសំឡេងនៅក្នុងបរិស្ថានរបស់ពួកគេ។ ពួកគេចូលចិត្តប្រភេទតន្ត្រីខុសៗគ្នា និងចូលចិត្តជ្រើសរើសការស្តាប់ប្រភេទតន្ត្រីមួយណាដោយផ្អែកលើអារម្មណ៍របស់ពួកគេ។ ពួកគេក៏ប្រហែលជាអាចសរសេរបទចម្រៀងដោយខ្លួនឯងបានផងដែរ។ ជារឿយៗ ពួកគេចូលចិត្តបញ្ចេញសំឡេងតិចៗ ហួច ឬក៏ច្រៀងតែម្តង។ អ្នកមានបញ្ញាដូរ្យតន្ត្រី អាចរៀនបានល្អបើមានតន្ត្រីនៅជាមួយពួកគេ ហើយពួកគេអាចចងចាំបានល្អតាមរយៈការធ្វើអ្វីមួយឡើងវិញតាមចង្វាក់ភ្លេង។ ការបង្រៀនពួកគេ អាចធ្វើឡើងតាមរយៈការបង្វែរមេរៀនឱ្យទៅជាកាព្យ ការនិយាយជាចង្វាក់ និងការបញ្ជាក់ការចងចាំពេលវេលា។ ការណែនាំសម្រាប់ជំនួយក្នុងការរៀនរួមមាន ឧបករណ៍តន្ត្រី ភ្លេង វិទ្យុ ឧបករណ៍ចាក់ភ្លេងផ្សេងៗ និងពហុព័ត៌មានផ្សេងៗ។

**អាជីពដែលសក្តិសម៖** តន្ត្រីករ អ្នកចម្រៀង អ្នកនិពន្ធបទចម្រៀង អ្នកសម្តែង គ្រូបង្រៀនដូរ្យតន្ត្រី អ្នកបង្កើតឧបករណ៍តន្ត្រី អ្នកដឹកនាំក្រុមភ្លេង អ្នកវិភាគភ្លេង អ្នកតែងភ្លេង ឌីជេ អ្នករចនាវីដេអូ/កុន អ្នកសម្តែង និងអ្នករៀបចំកម្មវិធីជប់លៀង។

**កាយសម្ព័ន្ធ៖** អ្នករៀនកាយសម្ព័ន្ធឆ្លាត គឺប្រើប្រាស់រាងកាយរបស់ខ្លួនឯងធ្វើចលនាបានយ៉ាងមានប្រសិទ្ធភាពដូចជា អ្នករាំ ឬគ្រូពេទ្យវះកាត់។ អ្នករៀនកាយសម្ព័ន្ធមានអំណោយផលផ្នែករាងកាយរបស់ពួកគេដូចជាបទពិសោធនៃការប៉ះពាល់ មានអារម្មណ៍ ចាប់កាន់ និងធ្វើអ្វីមួយ ក៏ដូចជាទទួលបាននូវបទពិសោធន៍ជាក់ស្តែង។ ពួកគេមានភាពប៉ិនប្រសប់ខាងកីឡា សម្តែងកាយសម្ព័ន្ធ ឬរាំ។ ពួកគេក៏ មានភាពប៉ិនប្រសប់យ៉ាងខ្លាំងក្នុងការប្រើប្រាស់ដៃ ភ្នែក ឱ្យស៊ីសង្វាក់គ្នា និងលេងហ្គេមបាល់ ឬធ្វើឱ្យមានលំនឹងខ្លួនយ៉ាងងាយស្រួលផងដែរ។ អ្នករៀនកាយ សម្ព័ន្ធ អាចមានការលំបាកក្នុងការផ្ចង់អារម្មណ៍ពេលរៀននៅសាលា ហើយអាចនិយាយបានថា ពួកគេមិនសូវមានភាពអត់ធ្មត់។ វិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពគឺ ការបញ្ចូលសកម្មភាពដែលប្រើប្រាស់រាងកាយ ការរៀនដោយមានសកម្មភាព និងការរៀនដែលទាក់ទាញដូចជារៀនធ្វើ និងការសម្តែងជាដើម។



**អាជីពដែលសក្តិសម៖** ជាងម៉ាស៊ីន សិល្បៈករ គ្រូបង្វឹក អ្នកហាត្ថពលកម្មអាជីព អ្នកវិភាគកីឡា អ្នកកីឡាកាយសម្ព័ន្ធ អ្នករាំ ឬអ្នកបង្កើតក្បាច់រាំ ជាងសំណង់ ជាងកាត់សក់ អង្គរក្ស អ្នកម៉ាស្សា ទន្តពេទ្យ គ្រូពេទ្យវះកាត់ តារាសម្តែង ទាហាន អ្នកពន្លត់អគ្គីភ័យ អ្នកបើកបរ អ្នកថែសួន ឬចុងភៅ។

**រូបភាពក្នុងលំហរ (Visual-Spatial)៖** អ្នករៀនឆ្លាតខាងរូបភាពគឺគិតអំពីរូបរាងក្នុងលំហរ ដូចជាវិស្វករ និងនាវិក។ ពួកគេពិតជាមានការយល់ដឹងច្រើនអំពីបរិស្ថានរបស់ពួកគេ ហើយពួកគេចូលចិត្តគូររូប លេងផ្គុំរូប មើលផែនទី និងមានភាពរវើរវាយ។ ពួកគេមានការស្រមើស្រមៃរស់រវើក និងតែងតែចងចាំអ្វីមួយតាមរយៈការមើលឃើញរូបភាពនៅក្នុងខួរក្បាលរបស់ពួកគេ ឬបង្កើតរូបភាពចេញពីចិត្តរបស់ពួកគេ។ ពួកគេអាចចូលចិត្តមើលរូបភាព និងដ្យាក្រាមនៅក្នុងសៀវភៅ មុនពេលពួកគេចាប់ផ្តើមអានវា ហើយពួកគេក៏ចូលចិត្តស្រមើស្រមៃបែបស្រ៊ីឌីផងដែរ។

របៀបនៃការរៀន Visual-Spacial ពាក់ព័ន្ធនឹងការប្រើប្រាស់ចក្ខុ ឬការសង្កេតទៅលើវត្ថុផ្សេងៗ។ ការណែនាំសម្រាប់វិធីសាស្ត្រ និងជំនួយផ្សេងៗ ក្នុងការរៀនមានដូចជា គំរូនៃវត្ថុអ្វីមួយ ការធ្វើបង្ហាញ ឧបករណ៍បង្ហាញ រូបថត គំនូរ ម៉ូដែលស្រ៊ីឌី ខ្សែភាពយន្ត វីដេអូ ពហុព័ត៌មាន និងអក្សរជាមួយរូបភាព គំនូសតាង ឬក្រាប។

**អាជីពដែលសក្តិសម៖** អ្នករចនារូបភាព អ្នកបង្កើតគេហទំព័រ សិល្បៈករ មគ្គុទ្ទេសក៍ទេសចរ អ្នក ផលិតផែនទី អ្នកថតរូប អ្នកដឹកនាំរឿង អ្នករចនាប្លង់ខាងក្នុង ជាងគំនូរ អ្នកថ្នៃម៉ូត អ្នកប្រឹក្សាខាងសម្លៀកបំពាក់ ជាងសំណង់ នាវិក ស្ថាបត្យករ គ្រូពេទ្យវះកាត់ អាកាសយានិក អ្នកជំនាញខាងទេសភាព អ្នកសរសេរផែនការទីក្រុង និងវិស្វករ។

**ការប្រាស្រ័យទាក់ទងអន្តរបុគ្គល៖** មនុស្សឆ្លាត រីករាយជាមួយការងារ ការរៀនសូត្រ ការជួយអ្នកដទៃ និងធ្វើជាមិត្តរបស់មនុស្សជុំវិញខ្លួន។ ពួកគេជាមនុស្សដែលមានមិត្តភក្តិច្រើន និងចេះយល់ចិត្តអ្នកដទៃ។ ការប្រាស្រ័យទាក់ទង គឺផ្សារភ្ជាប់ជាមួយសមត្ថភាពក្នុងការយល់ដឹងអំពី ចេតនា ការលើកទឹកចិត្ត និងតម្រូវការរបស់អ្នកដទៃ។ ពួកគេមានការយកចិត្តទុកដាក់ខ្លាំងចំពោះអ្នកដទៃ ហើយមនុស្សម្នាតែងតែទៅរកពួកគេដើម្បីសុំការជួយ ឬក៏សុំការណែនាំ។ ពួកគេក៏ជាអ្នកដែលមានភាពសាមញ្ញជាមួយជីវិតរបស់ខ្លួនឯង និងពូកែខាងដោះស្រាយជម្លោះរវាងមិត្តភក្តិ រីករាយក្នុងការធ្វើការងារជាក្រុម ចូលចិត្តធ្វើការចែករំលែក និងពូកែសង្កេតខាងភាសាកាយវិការ។



អ្នករៀនខាងការប្រាស្រ័យទាក់ទងអន្តរបុគ្គលទទួលផលប្រយោជន៍តាមរយៈការមើលឃើញអ្វីមួយចេញពីទស្សនៈអ្នកដទៃ ហើយរៀនតាមរយៈការធ្វើអន្តរសកម្មភាព។ ការបង្រៀនពួកគេអាចធ្វើឡើងតាមរយៈសកម្មភាពក្រុម សិក្ខាសាលា និងកិច្ចសន្ទនា។ ពួកគេជាអ្នកដែលត្រូវការពេលវេលា និងការយកចិត្តទុកដាក់ពីអ្នកបង្រៀនពួកគេ។

**អាជីពដែលសក្តិសម៖** គ្រូបង្រៀន អ្នកសម្តែង អ្នកព្យាបាលដោយទ្រឹស្តី គ្រូពេទ្យចិត្តវិកលវិទ្យា អ្នកកាន់ការផ្នែកលក់ អ្នកគ្រប់គ្រង អ្នកសម្ភាស អ្នកនយោបាយ ប៉ូលីស អ្នកធ្វើការងារសង្គម វេជ្ជបណ្ឌិត ឬគិលានុប្បដ្ឋាកយិកា ទីប្រឹក្សា អ្នកប្រឹក្សាយោបល់ អ្នកជំនួញ ភ្នាក់ងារទេសចរណ៍ អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកបម្រើ អ្នកផ្តល់សេវាផ្សាយពាណិជ្ជកម្មអាជីព គ្រូបង្វឹក ឬគ្រូជំនួយ។

**ការប្រាស្រ័យទាក់ទងខាងក្នុង** (Intrapersonal) ៖ មនុស្សឆ្លាតដោយខ្លួនឯងមានន័យថាមានការផុសគំនិតកើតចេញពីអារម្មណ៍ខាងក្នុង។ មនុស្សប្រភេទនេះ មានប្រាជ្ញា វិចារណញ្ញាណ និងការជំរុញទឹកចិត្ត ព្រមទាំងមានឆន្ទៈខ្ពស់ មានភាពជឿជាក់ និងមានទស្សនៈផ្ទាល់របស់ខ្លួនឯង។ មនុស្សដែលមានការប្រាស្រ័យទាក់ទងខាងក្នុង មានការប្តេជ្ញា ឯករាជ្យភាព និងអាចធ្វើការបានល្អជាមួយនឹងគោលបំណង និងពេលកំណត់របស់ខ្លួន។ ពេលខ្លះពួកគេជាមនុស្សដែលមានភាពខ្មាសអៀនចំពោះអ្នកដទៃ ហើយចូលចិត្តធ្វើការម្នាក់ឯង និងស្ងៀមស្ងាត់។ ពួកគេជាមនុស្សដែលមានគំនិតល្អប្រសើរចំពោះភាពខ្លាំង និងភាពខ្សោយ ក៏ដូចជាជម្រើសការងាររបស់ខ្លួនឯង។ ពួកគេអាច

ចាប់អារម្មណ៍នឹងសាសនា ឬប្រើប្រាស់សិល្បៈ ភាពយន្ត តន្ត្រី ឬការសរសេរកំណត់ហេតុប្រចាំថ្ងៃក្នុងការរៀបរាប់ពី អារម្មណ៍ខាងក្នុងរបស់ពួកគេ។

អ្នករៀនអំពីការប្រាស្រ័យទាក់ទងខាងក្នុង អាចធ្វើឡើងតាមរយៈការរៀនដោយឯករាជ្យ និងការត្រិះរិះពិចារណាដោយខ្លួនឯង។ ពួកគេគឺជាអ្នករៀនដែលមានភាពឯករាជ្យខ្ពស់បំផុត។ ការណែនាំសម្រាប់វិធីសាស្រ្ត និងជំនួយសម្រាប់រៀនរួមមាន សៀវភៅ សម្ភារៈដែលមានភាពច្នៃប្រឌិត កំណត់ហេតុមានភាពឯកជន និងពេលវេលា។

**អាជីពដែលសក្តិសមៈ** អ្នកសម្តែង សិល្បៈករ ម្ចាស់ជំនួញខ្នាតតូច អ្នកយកការណ៍ អ្នកដឹកនាំរឿង អ្នកប្រឹក្សាយោបល់ អ្នកធ្វើការសង្គម ទស្សនវិទូ អ្នករៀបគម្រោង អ្នកស្រាវជ្រាវ អ្នកចិត្តសាស្រ្ត អ្នកបណ្តុះបណ្តាលផ្ទាល់ខ្លួន ឬអ្នកនិពន្ធ។

ឱ្យសិស្សយកសៀវភៅ និងកំណត់ហេតុសិក្សារបស់ពួកគេមកសម្រាប់មេរៀនបន្ទាប់។

## មេរៀនទី ៣៥  ការវិភាគពីភាពជោគជ័យ និងការខាតល្អ

ពេលនេះអ្នកឈានជិតដល់ចុងបញ្ចប់ការសិក្សាឆ្នាំទី១ នៃមធ្យមសិក្សាទុតិយភូមិ។ យើងកំពុងតែងាកមកធ្វើការវិភាគភាពជោគជ័យ និងវាយតម្លៃការសិក្សាឆ្នាំទី១ នៃមេរៀនមគ្គុទ្ទេសក៍ និងការប្រឹក្សាអាជីព។

### *សកម្មភាពសិស្ស*

### *ជំហានទី ១*

ឱ្យសិស្សអាន និងកត់ត្រាទុកនូវអ្វីដែលពួកគេបានឆ្លងកាត់ ឬរៀនសូត្រ ចូលទៅក្នុងសៀវភៅកត់ត្រា និងកំណត់ហេតុសិក្សា ដើម្បីឱ្យមានការចងចាំសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងមេរៀន ប្រឹក្សាយោបល់ និងមគ្គុទ្ទេសក៍អាជីពនៃឆ្នាំសិក្សានេះ។

### *ជំហានទី២*

**ការពិភាក្សាក្រុម៖** តើអ្វីដែលសិស្សអាចធ្វើបានជោគជ័យខ្លាំងបំផុតនៅក្នុងឆ្នាំនេះ? តើអ្វីដែលបានកើតឡើងក្នុងភាពជោគជ័យនេះ? តើមានផលវិជ្ជមាន និងឥទ្ធិពលអ្វីខ្លះចំពោះភាពជោគជ័យនេះ? អ្នកអាចរៀបចំផែនទីគំនិតធំមួយទាំងអស់គ្នា អំពីប្រធានបទថា តើហេតុអ្វីបានជាទទួលបានភាពជោគជ័យ? តើអ្នកណាខ្លះបានចូលរួមចំណែកក្នុងភាពជោគជ័យនេះ ហើយពួកគេចូលរួមតាមវិធីណា? តើអ្នកណាខ្លះទៀត បានចូលរួមចំណែក? តើភាពជោគជ័យនេះ វាកើតចេញពីកត្តាអ្វីខ្លះ? សូមផ្តោតសំខាន់ទៅលើកត្តានានា និងអ្នកដែលបានជួយអ្នកឱ្យបានមកដល់ភាពជោគជ័យនេះ។ បើអ្នកមានការបង្ហាញអំពីការពេញចិត្ត និងការអគុណកាន់តែច្រើន កាន់តែល្អ។ លើសពីនេះ ព្យាយាមពិចារណាអំពីអ្វីដែលជាចំណុចខ្លាំង និងធនធានដែលអ្នកបានប្រើប្រាស់សម្រាប់ឈានមកដល់ភាពជោគជ័យ។ គិតអំពីបណ្តាញផ្សេងៗ ឬអ្នកក្រៅផ្សេងទៀតដែលបានជួយអ្នកឱ្យធ្វើបានជោគជ័យដូចនេះ។



អ្នកអាចប្រើប្រាស់មេរៀនទាំងមូលសម្រាប់ការពិភាក្សាបាន ដោយសារវាជាកិច្ចការធំមួយដែលរំឭកការចងចាំ និងចែករំលែកទាំងអស់គ្នា។ ព្យាយាមចងចាំព័ត៌មានលំអិតតាមដែលអាចធ្វើបាន រួចសរសេរវានៅលើផែនទីគំនិត។

### *ជំហានទី៣*

**សូមបន្តការពិភាក្សាដោយដាក់សំណួរឱ្យសិស្ស៖** តើអ្នកនឹងធ្វើការជាមួយគ្នាដូចម្តេចសម្រាប់ថ្នាក់ថ្មីបន្ទាប់ទៀត ដើម្បីប្រាកដថាភាពជោគជ័យសម្រាប់ទាំងអស់គ្នានឹងកើតមានម្តងទៀតនៅថ្នាក់ទី១១?

*ដកស្រង់ចេញពី Furman ២០០៩*

# មេរៀនទី ៣៦ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ទី១០ ឬឆ្នាំទី ១

## សកម្មភាពសិស្សទី១៖ បង្កើតគំនូរជីវចលរួមគ្នា

បែងចែកសិស្សជា ៥ ក្រុម ហើយចែកក្រដាសផ្ទាំងធំមួយក្រុម ១ សន្លឹក។ អ្នកគួរតែគូររូបប្រអប់ធំចំនួន ៥ ទៅលើក្រដាសទុកជាមុន។ អ្នកអាចចែកក្រដាសចំនួន ៥ សន្លឹកដែលមានបង់លំដាប់លេខរៀងឱ្យសិស្សក្នុងក្រុមនីមួយៗ ដោយក្រដាសនីមួយៗគឺត្រូវមានទំហំប៉ុននឹងប្រអប់គំនូរជីវចលមួយ។ វត្ថុបំណងគឺ ឱ្យសិស្សបង្កើតគំនូរជីវចលក្នុងប្រអប់ចំនួន ៥ ហើយគោលបំណងនៃគំនូរជីវចលនេះគឺជាសាច់រឿងពាក់ព័ន្ធនឹងការសិក្សារបស់ពួកគេក្នុងសប្តាហ៍ចុងក្រោយនៃថ្នាក់ទី១០។



ក្រុមនីមួយៗ មានរយៈពេល ៥ នាទី ដើម្បីគូររូបនៅលើក្រដាសសន្លឹកទី១ ដោយផ្តើមឡើងនូវសាច់រឿងខាងដើមដូចៗគ្នា។ បន្ទាប់មក ពួកគេត្រូវបន្តគូរសាច់រឿងនៅលើក្រដាសសន្លឹកទី២ និងសន្លឹកបន្តបន្ទាប់រៀងៗក្រុម ដោយប្រើពេល ៥ នាទីសម្រាប់ការគូរលើសន្លឹកនីមួយៗ។ សាច់រឿងត្រូវតែចាប់ផ្តើមនៅសន្លឹកទី១ (ផ្តើមរឿងលើប្រធានបទតែមួយ) និងបញ្ចប់នៅសន្លឹកទី៥។ នៅពេលគូរចប់ ក្រុមនីមួយៗនឹងមានសាច់រឿងគំនូរជីវចលរបស់ខ្លួនចំនួន ៥ សន្លឹក រួចយកវាទៅបិទភ្ជាប់នឹងប្រអប់ដែលបានបែងចែកសម្រាប់ក្រុមនីមួយៗនៅលើផ្ទាំងក្រដាសធំ។

សិស្សអាចប្រើការស្រមើស្រមៃរបស់ពួកគេ អំពីសាច់រឿងបន្តពីក្រដាសទី១បានដោយសេរី។ សាច់រឿងគំនូរជីវចលនេះ មិនមានភាពខុស ឬត្រូវនោះទេ។ ក្រុមនីមួយៗត្រូវឡើងបង្ហាញអំពីសាច់រឿងរបស់ពួកគេទៅវិញទៅមករហូតទាល់តែចប់។



## សកម្មភាពសិស្សទី២

សម្រាប់ពេលប្រឡងបញ្ចប់ អ្នកអាចបើកឱ្យមានការពិភាក្សាជាទូទៅមួយអំពីការសិក្សានៅឆ្នាំទី១ នេះ ថាតើពួកគេយល់យ៉ាងណា និងមានការរំពឹងទុកអ្វីខ្លះសម្រាប់ឆ្នាំបន្ទាប់។ អរគុណអ្នកគ្រប់គ្នាសម្រាប់ការខិតខំប្រឹងប្រែងធ្វើការងារបានល្អ!



# ផ្នែកទី ២
# ការរៀបចំផែនការអាជីព (ថ្នាក់ទី ១១)

## វត្ថុបំណងសម្រាប់ឆ្នាំទី២

ក្នុងឆ្នាំសិក្សាទី ២ (ថ្នាក់ទី ១១)នេះ សិស្សានុសិស្សនឹងត្រូវផ្តោតការយកចិត្តទុកដាក់លើ**ការរៀបចំផែនការអាជីព ការបន្តការសិក្សាទៅថ្ងៃអនាគត** និង**បញ្ហាផ្សេងៗ**ដែលជួបប្រទះក្នុងជីវិតប្រចាំថ្ងៃដូចជា ការដោះស្រាយបញ្ហា ការគិតបែបពិចារណាស៊ីជម្រៅជាដើម។

នៅក្នុងឆ្នាំសិក្សានេះ តម្រូវឱ្យបង្រៀនរយៈពេល ៣៦ ម៉ោង (៤៥ នាទី សម្រាប់ម៉ោងសិក្សា ១៥ នាទី សម្រាក)។ សិស្សានុសិស្ស នឹងត្រូវអនុវត្តគម្រោងសិក្សាចំនួន ២ ការសិក្សាលក្ខណៈជាក្លឹបមុខវិជ្ជាចំនួន ២ ព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដែលជាផ្នែកមួយសម្រួលដល់ការរៀន និងបង្រៀនមេរៀនប្រឹក្សាអាជីព។ ក្នុងម៉ោងសិក្សា សិស្សត្រូវមានសៀវភៅកត់ត្រា និងប៊ិកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

## ខ្លឹមសារមេរៀន ត្រូវបានបែងចែកដូចខាងក្រោម៖

| | |
|---|---|
| មេរៀនទី១ដល់ទី២៖ | តម្រង់ទិសសិស្សថ្នាក់ទី១១ សម្រាប់ឆ្នាំសិក្សាថ្មី |
| មេរៀនទី៣ ដល់ ១០៖ | បំណិនការងារគម្រោង |
| មេរៀនទី១១ ដល់ ១២៖ | ជំនាញផ្ទាល់ខ្លួន |
| មេរៀនទី១៣ ដល់ ១៤៖ | តម្រង់ទិសអំពីផែនការអាជីព និងជ្រើសរើសរកអាជីព |
| មេរៀនទី១៥ ដល់ ២១៖ | ការរៀបចំផែនការអាជីព |
| មេរៀនទី២២ ដល់ ២៥៖ | តេស្ត និងវិធីសាស្ត្រជំនួយក្នុងការជ្រើសរើសអាជីព |
| មេរៀនទី២៦ ដល់ ២៨៖ | ជម្រើសអប់រំបន្តដែលគាំទ្រផែនការអាជីព |
| មេរៀនទី២៩ ដល់ ៣៤៖ | ជំនាញ និងភាពខ្លាំង |
| មេរៀនទី៣៥ ដល់ ៣៦៖ | ការឆ្លុះបញ្ចាំង និងវាយតម្លៃការសិក្សាពេញ១ឆ្នាំ |

# មេរៀនទី ១ ស្វាគមន៍មកកាន់ថ្នាក់ទី១១ ឬឆ្នាំទី ២

មេរៀនទី ១ នៃមគ្គុទ្ទេសក៍ និងការប្រឹក្សាអាជីព នឹងត្រូវប្រើប្រាស់ក្នុងការតម្រង់ទិសសម្រាប់សិស្សថ្នាក់ទី១១ បន្ទាប់ពីពួកគេបានរៀនមេរៀនជាច្រើននៅថ្នាក់ទី១០។ វត្ថុបំណងនៃមេរៀននេះគឺៈ

- សិស្សគ្រប់គ្នាមានអារម្មណ៍ថាត្រូវបានស្វាគមន៍មកកាន់ថ្នាក់ថ្មី។

ក្នុងមេរៀននេះ សម្ភារៈដែលអ្នកត្រូវការមានដូចជាៈ ក្រដាស (ក្រដាសពណ៌ប្រសិនបើអាច) ប៊ិកពណ៌ កាវ និងកន្ត្រៃ សម្រាប់ធ្វើលំហាត់។

## សកម្មភាពសិស្សទី១ (រយៈពេល ១០-១៥ នាទី)

សួរសិស្សអំពីការសម្រាកវិស្សមកាលរបស់ពួកគេ តើពួកគេ និងក្រុមគ្រួសារមានការសំរាកលំហែដូម្តេចខ្លះ? បន្ទាប់មក ឱ្យពួកគេពិភាក្សានូវអ្វីដែលគេចងចាំអំពីមេរៀនប្រឹក្សាយោបល់ និងមគ្គុទ្ទេសក៍អាជីពកាលពីឆ្នាំមុន និងតើអ្វីខ្លះដែលពួកគេចូលចិត្ត អ្វីខ្លះដែលមានប្រយោជន៍សម្រាប់ពួកគេ?

## សកម្មភាពសិស្សទី២ (រយៈពេល ៣០ នាទី)

ផ្កា– ភាពប្រហាក់ប្រហែល និងភាពខុសគ្នា។ គូរង្វង់ឱ្យធំនៅចំកណ្តាលក្រដាស។ សិស្សត្រូវពិភាក្សាក្នុងក្រុម និងសរសេរភាពប្រហាក់ប្រហែលគ្នាឱ្យបានច្រើន តាមដែលអាចធ្វើបាន។ ពួកគេសរសេរចំណុចទាំងនេះទៅក្នុងរង្វង់។ ឱ្យសិស្សកាត់សន្លឹកក្រដាសជាទម្រង់ស្លឹកឈើ (តំណាងឱ្យពួកគេ) ស្លឹកមួយស្រទាប់តំណាងឱ្យសិស្សម្នាក់។ ពួកគេសរសេរចំណុចមួយដែលទាក់ទងនឹងពួកគេ មិនមែនសម្រាប់ក្រុមទាំងមូលទេ។ បន្ទាប់មក ឱ្យពួកគេបិទជុំវិញរង្វង់ ដើម្បីបង្កើតជាទម្រង់ផ្កា។



## សកម្មភាពសិស្ស ៣ (រយៈពេល ៥ នាទី)

អ្នកត្រូវពន្យល់សិស្សដោយសង្ខេបអំពីប្រធានបទដែលនឹងត្រូវរៀនសម្រាប់ថ្នាក់ទី ១១។ ឱ្យសិស្សយកសៀវភៅកត់ត្រាសម្រាប់មេរៀនមគ្គុទ្ទេសក៍ និងការប្រឹក្សាយោបល់អាជីព និងមួយក្បាលទៀតសម្រាប់ធ្វើសៀវភៅកំណត់ហេតុសិក្សា។ ពួកគេអាចបន្តប្រើប្រាស់សៀវភៅពីឆ្នាំមុន និងប្រើសៀវភៅដដែលសម្រាប់កត់ត្រា និងធ្វើជាសៀវភៅកំណត់ហេតុសិក្សា។

## មេរៀនទី ២ ការតម្រង់ទិសដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា

វត្ថុបំណងនៃមេរៀននេះគឺៈ

- រំឭកការចងចាំខ្លឹមសារមួយចំនួននៃមេរៀនពីឆ្នាំមុនដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា

### សកម្មភាពសិស្សទី១

អ្នកអាចរួមបញ្ចូលប្រធានបទនេះជាមួយបច្ចេកវិទ្យាព័ត៌មានវិទ្យា និងឱ្យសិស្សរកព័ត៌មានអំពីប្រធានបទនេះ ឬធ្វើតេស្តតាមអ៊ិនធឺណិត។ ប្រសិនបើអ្នកអាចសហការជាមួយនឹងគ្រូបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សិស្សអាចធ្វើលំហាត់នេះនៅក្នុងថ្នាក់ ឬនៅផ្ទះ ឬប្រើប្រាស់ទូរសព្ទវៃឆ្លាត (ស្មាតហ្វូន) របស់គេប្រសិនបើមាន។ ពួកគេក៏អាចធ្វើកិច្ចការនេះជាគូ ឬជាក្រុមប្រសិនបើសិស្សណាមិនអាចភ្ជាប់អ៊ិនធឺណិតបាន។

ពួកគេអាចប្រើទម្រង់ឯកសារតាមតំណភ្ជាប់ទៅអាសយដ្ឋានគេហទំព័រខាងក្រោម ឬធ្វើការស្រាវជ្រាវតាមទំព័របើកចំហរ (Google)។ គេហទំព័រខាងក្រោមនេះ សិស្សអាចប្រើប្រាស់ដើម្បីស្រាវជ្រាវចំណេះដឹងបន្ថែមជុំវិញវិធីសាស្ត្រនៃការរៀនសូត្រ ការណែនាំអំពីការសិក្សាចំណេះទូទៅ វិធីសាស្ត្ររៀនមុខវិជ្ជាផ្សេងៗឱ្យទទួលបានលទ្ធផលល្អ...។

https://www.educationcorner.com/study-skills.html

http://www.free-training-tutorial.com/times-tables-games.html

### សកម្មភាពសិស្សទី២

ឱ្យសិស្សធ្វើផែនទីគំនិតអំពីអ្វីដែលពួកគេបានរកឃើញចេញពីការស្រាវជ្រាវតាមអ៊ិនធឺណិត។ ឱ្យពួកគេបង្ហាញពី អ្វីខ្លះគួរឱ្យចាប់អារម្មណ៍ អ្វីខ្លះថ្មី អ្វីដែលគួរឱ្យចូលចិត្ត អ្វីដែលមិនគួរឱ្យចូលចិត្ត ដែលគេបានជួបប្រទះក្នុងការស្រាវជ្រាវនេះ។ ពួកគេអាចធ្វើកិច្ចការនេះក្នុងសៀវភៅជាលក្ខណៈបុគ្គល ជាគូ ឬជាក្រុមតូចៗដែលមានគ្នា ៣-៤ នាក់។



## មេរៀនទី ៣ ការធ្វើផែនការ

ពេលនេះ សិស្សនឹងចាប់ផ្ដើមការងារគម្រោងនៅក្នុងមេរៀនមគ្គុទ្ទេសក៍ និងប្រឹក្សាអាជីព។ មានមេរៀនចំនួន ៨ នឹងត្រូវបានប្រើប្រាស់ក្នុងការងារគម្រោងនេះ ដោយត្រូវចំណាយពេល ២ ខែដើម្បីបញ្ចប់។ អាស្រ័យហេតុនេះ អ្នកគួរតែបញ្ជាក់ប្រាប់សិស្សថាវាជាការងារដ៏ធំ ហើយទាមទារនូវការប្ដេជ្ញា និងតម្រង់ទិសខ្លួនឯងយ៉ាងខ្លាំង។ ការងារគម្រោងនេះ គឺមានភាពស្មុគស្មាញ និងមានការតម្រូវការច្រើនជាងការងារគម្រោងកាលពីឆ្នាំទី ១ ពីព្រោះអ្នកមានសមត្ថភាពស្ទួល និងការយល់ដឹងកាន់តែច្រើនជាងមុន ហើយបទបង្ហាញរបស់អ្នកក៏ទាមទារឱ្យមានគុណភាពខ្ពស់ដែរ។

នៅក្នុងមេរៀនដំបូងនេះ អ្នកត្រូវបែងចែកសិស្សជាក្រុម និងរៀបផែនការគម្រោងរបស់ពួកគេ។ មេរៀនបន្ទាប់ សិស្សនឹងត្រូវពន្យល់បង្ហាញអំពីគម្រោងរបស់ពួកគេ ដោយរៀបចំជាបទបង្ហាញ។ វត្ថុបំណងសម្រាប់ការងារគម្រោង (វត្ថុបំណងនៃមេរៀនទាំង ៨)គឺ៖

- សិស្សរៀនធ្វើការងារគម្រោងក្នុងក្រុមតូចៗ ដោយទទួលខុសត្រូវការងាររបស់គេ និងធ្វើបទបង្ហាញអំពីលទ្ធផលនៃពិភាក្សាក្រុម
- សិស្សរៀនធ្វើការដឹកនាំដោយខ្លួនឯង ឆ្លុះបញ្ចាំងព័ត៌មានដែលពួកគេប្រមូលបាន និងវិភាគដោយការពិចារណា (ទាំងនេះជាជំនាញដ៏សំខាន់ក្នុងជីវិតរបស់ពួកគេ)។

### សកម្មភាពសិស្សទី១៖ រៀបចំផែនការគម្រោង

បែងចែកសិស្សជា ៨ គូ ឬ ៨ ក្រុម សម្រាប់ប្រធានបទបំណិនទាំង ៨ ដែលមាននៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។ ក្រុមនីមួយៗនឹងចាប់ផ្ដើមធ្វើការលើប្រធានបទមួយក្នុងចំណោម ៨។

វត្ថុបំណងនៃការងារគម្រោងគឺ សិស្សនឹងរកឃើញអំពីលទ្ធផលរំពឹងទុកពីការរៀនសូត្រនៃប្រធានបទបំណិននីមួយៗ និងបង្កើតព័ត៌មានអំពីសារៈសំខាន់នៃបំណិនទាំងនោះក្នុងជីវិតប្រចាំថ្ងៃ ព្រមទាំងបង្កើតឧទាហរណ៍មួយចំនួននៃការអនុវត្តក្នុងស្ថានភាពជីវិតជាក់ស្ដែង។ ពួកគេអាចប្រមូលព័ត៌មានដោយសេរី តាមរយៈការសម្ភាសគ្រូ ឪពុកម្ដាយ សាច់ញាតិ មិត្តភក្តិ មនុស្សពេញវ័យដែលមានការងារធ្វើ ការសែត សៀវភៅ អ៊ិនធឺណិត ឬអ្វីផ្សេងដែលគេនឹកឃើញ។ វាជាការប្រសើរប្រសិនបើពួកគេអាចសម្រួចប្រធានបទទៅនឹងប្រធានបទបច្ចុប្បន្នមួយចំនួន។

### សន្លឹកកិច្ចការ៖ ផែនការគម្រោង

| ភារកិច្ចដែលត្រូវធ្វើ | កាលវិភាគ/ កាលបរិច្ឆេទ | ការទទួលខុសត្រូវក្នុងក្រុម | រៀបផែនការជាមួយគ្នាអំពីមាតិកានៃកិច្ចសម្ភាស ឬត្រូវរកព័ត៌មានផ្សេងទៀត |
|---|---|---|---|
| សម្ភាស (រៀបផែនការ តើអ្នកត្រូវសម្ភាសនរណា?) | | | |
| អ៊ិនធឺណិត ប្រភពគេហទំព័រ តើព័ត៌មានអ្វីដែលយើងកំពុងរកមើល | | | |
| កាសែត សៀវភៅ | | | |
| ប្រភពព័ត៌មានដទៃទៀតមួយណា? | | | |

### សម្រាប់អ្នកប្រឹក្សាអាជីព

បំណិន (សមត្ថភាពស្នូល) គឺមានភាពខុសៗគ្នាសម្រាប់វិភាគ។ ឧ. អក្សរសាស្រ្ត លេខសាស្រ្ត ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺមានភាពងាយស្រួលជាង ដោយសារតែមុខវិជ្ជាទាំងនេះត្រូវបានបង្រៀននៅឯសាលារៀន ហើយសិស្សអាចសម្គាល់គ្រូប្រចាំមុខវិជ្ជានោះ និងវាមានភាពងាយស្រួលក្នុងការមើលឃើញពីភាពទាក់ទងទៅនឹងពិភពពិត និងជីវិតការងារ។ ពេលនេះ បំណិនផ្សេងទៀត (ប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម ការពិចារណា និងការបង្កើតថ្មី។ល។) គឺមានភាពស្មុគស្មាញ និងពិបាកច្រើនសម្រាប់សិស្ស។ អ្នកគួរផ្តល់បំណិនដែលងាយស្រួល ទៅក្រុមសិស្សដែលទំនងមិនអាចបង្កើតព័ត៌មានបានច្រើនអំពីប្រធានបទពិបាក ហើយឱ្យប្រធានបទលំបាកទៅក្រុមណាដែលអ្នកគិតថាអាចធ្វើបានលទ្ធផលប្រសើរជាង។

# មេរៀនទី ៤ ការពន្យល់បកស្រាយ

## សកម្មភាពសិស្សទី ១

ណែនាំសិស្សឱ្យធ្វើការជាក្រុម និងដាក់ព័ត៌មានដែលគេប្រមូលបានមករហូតដល់ពេលនេះបញ្ចូលគ្នា។ ភារកិច្ចរបស់គ្រូប្រឹក្សាអាជីពគឺ រង់ចាំផ្តល់ជំនួយដល់ពួកគេក្នុងករណីមានការស្នើសុំ។ ពួកគេអាចសុំដំបូន្មានពីអ្នក ប៉ុន្តែត្រូវចាំថាពួកគេនឹងទទួលខុសត្រូវអំពីការងាររបស់គេផ្ទាល់។

## សកម្មភាពសិស្សទី ២

នៅចុងមេរៀន ឱ្យក្រុមនីមួយៗឡើងបង្ហាញដោយសង្ខេបអំពីវិធីសាស្ត្រដែលពួកគេប្រើក្នុងការប្រមូលព័ត៌មានកន្លងមក ផលលំបាកដែលពួកគេបានជួបប្រទះ (ក្រុមផ្សេងអាចចូលរួមបំពេញបន្ថែមចសចក្នុងការជួបផលលំបាក)។



# មេរៀនទី ៥ ការរៀបចំត្រៀមធ្វើបទបង្ហាញ

**សកម្មភាពសិស្ស** (រយៈពេល ១៥ នាទី/ក្រុម)

នៅក្នុងមេរៀននេះ ក្រុមនឹងរៀបចំសម្រាប់ធ្វើបទបង្ហាញ។ ណែនាំសិស្សឱ្យរៀបចំត្រៀមសម្ភារៈសម្រាប់ការធ្វើបទបង្ហាញដូចជា ផ្ទាំងក្រដាសធំ គំនូរកាសែត រូបថត រូបគំនូរ កាតប៉ុស្តាល់។ល។ ពួកគេត្រូវធ្វើការក្នុងក្រុមម្តងទៀត ដើម្បីរៀបចំបទបង្ហាញតាមប្រធានបទរៀងៗក្រុម។ អ្នកអាចដើរមើលតាមក្រុម ជួយពេលដែលគេត្រូវការជំនួយ។ ផ្ទាំងក្រដាសគ្រាន់តែជាផ្នែកមួយនៃបទបង្ហាញ។ អ្នកអាចលើកទឹកចិត្តពួកគេឱ្យរៀបចំត្រៀមសម្តែង ឬសម្តែងតួអំពីប្រធានបទរបស់ពួកគេ ប្រើតន្ត្រី ឬអ្វីដែលមានភាពច្នៃប្រឌិតដែលពួកគេចង់បង្ហាញអំពីប្រធានបទទៅកាន់ក្រុមដទៃទៀត។



## មេរៀនទី ៦ ការធ្វើបទបង្ហាញ ១

### សកម្មភាពសិស្សទី១ (រយៈពេល ២០ នាទី)

ក្រុមទី ១ (អក្សរសាស្ត្រ និងលេខសាស្ត្រ) បង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥ នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

### សកម្មភាពសិស្សទី២ (រយៈពេល ២០ នាទី)

ក្រុមទី ២ (ភាសាបរទេស) បង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

### សម្រាប់អ្នកប្រឹក្សាយោបល់៖

នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្នាក់ជាតិឆ្នាំ ២០១៥ លទ្ធផលរំពឹងទុកនៅក្នុងសមត្ថភាពស្នូលទាំងនេះ ត្រូវបានពន្យល់ដូចខាងក្រោម។ ដូចនេះអ្នកក៏អាចបន្ថែមនូវចំណុចមួយចំនួន ប្រសិនបើសិស្សមិនបានលើកឡើង៖

> «***អក្សរសាស្ត្រ និងលេខសាស្ត្រ៖*** *សិស្សអាចប្រើប្រាស់ភាសា និងគណិតវិទ្យាសម្រាប់យល់ដឹង ពន្យល់ បកស្រាយ និងការពារអំណះអំណាង សម្របសម្រួល លើកទឹកចិត្ត ស្វែងយល់ និងដោះស្រាយបញ្ហាទាំងក្នុងការសិក្សា ជីវិតប្រចាំថ្ងៃ និងការបំពេញការងារវិជ្ជាជីវៈ។*
> ***ភាសាបរទេស (ភាសាអង់គ្លេស និង/ឬបារាំង)៖*** *សិស្សមានសមត្ថភាពភាសាបរទេសគ្រប់គ្រាន់ សម្រាប់ប្រាស្រ័យទាក់ទង ស្រាវជ្រាវ និងបន្តការសិក្សា។*»

ទុកផ្ទាំងក្រដាសទាំងអស់សម្រាប់មេរៀនទី ១០។



# មេរៀនទី ៧ ការធ្វើបទបង្ហាញ ២

## សកម្មភាពសិស្សទី១ (រយៈពេល ២០ នាទី)

ក្រុមទី ៣ (បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍) បង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

## សកម្មភាពសិស្សទី២ (រយៈពេល ២០ នាទី)

ក្រុមទី ៤ (ប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម) បង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

## សម្រាប់អ្នកប្រឹក្សាយោបល់៖

នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្នាក់ជាតិឆ្នាំ ២០១៥ លទ្ធផលរំពឹងទុកនៅក្នុងសមត្ថភាពស្នូលទាំងនេះ ត្រូវបានពន្យល់ដូចខាងក្រោម។ ដូចនេះអ្នកក៏អាចបន្ថែមនូវចំណុចមួយចំនួន ប្រសិនបើសិស្សមិនបានលើកឡើង៖

*«**បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)៖** សិស្សអាចប្រើប្រាស់កុំព្យូទ័រ និង ICTសម្រាប់ការសិក្សា ជីវិតប្រចាំថ្ងៃរបស់ពួកគេ។*

***ប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម៖** សិស្សអាចប្រើប្រាស់អក្សរសាស្ត្រ និងលេខសាស្ត្រដើម្បីផ្សព្វផ្សាយគំនិត ចំណេះដឹង ជំនាញ អារម្មណ៍ និងទស្សនៈ ធ្វើសុភវិនិច្ឆ័យព័ត៌មានថាត្រូវទទួល ឬមិនទទួលដោយផ្អែកលើហេតុផល ចរចារស្វែងរកយន្តការ និងវិធីដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពបំផុតទៅតាមកាលៈទេសៈ ដើម្បីបានជាប្រយោជន៍ទាំងអស់គ្នា។»*

ទុកផ្ទាំងក្រដាសទាំងអស់សម្រាប់មេរៀនទី ១០។



# មេរៀនទី ៨ ការធ្វើបទបង្ហាញ ៣

### សកម្មភាពសិស្សទី១ (រយៈពេល ២០ នាទី)

ក្រុមទី ៥ (ការពិចារណា និងការបង្កើតថ្មី) នឹងបង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥ នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

### សកម្មភាពសិស្សទី២ (រយៈពេល ២០ នាទី)

ក្រុមទី ៦ (ការអនុវត្តចំណេះដឹង និងជំនាញ) នឹងបង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥នាទី + ក្រុមពិភាក្សា ១០នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

### សម្រាប់អ្នកប្រឹក្សាយោបល់

នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្នាក់ជាតិឆ្នាំ ២០១៥ លទ្ធផលរំពឹងទុកនៅក្នុងសមត្ថភាពស្នូលទាំងនេះ ត្រូវបានពន្យល់ដូចខាងក្រោម។ ដូចនេះអ្នកក៏អាចបន្ថែមនូវចំណុចមួយចំនួន ប្រសិនបើសិស្សមិនបានលើកឡើង៖

*«**ការវិភាគ និងការបង្កើតថ្មី៖** សិស្សអាច ១) វិភាគ និងវាយតម្លៃព័ត៌មាន ប្រមើលមើលបញ្ហា វិភាគបញ្ហាសម្រាប់រកដំណោះស្រាយសមស្រប និងប្រើប្រាស់ការគិតត្រិះរិះពិចារណា សម្រាប់ធ្វើសេចក្ដីសម្រេចចិត្ត ២) ធានាការរកឃើញថ្មីៗ បង្កើតលទ្ធភាពថ្មី គំនិតថ្មី ឬចំណេះដឹងថ្មី និង ៣)ជំរុញការស្រឡាញ់សិក្សាដោយឯករាជ្យ និងការសិក្សាពេញមួយជីវិត។*

*__អនុវត្តចំណេះដឹង និងជំនាញ៖__ សិស្សអាចអនុវត្តចំណេះដឹង និងជំនាញ ដែលបានមកពីការរៀនមុខវិជ្ជានីមួយៗ នៅគ្រប់កម្រិតថ្នាក់ ដើម្បីជាប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃផង និងដើម្បីប្រែក្លាយពីសង្គមព័ត៌មានទៅជាសង្គមចំណេះដឹង។»*

ទុកផ្ទាំងក្រដាសទាំងអស់សម្រាប់មេរៀនទី ១០។



# មេរៀនទី ៩ ការធ្វើបទបង្ហាញ ៤

## សកម្មភាពសិស្សទី១ (រយៈពេល ២០ នាទី)

ក្រុមទី ៧ (អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម) និងបង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥ នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

## សកម្មភាពសិស្សទី២ (រយៈពេល ២០ នាទី)

ក្រុមចុងក្រោយ (សហគ្រិនភាព និងភាពជាអ្នកដឹកនាំ) និងបង្ហាញការងារគម្រោងរបស់ពួកគេ។ បទបង្ហាញ ១៥ នាទី + ក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងអាចសួរសំណួរ ឬឱ្យយោបល់ត្រលប់ និងកត់ត្រាចូលសៀវភៅ/កំណត់ហេតុរបស់ពួកគេ)។

## សម្រាប់អ្នកប្រឹក្សាយោបល់

នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្នាក់ជាតិឆ្នាំ ២០១៥ លទ្ធផលរំពឹងទុកនៅក្នុងសមត្ថភាពស្នូលទាំងនេះ ត្រូវបានពន្យល់ដូចខាងក្រោម។ ដូចនេះអ្នកក៏អាចបន្ថែមនូវចំណុចមួយចំនួន ប្រសិនបើសិស្សមិនបានលើកឡើងៈ

> «***ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គមៈ*** *សិស្សអាចអនុវត្តសមត្ថភាពក្នុងការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម ជាការអភិវឌ្ឍបញ្ញា និងស្មារតី ដូចនេះសិស្សអាចបន្សាំជីវិតរស់នៅប្រចាំថ្ងៃទៅនឹងពិភពលោកដែលកំពុងតែផ្លាស់ប្តូរ និងប្រកួតប្រជែង។ សមត្ថភាពក្នុងការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គមមានគោលបំណងបំពាក់ពលរដ្ឋឱ្យមាន ១) ការទទួលខុសត្រូវសម្រាប់ខ្លួនឯង គ្រួសារ និងសង្គម ជាមួយនឹងការយោគយល់ ស្រឡាញ់ និងការប្តេជ្ញាចិត្ត ២) សីលធម៌រស់នៅ ការដឹងខុសត្រូវ ការការពារ និងពង្រីកអំពើសុចរិត ៣) ភាតរភាពក្នុងការបំពេញការទទួលខុសត្រូវជាក្រុម ឬទំនាក់ទំនងទំនងជាមួយគ្នាប្រកបដោយចិត្តមេត្តា និងករុណា ដើម្បីលើកកម្ពស់សុភមង្គលផ្ទាល់ខ្លួន គ្រួសារ និងសង្គម។*
>
> ***សហគ្រិនភាព និងភាពជាអ្នកដឹកនាំៈ*** *សហគ្រិនភាព និងភាពជាអ្នកដឹកនាំ គឺជាសមត្ថភាពរបស់សិស្សនៅក្នុងការអនុវត្តចំណេះដឹងសំខាន់ៗ ដែលបានរួមបញ្ចូលនូវសមត្ថភាពទាំង ៧ ដូចនេះអ្នកសិក្សាអាចនឹងធានានូវភាពជោគជ័យ នៅក្នុងអាជីវកម្មខ្នាតតូចដែលមានតម្រង់ទិសក្នុងការរកប្រាក់ចំណូល។»*

ទុកផ្ទាំងក្រដាសទាំងអស់សម្រាប់មេរៀនទី ១០។



## មេរៀនទី ១០ ការសន្ទេបខ្លឹមសារ

### សកម្មភាពសិស្សទី១

បំផុសការពិភាក្សាក្នុងក្រុមធំៈ

- តើពួកគេគិតថា ការងារគម្រោងរបស់គេបានដំណើរការដោយរបៀបណា?
- តើអ្វីដែលពួកគេមានមោទនភាពចំពោះការងារនេះ?
- តើពួកគេជួបប្រទះផលវិបាកអ្វីខ្លះ?
- តើមានជំនួយប្រភេទណាដែលគេទទួលបាន?
- តើពួកគេបានរៀនអ្វីអំពីការធ្វើការងារគម្រោង និងការទទួលខុសត្រូវ?
- តើពួកគេវាយតម្លៃ ប៉ាន់ប្រមាណ ឬដាក់ពិន្ទុទៅលើការអនុវត្តរបស់ពួកគេក្នុងការងារគម្រោងដោយរបៀបណា?

### សកម្មភាពសិស្សទី២

ឱ្យពួកគេសរសេរក្នុងសៀវភៅកំណត់ហេតុសិក្សារបស់ពួកគេ អំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនបន្ទាប់ពីការងារគម្រោង។

### សកម្មភាពសិស្សទី៣

ឱ្យសិស្សបិទផ្ទាំងព័ត៌មានគម្រោងរបស់ពួកគេលើជញ្ជាំងអគារសិក្សា ឬតាមផ្លូវដើរក្នុងសាលាក្នុងលក្ខណៈជាការតាំងពិព័រណ៍។ ដូចនេះសិស្សដទៃទៀតដែលរៀននៅក្នុងសាលាតែមួយ ក៏អាចមើលឃើញអំពីការងារដ៏ល្អដែលពួកគេបានធ្វើ។ ពួកគេ អាចឈរតាមផ្ទាំងព័ត៌មានគម្រោងរបស់ពួកគេ សម្រាប់ពន្យល់ព័ត៌មានគម្រោងទៅកាន់ «ទស្សនិកជន»។



# មេរៀនទី ១១   ការដោះស្រាយបញ្ហា

យើងមកដល់មេរៀនបំណិនសំខាន់ចំនួន ២ ទៀត ដែលយើងត្រូវការក្នុងជីវិតប្រចាំថ្ងៃ គឺការដោះស្រាយបញ្ហា និងជំនាញនៅក្នុងការគិតត្រិះរិះពិចារណា។ វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យសិស្សមានភាពបន្សាំទៅនឹងឧបករណ៍ដោះស្រាយបញ្ហាមួយ

ផ្តល់បទបង្ហាញខ្លីមួយទៅកាន់សិស្សអំពីវដ្តដំណោះស្រាយបញ្ហាខាងក្រោម។ អ្នកអាចគូរវានៅលើក្តារខៀន ដើម្បីងាយស្រួលដល់ការពន្យល់សិស្សៈ

*Cognitive Psychology, Fifth Edition, Robert J. Sternberg*
*Chapter 11*

## វដ្តដំណោះស្រាយបញ្ហា




### សកម្មភាពសិស្ស

បន្ទាប់មកឱ្យសិស្សធ្វើការជាលក្ខណៈបុគ្គល។ សិស្សត្រូវជ្រើសរើសបញ្ហាមួយ ដែលត្រូវយកមកអនុវត្តដោយប្រើវដ្តដំណោះស្រាយបញ្ហា។ អ្នកអាចចែកសន្លឹកកិច្ចការឱ្យពួកគេ ឬសរសេរសំណួរនៅលើក្តារខៀន។ ដូចនេះសិស្សអាចចម្លងចូលសៀវភៅរបស់គេបាន។ អ្នកអាចដើរជុំវិញហើយជួយពួកគេ ពេលដែលគេកំពុងគិតពីដំណោះស្រាយសម្រាប់បញ្ហារបស់គេ។ ពួកគេក៏អាចធ្វើការជាគូផងដែរប្រសិនជាពួកគេចង់ ប៉ុន្តែពេលខ្លះពួកគេជ្រើសរើសធ្វើការតែឯង ព្រោះបញ្ហាខ្លះគេមិនងាយក្នុងចែករំលែកជាមួយអ្នកដទៃទេ។

### សន្លឹកកិច្ចការ (កំណត់រកបញ្ហា និងរៀបចំព័ត៌មាន)

បញ្ហា ដែលខ្ញុំប្រាថ្នាក្នុងការវិភាគពេលនេះគឺៈ

_______________________________________________

_______________________________________________

| សំណួរ៖ | ចម្លើយ ... | ... ទីនេះ៖ |
|---|---|---|
| តើបញ្ហាជាអ្វី? | -តើអ្វីដែលខ្ញុំចង់សម្រេចបានឱ្យពិតប្រាកដ?<br>-តើការពិតជាអ្វី?<br>-តើនឹងមានរឿងអ្វីកើតឡើង ប្រសិនបើគ្មាន<br>-ការសម្រេចចិត្ត ឬគ្មានដំណោះស្រាយ?<br>-តើខ្ញុំត្រូវការអ្វីខ្លះ ដើម្បីរកដំណោះស្រាយ? | |
| ហេតុអ្វី? | -ហេតុអ្វីបានជាខ្ញុំចង់សម្រេចបានដំណោះស្រាយ?<br>-ហេតុអ្វីបានជាបញ្ហាកើតឡើង?<br>-ហេតុអ្វីបានជាខ្ញុំត្រូវរកដំណោះស្រាយ? | |
| ដោយរបៀបណា? | -តើបញ្ហាខុសគ្នាដោយរបៀបណា?<br>-តើព័ត៌មានដែលខ្ញុំកំពុងតែប្រមូល ទាក់ទងគ្នាដោយរបៀបណា?<br>-តើខ្ញុំអាចដឹងព័ត៌មានបន្ថែមទៀតដោយរបៀបណា?<br>-តើខ្ញុំអាចទាក់ទងអ្នកដែលពាក់ព័ន្ធដោយរបៀបណា? | |
| នៅឯណា? | -តើបញ្ហាកើតឡើងនៅកន្លែងណា?<br>-តើវាប៉ះពាល់នៅកន្លែងណាខ្លះ? | |
| ជានរណា? | -តើនរណាដែលខ្ញុំព្យាយាមផ្តោតការយកចិត្តទុកដាក់?<br>-តើនរណាខ្លះដែលខ្វល់ខ្វាយអំពីស្ថានភាពរបស់ខ្ញុំ?<br>-តើនរណាខ្លះដែលរងផលប៉ះពាល់?<br>-នរណាខ្លះដែលពាក់ព័ន្ធ?<br>-នរណាដែលត្រូវជូនដំណឹង? | |
| ពេលណា? | -តើបញ្ហាកើតឡើងនៅពេលណា?<br>-តើយើងត្រូវធ្វើសកម្មភាពនៅពេលណា?<br>-តើត្រូវដោះស្រាយបញ្ហានៅពេលណា? | |

ពេលនេះគិតអំពីដំណោះស្រាយចំនួន ៣ ដែលអ្នកបង្កើតសម្រាប់ដោះស្រាយជាមួយបញ្ហារបស់អ្នក (ជ្រើសរើសយុទ្ធសាស្ត្រ)៖

| ដំណោះស្រាយ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| លទ្ធភាព ដំណោះស្រាយ ១ (សរសេរនៅទីនេះ) | | |
| លទ្ធភាព ដំណោះស្រាយ ២ | | |
| លទ្ធភាព ដំណោះស្រាយ ៣ | | |

បន្ទាប់ពីធ្វើដំណើរការនេះរួច សរសេរចូលកំណត់ហេតុសិក្សារបស់អ្នក ពីរបៀបដែលអ្នកចាត់ចែងធនធាន និងតាមដានដំណោះស្រាយ ដើម្បីវាយតម្លៃភាពជោគជ័យនៃវដ្តដំណោះស្រាយបញ្ហារបស់អ្នក។



## មេរៀនទី ១២ ការត្រិះរិះពិចារណា

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សស៊ាំទៅនឹងគំនិត និងសារៈសំខាន់នៃការគិតត្រិះរិះពិចារណា

### សកម្មភាពសិស្សទី១

បង្កើតការពិភាក្សាអំពីការគិតត្រិះរិះពិចារណា និងសរសេរនូវលទ្ធផលសំខាន់ៗលើក្តារខៀន៖

- តើការគិតត្រិះរិះពិចារណា មានន័យយ៉ាងដូចម្តេច?
- ហេតុអ្វីបានជាវាមានសារៈសំខាន់?
- សូមឱ្យឧទាហរណ៍ល្អៗអំពីការគិតត្រិះរិះពិចារណា (ចេញពីហេតុការណ៍នៅផ្ទះ សាលារៀន ជីវិតការងារ)?

### សកម្មភាពសិស្សទី២

បែងចែកសិស្សជាក្រុមដែលមានគ្នាចំនួន ៤-៥ នាក់ក្នុងមួយក្រុម។ ឱ្យពួកគេគិត ហើយជ្រើសរើសប្រធានបទមួយដែលមនុស្សភាគច្រើនយល់ឃើញប្រហាក់ប្រហែលគ្នា ឬប្រធានបទណាដែលមនុស្សភាគច្រើនមានការយល់ឃើញផ្សេងៗគ្នា។ (ឧ. ចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ អ្វីគ្រប់យ៉ាងនៅសហរដ្ឋអាមេរិកសុទ្ធតែល្អ ជនជាតិអូស្ត្រាលីទាំងអស់សុទ្ធតែជាអ្នកមាន។ល។)។ ណែនាំសិស្សពីមធ្យោបាយណាមួយសម្រាប់អនុវត្តការគិតត្រិះរិះពិចារណា (Taxonomy of Socratic questions by Paul)។ ចែកសន្លឹកកិច្ចការសម្រាប់សិស្សម្នាក់ៗ ឬផ្តល់ឱ្យមួយសន្លឹកសម្រាប់មួយក្រុម។ ដូចនេះពួកគេអាចអានជាមួយគ្នានៅក្នុងក្រុម។ វាដូចជាផែនទីមួយ៖ ចម្លើយសម្រាប់សំណួរមួយ នឹងនាំទៅកាន់ក្រុមសំណួរមួយប្រភេទទៀត (មិនត្រូវបានកំណត់ទុកមុនដោយគ្រូ ឬនរណាម្នាក់ឡើយ)។ តួនាទីរបស់គ្រូ គឺចាំសួរប្រដេញ ហើយសិស្សត្រូវរៀបចំចម្លើយរបស់ខ្លួន ឬគ្រូណែនាំឱ្យសិស្សសម្តែងតួលក្ខណជាគូ ដោយម្នាក់ជាអ្នកសួរប្រដេញ ម្នាក់ជាអ្នកឆ្លើយ ដើម្បីបំផុសឱ្យការគិតរបស់សិស្សមានការរីកចម្រើន។

### សន្លឹកកិច្ចការ

អានតារាងខាងក្រោម ឬគំរូនៃសំណួររបស់សូក្រាតក្នុងការធ្វើចំណាត់ថ្នាក់ប្រភេទ (ដោយលោក រីឆាតប៉ូល) ដែលបង្កើតឡើងដោយផ្អែកតាមទស្សនៈនៃការរៀនសូត្រចេញពីបញ្ហា។ វិភាគនូវការលើកឡើងដែលជាប្រធានបទនៅក្នុងក្រុមរបស់អ្នក ដោយប្រើចំណាត់ថ្នាក់ប្រភេទ។ សូមសំគាល់ថា អ្នកមិនត្រូវការសំណួរទាំងអស់នោះទេ សំណួរខ្លះមិនទាក់ទងនឹងប្រធានបទរបស់អ្នកនោះទេ។ ផ្តោតលើតែសំណួរណា ដែលផ្តល់ជាគំនិតថ្មី និងគំនិតជួយដល់អ្នកប្រៀបធៀបនឹងបទពិសោធន៍ផ្ទាល់ខ្លួន។ ការពិភាក្សាអាចមានជាពហុភាព និងចម្រុះភាពតាមលទ្ធភាពអាចធ្វើបាន។ អ្នកគួរតែនាំយកទស្សនៈកាន់តែច្រើន កាន់តែល្អតាមដែលអាចធ្វើបាន ប្រសិនបើអ្នកទាំងអស់ក្នុងក្រុម យល់ស្របតាមគ្នាគ្រប់រឿង អ្នកបរាជ័យ/ចាញ់ហើយ!

| ប្រភេទសំណួរដែលសួរដេញនូវហេតុផល និងភស្តុតាង | | |
|---|---|---|
| **សំណួរសម្រាប់សួរបញ្ជាក់** | **សំណួរដែលសួរដេញនូវការសន្មត** | **សំណួរដែលសួរដេញនូវហេតុផល និងភស្តុតាង** |
| តើអ្នកមានន័យថា_____យ៉ាងដូចម្ដេច?<br>តើចំណុចសំខាន់ដែលអ្នកចង់និយាយគឺអ្វី?<br>តើវា ______ទាក់ទងទៅនឹង______ ដោយរបៀបណា?<br>តើអ្នកអាចនិយាយពន្យល់របៀបផ្សេងបានទេ?<br>នេះគឺជាចំណុចសំខាន់ ______ ឬ ______ដែលអ្នកចង់និយាយ?<br>តើអ្នកគិតថាអ្វីទៅជាបញ្ហាចម្បងនៅចំណុចនេះ?<br>ខ្ញុំដូចជាមិនសូវយល់ តើអ្នកមានន័យថា______ ឬ______?<br>តើចំណុចនេះអាចទាក់ទងនឹងបញ្ហា/ការពិភាក្សា/សាច់រឿងរបស់ពួកយើងយ៉ាងដូចម្ដេច?<br>តើអ្នក______ មានន័យចំពោះឃ្លានេះយ៉ាងដូចម្ដេច? តើអ្នកយក______ ដើម្បីមានន័យសម្រាប់ឃ្លារបស់គាត់?<br>______,តើអ្នកអាចសង្ខេបដោយពាក្យរបស់អ្នកនូវអ្វី _______ដែលបាននិយាយ? .... _______, តើនេះជាអ្វីដែលអ្នកចង់និយាយមែនទេ?<br>តើអ្នកអាចឱ្យឧទាហរណ៍បានទេ?<br>តើចំណុចនេះអាចជាឧទាហរណ៍?<br>តើអ្នកអាចពន្យល់បន្ថែមចំណុចនេះបានទេ?<br>តើអ្នកអាចនិយាយបន្ថែមនូវចំណុចនេះបានទេ?<br>ហេតុអ្វីបានជាអ្នកនិយាយដូចនេះ? | តើការសន្មតរបស់អ្នកជាអ្វី?<br>តើលោក X ឬ កញ្ញា Z ការសន្មត ថាជាអ្វី?<br>តើពួកយើងអាចសន្មត់អ្វីជំនួសវិញ?<br>អ្នកដូចជាសន្មត់ថា______។ តើខ្ញុំយល់អញ្ចឹងត្រូវទេ?<br>រាល់ហេតុផលរបស់អ្នកអាស្រ័យលើគំនិតដែលថា______។ ហេតុអ្វីបានជាអ្នកពឹងផ្អែកហេតុផលរបស់អ្នកលើ ______ ជំនួសឱ្យ______?<br>អ្នកដូចជាសន្មត។ តើអ្នកអាចបកស្រាយដែលថាយកវាជាប្រយោជន៍យ៉ាងដូចម្ដេច?<br>តើវាពិតជាហេតុផលហ្នឹងមែន? ហេតុអ្វីបានជាអ្នកគិតថាការសន្មតគួរតែជាចំណុចនេះ?<br>ហេតុអ្វីបានជានរណាម្នាក់ធ្វើការសន្មតបែបនេះ? | តើអ្វីអាចជាឧទាហរណ៍ទៅ?<br>តើអ្នកដឹងដោយរបៀបណា?<br>ហេតុអ្វីបានជាអ្នកគិតថាវាជាការពិត?<br>តើអ្នកមានភស្តុតាងទេ?<br>តើវាបង្កើតភាពខុសគ្នាពីមុនយ៉ាងដូចម្ដេច?<br>តើហេតុផលរបស់អ្នកក្នុងការនិយាយបែបនេះមានអ្វីខ្លះ?<br>តើអ្នកត្រូវការព័ត៌មានអ្វីខ្លះ?<br>តើអ្នកអាចពន្យល់ហេតុផលរបស់អ្នកមកពួកយើងបានទេ?<br>តើហេតុផលទាំងនេះគ្រប់គ្រាន់ទេ?<br>ហេតុអ្វីបានជាអ្នកនិយាយដូច្នេះ?<br>តើអ្វីនាំឱ្យអ្នកជឿបែបនេះ?<br>តើវាអាចអនុវត្តបានយ៉ាងដូចម្ដេចសម្រាប់ករណីនេះ?<br>តើអ្វីអាចធ្វើឱ្យអ្នកដូរចិត្តបាន?<br>ក៏ប៉ុន្តែ តើវាជាភស្តុតាងដ៏ល្អសម្រាប់ការជឿនោះទេ?<br>តើមានហេតុផលអ្វីមួយដែលសង្ស័យចំពោះភស្តុតាងនោះទេ?<br>តើនរណាដែលដឹងថាវាជាការពិត?<br>តើអ្នកនឹងនិយាយអ្វីទៅកាន់មនុស្សម្នាក់ដែលនិយាយថា _____?<br>តើអ្នកផ្សេងអាចឲ្យភស្តុតាងសម្រាប់គាំទ្រទស្សនៈនោះបានទេ?<br>ដោយហេតុផលណាដែលអ្នកសរុបបែបនេះ?<br>តើយើងអាចដឹងយ៉ាងដូចម្ដេចថាវាជាការពិត? |
| **សំណួរអំពីការគិត ឬទស្សនៈ** | **សំណួរដែលសួរដេញអំពីផលជះ និងផលវិបាក** | **សំណួរអំពីការសួរ** |
| តើអ្នកចង់បង្ហាញពីអ្វីដោយថា? | តើយើងរកឃើញដោយរបៀបណា? | |

| | |
|---|---|
| នៅពេលដែលអ្នកនិយាយ_____, តើអ្នកកំពុងបង្ហាញថា_____?<br>ប៉ុន្តែ ប្រសិនបើវាកើតឡើង តើមានអ្វីទៀតនឹងកើតឡើងចេញពីរឿងនេះ? ហេតុអ្វី?<br>តើវានឹងប៉ះពាល់អ្វីខ្លះ? តើវាចាំបាច់នឹងកើតឡើង ឬក៏អាចកើតឡើង/ប្រហែលនឹងកើតឡើង?<br>តើមានជម្រើសផ្សេងទៀតទេ?<br>ប្រសិនបើ _____និង_____ ជាសាច់រឿង អញ្ចឹងតើមានអ្វីទៀតដែលអាចជាពិតដែរ?<br>ប្រសិនបើយើងនិយាយថា____ គឺមានសុជីវធ៌ម ចុះ_____? | តើសំណួរនេះចង់សន្មត់អំពីអ្វី?<br>តើ_____សួរសំណួរនេះដោយរបៀបផ្សេងបានទេ?<br>តើមាននរណាម្នាក់អាចដោះស្រាយសំណួរនេះបានដោយរបៀបណា?<br>តើយើងអាចបំបែកសំណួរនេះបានទេ?<br>តើសំណួរនេះច្បាស់ទេ?<br>តើសំណួរនេះងាយស្រួល ឬពិបាកក្នុងការឆ្លើយ? ហេតុអ្វី?<br>តើសំណួរនេះឱ្យយើងវាយតម្លៃអ្វីម្យ៉ាង? អ្វីទៅ?<br>តើពួកយើងទាំងអស់គ្នាយល់ស្របទេថានេះជាសំណួរ?<br>ដើម្បីឆ្លើយសំណួរនេះ តើមានសំណួរផ្សេងដែលត្រូវឆ្លើយមុនទេ?<br>ខ្ញុំមិនប្រាកដនូវអ្វីដែលអ្នកបកស្រាយសំណួរនេះទេ។ តើវាដូចគ្នាហ្នឹង_____?<br>តើ_____ បរិយាយអំពីសាច់រឿងយ៉ាងដូចម្តេច?<br>ហេតុអ្វីបានជាសាច់រឿងនេះសំខាន់? តើនេះជាសំណួរដែលសំខាន់ជាងគេ ឬក៏មានសំណួរបង្កប់ដែលជាសាច់រឿងពិត? |

*តារាងត្រូវបានកែសម្រួលចេញពី៖* http://ed.fnal.gov/trc_new/tutorial/taxonomy.html and Paul, Richard, *Critical Thinking: How to Prepare Students for a Rapidly Changing World,* 1993.

### សកម្មភាពសិស្សទី៣

ឱ្យសិស្សផ្តល់យោបល់ថាតើការគិត និងការយល់របស់ពួកគេ ត្រូវបានបើកទូលាយ ដោយសារការប្រើប្រាស់សំណួររបស់សូក្រាតក្នុងការចាត់ថ្នាក់ប្រភេទ។ តើអ្នកគិតត្រិះរិះពិចារណាយ៉ាងដូចម្តេចខ្លះ មកដល់ពេលនេះ (បន្ថែមនូវទិដ្ឋភាពថ្មីៗ ទៅលើក្តារខៀនដែលអ្នកបានសរសេរនៅលំហាត់ទី១)?



# មេរៀនទី ១៣ ការតម្រង់ទិសអាជីពការងារ

ពេលនេះ យើងចាប់ផ្តើមប្រធានបទធំទី ២ ក្នុងឆ្នាំសិក្សានេះ គឺការរៀបចំផែនការអាជីព។

ការអប់រំ និងជម្រើសសម្រាប់អាជីព គឺត្រូវបានទទួលឥទ្ធិពលដោយកត្តាជាច្រើនដូចជា មុខវិជ្ជាដែលចូលចិត្តនៅសាលា ចំណាប់អារម្មណ៍ និងចំណង់ចំណូលចិត្ត បុគ្គលិកលក្ខណៈ ក្តីសុបិនកាលពីកុមារភាព វប្បធម៌ បុគ្គលគំរូ ភាពត្រចះត្រចង់នៃការងារ និងការផ្លាស់ប្តូរនៅក្នុងទីផ្សារការងារ ហើយពេលខ្លះក៏ដោយសារតែការរំពឹងទុករបស់អ្នកដទៃដែរ។ ទោះជាយ៉ាងណាក៏ដោយ វាជាការសំខាន់ដែលសិស្សត្រូវទទួលបានការអប់រំ និងបណ្តុះបណ្តាល ដើម្បីផ្តល់ឱកាសដល់ពួកគេក្នុងការអភិវឌ្ឍជំនាញ និងលទ្ធភាពក្នុងការស្វែងរកការងារដ៏គួរឱ្យចាប់អារម្មណ៍។ គោលបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សស្វែងរកចំណាប់អារម្មណ៍ ការរំពឹងទុក និងបំណងប្រាថ្នាដែលទាក់ទងនឹងអាជីពរបស់ពួកគេនាពេលអនាគត។

បន្ទាប់មក នៅពេលដែលសិស្សរបស់អ្នក មានព័ត៌មានច្រើនអំពីជម្រើសការអប់រំ និងអាជីព ពួកគេអាចវាយតម្លៃថាតើចំណាប់អារម្មណ៍របស់គេមានការប្រែប្រួលយ៉ាងណា។

## សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

បង្កើតការសន្ទនាអំពីជម្រើសសម្រាប់អាជីព។ ឧ. តើសិស្សនៅចាំបានទេអំពីអាជីពស្ថិតក្នុងក្តីសុបិនដំបូង កាលពីនៅកុមារភាពរបស់ពួកគេ? តើក្តីសុបិនទាំងនេះមានការប្រែប្រួលដែរឬទេ? តើពួកគេបានគិតអំពី ការរៀបចំផែនការអាជីព ឬការអប់រំបន្ថែមច្រើនកម្រិតណា?

## សកម្មភាពសិស្សទី២ (រយៈពេល ៣០ នាទី)

លំហាត់ខាងក្រោមជួយសិស្សក្នុងការស្វែងរកចំណាប់អារម្មណ៍ ការរំពឹងទុក និងបំណងប្រាថ្នាដែលទាក់ទងនឹងជម្រើសសម្រាប់អាជីពរបស់ពួកគេនាពេលបច្ចុប្បន្ន។ ចែកសន្លឹកកិច្ចការឱ្យសិស្សគ្រប់គ្នា ឬឱ្យសិស្សចម្លងចូលសៀវភៅតាមការណែនាំរបស់អ្នក។



### សន្លឹកកិច្ចការ៖ ឆ្ពោះទៅរកជម្រើសអាជីពការងារ

តើអ្វីខ្លះដែលអាចមានឥទ្ធិពលទៅលើជម្រើសការអប់រំ និងអាជីពរបស់អ្នក? បំពេញក្នុងពពុះគំនិតខាងក្រោម៖



តើនរណាអាចគាំទ្រជម្រើសអាជីពរបស់អ្នក? សរសេរលើផ្ទាំងក្រដាស។



តើបុគ្គលគំរូបែបណាដែលអ្នកចង់ដើរតាម? ការងាររបស់បុគ្គលរូបណាដែលអ្នកស្ញប់ស្ញែងជាងគេ? តើពួកគេបានធ្វើអ្វីខ្លះ?



តើយោបល់ប្រភេទណាដែលអ្នកបានឮ អំពីផែនការអនាគតរបស់អ្នក?



តើយោបល់ទាំងនេះមានឥទ្ធិពលលើជម្រើសអប់រំ និងអាជីពរបស់អ្នកដែរឬទេ? គូសសញ្ញា (X) នៅលើខ្សែបន្ទាត់ខាងក្រោម ដើម្បីបង្ហាញអំពីទំហំឥទ្ធិពលដែលពួកគេមាន។

មិនមានឥទ្ធិពលលើខ្ញុំទេ ព្រោះខ្ញុំដឹងនូវអ្វីដែលខ្ញុំត្រូវធ្វើ!

ច្រើនណាស់ អ្នកផ្សេងគេដឹងថាអ្វីដែលល្អបំផុតសម្រាប់ខ្ញុំ





### សកម្មភាពសិស្សទី៣ (រយៈពេល ១០ នាទី)

ឱ្យសិស្សឆ្លុះបញ្ចាំងសំណួរទាំងនេះទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។ នៅពេលដែលអ្នកសង្ស័យ «តើអាជីពប្រភេទណាដែលសក្តិសមសម្រាប់ខ្ញុំ» អ្នកប្រហែលជាភ្ញាក់ផ្អើលហើយថា អ្នកមានចម្លើយទាំងអស់នៅក្នុងខ្លួនរបស់អ្នក។ អ្នកមានបំណងប្រាថ្នាជាក់លាក់ ឬការរំពឹងទុកសម្រាប់អាជីពក្នុងក្តីស្រមៃ ហើយអ្នកអាចរៀបរាប់អំពីលក្ខណៈរបស់ការងារដែលអ្នកគិតថាសំខាន់បំផុតសម្រាប់ការងារក្នុងក្តីស្រមៃរបស់អ្នក។ ដោយកំណត់រកលក្ខណៈសំខាន់ៗទាំងនេះ អ្នកក៏អាចរកចម្លើយសម្រាប់សំណួរខាងក្រោម៖

- តើអាជីពការងារបែបណាដែលខ្ញុំគួរជ្រើសរើស?
- តើការងារប្រភេទណាដែលខ្ញុំពេញចិត្ត?
- តើការងារប្រភេទណាដែលសក្តិសមនឹងបុគ្គលិកលក្ខណៈរបស់ខ្ញុំ?



# មេរៀនទី ១៤ ការស្វះស្វែងរកអាជីពការងារដ៏សក្តិសម

វត្ថុបំណងនៃមេរៀននេះគឺះ

- សិស្សនឹងចាប់ផ្តើមប្រៀបធៀបអាជីពអនាគតរបស់ខ្លួន ផ្អែកទៅលើការពិតជាក់ស្តែង

## សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

បែងចែកសិស្សជាក្រុមដែលមានគ្នា៤នាក់។ ឱ្យសិស្សសរសេរលើផ្ទាំងក្រដាសនូវការងារដែលគេចាប់អារម្មណ៍ឱ្យបានច្រើនតាមដែលគេអាចធ្វើបាន។

## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

បន្ទាប់មក ឱ្យពួកគេសម្រេចជ្រើសយកការងារវិជ្ជាជីវៈ ២ ដែលគេចាប់អារម្មណ៍។ ពួកគេគួរតែប្រមូលព័ត៌មានអំពីការងារវិជ្ជាជីវៈទាំង ២ ដោយប្រើប្រភពព័ត៌មានខុសគ្នាៗ (កាសែត អ៊ិនធឺណិត សៀវភៅ ឬកូនសៀវភៅព័ត៌មានរបស់ការិយាល័យប្រឹក្សាយោបល់អំពីអាជីព) ឬយោងតាមអ្វីដែលគេបានដឹងរួចហើយ។ ពួកគេអាចធ្វើកិច្ចការនេះជាលក្ខណៈបុគ្គល ឬជាគូ។ ចែកសន្លឹកកិច្ចការឱ្យពួកគេ ឬឱ្យពួកគេសរសេរតារាងប្រៀបធៀបនេះចូលក្នុងសៀវភៅរបស់ពួកគេ។ (អ្នកក៏អាចសហការជាមួយ គ្រូ បច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីហាត់ធ្វើកិច្ចការនេះនៅក្នុងថ្នាក់កុំព្យូទ័រ។ ប្រសិនបើអ្នកចង់ឱ្យពួកគេប្រើប្រភពព័ត៌មានផ្សេងទៀត អ្នកអាចឱ្យកិច្ចការនេះទៅសិស្សជាលំហាត់នៅផ្ទះ)។

## សន្លឹកកិច្ចការ

ប្រៀបធៀបលទ្ធភាពអាជីពការងារ ២ ដែលអ្នកចាប់អារម្មណ៍។

| ការពណ៌នា | ជម្រើសអាជីពទី១ | ជម្រើសអាជីពទី២ |
|---|---|---|
| តួនាទី និងភារកិច្ចចម្បងៗះ | | |
| ការអប់រំ ការបង្កើត ឬតម្រូវការផ្លូវការដទៃទៀត | | |
| ជំនាញផ្ទាល់ខ្លួនដែលមាន (ជំនាញសង្គម ជំនាញភាសា ឬផ្សេងទៀត) | | |
| បទពិសោធការងារដែលត្រូវការ | | |
| ឱកាសការងារពេលអនាគតនៅសាខា | | |
| ប្រាក់ខែ | | |
| ម៉ោងធ្វើការ | | |
| ការវាយតម្លៃប្រៀបធៀបនៃជម្រើសទាំង២របស់ខ្ញុំ (គុណសម្បត្តិ និងគុណវិបត្តិ) | | |

## សកម្មភាពសិស្សទី៣

ប្រសិនបើសិស្សធ្វើលំហាត់នេះរួចរាល់នៅសាលា អ្នកអាចឱ្យសិស្សបូកសរុបបានដោយគូស រង់លើផ្ទាំងក្រដាសនូវអាជីពការងារដែលពួកគេបានវាយតម្លៃលម្អិតរួច។ ពេលនេះអ្នកអាចយល់បានអំពីការងារវិជ្ជាជីវៈណាដែលទទួលបានចំណាប់អារម្មណ៍ច្រើនជាងគេសម្រាប់ក្រុម។



# មេរៀនទី ១៥ ការរៀបចំផែនការសម្ភាសប្រមូលព័ត៌មាន

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សរៀនធ្វើការងារគម្រោងជាលក្ខណៈបុគ្គល
- សិស្សនឹងទទួលបានព័ត៌មានច្រើនអំពីអាជីពដែលពួកគេប៉ងប្រាថ្នាសម្រាប់ខ្លួនឯង

មុននឹងចាប់ផ្តើមមេរៀន អ្នកត្រូវណែនាំសិស្សថា ក្នុងមេរៀននេះ សិស្សនឹងត្រូវធ្វើការងារគម្រោងជាលក្ខណៈបុគ្គលបន្តពីមេរៀនមុន ដោយសម្ភាសប្រមូលព័ត៌មាន និងបង្ហាញលទ្ធផល។

លំហាត់ក្នុងមេរៀនមុនគឺ៖ ស្វែងរកព័ត៌មានអំពីអាជីពការងារចំនួន ២ (ចេញពីទំព័រអ៊ិនធឺណិត សៀវភៅ កាសែត ឬការិយាល័យប្រឹក្សាយោបល់អំពីអាជីព...)។ ដាក់បញ្ចូលព័ត៌មានដែលអ្នកប្រមូលបានទាំងអស់ ចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុរបស់អ្នក និងជ្រើសរើសអាជីពមួយដែលអ្នកចង់ដឹងបន្ថែម។

## សកម្មភាពសិស្សទី១

បែងចែកសិស្សជាក្រុមដែលមានគ្នាចំនួន ៦នាក់។ ដោយប្រើរយៈពេល ១៥ នាទី សិស្សណាម្នាក់ត្រូវបង្ហាញទៅកាន់សមាជិកក្រុម នូវអាជីពការងារណាមួយដែលគេចង់បានព័ត៌មានបន្ថែម។ ភារកិច្ចរបស់សមាជិកដទៃទៀតក្នុងក្រុម គឺពិភាក្សាគ្នាកំណត់សមាសភាពអ្នកដែលនឹងត្រូវសម្ភាសពាក់ព័ន្ធនឹងអាជីពដែលគេស្នើឡើងនោះ ហើយត្រូវរកបុគ្គលនោះបានដោយរបៀបណា។ អ្នកអាចជួយសិស្សក្នុងការស្វែងរកអ្នកដែលត្រូវផ្តល់សម្ភាសសមស្រប និងលើកទឹកចិត្តសិស្សឱ្យទាក់ទងពួកគេ។ ជាទូទៅ វាជាការងាយស្រួលក្នុងការស្វែងរកអ្នកដែលត្រូវសម្ភាស ព្រោះមនុស្សភាគច្រើនចូលចិត្តនិយាយពីការងារវិជ្ជាជីវៈរបស់ពួកគេ។

## សកម្មភាពសិស្សទី២

ពេលនេះ សិស្សបន្តរៀបសំណួរសម្រាប់ធ្វើការសម្ភាស។ សិស្សគ្រប់គ្នាសរសេរសំណួរទាំងនេះក្នុងសៀវភៅ ឬប្រើសន្លឹកកិច្ចការ។ សំណួរមួយចំនួនមាននៅក្នុងសន្លឹកកិច្ចការរួចជាស្រេច ប៉ុន្តែអ្នកត្រូវលើកទឹកចិត្តសិស្សឱ្យរៀនបង្កើតសំណួរដោយខ្លួនឯង និងជួយពួកគេក្នុងករណីចាំបាច់។

## សន្លឹកកិច្ចការ

### *កិច្ចសម្ភាសសម្រាប់ប្រមូលព័ត៌មាន*

ព័ត៌មានដែលល្អបំផុត គឺបានមកពីអ្នកដែលកំពុងធ្វើការនៅក្នុងអាជីពនោះ។ ព័ត៌មានដែលទទួលបានតាមរយៈការសម្ភាសនេះ គឺមានសារៈសំខាន់ក្នុងការជួយឱ្យសិស្សស្វែងយល់ពីអាជីពបន្ថែមពីលើការអានសៀវភៅ ប្រើប្រាស់អ៊ិនធឺណិត និងអានការពិពណ៌នាអំពីការងារ។ អ្នកអាចបង្កើតសំណួរដោយខ្លួនឯង ឬប្រើប្រាស់សំណួរខាងក្រោមដើម្បីសម្ភាស៖

- តើហេតុអ្វីបានជាអ្នកចាប់អារម្មណ៍អាជីពការងារនេះ?
- តើអ្នកធ្វើការងារនេះយូរប៉ុណ្ណាហើយ?
- តើអ្នកធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ និងប៉ុន្មានថ្ងៃក្នុងមួយសប្តាហ៍?
- តើអ្នកមានភារកិច្ចការទទួលខុសត្រូវក្នុងមុខតំណែងអ្វីខ្លះ?
- តើអ្វីដែលអ្នកចូលចិត្តបំផុតពីការងាររបស់អ្នក?

- តើអ្វីដែលអ្នកចូលចិត្តតិចតួចពីការងាររបស់អ្នក?
- តើការងាររបស់អ្នកតម្រូវឱ្យមានការអប់រំ និងការបណ្តុះបណ្តាលអ្វីខ្លះ?
- តើជំនាញ និងចំណេះដឹងអ្វីខ្លះដែលសំខាន់នៅក្នុងការងាររបស់អ្នក? តើមានលក្ខខណ្ឌអ្វីបន្ថែមទៀតឬទេ?
- តើប្រាក់ខែដំបូងក្នុងអាជីពនេះមានចំនួនប៉ុន្មាន?
- តើអ្នកមើលឃើញអនាគតល្អអ្វីខ្លះក្នុងការងារនេះ? តើអ្នកមានដំបូន្មានអ្វីខ្លះសម្រាប់ផ្តល់ឱ្យអ្នកដែលកំពុងពិចារណាជ្រើសរើសអាជីព?



*(សកម្មភាពនេះត្រូវបានកែសម្រួលចេញពីលំហាត់ដែលបានបង្កើតឡើងដោយHiekkataipale et al., ២០១៣ សូមមើលសៀវភៅប្រឹក្សាយោបល់ស្តីពីអាជីព របស់ FCA ២០១៦)*

| |
|---|
| ឈ្មោះអ្នកត្រូវសម្ភាស៖___________________________________<br>កន្លែងការងារ/ក្រុមហ៊ុន៖______________________________________<br>ការងារបច្ចុប្បន្ន៖__________________________________________________<br>ថ្ងៃខែ និងទីកន្លែងសម្ភាស៖ ___________________________ |
| តើខ្ញុំដឹងអ្វីខ្លះ? (សរសេរចម្លើយនៅទីនេះ៖) |

# មេរៀនទី ១៦ ការរៀបចំត្រៀមធ្វើបទបង្ហាញ

## សកម្មភាពសិស្ស

នៅក្នុងមេរៀននេះ សិស្សនឹងរៀបចំទិន្នន័យរបស់ពួកគេសម្រាប់ធ្វើបទបង្ហាញ។ អ្នកត្រូវណែនាំឱ្យសិស្សរៀបចំផ្ទាំងក្រដាសធំ ដែលមានបិទរូបថត រូបគំនូរ ឬគំរូអត្ថបទកាសែតដកស្រង់ អមជាមួយនឹងគោលគំនិតសំខាន់ៗអំពី អាជីពដែលគេប្រមូលព័ត៌មានបានតាមរយៈការស្រាវជ្រាវ និងកិច្ចសម្ភាសកន្លងមក។ បន្ថែមពីលើផ្ទាំងក្រដាសធំ ពួកគេអាចបន្ថែមអ្វីផ្សេងទៀតទៅលើបទបង្ហាញរបស់ពួកគេដូចជា ការសម្តែងខ្លី ប្រើតន្ត្រី ឬចាក់សំឡេងដែលបានថតទុកពេលសម្ភាស។ អ្នកអាចដើរមើលជុំវិញ និងផ្តល់ជំនួយនៅពេលដែលគេត្រូវការ។ បទបង្ហាញនេះ ត្រូវតែមានលក្ខណៈខ្លីសាមញ្ញ ដែលចំណាយ ពេលត្រឹម ៥ នាទីសម្រាប់ការបង្ហាញអាជីពនីមួយៗ។

**ការត្រៀមសម្រាប់មេរៀនបន្ទាប់៖** បើអ្នកមានសិស្ស ២០ នាក់ក្នុងម៉ោងបង្រៀននេះ អ្នកត្រូវបែងចែកឱ្យមានបទបង្ហាញចំនួន ៧ (ប្រើពេល ៥ នាទីសម្រាប់បទបង្ហាញនីមួយៗ)។ ករណីអ្នកមានសិស្ស ៣០ នាក់វិញ អ្នកត្រូវបែងចែកឱ្យមានបទបង្ហាញចំនួន ១០ (ប្រើពេលត្រឹម ៣ នាទីសម្រាប់បទបង្ហាញនីមួយៗ)។



## មេរៀនទី ១៧  បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ១

### សកម្មភាពសិស្ស

សិស្សគ្រប់រូបនឹងត្រូវបង្ហាញការងារគម្រោងរបស់គេ។ បទបង្ហាញចំនួន ៧-១០ ប្រធានបទ (សិស្សមានពេល ៣-៥ នាទីក្នុងមួយបទបង្ហាញ)។ អ្នកអាចទុកពេលបន្តិចសម្រាប់សិស្ស ផ្សេងលើកជាសំណួរទៅលើបទបង្ហាញនីមួយៗ។ អ្នកត្រូវធានាថា សិស្សម្នាក់ៗមានពេលវេលាស្មើៗ គ្នាក្នុងការធ្វើបទបង្ហាញរបស់ពួកគេ។ អ្នកត្រូវរក្សាទុកផ្ទាំងក្រដាសធ្វើបទបង្ហាញរបស់សិស្សរួច និងអាចធ្វើការតាំងបង្ហាញមួយទៀតសម្រាប់សិស្សទាំងអស់ ប្រសិនបើអ្នកចង់។

## មេរៀនទី ១៨  បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ២

### សកម្មភាពសិស្ស

ពេលនេះ សិស្សគ្រប់រូបនឹងត្រូវបង្ហាញការងារគម្រោងរបស់គេ។ បទបង្ហាញចំនួន ៧-១០ ប្រធានបទ (សិស្សមានពេល ៣-៥ នាទីក្នុងមួយបទបង្ហាញ)។ អ្នកអាចទុកពេលបន្តិចសម្រាប់សិស្សផ្សេងលើកជាសំណួរទៅលើបទបង្ហាញនីមួយៗ។ អ្នកត្រូវធានាថា សិស្សម្នាក់ៗមានពេលវេលាស្មើៗគ្នាក្នុងការធ្វើបទបង្ហាញរបស់ពួកគេ។ អ្នកត្រូវរក្សាទុកផ្ទាំងក្រដាសធ្វើបទបង្ហាញរបស់សិស្សរួច និងអាចធ្វើការតាំងបង្ហាញមួយទៀតសម្រាប់សិស្សទាំងអស់ ប្រសិន បើអ្នកចង់។



## មេរៀនទី ១៩  បទបង្ហាញអំពីកិច្ចសម្ភាសប្រមូលព័ត៌មាន ៣

### សកម្មភាពសិស្ស

ពេលនេះ សិស្សគ្រប់រូបនឹងត្រូវបង្ហាញការងារគម្រោងរបស់គេ។ បទបង្ហាញចំនួន ៧-១០ ប្រធានបទ (សិស្សមានពេល ៣-៥ នាទីក្នុងមួយបទបង្ហាញ)។ អ្នកអាចទុកពេលបន្តិចសម្រាប់សិស្សផ្សេងលើកជាសំណួរទៅលើបទបង្ហាញនីមួយៗ។ អ្នកត្រូវធានាថា សិស្សម្នាក់ៗមានពេលវេលាស្មើៗគ្នាក្នុងការធ្វើបទបង្ហាញរបស់ពួកគេ។ អ្នកត្រូវរក្សាទុកផ្ទាំងក្រដាសធ្វើបទបង្ហាញរបស់សិស្សរួច និងអាចធ្វើការតាំងបង្ហាញមួយទៀតសម្រាប់សិស្សទាំងអស់ ប្រសិនបើអ្នកចង់។

# មេរៀនទី ២០  ការសង្ខេបខ្លឹមសារ

## សកម្មភាពសិស្សទី១

បំផុសការពិភាក្សាទៅកាន់ក្រុមទាំងមូល៖

- តើពួកគេគិតថាការងារគម្រោងរបស់គេបានដំណើរការដោយរលូនឬទេ?
- តើអ្វីដែលពួកគេមានមោទនភាព?
- តើអ្វីដែលគេអាចធ្វើបាន ខុសពីលើកនេះ?
- តើពួកគេជួបប្រទះផលវិបាកអ្វីខ្លះ?
- តើមានជំនួយប្រភេទណាដែលគេទទួបាន?
- តើពួកគេបានរៀនអ្វីខ្លះ អំពីការធ្វើការងារគម្រោង និងការទទួលខុសត្រូវ? តើពួកគេវាយតម្លៃ ប៉ាន់ប្រមាណ ឬដាក់ពិន្ទុទៅលើការអនុវត្តរបស់ពួកគេក្នុងការងារគម្រោងដោយរបៀបណា?

## សកម្មភាពសិស្សទី២

ឱ្យសិស្សសរសេរ ឬគូរក្នុងសៀវភៅកំណត់ហេតុសិក្សារបស់ពួកគេ អំពីចំណាប់អារម្មណ៍រួមអំពីការងារគម្រោង។

## សកម្មភាពសិស្សទី៣

ឱ្យសិស្សបិទផ្ទាំងព័ត៌មានគម្រោងរបស់គេលើជញ្ជាំងអគារ ឬតាមផ្លូវដើរក្នុងសាលា ក្នុងលក្ខណៈជាការតាំងពិព័រណ៍។ ដូចនេះ សិស្សដទៃទៀតដែលរៀននៅក្នុងសាលាជាមួយគ្នា ក៏អាចមើលឃើញអំពីការងារដ៏ល្អដែលពួកគេបានធ្វើ។ ពួកគេ អាចឈរតាមផ្ទាំងព័ត៌មានគម្រោងរៀងៗខ្លួនដើម្បីពន្យល់ព័ត៌មានគម្រោងទៅកាន់ «ទស្សនិកជន»។



# មេរៀនទី ២១  ការរៀបចំផែនការអាជីព ដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សមានភាពបន្សុំាជាមួយនឹងការប្រើប្រាស់ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងការរៀបចំផែនការអាជីព

អ្នកអាចឱ្យសិស្សរកព័ត៌មានអំពីប្រធានបទ ឬធ្វើតេស្តតាមអ៊ិនធឺណិត នៅក្នុងការរៀបចំផែនការអាជីព។ ប្រសិនបើអ្នកអាចសហការជាមួយនឹង គ្រូបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សិស្សអាចធ្វើលំហាត់នេះនៅក្នុងថ្នាក់ ឬក៏ជាលំហាត់នៅផ្ទះ ឬប្រើប្រាស់ទូរសព្ទឆ្លាតវៃ (ស្មាតហ្វូន) របស់គេប្រសិនបើមាន។ ពួកគេក៏អាចធ្វើកិច្ចការនេះជាគូ ឬជាក្រុមប្រសិនបើសិស្សណាមិនអាចភ្ជាប់អ៊ិនធឺណិតបាន។

## សកម្មភាពសិស្ស

អ្នកអាចប្រើទំព័រតំណភ្ជាប់ខាងក្រោមនេះ ក្នុងការធ្វើតេស្តមួយចំនួនតាមអ៊ីនធឺណេត ដើម្បីទទួលបានព័ត៌មានបន្ថែមជុំវិញការរៀបចំផែនការអាជីព៖

http://blog.connectionsacademy.com/a-career-planning-exercise-for-high-school-students/

https://www.whatcareerisrightforme.com/career-aptitude-test.php

https://www.monster.com/career-advice/article/best-free-career-assessment-tools

http://getalife.fi/game/getalife? lang=en-US



# មេរៀនទី ២២ យុថ្កាអាជីព

វត្ថុបំណងនៃមេរៀននេះគឺៈ

- ផ្តល់ឱ្យសិស្សនូវទិដ្ឋភាពមួយទៀតនៃការជ្រើសរើសអាជីពការងារ

ដំបូងផ្តល់ឱ្យសិស្សនូវការណែនាំខ្លីស្តីពី យុថ្កាអាជីពដោយ លោកSchein ។

## សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

ចែកសន្លឹកកិច្ចការដល់សិស្ស និងឱ្យពួកគេអនុវត្តការងារជាលក្ខណៈបុគ្គល។

## សន្លឹកកិច្ចការ

សូមធ្វើការវាយតម្លៃលើគុណតម្លៃ និងចេតនាក្នុងការតម្រង់ទិសទៅលើអាជីព។ អ្វីទៅដែលសំខាន់ចំពោះអ្នក នៅពេលអ្នកគិតអំពីអាជីពការងារនាពេលអនាគត?

អានសំណេរក្នុងតារាងខាងក្រោម រួចផ្តល់លំដាប់លេខរៀងតាមកម្រិតសំខាន់ដែលអ្នកជ្រើសរើសពី ១ ដល់ ៨។ លេខ ១ មានន័យថា យុថ្កាសំខាន់ខ្លាំងសម្រាប់អ្នក និងលេខ ៨ មានន័យថាមិនសូវសំខាន់។ ត្រូវចាំថា អ្នកអាចប្រើលេខទាំងនោះតែមួយដងគត់។

| | **លំដាប់** |
|---|---|
| ខ្ញុំចូលចិត្តបង្ហាញឱ្យអ្នកដទៃឃើញថាខ្ញុំពូកែជាងគេលើសកម្មភាពអ្វីមួយ។ ខ្ញុំចូលចិត្តការប្រកួតប្រជែងដោយប្រើជំនាញផ្សេងៗ ហើយធ្វើឱ្យប្រសើរលេចធ្លោរជាងគេ។ (**សមត្ថភាពបច្ចេកទេស/ការបំពេញតួនាទី**) | |
| ខ្ញុំចង់ក្លាយជាអ្នកគ្រប់គ្រងម្នាក់។ ខ្ញុំចូលចិត្តដោះស្រាយបញ្ហា និងធ្វើការជាមួយមនុស្សប្រភេទផ្សេងៗគ្នា។ ខ្ញុំជាអ្នកចូលចិត្តមានការទទួលខុសត្រូវ។ (**សមត្ថភាពគ្រប់គ្រងទូទៅ**) | |
| ខ្ញុំចង់ធ្វើការនៅក្រោមច្បាប់ និងបទបញ្ញាដែលខ្ញុំបង្កើតឡើង។ ខ្ញុំមិនចូលចិត្តបទដ្ឋានស្តង់ដានោះទេ ហើយខ្ញុំចូលចិត្តធ្វើការតែឯង។ (**ស្វយ័ត/ឯករាជ្យ**) | |
| ខ្ញុំស្វែងរកស្ថិរភាព និងការបន្តដំណើរក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំមិនចូលចិត្តការប្រថុយប្រថានទេ។ ខ្ញុំចូលចិត្តការងារប្រចាំថ្ងៃ និងកិច្ចសន្យារយៈពេលវែង។ (**សុវត្ថិភាព/ស្ថិរភាព**) | |
| ខ្ញុំចូលចិត្តការច្នៃប្រឌិត ការបង្កើតថ្មី និងការបង្កើតអាជីវកម្មខ្លួនឯង។ ភាពជាម្ចាស់ គឺពិតជាសំខាន់ណាស់សម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំជាមនុស្សឆាប់ធុញទ្រាន់។ ទ្រព្យសម្បត្តិ គឺជាសញ្ញានៃភាពជោគជ័យសម្រាប់ខ្ញុំ។ (**សហគ្រិនភាព**) | |
| ខ្ញុំចូលចិត្តការងារជួយអ្នកដទៃ ជាងប្រើប្រាស់ទេពកោសល្យរបស់ខ្ញុំ។ ខ្ញុំចង់ធ្វើការក្នុងវិស័យរដ្ឋបាលសាធារណៈ ឬផ្នែកគ្រប់គ្រងធនធានមនុស្ស។ (**សេវាកម្ម/ការលះបង់**) | |
| ខ្ញុំស្វែងរកការជំរុញលើកទឹកចិត្ត ចំពោះបញ្ហាពិបាកៗដែលខ្ញុំអាចដោះស្រាយបាន។ ខ្ញុំនឹងផ្លាស់ប្តូរការងារ នៅពេលដែលធុញនឹងការងារបច្ចុប្បន្ន។ អាជីពរបស់ខ្ញុំអាចខុសៗគ្នា។ (**ការប្រកួតប្រជែង**) | |
| ខ្ញុំពេញចិត្តនឹងរបៀបដែលខ្ញុំរស់នៅ។ ខ្ញុំគិតថាអាជីពការងារ និងជីវិតរស់នៅគឺជារឿងតែមួយ។ ខ្ញុំចូលចិត្តភាពបត់បែន។ (**បែបបទនៃជីវិត**) | |

តើអ្វីជាយុថ្កាសំខាន់បំផុតរបស់អ្នក?

_____________________________________________

*កែសម្រួលចេញពី Edgar H. Schein: Career Anchors. Discovering Your Real Values*

## សកម្មភាពសិស្សទី២

សរសេរយុថ្កាទាំងអស់នៅលើក្ដារខៀន ដោយទុកចន្លោះខាងក្រោមសម្រាប់សរសេរឈ្មោះ។ ឱ្យសិស្សគ្រប់គ្នាសរសេរឈ្មោះរបស់គេនៅពីក្រោមយុថ្កា ដែលគេគិតថាសក្ដិសមសម្រាប់គេ។ ពិនិត្យមើលលទ្ធផលជាមួយគ្នា។ តើមានយុថ្កាណាដែលមានការបោះឆ្នោតគាំទ្រច្រើនជាងគេទេ (= ឈ្មោះ)? តើមានយុថ្កាណាដែលគ្មានប្រជាប្រិយភាព? ពិភាក្សាលទ្ធផលជាមួយគ្នា ហេតុអ្វីយុថ្កាមួយចំនួនទទួលបានប្រជាប្រិយភាពជាងគេ ខណៈជាយុថ្កាមួយចំនួនទៀតមិនសូវមានប្រជាប្រិយភាព? (អ្នកមានពេល ១៥-២០នាទី)។

## សម្រាប់អ្នកប្រឹក្សាយោបល់

ការតម្រង់ទិសទៅលើអាជីព អាស្រ័យទៅលើចំណុចជាច្រើនដូចជា៖

- ចំណេះដឹងទៅលើមុខរបរខុសៗគ្នា
- ជំនាញ និងគុណភាពរបស់អ្នក
- ស្ថានភាពជីវិត
- ប្រាក់បៀវត្ស
- គុណតម្លៃរបស់ការងារ
- សហការី ចៅហ្វាយនាយ
- បរិស្ថានការងារ
- ពេលម៉ោងធ្វើការងារ
- ទីកន្លែងធ្វើការងារ
- សុវត្ថិភាពការងារ
- យេនឌ័រ និងអាយុ
- ប្រវត្តិគ្រួសារ
- តម្រូវការការអប់រំ
- ជុំវិញវប្បធម៌ទូទៅ
- បញ្ហាសុខភាពបច្ចុប្បន្ន
- ចក្ខុ សោតវិញ្ញាណ ពិការភាពផ្នែកពណ៌
- ពិការរូបរាងកាយ
- ធនធានខួរក្បាល



មិនមែនមានការងារតែមួយដែលល្អសម្រាប់អ្នកនោះទេ តែអាចមានអាជីពការងារមួយចំនួនសក្ដិសមនឹងអ្នក។

អាជីពមួយ មិនសម្រាប់តែមនុស្សម្នាក់អាចធ្វើបាននោះទេ។ មនុស្សគ្រប់រូប មានសិទ្ធិជ្រើសរើសអាជីពការងារណាមួយ ដែលមានលក្ខណៈសក្ដិសមនឹងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់គេ ហើយក៏មិនប្រាកដថា អ្នកត្រូវតែបន្តដើរលើមាគ៌ាអាជីពជាក់លាក់ណាមួយអស់មួយជីវិតនោះដែរ។ អ្នកអាចនឹងធ្វើការផ្លាស់ប្តូរអាជីពការងារច្រើនដងនៅក្នុងមួយជីវិត។ យុថ្កាអាជីព ផ្ដល់នូវទស្សនាទាននៃគុណតម្លៃរបស់អ្នក ដែលអាចនឹងនាំផ្លូវ ឬតម្រង់ទិសអ្នកក្នុងការជ្រើសរើសអាជីព។ មនុស្ស

ម្នាក់ៗ ជ្រើសរើសអាជីពការងារសម្រាប់ហេតុផលខុសៗគ្នា។ អាជីពរបស់មនុស្សម្នាក់ៗគឺ «ត្រូវបានតម្រង់ទិស» ដោយទេពកោសល្យ សមត្ថភាព ចំណូលចិត្ត ចេតនា និងគុណតម្លៃរបស់គេផ្ទាល់។

### យុថ្កាអាជីពគឺ៖

### ១. សមត្ថភាពបច្ចេកទេស/ការបំពេញតួនាទី

មនុស្សប្រភេទនេះ មានសមត្ថភាពខ្ពស់។ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មនុស្សជំពូកនេះ ពេញចិត្តនឹងធ្វើអ្វីមួយឈរនៅលំដាប់លេខ១។ ពួកគេចូលចិត្តប្រកួតប្រជែង ប្រើប្រាស់ជំនាញរបស់ពួកគេទប់ទល់នឹងការប្រជែងនោះ ហើយធ្វើការងារបានត្រឹមត្រូវ និងធ្វើឱ្យប្រសើរជាងអ្នកដទៃ។

### ២. សមត្ថភាពគ្រប់គ្រងទូទៅ

ដោយទេពកោសល្យពីធម្មជាតិ មនុស្សប្រភេទនេះ មានឧបនិស្ស័យចង់ក្លាយជាអ្នកគ្រប់គ្រង (មិនមែនដោយសារការធ្វើជាអ្នកគ្រប់គ្រងអាចទទួលបានលុយច្រើននោះទេ)។ ពួកគេចូលចិត្តការប្រឈមមុខដោះស្រាយបញ្ហា និងធ្វើការជាមួយមនុស្សប្រភេទផ្សេងៗ។ ពួកគេចូលចិត្តការទទួលខុសត្រូវ។ ដើម្បីទទួលបានជោគជ័យក្នុងការងាររបស់ខ្លួន ពួកគេក៏ត្រូវការការគាំទ្រផ្នែកស្មារតីផងដែរ។

### ៣. ស្វយ័ត/ឯករាជ្យ

តម្រូវការជាមូលដ្ឋានរបស់មនុស្សជំពូកនេះ គឺចង់ធ្វើការនៅក្រោមច្បាប់ និងបទបញ្ញាដែលខ្លួនបង្កើតឡើង ពោលគឺមិនចង់ស្ថិតក្រោមសម្ពាធអ្នកដទៃឡើយ។ ពួកគេព្យាយាមចៀសឱ្យឆ្ងាយពីបទដ្ឋានស្តង់ដាររួមរបស់ស្ថាប័ន ហើយចូលចិត្តធ្វើការតែម្នាក់ឯង។

### ៤. សុវត្ថិភាព/ស្ថិរភាព

មនុស្សដែលផ្តោតលើសុវត្ថិភាព តែងស្វែងរកស្ថិរភាព និងការបន្តដំណើរទៅមុខសន្សឹមៗ ជាមូលដ្ឋាននៃជីវិតការងាររបស់ពួកគេ។ ពួកគេចៀសឆ្ងាយពីការប្រថុយប្រថាន និងជាទូទៅស្រឡាញ់ការធ្វើការយូរអង្វែងក្នុងស្ថាប័នមួយ ឬក្នុងការងារជាក់លាក់ណាមួយរបស់ពួកគេ។

### ៥. សហគ្រិនភាព

មនុស្សប្រភេទនេះចូលចិត្តការច្នៃប្រឌិត ការបង្កើតថ្មី និងភាគច្រើនគឺផ្តោតលើការបង្កើតអាជីវកម្មដោយខ្លួនឯង។ ពួកគេខុសពីមនុស្សប្រភេទស្វយ័តភាព ដោយសារពួកគេនឹងចែករំលែកបន្ទុកការងារដល់អ្នកដទៃ។ ពួកគេគិតអំពី ភាពជាម្ចាស់សំខាន់ខ្លាំងណាស់ មនុស្សប្រភេទនេះ នឹងមានអារម្មណ៍ធុញទ្រាន់ ប្រសិនគេធ្វើការតែមួយកន្លែង។ ទ្រព្យសម្បត្តិ គឺជាសញ្ញានៃភាពជោគជ័យរបស់ពួកគេ។

### ៦. សេវាកម្ម/ការលះបង់

មនុស្សជំពូកនេះ ជាអ្នកមានសណ្តានចិត្ត ឬមានទេពកោសល្យក្នុងការជួយឈឺឆ្អាលអ្នកដទៃ។ ពួកគេនឹងមានភាពជោគជ័យខ្ពស់ នៅពេលដែលពួកគេជ្រើសរើសអាជីពការងារក្នុងវិស័យសេវាកម្មរដ្ឋបាលសាធារណៈ ឬផ្នែកគ្រប់គ្រងធនធានមនុស្ស។

### ៧. ការប្រកួតប្រជែង

មនុស្សជំពូកនេះ ជាប្រភេទមនុស្សដែលចេះជំរុញទៅមុខដោយខ្លួនឯងនៅពេលពួកគេជួបបញ្ហាប្រឈម ឬបញ្ហាស្មុគស្មាញពិបាកដោះស្រាយ។ មនុស្សប្រភេទនេះ នឹងផ្លាស់ប្តូរការងារ នៅពេលដែលគេមានអារម្មណ៍ធុញនឹងការងារបច្ចុប្បន្ន ហើយអាជីពរបស់ពួកគេអាចប្រែប្រួលពីមួយទៅមួយ។

### ៨. របៀបរបបនៃជីវិត

មនុស្សប្រភេទនេះ ចូលចិត្តពិនិត្យសង្កេតមើលពីដំណើរជីវិតរបស់ខ្លួន និងបរិយាកាសដែលខ្លួនកំពុងរស់នៅ។ ពួកគេមិនសូវមានតុល្យភាពរវាងការងារ និងជីវិតរស់នៅផ្ទាល់ខ្លួនប៉ុន្មានទេ។ ពួកគេ ច្រើនប្រើប្រាស់ពេលវេលាឈប់សម្រាករយៈពេលវែង ធ្វើដំណើរកម្សាន្តដូចជាជិះទូកតាមសមុទ្រ ឬដំណើរកម្សាន្តតាមទឹកន្លែងធម្មជាតិ។

កែសម្រួលចេញពី Edgar H. Schein: *Career Anchors. Discovering Your Real Values.*



# មេរៀនទី ២៣ ការរៀបចំផែនការអាជីពដោយប្រើតេស្ត RIASEC 1

យើងបន្តមេរៀនរៀបចំផែនការអាជីព ដោយប្រើតេស្តជម្រើសអាជីពដែលបង្កើតឡើងដោយលោក Holland។ វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សនឹងទទួលបានតេស្តអនុវត្តថ្មីមួយទៀត ជាជំនួយក្នុងការជ្រើសរើសអាជីព
- បន្សាំជាមួយនឹងតេស្តដែលបានប្រើនៅក្នុងការជ្រើសរើសអាជីពការងារ

## សកម្មភាពសិស្ស

ចែកសន្លឹកកិច្ចការឱ្យសិស្ស ហើយឱ្យពួកគេធ្វើកិច្ចការជាលក្ខណៈបុគ្គល។ ក្នុងមេរៀននេះ សិស្សប្រហែលជាមានពេលត្រឹមតែការធ្វើតេស្ត និងបូកពិន្ទុប៉ុណ្ណោះ។ ការពិភាក្សា និងការឆ្លុះបញ្ចាំង នឹងត្រូវធ្វើនៅមេរៀនបន្ទាប់។ ប្រាប់សិស្សឱ្យយកលទ្ធផលតេស្តនេះមកជាមួយ សម្រាប់មេរៀនបន្ទាប់។

## សន្លឹកកិច្ចការ

មានការងារចំនួន ៦ ក្រុម (R, I, A, S, E និង C)។ ចូរគូសជ្រើសរើសដោយប្រើសញ្ញា (✓) ក្នុងប្រអប់ខាងមុខប្រភេទការងារណាដែលអ្នកចាប់អារម្មណ៍។

| | R | | I | | A |
|---|---|---|---|---|---|
| | វិស្វករ | | មេធាវី | | អ្នកច្នៃម៉ូតសំលៀកបំពាក់ |
| | ជាងឡាន | | ជីវៈវិទូ | | វិស្វករសំណង់ស៊ីវិល |
| | ជាងផ្សារ | | ប្រវត្តិវិទូ | | តន្ត្រីករ |
| | កម្មករសំណង់ | | ជំនួយការមន្ទីរពិសោធន៍ | | តារាសម្តែង |
| | អ្នកដុតនំ | | អ្នកបកប្រែ | | អ្នករាំ |
| | មន្ត្រីនគរបាល | | រូបវិទូ | | អ្នកថតរូប |
| | ជាងឈើ | | ឱសថការី | | អ្នកកាសែត |
| | អ្នកថែសួន | | អ្នករចនារូបភាពកុំព្យូទ័រ | | អ្នករចនាក្រាហ្វិក |
| | ជាងធ្វើសក់/អ្នកកាត់ដេរ | | អ្នកបើកបរយន្តហោះ | | អ្នករចនាប្លង់ខាងក្នុង |
| | កសិករ | | គណិតវិទូ | | អ្នកសិល្បៈ (គំនូរ ជាងចម្លាក់...) |

| | S | | E | | C |
|---|---|---|---|---|---|
| | គ្រូបង្រៀន | | នាយកគ្រប់គ្រង | | លេខាធិការ |
| | កីឡាករ | | អ្នករាយការណ៍តាមទូរទស្សន៍ | | អ្នកទទួលភ្ញៀវ |
| | អ្នកម៉ាស្សា | | អ្នកធ្វើការនៅធនាគារ | | គណនេយ្យករ |
| | ចិត្តវិទូ | | ជំនួយការហាង | | អ្នករត់សំបុត្រនៅការិយាល័យ |
| | មគ្គុទ្ទេសក៍ទេសចរណ៍ | | អ្នកជួញដូរឡាន | | អ្នកកាន់ស្តុក |
| | អ្នករត់តុ | | ប្រធានផ្នែកលក់ | | បណ្ណសារ |
| | គិលានុបដ្ឋាកយិកា | | ភ្នាក់ងារលក់អចលនៈទ្រព្យ | | អ្នករត់សំបុត្រនៅធនាគារ |
| | អ្នកប្រឹក្សាយោបល់ | | អ្នកលក់ | | អ្នកគាំទ្រផ្នែកព័ត៌មានវិទ្យា |
| | អ្នកកាត់សក់ប្រុស/ស្រី | | អ្នកគ្រប់គ្រងសណ្ឋាគារ | | បេឡាករ |
| | វេជ្ជបណ្ឌិត | | អ្នកមើលថែហាង | | ស្ថិតិវិទូ |

តើអ្នកគូសជ្រើសរើសការងារនៅក្នុងក្រុមនីមួយៗបានចំនួនប៉ុន្មាន?

R____ I ____ A ____ S ____ E ____ C ____

ក្រុមនៃប្រភេទការងារដែលអ្នកជ្រើសរើសយកច្រើនជាងគេគឺ______

ក្រុមនៃប្រភេទការងារនីមួយៗ តាមតំណាងឱ្យការងារក្នុងវិស័យ៖

- R = វិស័យអនុវត្ត បច្ចេកវិទ្យាការងារខាងក្រៅ
- I = វិស័យវិទ្យាសាស្ត្រស្រាវជ្រាវ ធនធានធម្មជាតិ និងវិទ្យាសាស្ត្រសង្គម
- A = វិស័យសិល្ប: និងការទំនាក់ទំនង
- S = វិស័យសង្គមកិច្ច អប់រំបណ្តុះបណ្តាល និងសុខភាពសាធារណ:
- E = វិស័យសេវាកម្ម គ្រប់គ្រង បដិសណ្ឋារកិច្ច និងកម្សាន្ត
- C = វិស័យហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណ:

ផ្អែកលើលទ្ធផលខាងលើ តើវិស័យ ឬអាជីពការងារណាមួយដែលមានលក្ខណ:សមរម្យជាមួយអ្នក?

________________________________________________________________

________________________________________________________________

ចូរអានល្បះនីមួយៗនៅក្នុងតារាងនីមួយៗ។ បន្ទាប់មក ចូរអ្នកគូសសញ្ញាជ្រើសរើសនៅក្នុងប្រអប់ដែលមាននៅក្នុងតារាង ប្រសិនបើអ្នកយល់ស្របទៅនឹងខ្លឹមសារដែលបានលើកឡើង។

| | | | | | | |
|---|---|---|---|---|---|---|
| ខ្ញុំចូលចិត្តធ្វើការងារដែលទាក់ទងនឹងឡាន | □ | | | | | |
| ខ្ញុំចូលចិត្តលេងល្បែងផ្គុំរូបភាព | | □ | | | | |
| ខ្ញុំពូកែធ្វើការដោយឯករាជ្យ | | | □ | | | |
| ខ្ញុំចូលចិត្តធ្វើការងារជាក្រុម | | | | □ | | |
| ខ្ញុំជាមនុស្សមានមហិច្ឆិតា ខ្ញុំកំណត់គោលដៅសម្រាប់ខ្លួនឯង | | | | | □ | |
| ខ្ញុំចូលចិត្តរៀបចំការងារឱ្យមានសណ្តាប់ធ្នាប់ (ឯកសារ តុ ការិយាល័យ) | | | | | | □ |
| ខ្ញុំចូលចិត្តធ្វើការងារសាងសង់ | □ | | | | | |
| ខ្ញុំចូលចិត្តស្វែងយល់អំពីសិល្ប: និងតន្ត្រី | | | □ | | | |
| ខ្ញុំចូលចិត្តទទួលការណែនាំច្បាស់លាស់ដើម្បីអនុវត្តតាម | | | | | | □ |
| ខ្ញុំចូលចិត្តការណែនាំ ឬបញ្ចុះបញ្ចូលអ្នកដទៃ | | | | | □ | |
| ខ្ញុំចូលចិត្តធ្វើការងារពិសោធ | | □ | | | | |
| ខ្ញុំចូលចិត្តបង្រៀន ឬបណ្តុះបណ្តាលមនុស្ស | | | | □ | | |
| ខ្ញុំចូលចិត្តព្យាយាមជួយអ្នកដទៃដោះស្រាយបញ្ហារបស់ពួកគេ | | | | □ | | |
| ខ្ញុំចូលចិត្តមើលថែរក្សាសត្វ | □ | | | | | |
| ខ្ញុំមិនប្រកាន់ក្នុងការធ្វើការ ៨ ម៉ោងនៅក្នុងការិយាល័យនោះទេ | | | | | | □ |
| ខ្ញុំចូលចិត្តលក់របស់របរ | | | | | □ | |
| ខ្ញុំរីករាយនឹងការសរសេរបែបច្នៃប្រឌិត | | | □ | | | |
| ខ្ញុំរីករាយនឹងវិទ្យាសាស្ត្រ | | □ | | | | |
| ខ្ញុំគឺជាមនុស្សដែលឆាប់ចាប់យកការទទួលខុសត្រូវថ្មី | | | | | □ | |
| ខ្ញុំចាប់អារម្មណ៍ក្នុងការដោះស្រាយវិបត្តិរបស់មនុស្ស | | | | □ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ខ្ញុំរីករាយនឹងរិះគិតថាតើវត្ថុមួយវាដំណើរការបានយ៉ាងដូចម្តេច | | □ | | | | |
| ខ្ញុំចូលចិត្តរៀបវត្ថុបញ្ចូលគ្នា ឬផ្គុំវត្ថុ | □ | | | | | |
| ខ្ញុំគឺជាមនុស្សដែលមានការច្នៃប្រឌិតខ្ពស់ | | | □ | | | |
| ខ្ញុំចូលចិត្តផ្តោតទៅលើភាពលម្អិត | | | | | | □ |
| ខ្ញុំចូលចិត្តរៀបចំឯកសារ ឬវាយអត្ថបទ | | | | | | □ |
| ខ្ញុំចូលចិត្តវិភាគ (បញ្ហា/ស្ថានភាព) | | □ | | | | |
| ខ្ញុំចូលចិត្តលេងឧបករណ៍តន្ត្រី ឬច្រៀង | | | □ | | | |
| ខ្ញុំរីករាយនឹងរៀនសូត្រអំពីវប្បធម៌ផ្សេងៗ | | | | □ | | |
| ខ្ញុំចង់បង្កើតអាជីវកម្មដោយផ្ទាល់ខ្លួន | | | | | □ | |
| ខ្ញុំចូលចិត្តធ្វើម្ហូប | □ | | | | | |
| ខ្ញុំចូលចិត្តការសំដែងនៅក្នុងឆាកសម្តែង | | | □ | | | |
| ខ្ញុំគឺជាមនុស្សដែលចូលចិត្តអនុវត្ត | □ | | | | | |
| ខ្ញុំចូលចិត្តធ្វើការជាមួយលេខ ឬក្រាហ្វិក | | □ | | | | |
| ខ្ញុំចូលចិត្តពិភាក្សាអំពីបញ្ហា | | | | □ | | |
| ខ្ញុំពូកែរក្សាកំណត់ហេតុ និងកត់ត្រាការងាររបស់ខ្ញុំ | | | | | | □ |
| ខ្ញុំចូលចិត្តដឹកនាំ | | | | | □ | |
| ខ្ញុំចូលចិត្តធ្វើការនៅខាងក្រៅ | □ | | | | | |
| ខ្ញុំចូលចិត្តធ្វើការនៅខាងក្នុងការិយាល័យ | | | | | | □ |
| ខ្ញុំពូកែគណិតវិទ្យា | | □ | | | | |
| ខ្ញុំចូលចិត្តជួយអ្នកដទៃ | | | | □ | | |
| ខ្ញុំចូលចិត្តគូរគំនូរ | | | □ | | | |
| ខ្ញុំចូលចិត្តថ្លែងសុន្ទរកថា | | | | | □ | |
| ពិន្ទុសរុបរួម | | | | | | |
| | R | I | A | S | E | C |

***គណនាតែចំនួនសញ្ញាដែលបានគូសនៅក្នុងប្រអប់!***

១) យកពិន្ទុសរុបរួមខាងលើដាក់ចូលទៅក្នុងក្រឡោនខាងក្រោម៖

| | ប្រភេទបុគ្គលិកលក្ខណៈ | ពិន្ទុសរុបរួមរបស់អ្នក |
|---|---|---|
| R | ប្រាកដនិយម | |
| I | ពូកែអង្កេត | |
| A | សិល្បៈនិយម | |
| S | ប្រាស្រ័យរាក់ទាក់ | |
| E | ត្រិះរិះពិចារណា | |
| C | រក្សាសណ្តាប់ធ្នាប់ | |

ប្រភេទបុគ្គលិកលក្ខណៈរបស់ខ្ញុំគឺ _________________ (ពិន្ទុច្រើនជាងគេ)

អានការពិពណ៌នារបស់ប្រភេទបុគ្គលិកលក្ខណៈរបស់អ្នក (សូមមើលទំព័របន្ទាប់)។

តើប្រភេទបុគ្គលិកលក្ខណៈដែលអ្នកបានពិន្ទុច្រើនជាងគេ ពិពណ៌នាពីអ្នកបានត្រឹមត្រូវកម្រិតណា?

ជាទូទៅ បន្ទាប់ពីធ្វើតេស្តខាងលើរួចពិន្ទុរបស់អ្នកក្នុងចំណោមអក្សរទាំង ៦ ក្រុមខាងលើអាចនឹងមានប្រហាក់ប្រហែលគ្នា។ ទោះជាយ៉ាងនេះក្តី សូមអ្នកជ្រើសយកអក្សរចំនួន ៣ ដែលអ្នកទទួលបានពិន្ទុខ្ពស់ជាងគេសរសេរចូលក្នុងប្រលោះខាងក្រោម។ អក្សរទាំង ៣ នេះហើយ ជាលេខកូដ Holland របស់អ្នក។

២) លេខកូដ Holland របស់ខ្ញុំ

______ ______ ______

តើលេខកូដ Holland របស់អ្នកត្រូវនឹងអ្វីដែលអ្នករំពឹងទុកទេ?

តើវិស័យអាជីពការងារ និងភារកិច្ចណាដែលត្រូវនឹងអ្នកដោយផ្អែកលើលទ្ធផលតេស្តនេះ?

តើអ្នកចាប់អារម្មណ៍នៅក្នុងវិស័យទាំងនោះទេ? ជ្រើសរើស ២ ឬ ៣ វិស័យដែលអ្នកចាប់អារម្មណ៍បំផុត?

(ប្រភពសម្រាប់លំហាត់នេះ៖ សៀវភៅប្រឹក្សាអាជីព និងព័ត៌មានស្ដីពីការសិក្សាជំនាញ ក្រ.អយក២០១៦)

| ប្រភេទនៃបុគ្គលិកលក្ខណៈ | ការពិពណ៌នាទូទៅ | វិស័យនៃអាជីពការងារ |
|---|---|---|
| ប្រាកដនិយម<br>R | មនុស្សប្រាកដនិយម គឺជាអ្នកដែលមានការអនុវត្តជាក់ស្តែង មានស្ថេរភាព មានលក្ខណៈធម្មជាតិ មានការតស៊ូ សុភាពរាបសា មានសន្តិភាព បើកចំហ និងអៀនប្រៀន។ ពួកគេមានសម្បទាខាងអត្តពលកម្ម ឬមេកានិច។ ពួកគេចូលចិត្តធ្វើការជាមួយម៉ាស៊ីន ឧបករណ៍ រុក្ខជាតិ ឬសត្វ ឬបរិយាកាសខាងក្រៅ ប៉ុន្តែពួកគេមិនចូលចិត្តការងារក្នុងការិយាល័យ ហើយក៏អាចមានការលំបាកក្នុងការសម្របខ្លួនក្នុងបរិយាកាសសង្គមជាមួយគេ។ | កសិកម្ម<br>សេវាសុខភាព<br>ព័ត៌មានវិទ្យា<br>មេកានិច<br>វិស្វកម្ម<br>ចំណីអាហារ<br>និងបដិសណ្ឋារកិច្ច |
| ពូកែអង្កេត<br>I | អ្នកពូកែអង្កេត គឺជាអ្នកវិភាគវែកញែក មានភាពឆ្លាតវៃ ជឿលើវិទ្យាសាស្ត្រ ចេះត្រិះរិះពិចារណា ចង់ដឹង មានភាពឯករាជ្យ ចេះបម្រុងទុក និងគោរពពេលវេលា។ ពួកគេចូលចិត្តធ្វើការអង្កេត វិភាគ វាយតម្លៃ ឬដោះស្រាយបញ្ហាផ្សេងៗ។ ពួកគេជាមនុស្សដែលផ្តោតសំខាន់លើការងារ និងរីករាយជាមួយនឹងកិច្ចការដែលស្វែងរកការបកស្រាយចំពោះបញ្ហាមិនច្បាស់លាស់។ ពួកគេចូលចិត្តធ្វើការបែបឯករាជ្យ និងមិនចូលចិត្តរឿងធ្វើសកម្មភាពដដែលៗ។ ពួកគេក៏អាចជាមនុស្សខ្វះខាតជំនាញភាពជាអ្នកដឹកនាំ។ | ជីវៈវិទ្យា<br>វិស្វកម្ម<br>គីមីវិទ្យា<br>ឱសថសាស្ត្រ/វះកាត់<br>សេដ្ឋកិច្ច<br>ចិត្តវិទ្យា |
| សិល្បៈនិយម<br>A | មនុស្សដែលមានសិល្បៈ គឺជាអ្នកដែលមានភាពច្នៃប្រឌិត បើកចំហ ប៉ិនប្រសប់ មិនយកលំនាំតាមគេ ចេះវែកញែក មានភាពឯករាជ្យ និងជាមនុស្សចិត្តច្រើន។ ពួកគេមិនចូលចិត្តរចនាសម្ព័ន្ធ និងវិន័យនោះទេ តែពួកគេចូលចិត្តធ្វើការងារនៅក្នុងបរិយាកាសឯករាជ្យដោយប្រើប្រាស់ការស្រមើស្រមៃផ្ទាល់ខ្លួន។ ពួកគេ មានឆន្ទៈក្នុងការប្រកួតប្រជែង ដើម្បីសាកល្បងអ្វីដែលថ្មី ប៉ុន្តែពួកគេមិនមែនជា មនុស្សដែលមានភាពល្អិតល្អន់នោះឡើយ។ | សិល្បៈ និងទំនាក់ទំនង<br>កែសម្ផស្ស<br>វិចិត្រសិល្បៈ<br>ថតរូប<br>វិទ្យុ និងទូរទស្សន៍<br>រចនាប្លង់ខាងក្នុង<br>ស្ថាបត្យកម្ម |
| ប្រាស្រ័យរាក់ទាក់<br>S | ក្រុមនេះ គឺជាអ្នកដែលមានភាពរួសរាយរាក់ទាក់ ចិត្តល្អ ចេះអធ្យាស្រ័យ ចេះជួយទុក្ខធុរៈ ចេះសហការណ៍ ជួយគាំទ្រ ចុះសម្រុងជាមួយអ្នកដទៃ និងមានការទទួលខុសត្រូវ។ ពួកគេចូលចិត្តធ្វើការងារជាមួយមនុស្ស និងមានការខ្វល់ខ្វាយពីសុខទុក្ខរបស់អ្នកដទៃ។ ពួកគេមានជំនាញខាងនិយាយ និងប្រាស្រ័យទាក់ទង។ មនុស្សប្រភេទនេះមិនចូលចិត្តធ្វើការជាមួយម៉ាស៊ីន ឬក៏ការងារដែលមានក្រឹត្យក្រម មានរចនាសម្ព័ន្ធច្រើននោះទេ។ | អ្នកប្រឹក្សាយោបល់<br>គិលានុប្បដ្ឋាកយិកា<br>ព្យាបាលបែបរូបសាស្ត្រ<br>ផ្សាយពាណិជ្ជកម្ម<br>ទំនាក់ទំនងសាធារណៈ<br>អប់រំ<br>សេវាសុខភាព<br>សេវាសាធារណៈ និង<br>សេវាអតិថិជន |

| | | |
|---|---|---|
| ត្រិះរិះពិចារណា<br>E | មនុស្សត្រិះរិះពិចារណា គឺជាអ្នកដែលមានមហិច្ឆតា មានការលើកទឹកចិត្ត សុទិដ្ឋិនិយម មានទំនាក់ទំនងសង្គម មានការជឿជាក់លើខ្លួនឯង និងឆ្លាតវៃ។ ពួកគេឱ្យតម្លៃទៅលើកេរ្តិ៍ឈ្មោះ អំណាច ប្រាក់កាស និងតំណែង។ ពួកគេចូលចិត្តធ្វើការជាមួយអ្នកដទៃ និងរីករាយក្នុងការធ្វើឱ្យអ្វីមួយអាចកើតឡើងបាន។ ពួកគេ គឺជាអ្នកដឹកនាំដ៏ក្លៀវក្លាជាមួយនឹងជំនាញនិយាយ ហើយនឹងមានឆន្ទៈខ្ពស់ក្នុងការចូលរួមសម្រេចគោលដៅ និងការកើនឡើងនូវសេដ្ឋកិច្ចរបស់ស្ថាប័ន។ ពួកគេជាប្រភេទមនុស្សដែលមិនចូលចិត្តវិទ្យាសាស្ត្រ និងការគិតជាប្រព័ន្ធនោះទេ។ | អចលនទ្រព្យ<br>ទីផ្សារ/ផ្នែកលក់<br>ច្បាប់<br>វិទ្យាសាស្ត្រនយោបាយ<br>ពាណិជ្ជកម្មអន្តរជាតិ<br>ធនាគារ/ហិរញ្ញវត្ថុ<br>ជំនួញ |
| រក្សាសណ្តាប់ធ្នាប់<br>C | មនុស្សប្រភេទនេះ គឺជាអ្នកដែលល្អិតល្អន់ មានសណ្តាប់ធ្នាប់ ម៉ត់ចត់ មានសមត្ថភាព ចេះទទួលខុសត្រូវ មានការប្រុងប្រយ័ត្ន ចេះថែរក្សា និងបម្រុងទុក។ ពួកគេចូលចិត្តបរិយាកាសដែលរៀបចំរៀបរយ ទៅតាមដំណើរការ និងលំដាប់លំដោយដែលបានកំណត់ទុក។ ពួកគេជាមនុស្សដែលពូកែបំផុត ខាងកំណត់ការងារ/ការទទួលខុសត្រូវ។ ពួកគេចូលចិត្តធ្វើការជាមួយទិន្នន័យ និងភាពច្បាស់លាស់ជាជាងធ្វើការជាមួយទស្សនៈ។ ជាពិសេស ពួកគេចៀសវាងស្ថានភាពមិនច្បាស់លាស់ និងមានបញ្ហា។ | គណនេយ្យ<br>ការងាររាយការណ៍<br>សម្រាប់តុលាការ<br>ធានារ៉ាប់រង<br>រដ្ឋបាល<br>វេជ្ជសាស្ត្រ<br>ធនាគារ<br>ការងារដំណើរការ<br>ទិន្នន័យ<br>សេដ្ឋកិច្ច |

## សម្រាប់អ្នកប្រឹក្សាយោបល់៖



ក្របខណ្ឌការងារហូឡង់ (Holland Occupational Themes) គឺជាទ្រឹស្តីមួយដែលបានបង្កើតឡើងដោយ John L. Holland។ Holland បានលើកឡើងថាជម្រើសនៃការងារ គឺជាការបង្ហាញអំពីបុគ្គលិកលក្ខណៈរបស់បុគ្គល។ ជាងនេះទៅទៀត ការជ្រើសរើសអាជីពណាមួយ មហាវិទ្យាល័យណាមួយ ឬកម្មវិធីបណ្តុះបណ្តាលណាមួយដែលវាសក្តិសមនឹងបុគ្គលិកលក្ខណៈរបស់អ្នក ភាគច្រើនវាអាចនាំឱ្យអ្នកមានភាពរីករាយ និងមានភាពជោគជ័យ។

បើតាមលោក Holland គេអាចធ្វើចំណាត់ថ្នាក់ក្រុមមនុស្សជាប្រាំមួយជំពូកផ្សេងៗគ្នា តាមរយៈបុគ្គលិកលក្ខណៈ និងចំណាប់អារម្មណ៍របស់ពួកគេ ដោយក្នុងនោះមានប្រភេទដូចជា ប្រាកដនិយម ពូកែអង្កេត សិល្បៈនិយម ប្រាស្រ័យរាក់ទាក់ ត្រិះរិះពិចារណា និងរក្សាសណ្តាប់ធ្នាប់។ បុគ្គលិកលក្ខណៈទាំងប្រាំមួយនេះ បង្កើតបានជាពាក្យកាត់ថា RIASEC។

វាមានសារៈសំខាន់ណាស់ ក្នុងការយកចិត្តទុកដាក់ទៅលើ បុគ្គលិកលក្ខណៈដ៏ខ្លាំងក្លាណាមួយ។ ដោយឡែកបុគ្គលិកលក្ខណៈ នៃការងារ មិនអាចបកស្រាយឱ្យបានក្បោះក្បាយតាមរយៈក្រុមតែមួយជំពូកនោះទេ។ Holland បានបញ្ជាក់ថា យើងទាំងអស់គ្នាសុទ្ធតែមាន លក្ខខណ្ឌ និងភាពស្រដៀងគ្នាមួយចំនួនជាមួយនឹងក្រុមជាច្រើននៅក្នុងក្រុមទាំង៦ជំពូកនេះ (R, I, A, S, E ឬ C) ប៉ុន្តែក្នុងនោះ មានក្រុម ចំនួន ៣ ជំពូកដែលមនុស្សយើងមានភាពទាក់ទងជាចម្បង។ ក្រុមទាំង ៣នេះ មានបីតួអក្សរជាកូដរបស់ Holland និងជាកូដនៃ ការចាប់អារម្មណ៍របស់យើង។ លើសពីនេះ មានកូដនៃការចាប់អារម្មណ៍ជាង ១៥០កូដ (ឧ. RES, IAS ជាដើម)។

តេស្តកូដហូឡង់ គឺជាទម្រង់មួយដែលមានប្រជាប្រិយភាពបំផុត ក្នុងការប្រើប្រាស់សម្រាប់ការ តេស្តអំពីអាជីពការងារនាពេលបច្ចុប្បន្ន។ ទោះបីជាតេស្តនេះមិនតម្រូវឱ្យមានចម្លើយជាក់លាក់ក៏ដោយ ក៏មិនមែនមានន័យថាតេស្តសមត្ថភាពការងារ មិនអាចជឿជាក់បាននោះដែរ។ ទោះជាយ៉ាងណាក្តី មានការណែនាំឱ្យចងចាំថា លទ្ធផលនៃការធ្វើតេស្តនេះអាចត្រឹមតែបង្ហាញផ្លូវពីរបៀបនៃការជ្រើសរើសគន្លងអាជីពប៉ុណ្ណោះ។

តេស្តនេះត្រូវបានរៀបចំឡើងដើម្បីជួយដល់សិស្ស ក្នុងការផ្គូផ្គងចំណង់ចំណូលចិត្ត និងជំនាញ ជាមួយនឹងអាជីពការងារដែលពាក់ព័ន្ធ។ វាអាចជួយដល់សិស្សានុសិស្សក្នុងការចាប់ផ្តើមគិតអ្វីដែលជាបុគ្គលិកលក្ខណៈផ្ទាល់របស់ពួកគេ ហើយលក្ខណៈទាំងនោះ វាសក្តិសមនឹងបរិយាកាសការងារ និងអាជីពជាក់លាក់មួយណាពិតប្រាកដ។



## មេរៀនទី ២៤ ការរៀបចំផែនការអាជីពដោយប្រើតេស្ត RIASEC 2

មេរៀនមុន យើងបានធ្វើតេស្តសម្រាប់ការជ្រើសរើសអាជីព។ ពេលនេះ យើងបន្តការឆ្លុះបញ្ចាំងអំពីលទ្ធផលរបស់វា។ មុនដំបូង អ្នកត្រូវផ្តល់នូវការណែនាំឡើងវិញដល់សិស្សនូវអ្វីជាតេស្ត RIASEC (ប្រើប្រាស់អត្ថបទសម្រាប់អ្នកប្រឹក្សាយោបល់ដែលមាននៅក្នុងចុងមេរៀនមុន ប្រហែល ១០នាទី)

### សកម្មភាពសិស្សទី១ (រយៈពេល ១០-១៥ នាទី)



បង្កើតការពិភាក្សាជាក្រុមអំពីតេស្តនេះ៖

- តើពួកគេមានអារម្មណ៍បែបណាចំពោះការធ្វើតេស្តនេះ?
- តើពួកគេគិតថាលទ្ធផលនៃការធ្វើតេស្តនេះ ត្រឹមត្រូវដែរឬទេ?
- តើពួកគេមានសំណួមពរ ឬគំនិតថ្មីអ្វីទេ សម្រាប់អាជីពដោយផ្អែកលើលទ្ធផលតេស្ត *RIASEC*?

សរសេររាល់អាជីពវិជ្ជាជីវៈ ដែលជាលទ្ធផលចេញពីតេស្ត RIASEC ចូលក្នុងផ្ទាំងក្រដាសធំឱ្យមានឆ្ងាយពីគ្នាបន្តិច ដើម្បីមានគម្លាតទុកសរសេរលំហាត់បន្ទាប់។

### សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

ឱ្យសិស្សកាត់ក្រដាសរាងស្លឹកឈើ ហើយសរសេរឈ្មោះរបស់ពួកគេ រួចបិទនៅជិតអាជីពវិជ្ជាជីវៈដែលបានសរសេរនៅលើផ្ទាំងក្រដាស។

### សកម្មភាពសិស្សទី៣ (រយៈពេល ២០ នាទី)

ឱ្យសិស្សគូរចូលក្នុងសៀវភៅ ឬកំណត់ហេតុសិក្សា នូវរូបភាពការងារនាពេលអនាគត ដោយឱ្យពួកគេស្រមៃថា នៅពេលពួកគេធ្វើការងារនោះ តើពួកគេនឹងស្លៀកសម្លៀកបំពាក់បែបណា? មានអ្វីខ្លះដែលនៅជុំវិញគេ? អ្នកណាខ្លះដែលពាក់ព័ន្ធ? តើពួកគេធ្វើការក្នុងបរិយាកាសបែបណា? នៅពេលដែលពួកគេធ្វើរួចហើយ ពួកគេអាចចែករំលែកគំនូររបស់គេទៅកាន់ក្រុមដែលមានគ្នាពី ៥-៦ នាក់។

# មេរៀនទី ២៥ ល្បែងសិក្សាអំពីគុណតម្លៃ

អ្នកត្រូវបន្ថែមកត្តាចុងក្រោយទៅក្នុងជម្រើសអាជីពការងាររបស់សិស្ស នោះគឺ «គុណតម្លៃ»។ វត្ថុបំណងនៃមេរៀននេះគឺ៖

- បង្កើនការយល់ដឹងរបស់សិស្សពីសារៈសំខាន់នៃគុណតម្លៃ ទៅលើការរៀបចំផែនការអាជីព។

## សកម្មភាពសិស្សទី១ (រយៈពេល ៣០ នាទី)

ឱ្យសិស្សប្រើប្រាស់សន្លឹកសៀវភៅរបស់ពួកគេ។ ពួកគេត្រូវកាត់ក្រដាសតូចៗចំនួន ៣៨ សន្លឹក និងសរសេរគុណតម្លៃមួយទៅលើក្រដាសមួយសន្លឹក (អ្នកត្រូវសរសេរគុណតម្លៃទៅលើក្តារខៀនឱ្យសិស្សចម្លង)។

ផ្តល់ការណែនាំនេះទៅដល់សិស្ស៖ ពេលនេះពួកគេមានគុណតម្លៃដែលពាក់ព័ន្ធនឹងការងារចំនួន ៣៨ គោលដៅ ឬការពិពណ៌នាអំពីការងារ។ ឱ្យសិស្សជ្រើសរើសគុណតម្លៃចំនួន ១០ ទៅ ២០ ដែលគេមានអារម្មណ៍ថាសំខាន់សម្រាប់អនាគតការងាររបស់គេ។ បន្ទាប់មក ជ្រើសរើសគុណតម្លៃដែលសំខាន់បំផុតតាមវិធីនេះ៖ ជ្រើសយកគុណតម្លៃពីរ ហើយប្រៀបធៀបថា មួយណាសំខាន់ជាង។ ដាក់គុណតម្លៃដែលសំខាន់នៅខាងលើគេបំផុត និងរាយចុះមកក្រោមតាមលំដាប់នៃកម្រិតសំខាន់ដែលអ្នកយល់ឃើញ។

## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

ឱ្យសិស្សចម្លង ឬបិទកាតគុណតម្លៃរបស់ពួកគេចូលក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។

## សកម្មភាពសិស្សទី៣ (រយៈពេល ១០ នាទី)

លើកសំណួរឱ្យសិស្សគ្រប់គ្នាគិតដោយខ្លួនឯង៖ តើគុណតម្លៃនេះនឹងធ្វើឱ្យមានការប្រែប្រួលជម្រើសការងារ ឬក៏ធ្វើឱ្យអាជីពរបស់ពួកគេកាន់តែច្បាស់ជាងមុនឬទេ? ពួកគេអាចផ្លាស់ប្តូរ និងចែករំលែកការគិតរបស់ពួកគេជាមួយដៃគូ។ (ប្រហែល ១០នាទី)។



## គុណតម្លៃ

ការងារឯករាជ្យ
ការជួយអ្នកដទៃ
ការច្នៃប្រឌិត
ការផ្សងព្រេង
ការចូលរួមក្នុងសកម្មភាពសង្គម
ការធ្វើសេចក្តីសម្រេចចិត្ត
កន្លែងការងារអចិន្ត្រៃយ៍
មានឋានៈនៅក្នុងសង្គមខ្ពស់
ប្រឹក្សាយោបល់/ការណែនាំ
ភាពចម្រុះ
សហគមន៍ការងារល្អ
មិត្តភាពជាមួយសហការី
របៀបរៀបរយ
ការចូលរួមសង្គម/ការធ្វើការងារជាមួយមនុស្ស
ធម្មជាតិ និងបរិស្ថាន
ប្រាក់ខែល្អ
ភាពកែច្នៃ
កាលវិភាគខ្លួនឯង/ស្វយ័ត
ការទាមទារ

ភាពប្រកួតប្រជែង
ការអភិវឌ្ឍខ្លួនឯង
សុវត្ថិភាព
ជំនាញ
យុត្តិធម៌
សមភាព
សិល្បៈ
ភាពរីករាយ
ភាពច្នៃប្រឌិតថ្មីៗ
ភាពបន្ទាន់
ផលិតភាព
គុណតម្លៃនៃការងារ
ជំនាញអភិវឌ្ឍ
ភាពជោគជ័យ
បញ្ហាប្រឈម
បញ្ហាប្រឈមផ្នែករាងកាយ
ប៉ះពាល់ដល់មនុស្ស
មនោគមវិជ្ជា

## មេរៀនទី ២៦ ជម្រើសនៃការអប់រំបន្ត ១

វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សនឹងយល់ដឹងពីប្រព័ន្ធអប់រំបន្តនៅកម្ពុជា
- សិស្សនឹងយល់ដឹងពីជម្រើសនៃការអប់រំបន្តដើម្បីអភិវឌ្ឍអាជីពការងាររបស់ពួកគេ

បន្ទាប់ពីដំណាក់កាលប្រមូលព័ត៌មាន សម្ភាស និងពិភាក្សាជាមួយគ្រូប្រឹក្សាយោបល់ក្នុងមេរៀនមុនរួចមក សិស្សអាចរកឃើញនូវជម្រើសអាជីពដែលពួកគេចាប់អារម្មណ៍ និងធ្វើការជ្រើសរើសអាជីពការងារជាបណ្តោះអាសន្នយ៉ាងហោច ២-៣ ដើម្បីត្រៀមសម្រាប់ការសម្រេចចិត្តជាក់លាក់នៅពេលខាងមុខនេះ។

គោលបំណងសំខាន់ក្នុងមេរៀននេះ គឺនឹងជួយសិស្សប្រមូលព័ត៌មានដែលពាក់ព័ន្ធអំពីការអប់រំ និងការបណ្តុះបណ្តាល ឆ្លើយតបនឹងការអភិវឌ្ឍអាជីពបណ្តោះអាសន្ននៅពេលអនាគតរបស់ពួកគេ ហើយជួយគាំទ្រពួកគេក្នុងការរៀបចំផែនការនៃការអប់រំបន្តឱ្យទទួលបានជោគជ័យ។ វាជាការសំខាន់ក្នុងការលើកទឹកចិត្តសិស្ស ឱ្យប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗគ្នាដែលអាចទទួលបានពីការអាន ការប្រើប្រាស់អ៊ិនធឺណិត អ្នកប្រឹក្សាយោបល់លើអាជីព ឪពុកម្តាយ មិត្តភក្តិ ឬការសម្ភាសអ្នកដែលកំពុងបំពេញការងារក្នុងអាជីពនោះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការសម្រេចចិត្តជ្រើសរើសអាជីព និងជម្រើសសមស្របសម្រាប់ការអប់រំបន្ត។ ពួកគេអាចសិក្សាប្រៀបធៀបព័ត៌មានដែលប្រមូលបាន ដើម្បីធ្វើសេចក្តីព្រាងផ្ទាល់ខ្លួនស្តីពី ជម្រើសអាជីព និងការអប់រំបន្ត នៅពេលអនាគត។ អ្នកប្រឹក្សាយោបល់ ដើរតួនាទីដ៏សំខាន់ក្នុងការដឹកនាំតម្រង់សិស្សឱ្យ ប្រើប្រាស់ប្រភពព័ត៌មានដែលត្រូវនឹងគោលបំណងសិស្ស។

### សកម្មភាពសិស្ស

ចែកសន្លឹកកិច្ចការឱ្យសិស្ស ឬសរសេរសំណួរនៅលើក្តារខៀន។ ឱ្យពួកគេធ្វើអ្វីដែលអាចធ្វើបានសម្រាប់មេរៀននេះ ហើយសំណួរដែលនៅសល់ទុកធ្វើលំហាត់នៅផ្ទះ។ ពួកគេនឹងប្រើប្រាស់ពេលវេលាមេរៀនទាំងស្រុងសម្រាប់លំហាត់នេះ។ អ្នកក៏អាចអនុញ្ញាតឱ្យពួកគេចេញពីថ្នាក់មុនម៉ោងបន្តិចដើម្បីប្រមូលព័ត៌មាននៅកន្លែងផ្សេង។

### សន្លឹកកិច្ចការ៖ ការស្វែងរកការអប់រំ

ផ្អែកលើការវិះរក និងរបកគំហើញពីវគ្គមុន កំណត់យកជម្រើសអាជីពការងារចំនួន ២-៣ ដែលអ្នកចាប់អារម្មណ៍បំផុត។

តើការអប់រំ និងការបណ្តុះបណ្តាលប្រភេទណា ដែលត្រូវការនៅក្នុងអាជីពការងារទាំងអស់នេះ? តើទិដ្ឋភាពសំខាន់ដទៃទៀតណាខ្លះដែលអ្នកគួរតែដឹងអំពីការអប់រំ ឬការបណ្តុះបណ្តាល? សំណួរដែលមាននៅលើតារាងនឹងជួយអ្នកក្នុងការវិះរកព័ត៌មាននេះ។ ស្រាវជ្រាវរកព័ត៌មាន ហើយបំពេញនៅក្នុងតារាង។ ប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗគ្នាដូចជា កាតាឡុក អ៊ិនធឺណិត និងជួបជាមួយអ្នកប្រឹក្សាអាជីព ឪពុកម្តាយ ឬមនុស្សពេញវ័យដទៃទៀត។ អ្នកក៏អាចសម្ភាសនរណាម្នាក់ដែលកំពុងសិក្សា ឬធ្វើការក្នុងវិស័យណាមួយ!

នៅពេលដែលអ្នកប្រមូលព័ត៌មានបានទាំងអស់នៅលើតារាងហើយ អ្នកអាចចងក្រងព័ត៌មានដែលពាក់ព័ន្ធនឹងផែនការអប់រំបន្ត និងជម្រើសអាជីព ហើយធ្វើការប្រៀបធៀបរវាងអាជីពទាំងនោះ រួចចាប់ផ្តើមក្នុងការរៀបចំផែនការនៃការអប់រំបន្តរបស់អ្នក។

| | អាជីព ក | អាជីព ខ | អាជីព គ |
|---|---|---|---|
| អាជីពដែលខ្ញុំចាប់អារម្មណ៍ | | | |
| ខ្ញុំចាប់អារម្មណ៍នឹងអាជីពនេះដោយសារតែ... | | | |
| តើការអប់រំ និងការបណ្តុះបណ្តាលប្រភេទណាដែលត្រូវការនៅក្នុងអាជីពការងារក្នុងវិស័យនេះ? | | | |
| តើជំនាញដែលអ្នកទទួលបានពីការអប់រំ ឬបណ្តុះបណ្តាលបន្តអាចធ្វើការងារក្នុងវិស័យអ្វីខ្លះ? | | | |
| តើភារកិច្ចប្រភេទណាដែលអ្នកអាចធ្វើបានបន្ទាប់ពីការអប់រំ ឬការបណ្តុះបណ្តាលនេះរួច? | | | |

| | អាជីព ក | អាជីព ខ | អាជីព គ |
|---|---|---|---|
| តើស្ថាប័នណាដែលផ្តល់បានការអប់រំ ឬការបណ្តុះបណ្តាលនេះ? តើស្ថាប័នមួយណាដែលនៅជិតផ្ទះអ្នក? | | | |
| តើតម្រូវការអ្វីខ្លះសម្រាប់ការចូលសិក្សាការអប់រំ ឬការបណ្តុះបណ្តាលនេះ? | | | |
| តើការអប់រំ ឬកម្មវិធីបណ្តុះបណ្តាលនេះមានរយៈពេលប៉ុន្មាន? | | | |
| រាយបញ្ជីការងារ និងមុខរបរអាជីពដែលការអប់រំនេះ នឹងផ្តល់ជំនាញ និងចំណេះដឹងសម្រាប់ការងារនោះ។ | | | |



# មេរៀនទី ២៧ ជម្រើសនៃការអប់រំបន្ត ២

## សកម្មភាពសិស្សទី១ (រយៈពេល ១០ នាទី)

ឱ្យសិស្សធ្វើបទបង្ហាញនូវអ្វីដែលគេរកឃើញអំពីការអប់រំសម្រាប់អភិវឌ្ឍអាជីពការងារ និង ពិនិត្យមើលថាតើលទ្ធផលនោះ មានផលប៉ះពាល់លើផែនការអាជីពរបស់ពួកគេដែរឬទេ? ពួកគេអាចប្រាប់បានដោយសេរីនូវលទ្ធផលដែលបានមកពីការស្វែងរកព័ត៌មាន។

## សកម្មភាពសិស្សទី២ (រយៈពេល ៤០ នាទី)

ឱ្យសិស្សធ្វើផែនការអប់រំបន្តដោយយោងតាមអ្វីដែលពួកគេរកឃើញ។ ពួកគេអាចប្រើប្រាស់សន្លឹកកិច្ចការ ឬសរសេរចូលសៀវភៅរបស់គេ។ ប្រសិនបើពួកគេមិនអាចបញ្ចប់លំហាត់នេះនៅក្នុងថ្នាក់បាន ពួកគេអាចយកទៅបញ្ចប់នៅផ្ទះបាន។

## សន្លឹកកិច្ចការ

លំហាត់នេះ នឹងជួយឱ្យអ្នកពិចារណា និងរៀបចំផែនការបន្ទាប់ទៀត។ អ្នកបានរិះរកជម្រើសអាជីពបណ្ដោះអាសន្ន ២ រួចហើយ។ ពេលនេះ ដល់ពេលដែលត្រូវបរិយាយអំពីជម្រើសរបស់អ្នក និងទទួលស្គាល់គោលដៅអាជីពរបស់អ្នក!

តើផែនការបែបណាដែលអ្នកមានបន្ទាប់ពីរៀនចប់? សិក្សា ការងារ អ្វីផ្សេងទៀត? សរសេរគំនិត និងការគិតរបស់អ្នកនៅលើសៀវភៅកត់ត្រា។



## ផែនការសិក្សារបស់ខ្ញុំ

តើអ្នកមានផែនការជាក់លាក់ហើយឬនៅ សម្រាប់ការសិក្សាបន្តរបស់អ្នក? ត្រូវរៀបចំឱ្យបានល្អជាមុន ស្រាវជ្រាវរកព័ត៌មានដែលពាក់ព័ន្ធ និងដំណើរការដាក់ពាក្យ ហើយបំពេញក្នុងទម្រង់ខាងក្រោម។ អ្នកត្រូវមានជម្រើសយ៉ាងហោចណាស់ ២ សម្រាប់ផែនការសិក្សារបស់អ្នក ដើម្បីឱ្យមានទ្វារបើកចំហរសម្រាប់អនាគតកាន់តែច្រើន កាន់តែប្រសើរ។

| **ជម្រើសទី ១** | **ជម្រើសទី ២** |
|---|---|
| ការអប់រំ ឬកម្មវិធីបណ្តុះបណ្តាល<br><br>វិទ្យាស្ថានអប់រំ (មជ្ឈមណ្ឌលបណ្តុះបណ្តាល សកលវិទ្យាល័យ មហាវិទ្យាល័យ)<br><br>សញ្ញាបត្រ/វិញ្ញាបនបត្រ<br><br>តម្រូវការសម្រាប់ការអនុញ្ញាតឱ្យចូល<br><br>និងលក្ខណៈវិនិច្ឆ័យ<br><br>ពេលណាដែលត្រូវដាក់ពាក្យ/ថ្ងៃផុតកំណត់សម្រាប់ដាក់ពាក្យ<br><br>ដាក់ពាក្យដោយរបៀបណា/ពាក្យសុំ និងតម្រូវការបន្ថែម | ការអប់រំ ឬកម្មវិធីបណ្តុះបណ្តាល<br><br>វិទ្យាស្ថានអប់រំ (មជ្ឈមណ្ឌលបណ្តុះបណ្តាល សកលវិទ្យាល័យ មហាវិទ្យាល័យ)<br><br>សញ្ញាបត្រ/វិញ្ញាបនបត្រ<br><br>តម្រូវការសម្រាប់ការអនុញ្ញាតឱ្យចូលរៀន និងលក្ខណៈវិនិច្ឆ័យ<br><br>ពេលណាដែលត្រូវដាក់ពាក្យ/ថ្ងៃផុតកំណត់សម្រាប់ដាក់ពាក្យ<br><br>ដាក់ពាក្យដោយរបៀបណា/ពាក្យសុំ និងតម្រូវការបន្ថែម<br><br>ប្រលងចូលនៅពេលណា?<br><br>សម្ភារៈដែលត្រូវការលំហាត់វាយតម្លៃជម្រុះ |

តើនឹងមានរឿងអ្វីកើតឡើង ប្រសិនបើគេមិនទទួលអ្នកឱ្យចូលរៀនក្នុងវគ្គបណ្តុះបណ្តាលណាមួយ ពាក់ព័ន្ធនឹងអាជីពការងាររបស់អ្នក ដែលអ្នកបានដាក់ពាក្យ? តើអ្នកមានជម្រើសផ្សេងពីនេះទេ? សូមសរសេរផែនការជំនួយរបស់អ្នកនៅលើសៀវភៅកត់ត្រា។



## ផែនការការងាររបស់ខ្ញុំ

តើអ្នកមានផែនការស្វែងរកការងារ និងការងារភ្លាមៗបន្ទាប់ពីរៀនចប់ឬទេ? លំហាត់នេះ នឹងជួយ អ្នករៀបចំជំហានបន្ទាប់ក្នុងការស្វែងរកការងារ។

**ផែនការការងាររបស់ខ្ញុំ**

តើខ្ញុំចង់ធ្វើការនៅកន្លែងណា?

តើនរណាដែលខ្ញុំអាចទាក់ទងសួរសម្រាប់រកការងារ? តើខ្ញុំអាចទាក់ទងពួកគេដោយរបៀបណា?

តើខ្ញុំអាចរកព័ត៌មានអំពីការងារដែលទំនេរនៅកន្លែងណា?

តើត្រូវដាក់ពាក្យរកការងារធ្វើដោយរបៀបណា? តើមានពាក្យសុំការងារប្រភេទណាដែលគេត្រូវការ?

តើត្រូវត្រៀមសម្រាប់កិច្ចសម្ភាសន៍ការងារដោយរបៀបណា?

ព័ត៌មានពាក់ព័ន្ធផ្សេងទៀត



# មេរៀនទី ២៨ ដំណើរការសិក្សាខ្ញុំ

វត្ថុបំណងនៃមេរៀននេះគឺៈ

- ឱ្យសិស្សយល់ថា ការសិក្សាជាដំណើរការពេញមួយជីវិត និងមានជំហានជាបន្តបន្ទាប់គ្នា

## សកម្មភាពសិស្សទី១

គោលបំណងនៃសកម្មភាពនេះគឺ ដើម្បីសម្របសម្រួលឱ្យសិស្សបង្ហាញនូវបទពិសោធន៍សំខាន់ៗក្នុងការសិក្សាអំឡុងពេលនៅសាលារៀន ជីវិតប្រចាំថ្ងៃ និងអាជីពការងារនាអនាគត។ សិស្សអាចមើលឃើញកាន់តែច្បាស់នូវមនុស្សសំខាន់ៗដែលនៅជុំវិញខ្លួនគេ និងកំណត់ថា នរណាខ្លះអាចមានឥទ្ធិពលលើជីវិតពួកគេ ហើយថាតើក្តីសុបិន និងផែនការដែលទាក់ទងនឹងអាជីពនាពេលអនាគតរបស់គេ បានប្រែប្រួលយ៉ាងណាទៅតាមពេលវេលាជាងមួយឆ្នាំមកនេះ។ ដំណើរការរៀនសូត្រនេះ អាចឱ្យសិស្សកំណត់រូបភាពគោលដៅ និងផែនការអនាគតបានកាន់តែច្បាស់លាស់ថែមមួយកម្រិតទៀត។

ដំណើរនៃការរៀនសូត្រអាចជាបន្ទាត់ពេលវេលា គន្លងផ្លូវ ផែនទីគំនិត ឬរបាយការណ៍/អត្ថបទ។ លើកទឹកចិត្តសិស្សឱ្យប្រើប្រាស់អត្ថបទ រូបភាព និងគូស័រពណ៌ ដើម្បីឱ្យការរៀនមេរៀននេះមានភាពរស់រវើក និងបរិយាយខ្លឹមសារបានល្អ។ ពួកគេនឹងធ្វើលំហាត់នេះក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។







ដំណើរនៃការរៀនសូត្រ គឺជាវិញ្ញាសាទូលំទូលាយមួយក្នុងជីវិត ដែលអាចប្រើសម្រាប់ជាមូលដ្ឋានធ្វើការប្រឹក្សាយោបល់រវាងម្នាក់នឹងម្នាក់ ឬប្រឹក្សាជារួមនៅក្នុងថ្នាក់រៀន។ ពេលខ្លះ វាក៏អាចជាលំហាត់មួយសម្រាប់សិស្សធ្វើនៅផ្ទះ ដោយសារវាត្រូវការពេលច្រើនដើម្បីបញ្ចប់។ ជាមួយគ្នានេះ អាយុរបស់សិស្ស ក៏ជាផ្នែកមួយនៃការកំណត់ថាតើដំណើរការរៀនសូត្ររបស់គេឈានដល់កម្រិតណា។

ពន្យល់សិស្សពីគោលបំណងនៃការគូរ (អាចជាដ្យាក្រាម) ដំណើរការរៀនសូត្រ (ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត)។ អ្នកអាចផ្តល់ជាឧទាហរណ៍នៃដំណើរការរៀនសូត្ររបស់អ្នកផ្ទាល់ដល់សិស្ស និងប្រាប់សិស្សនូវអ្វីដែលអាចប្រាប់បានការវិវត្តផ្សេងៗគ្នាលើដំណើរការរៀនសូត្ររបស់អ្នក។ ផ្តល់ពេលវេលាសមស្របដល់សិស្ស ដើម្បីឱ្យពួកគេគូរពីដំណើរការរៀនសូត្ររបស់ខ្លួន។

## សកម្មភាពសិស្សទី២

បង្កើតក្រុមដែលមានសិស្សចាប់ពី ២–៣ នាក់ ហើយឱ្យពួកគេបង្ហាញ និងចែករំលែកនូវដំណើរការរៀនសូត្ររបស់ពួកគេជាមួយសមាជិកដទៃទៀតក្នុងក្រុម។ បន្ទាប់មកអ្នកអាចសួរនូវសំណួរបន្ថែមមួយចំនួនទៀតដូចជា៖

- តើអ្នកមានអារម្មណ៍បែបណាក្នុងការគូរដំណើរការរៀនសូត្ររបស់អ្នក?
- តើវាអាចជួយឱ្យអ្នករៀបចំដំណាក់កាលនីមួយៗនៃជីវិត និងបទពិសោធមួយចំនួននៃការរៀនសូត្របានល្អប្រសើរទេ?
- តើអ្វីខ្លះជាចំណុចរំលេចឡើងក្នុងដំណើរការនៃការរៀនសូត្ររបស់អ្នក?

ប្រសិនបើអ្នកធ្វើនៅលើក្រដាសដាច់ដោយឡែក អ្នកអាចប្រមូលសន្លឹកកិច្ចការនោះសម្រាប់ជាព័ត៌មានរបស់អ្នក និងប្រគល់ឱ្យសិស្សវិញនៅពេលក្រោយ។ ប្រសិនបើពួកគេប្រើសៀវភៅ អ្នកអាចឱ្យពួកគេបង្ហាញអ្នកនៅពេលប្រឹក្សាយោបល់ជាលក្ខណៈបុគ្គល សម្រាប់ជាព័ត៌មាន។

*(មេរៀននេះ ត្រូវបានកែសម្រួលចេញពីលំហាត់ដែលបានបង្កើតឡើងដោយ Heikkinen et al., ២០១៥)*



# មេរៀនទី ២៩  ក្លឹបមុខវិជ្ជា

មេរៀននេះ និងមេរៀន ៤ បន្ទាប់ទៀត គឺផ្តោតសំខាន់សម្រាប់ក្លឹបមុខវិជ្ជា។ ក្លឹបមុខវិជ្ជា អាចរៀបចំខុសៗគ្នានៅក្នុងសាលារបស់អ្នក អាស្រ័យលើស្ថានភាពជាក់ស្តែង។ ដូចនេះ អ្នកអាចបែងចែកក្លឹប មុខវិជ្ជាទាំង ៤ នេះ ដោយរៀបចំពេលខុសៗគ្នានៅក្នុងឆ្នាំសិក្សា។ នេះគឺជាសំណើរមួយអំពីរបៀបធ្វើវា។

នៅក្នុងមេរៀននេះ មិនតម្រូវឱ្យអ្នកបង្រៀនអ្វីថ្មីបន្ថែមដល់សិស្សនោះទេ។ អ្នកត្រូវណែនាំឱ្យសិស្សម្នាក់សាកល្បងដឹកនាំការអនុវត្តសកម្មភាពក្លឹបសិក្សានៅក្នុងថ្នាក់។ ពួកគេអាចធ្វើអ្វីដែលគេចង់ ធ្វើដើម្បីជាការចែករំលែកចំណេះដឹងដែលរៀនកន្លងមករវាងគ្នានិងគ្នាជាលក្ខណៈគូ ឬក្រុមតូចៗ ឬអាចជាការរៀនលក្ខណៈបុគ្គលម្នាក់ៗ។ តួនាទីរបស់អ្នក គឺរង់ចាំផ្តល់ជំនួយនៅពេលមានការស្នើសុំពីសិស្ស និងជំរុញលើកទឹកចិត្តសិស្សឱ្យសហការជួយគ្នាទៅវិញទៅមក។ ការប្រជុំក្លឹបមុខវិជ្ជា ក៏អាចត្រូវបានប្រើសម្រាប់សិស្សដែលអវត្តមានក្នុងម៉ោងសិក្សាមុនៗ ដើម្បីឱ្យពួកគេអាចបញ្ចប់ភារកិច្ចដែលនៅសេសសល់។ ជារួមនៅក្នុងមេរៀននេះ សិស្សគ្រប់គ្នានឹងបំពេញភារកិច្ចផ្ទាល់ខ្លួនរបស់គេ បញ្ចប់កិច្ចការសល់ពីមុន ឬក៏ធ្វើលំហាត់បន្ថែម ដោយប្រើប្រាស់ព័ត៌មានខាងក្រោម ឬសរសេរកំណត់ហេតុសិក្សារបស់គេ។ ភារកិច្ចរបស់អ្នកគឺ បង្កបរិយាកាសរីករាយ និងមានភាពច្នៃប្រឌិត និងរង់ចាំផ្តល់ជាជំនួយដល់សិស្សនៅពេលដែលពួកគេត្រូវការ។ អ្នកអាចចាក់តន្ត្រីដោយបើកសំឡេងស្រាលៗនៅក្នុងថ្នាក់ ដើម្បីជាការជួយឱ្យអារម្មណ៍ល្អ។ អ្នកដែលបានត្រូវបញ្ចប់លំហាត់វគ្គមុន អាចធ្វើលំហាត់នេះបាន៖

## សកម្មភាពសិស្ស

### *និមិត្តសញ្ញាអាវុធផ្ទាល់ខ្លួន*

វត្ថុបំណងគឺសម្រាប់ឱ្យសិស្សរៀនសូត្រក្នុងការកំណត់ពីចំណុចល្អៗរបស់ពួកគេ ហើយចែករំលែកទៅកាន់សិស្សដទៃទៀត។ ការណែនាំ អាចប្រើប្រាស់ពេល ៥ នាទី និងនិមិត្តសញ្ញាត្រូវការពេលធ្វើការប្រហែល ៤០នាទី។

### *អ្នកប្រឹក្សាយោបល់ ដំបូងត្រូវប្រាប់អំពីអត្ថន័យនៃនិមិត្តសញ្ញាអាវុធ៖*

ប្រវត្តិនៃនិមិត្តសញ្ញារោមសត្វ ចាប់ផ្តើមចេញពីក្រុមប្រយុទ្ធ នៅពេលដែលនិមិត្តសញ្ញាត្រូវបានប្រើសម្រាប់សម្គាល់ក្រុមប្រយុទ្ធនីមួយៗ ឧទាហរណ៍សញ្ញាត្រូវបានប្រើនៅលើខែល ទង់ជ័យជាដើម។ បន្ទាប់ពីពេលនោះមក និមិត្តសញ្ញាអាវុធត្រូវបានប្រើជានិមិត្តសញ្ញារបស់ក្រុមមនុស្សទៅតាមជំនាន់ខុសៗគ្នា ហើយក្រោយមកប្រើប្រាស់ជានិមិត្តសញ្ញារបស់រដ្ឋ រាជធានី និងក្រុងជាច្រើន។ មូលដ្ឋានទូទៅរបស់និមិត្តសញ្ញាអាវុធ ត្រូវបានធ្វើឡើងដោយយោងទៅតាមលក្ខណៈរបស់អ្នកពាក់ ឬអ្នកប្រើប្រាស់និមិត្តសញ្ញានេះ។ ឧទាហរណ៍ (ទីក្រុងមួយនៅក្នុងប្រទេសហ្វាំងឡង់) និមិត្តសញ្ញាដែលត្រូវបានប្រើ គឺក្រុមសត្វរមាំងដែលជារបរចិញ្ចឹមជីវិតដ៏សំខាន់នៅទីនោះ។

- បង្កើតនិមិត្តសញ្ញាអាវុធ (គូររូបចូលក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់អ្នក)។
- បែងចែកនិមិត្តសញ្ញាចេញជា ៥ផ្នែក។
- អ្នកអាចពិពណ៌នាជាមួយអត្ថបទ ឬគំនូរ

ផ្នែកទី ១៖ សរសេរ ឬគូសនូវហេតុការណ៍ដែលរីករាយបំផុតក្នុងជីវិតរបស់អ្នក។

ផ្នែកទី ២៖ សរសេរនូវគោលដៅសំខាន់បំផុតរបស់អ្នកនៅពេលនេះ។

ផ្នែកទី ៣៖ សរសេរសំគាល់នូវរឿងដែលពិបាកបំផុតដែលអ្នកធ្វើវាសម្រេចបាន។

ផ្នែកទី ៤៖ សរសេរនូវជំនាញ ឬគុណលក្ខណៈដែលអ្នកផ្សេងពេញចិត្តអ្នក (អ្នកក៏អាចសួរមិត្តរួមថ្នាក់ ប្រសិនបើអ្នករកមិនឃើញ)។

ផ្នែកទី ៥៖ សរសេរបាវចនារបស់អ្នកដែលមានលក្ខណៈវិជ្ជមាន និងពិពណ៌នាអំពីខ្លួនអ្នក។

និមិត្តសញ្ញាត្រូវបានចែករំលែក ដោយការពិភាក្សានៅក្នុងក្រុមតូច។

*ប្រភព៖*http://www.mll.fi/nuortennetti/mielenterveys/hyva-mina/kohota-itsetuntoa/



# មេរៀនទី ៣០ កងវង្វង់នៃអាជីព

## សកម្មភាពសិស្ស

បង្កើតផែនទីគំនិតអំពីវត្ថុដែលពាក់ព័ន្ធនឹងគោលដៅអាជីពរបស់អ្នក។ មុនដំបូង គូសកង់រង្វង់អាជីពនៅខាងក្រោមចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់អ្នក។ បន្ទាប់មក បន្ថែមនូវចំណុចផ្សេងៗជុំវិញវា។ វត្ថុបំណងគឺបង្កើនការយល់ដឹងអំពីគោលដៅ និងជម្រើសអាជីពរបស់អ្នក។




វិស័យកង់រង្វង់អាជីព ត្រូវការសារតានៃការអប់រំ ទំនាក់ទំនង (អ្នកដែលពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់អ្នក) ប្រវត្តិការងារដែលមាន (ទីផ្សារការងារ) និងចំណង់ចំណូលចិត្ត។

«របៀបរបបផ្ទាល់ខ្លួន» ឧទាហរណ៍ តើអ្នកវិភាគរឿងរ៉ាវដោយទ្រឹស្តី ឬតាមរយៈការអនុវត្ត។ ប្រសិនបើអ្នកចូលចិត្តធ្វើការជាមួយអ្នកដទៃ ឬចូលចិត្តធ្វើការដោយឯករាជ្យ ឬអ្នកអាចពិចារណាអំពីអាជីពថាតើវាអាចនាំមកនូវរបៀបរបបនៃការរស់នៅដល់អ្នករបៀបណា? (ប្រសិនបើការងារមានការធ្វើដំណើរច្រើន ឬក៏មានតម្រូវការវត្តបណ្តុះបណ្តាលច្រើន ការងារពេញមួយថ្ងៃ តើខ្ញុំត្រូវធ្វើការពេលយប់ដែរឬទេ?)

កិច្ចការនេះក៏បានកំណត់ពីសមត្ថភាព និងជំនាញរបស់អ្នកផងដែរដែលជារឿងសាមញ្ញនៅក្នុងជីវិតការងារ (ដូចជាជំនាញទំនាក់ទំនង និងដោះស្រាយបញ្ហា) ឬជំនាញពិសេសក្នុងវិស័យណាមួយ។ ជំនាញក៏អាចរួមបញ្ចូលចំណុចខ្លាំង និងគុណសម្បត្តិដូចជា ភាពច្នៃប្រឌិត និងភាពអត់ធ្មត់។ ការធ្វើឱ្យស៊ីជម្រៅនូវចំណេះដឹងរបស់ខ្លួន ក៏រួមបញ្ចូលនូវការកំណត់ឱ្យឃើញនូវចំណាប់អារម្មណ៍ និងគុណតម្លៃរបស់ខ្លួនអ្នកផ្ទាល់។

*ប្រភព៖ Amundson ២០០៥ និង*

http://www.okanagan.bc.ca/Student_Services/students/counselling/Career_Planning/The_Career_Decision_Wheel.html

# មេរៀនទី ៣១ លំហរនៃជីវិត

## សកម្មភាពសិស្ស

យើងបន្តលំហាត់បង្កើតផែនទីដោយប្រើប្រាស់ទ្រឹស្តីរបស់ Vance Peavy ។ នៅក្នុងទ្រឹស្តីកសាងសង្គម គាត់មើលឃើញថា ជីវិតរបស់យើងរួមមានធាតុផ្សំដ៏មានអត្ថន័យចំនួន ៥។ ធាតុផ្សំទាំងនេះគឺ៖

- ជីវិតការងារ និងការរៀនសូត្រ (រួមមាន សាលា និងការអប់រំ)
- ភាពស្និទ្ធស្នាល និងទំនាក់ទំនង (មិត្តភាព គ្រួសារ)
- សុខមាលភាព សុខភាព ការមើលថែខ្លួនឯង (ហាត់ប្រាណ គេង ញ៉ាំ)
- គំនិតច្នៃប្រឌិត ការកម្សាន្ត ការលំហែ លេងសើច ចំណង់ចំណូលចិត្ត
- ជំនឿផ្នែកស្មារតី ទស្សនៈអំពីពិភពលោក ឬទស្សនៈវិជ្ជាទៅលើជីវិត

គូសរូបរង្វង់ចំនួន ៣ ចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់អ្នក។ រង្វង់ទី ១ គឺគ្រាន់តែជាគំរូសម្រាប់ចងចាំនូវផ្នែកទាំងប្រាំ។ រង្វង់ទី ២ គឺធ្វើការប៉ាន់ប្រមាណអំពីពេលវេលាដែលអ្នកបានប្រើប្រាស់នៅក្នុងជីវិតគិតជាភាគរយ។ រង្វង់ទី ៣ គឺធ្វើវាឱ្យមើលឃើញថាតើវាមានភាពសំខាន់បែបណាចំពោះអ្នក (កាន់តែសំខាន់ ផ្នែកនេះកាន់តែធំ)។ នេះគឺជាមធ្យោបាយដែលអ្នកធ្វើឱ្យវាមើលឃើញនូវកត្តាទាំងនេះ។

បន្ទាប់ពីគូសរង្វង់ទាំងនេះ អ្នកអាចពិភាក្សាជាមួយដៃគូ អំពីការប៉ាន់ប្រមាណរបស់អ្នក។









*ប្រភព៖ Peavy ១៩៩៩ សូមមើលផងដែរ៖*

http://www.sociodynamic-constructivist-counselling.com/maps_visualizations1.html

# មេរៀនទី ៣២ បាតដៃទេពកោសល្យ

## សកម្មភាពសិស្ស

វត្ថុបំណងនៃមេរៀននេះគឺ ដើម្បីរំលេចនូវចំណុចខ្លាំង និងទេពកោសល្យរបស់សិស្សត្រូវបាន មើលឃើញនៅក្នុងទម្រង់មួយ។ ឱ្យសិស្សដាក់បាតដៃរបស់គេនៅលើសន្លឹកសៀវភៅ ឬកំណត់ហេតុ ឬនៅលើក្រដាសមួយសន្លឹកផ្សេងទៀត រួចគូសផ្គាមទម្រង់បាតដៃនោះ។ បន្ទាប់មកឱ្យសិស្ស សរសេរពីទេពកោសល្យ និងចំណុចខ្លាំងរបស់គេ (ក្នុងមធ្យោបាយជាផែនទីគំនិត) ទៅលើគ្រប់ ម្រាមនោះ។

បាតដៃទេព្យកោសល្យរួមមាន៖

១) ចំណេះដឹង (ការពិតដែលអ្នកដឹង រឿងរ៉ាវទ្រឹស្តី ព័ត៌មានដែលអ្នកបានប្រមូល)

២) ជំនាញ (សមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មាន)

៣) ការសម្របទៅនឹងបរិស្ថានជុំវិញ (បទបញ្ជារបស់សាលា បរិស្ថាន សង្គម និងជីវិតការងារ)

៤) មានបណ្តាញ ជាមួយអ្នកដែលខ្ញុំសហការជាមួយ

៥) ថាមពល (សកម្មភាព ចំណាប់អារម្មណ៍ ការតាំងចិត្ត)




*ប្រភព៖* http://vipuajavetoa.turkuamk.fi/wp-content/uploads/pohjat/_tyokorttipohja_taitokasi.pdf

# មេរៀនទី ៣៣  ការគិតអំពីជីវិតការងារ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សយល់ដឹងពីខ្លឹមសារមេរៀនប្រឹក្សាអាជីពនៅឆ្នាំបន្ទាប់ ដែលផ្តោតសំខាន់លើមេរៀនជំនាញផ្សេងៗក្នុងជីវិតការងារ

## សកម្មភាពសិស្ស៖ សន្លឹកកិច្ចការ (រយៈពេល ១០ នាទី)

តាមរយៈសន្លឹកកិច្ចការនេះ សិស្សនឹងយល់ដឹង និងបង្កើនភាពជឿជាក់លើព័ត៌មានពាក់ព័ន្ធនឹងជំនាញដែលពួកគេត្រូវមាននៅពេលបំពេញការងារ តាមរយៈការចែករំលែកបទពិសោធន៍ពីរៀមច្បងដែលធ្លាប់បំពេញការងារកន្លងមក។

អ្នកអាចសរសេរសំណួរខាងក្រោមលើក្តារខៀន ឬហៅឱ្យសិស្សកត់។ សិស្សត្រូវឆ្លើយសំណួរទាំងនោះចូលទៅក្នុងសៀវភៅរបស់ពួកគេ។

១.តើអាជីពការងារអ្វី ដែលអាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់សមត្ថភាព និងចំណេះដឹងបានល្អ?

២.ក្នុងចំណោមការអប់រំ ជំនាញវិជ្ជាជីវៈ និងសមិទ្ធផលជោគជ័យផ្ទាល់ខ្លួន តើមួយណាដែលធ្វើឱ្យអ្នកមានមោទនភាពជាងគេ?



៣.តើអ្នកមានភាពភ័យខ្លាចអំពីជីវិតការងារដែរឬទេ? ប្រសិនបើមានអ្វីខ្លះ?

៤.តើបញ្ហាអ្វីដែលធ្វើឱ្យអ្នកនឿយណាយបំផុតនៅក្នុងការស្វែងរកការងារ? អ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍ចុះចាញ់?

៥.ក្នុងនាមជានិយោជិតដ៏មានសក្តានុពលម្នាក់ តើអ្នកត្រូវមានចំណុចខ្លាំងអ្វីខ្លះ?

៦.តើនៅក្នុងស្ថានភាពបែបណា ដែលធ្វើឱ្យអ្នកមិនអាចរស់នៅក្នុងជីវភាពសមរម្យបាន?

៧.ចូររៀបរាប់ឈ្មោះសកម្មភាពដ៏មានន័យបំផុតសម្រាប់ជីវិតអ្នកចំនួនបី ដែលអ្នកកំពុងធ្វើ។

៨.តើអ្វីដែលអាចជួយអ្នកឱ្យពុះពារជំនះឧបសគ្គ និងបន្តដំណើរជីវិតទៅមុខ?

ណែនាំឱ្យសិស្សរៀបកៅអីអង្គុយជារង្វង់ចំនួនពីរជាន់។ រង្វង់ខាងក្នុង មានកៅអីចំនួន ៥ ហើយសិស្សដែលនៅសល់ត្រូវអង្គុយនៅកៅអីក្នុងរង្វង់ខាងក្រៅ។ អ្នកអង្គុយខាងក្នុងត្រូវពិភាក្សាសំណួរទី១ ប្រហែល ៣-៥នាទី។ សិស្សដែលអង្គុយនៅរង្វង់ខាងក្រៅមិនអាចផ្តល់យោបល់អ្វីទាំងអស់នៅដំណាក់កាលនេះ ប៉ុន្តែពួកគេអាចកត់ត្រាអំពីទស្សនៈផ្សេងៗចេញពីការពិភាក្សា។ នៅពេលដែលការសន្ទនានៅខាងក្នុងបញ្ចប់ ឬរអាក់រអួល អ្នកប្រឹក្សាយោបល់អនុញ្ញាតឱ្យសិស្សដែលអង្គុយនៅរង្វង់ខាងក្រៅចូលរួមក្នុងការសន្ទនា ដោយណែនាំឱ្យសិស្សនៅរង្វង់ខាងក្រៅដែលចង់មានយោបល់ក្រោកឈររួចដើរសំដៅទៅប្តូរកន្លែងរបស់អ្នកអង្គុយរង្វង់ខាងក្នុង និងបញ្ចេញមតិរបស់ខ្លួនទៅកាន់កិច្ចពិភាក្សា។ អ្នកត្រូវសម្របសម្រួលឱ្យសិស្សធ្វើបែបនេះ រហូតទាល់តែគ្មានអ្នកណាចង់បន្ថែមគំនិតអ្វីផ្សេងទៅក្នុងកិច្ចពិភាក្សា។ បន្ទាប់មក អ្នកត្រូវបន្តទៅសំណួរទី២-៨ទៀត។ សម្រាប់សំណួរនីមួយៗ មានពេលប្រហែលពី ៣-៤ នាទី។

*ប្រភព៖* http://www.ryhmayttaminen.fi/itsearviointi/3-vuosi/

## មេរៀនទី ៣៤ ផែនការអាជីព និងការអប់រំរបស់ខ្ញុំ

គោលបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សយល់ដឹងពីទិដ្ឋភាពពាក់ព័ន្ធដែលមានឥទ្ធិពលលើជម្រើសអាជីពការងារ និងផែនការរបស់ពួកគេ បន្ទាប់ពីរៀនចប់។

សិស្សអាចប្រមូលព័ត៌មាន លទ្ធផល និងការគិតចេញពីលំហាត់វគ្គមុន និងតេស្តដែលពួកគេបានបញ្ចប់ក្នុងមេរៀនប្រឹក្សាអាជីព។ នៅពេលដែលបញ្ចប់ការឆ្លើយសំណួរខាងក្រោម សិស្សនឹងមើលឃើញអំពីជំនាញ សមត្ថភាព ចំណាប់អារម្មណ៍ ចំណូលចិត្ត និងការរំពឹងទុករបស់ពួកគេថាតើស្របទៅនឹងផែនការក្រោយបញ្ចប់ការសិក្សាដែរឬទេ ហើយតម្រូវឱ្យមានការរិះគិតឡើងវិញនូវអាជីពការងារណាដែលសមស្របសម្រាប់ពួកគេ ផ្អែកលើចំណង់ចំណូលចិត្ត និងការចំណាប់អារម្មណ៍ឬទេ? លំហាត់នេះ អាចយកទៅប្រើនៅក្នុងការប្រឹក្សាយោបល់ដោយផ្ទាល់ជាមួយសិស្សម្នាក់ៗ ឬប្រឹក្សាជារួមក្នុងថ្នាក់។

### សកម្មភាពសិស្ស

សិស្សនឹងធ្វើការបូកសរុបរបស់ពួកគេ ដោយប្រើប្រាស់សន្លឹកកិច្ចការ។

### សន្លឹកកិច្ចការ

***ផែនការអាជីព និងការអប់រំរបស់ខ្ញុំ***

សរសេរលទ្ធផល «ផែនការអាជីព និងការអប់រំរបស់ខ្ញុំ» ចូលទៅក្នុងសៀវភៅរបស់អ្នក។ សំណួរ និងគំរូនៃការបូកសរុបខាងក្រោម និងជួយអ្នកនៅក្នុងការបំពេញវា។ អ្នកអាចប្រមូលព័ត៌មាន លទ្ធផល និងការគិតចេញពីលំហាត់វគ្គមុន និងតេស្តដែលពួកគេបានបញ្ចប់ក្នុងមេរៀនប្រឹក្សាអាជីព។

***អំពីខ្ញុំ៖***

តើមុខវិជ្ជាណាមួយដែលអ្នកចូលចិត្តរៀនជាងគេនៅសាលា?

តើអ្វីជាចំណុចខ្លាំង និងជំនាញរបស់អ្នក?

តើអ្នកត្រូវការអភិវឌ្ឍជំនាញអ្វីបន្ថែមទៀត? តើចំណុចខ្សោយរបស់អ្នកមានអ្វីខ្លះ?

តើអ្នកមានចំណាប់អារម្មណ៍ និងចំណង់ចំណូលចិត្តអ្វីខ្លះ?

តើអ្នកមានបទពិសោធន៍ការងារអ្វីខ្លះ? ឧទាហរណ៍ ការងារបន្ទាប់ពីរៀនចប់ ជួយការងារនៅក្នុងចំការ ឬអាជីវកម្មរបស់គ្រួសារ ឬស្ម័គ្រចិត្តនៅក្នុងកម្មវិធីសង្គមនៅក្នុងមូលដ្ឋាន។

ចូរពិពណ៌នានូវអ្វីដែលអ្នកចូលចិត្តធ្វើ ឬអ្វីដែលអ្នកមានភាពពូកែដែលមិនបានរៀបរាប់ខាងលើ (ឧទាហរណ៍ លេងឧបករណ៍តន្ត្រី សរសេររឿង លេងល្បែងកុំព្យូទ័រ សាងសង់ ឬជួសជុលវត្ថុផ្សេងៗ) រួមបញ្ចូលសកម្មភាពដែលទាក់ទងក្នុងសាលា និងក្រៅសាលា។

កំណត់អ្វីដែលជាគុណតម្លៃសំខាន់អំពីការងារសម្រាប់អ្នក (ដូចជាការងារឯករាជ្យ ធ្វើការនៅខាងក្រៅ..។ល។)។

*ផែនការបច្ចុប្បន្នបន្ទាប់ពីខ្ញុំរៀនចប់*

អ្នកបានរិះរកនូវជម្រើសអាជីពបឋមកាលពីមេរៀនមុន។ ពេលនេះ ដល់ពេលដែលអ្នកត្រូវបញ្ជាក់ពីជម្រើសរបស់អ្នក។ តើការអប់រំ និងកម្មវិធីបណ្តុះបណ្តាលមួយណាដែលអ្នកគិតថាពេញចិត្តអ្នកជាងគេ?

តើអ្នកបានគិតអំពីមាគ៌ាអាជីពផ្សេងៗគ្នា ដែលទាក់ទងទៅនឹងកម្រិតនៃការអប់រំ និងការបណ្តុះបណ្តាលដែលអ្នកត្រូវការដែរឬទេ? ការងារប្រហាក់ប្រហែលគ្នាជាច្រើន ទាមទារនូវកម្រិតអប់រំខុសៗគ្នា (ឧ. អ្នកបច្ចេកទេស ជាមួយនឹង វិស្វករ)។

តើការអប់រំកម្រិតណាដែលសក្តិសមនឹងអ្នក បើប្រៀបធៀបនឹងរបៀបរៀនសូត្រ គោលដៅអាជីព និងស្ថានភាពសេដ្ឋកិច្ចរបស់អ្នក?

តើអ្នកនឹងចាប់ផ្តើមអាជីពការងារអ្វី បន្ទាប់ពីរៀនចប់? តើអ្នកចង់ធ្វើការនៅកន្លែងណា?

មនុស្សជាច្រើនយល់ថា វាមានប្រយោជន៍ក្នុងការមានផែនការជំនួយ។ តើមានរឿងអ្វីនឹងកើតឡើង ប្រសិនបើអ្នកមិនអាចទទួលបានវគ្គបណ្តុះបណ្តាល ឬការងារដែលអ្នកបានដាក់ពាក្យ? តើអ្នកមានយោបល់ផ្សេងទេ?

*សម្រេចគោលដៅអ្នកពីទីនេះ*

តើអ្នកអាចធ្វើអ្វីបាន សម្រាប់ការត្រៀមការអប់រំ ឬការងារទៅអនាគត ខណៈដែលអ្នកកំពុងរៀននៅឡើយ?

តើមុខវិជ្ជាណាដែលអ្នកគួរសិក្សាបន្ថែម? តើអ្នកអាចធ្វើអ្វីបន្ថែមទៀតក្នុងការពង្រីកចំណេះដឹង និងជំនាញរបស់អ្នក?

តើមានវគ្គបន្ថែមណាដែលគេផ្តល់ជូន ហើយអ្នកអាចរៀនបាន?

*សំណួរសម្រាប់ពិចារណាបន្ទាប់ពីអ្នករៀនចប់៖*

តើចំណាប់អារម្មណ៍ ចំណូលចិត្ត និងការរំពឹងទុករបស់អ្នក ស្របទៅនឹងផែនការក្រោយបញ្ចប់ការសិក្សាដែរឬទេ? ប្រសិនបើមិនសមស្រប តើអាជីពការងារណាដែលសមស្របតាមចំណង់ចំណូលចិត្ត និងចំណាប់អារម្មណ៍របស់អ្នក?

តើជំនាញ និងសមត្ថភាពបច្ចុប្បន្នរបស់អ្នក អាចឱ្យអ្នកទទួលបានការអប់រំ និងកម្មវិធីបណ្តុះបណ្តាលដែលត្រូវការសម្រាប់ការងារដែលអ្នកកំពុងស្វែងរកដែរឬទេ? ចាប់ផ្តើមដោយការពិនិត្យមើលការអប់រំ ឬវគ្គបណ្តុះបណ្តាលដែលទាមទារសម្រាប់ការងារ រួចសួរខ្លួនឯងថា *«តើខ្ញុំអាចធ្វើបានទេ?»*

*ការបូកសរុប «ផែនការអាជីព និងការអប់រំរបស់ខ្ញុំ» (ឧទាហរណ៍)*

*អំពីខ្ញុំ*

| មុខវិជ្ជាដែលពេញចិត្ត | បទពិសោធន៍ការងារ ឬអ្វីដែលប្រហាក់ប្រហែល | ចំណាប់អារម្មណ៍និងចំណង់ចំណូលចិត្ត | ចំណុចខ្លាំងនិងជំនាញ | ចំណុចដែលប្រឈម | គុណតម្លៃសំខាន់អំពីការងារ | ខ្ញុំចូលចិត្តធ្វើ |
|---|---|---|---|---|---|---|
| ✓ ភាសាអង់គ្លេស<br>✓ ភូមិវិទ្យា<br>✓ ប្រវត្តិវិទ្យា | ការងារបន្ទាប់ពីរៀនចប់<br>✓ ជំនួយការហាង<br>✓ បេះផ្លែស្របឺរី<br>✓ អ្នកថែទាំសត្វសេះ<br>ផ្សេងៗ៖<br>✓ លេខានៅសមាគមមួយ | ✓ បាល់បោះ<br>✓ សកម្មភាពក្លឹបភាសានិងវប្បធម៌បរទេស<br>✓ ការងារស្ម័គ្រចិត្ត | ✓ ពូកែភាសា<br>✓ អ្នកធ្វើការងារជាក្រុម<br>✓ ការងារសង្គម<br>✓ ការទទួលខុសត្រូវ | ចំណុចខ្សោយ<br>✓ គណិតវិទ្យា សុទិដ្ឋិនិយមជ្រុល<br>✓ មនុស្សប្រភេទរីករាយសប្បាយ | ✓ ធ្វើការជាមួយមនុស្ស<br>✓ ធ្វើការដែលមានពេលវេលាបត់បែន<br>✓ ការងារឯករាជ្យ<br>✓ ធ្វើដំណើរទៅបរទេស | ✓ ការអាន<br>✓ ដោះស្រាយល្បែងផ្គុំរូប<br>✓ ការធ្វើដំណើរ |

សរសេរការបូកសរុបរបស់អ្នកដូចក្នុងឧទាហរណ៍ចូលទៅក្នុងសៀវភៅរបស់អ្នក។



*ផែនការរបស់ខ្ញុំបន្ទាប់ពីរៀនចប់ (ឧទាហរណ៍)*

ជម្រើសអាជីព និងការអប់រំ៖
១. អាជីវកម្ម (សកលវិទ្យាល័យ)
២. ធ្វើដំណើរ និងទេសចរណ៍ (មហាវិទ្យាល័យ)
៣. បុរាណវិទ្យា (ស.វិទ្យាល័យ)

ផែនការបម្រុងទុក
- ✓ បញ្ចប់ការសិក្សា និងស្វែងរកបទពិសោធន៍ការងារ
- ✓ សិក្សាតាមអនឡាញ នៅសកលវិទកាល័យបើក

*សម្រេចគោលដៅអ្នកពីទីនេះ៖*
- ✓ សង្កត់ធ្ងន់លើការសិក្សាភាសា
- ✓ រៀនថ្នាក់គណិតបន្ថែម
- ✓ តម្រង់ទិសជាមួយនឹងសៀវភៅដែលត្រូវការសម្រាប់ប្រលងចូល

សរសេរការបូកសរុបរបស់អ្នកដូចក្នុងឧទាហរណ៍ចូលទៅក្នុងសៀវភៅរបស់អ្នក។

*ប្រភព៖ សៀវភៅប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញ ក្រ.អយក ២០១៦។*

# មេរៀនទី ៣៥ យោបល់វិជ្ជមានទៅកាន់មិត្តរួមថ្នាក់

វត្ថុបំណងនៃលំហាត់នេះគឺ៖

- សិស្សនឹងផ្តល់យោបល់ជាវិជ្ជមានទៅឱ្យមិត្តរួមថ្នាក់គេ អំពីការធ្វើការងារគម្រោង និងការងារជាក្រុមជាមួយ

## សកម្មភាពសិស្ស៖ កៅអីទំនេរ

គោលបំណងគឺ ផ្តល់យោបល់ត្រលប់វិជ្ជមានដល់សិស្ស ទៅលើសកម្មភាពរបស់គេកន្លងមក។ លំហាត់នេះ នឹងបានជាចំណែកមួយជួយគាំទ្រដល់កន្លែងការងារ និតជំនាញផ្តល់យោបល់ត្រលប់។

***ជំហានទី ១***

ឱ្យសិស្សគ្រប់រូបសរសេរឈ្មោះរបស់គេនៅលើក្រដាសមួយសន្លឹក រួចបត់យកទៅដាក់ចូលក្នុងប្រអប់មួយដែលអ្នកត្រៀមបម្រុងទុក។ បន្ទាប់មក ឱ្យសិស្សម្នាក់ៗចាប់យកក្រដាសមួយសន្លឹកចេញពីក្នុងប្រអប់នោះ (ករណីយកចំលើឈ្មោះខ្លួនឯង គេត្រូវដាក់ចូលវិញរួចលូកចាប់ម្តងទៀត)។ សិស្សត្រូវសរសេរមតិយោបល់ជាវិជ្ជមានចំនួន ៣ ចំណុច បរិយាយពីអ្នកដែលមានឈ្មោះក្នុងក្រដាសនោះ (អាចជា សកម្មភាព និងអត្តចរិតធ្វើការងារក្រុម... ចៀសវាងវាយតម្លៃរឿងបុគ្គលផ្ទាល់ខ្លួន)។

***ជំហានទី ២***

បន្ទាប់ពីនោះ សិស្សអង្គុយនៅលើកៅអីដែលរៀបជារង្វង់ តែត្រូវទុកកៅអីមួយឱ្យនៅទំនេរ។ សិស្សគ្រប់រូប នឹងត្រូវទៅអង្គុយលើកៅអីទំនេរនោះម្នាក់ម្តងៗ ដើម្បីផ្តល់យោបល់ត្រលប់ទៅមិត្តរួមថ្នាក់គេ។ ការផ្តល់យោបល់ ត្រលប់ត្រូវបានធ្វើក្នុងទម្រង់ជា៖ «ខ្ញុំស្នើសុំចំណុចនេះព្រោះ...» ហើយបន្ទាប់មក គេត្រូវផ្តល់យោបល់ជាវិជ្ជមាន (ដែលបានរៀបចំខាងលើចំនួន ៣ ចំណុច) ទៅកាន់មិត្តណាម្នាក់។ បន្ទាប់ពីផ្តល់យោបល់ចប់ អ្នកត្រូវនិយាយ «អរគុណសម្រាប់ការស្តាប់»។ គ្រូត្រូវធានាថាសិស្សម្នាក់ៗបានផ្តល់ និងទទួលយកយោបល់ត្រលប់។

យើងមានពេលតិចតួចណាស់សម្រាប់យោបល់ត្រលប់នីមួយៗ ដូចនេះអ្នកត្រូវគ្រប់គ្រងពេលវេលាឱ្យបានល្អ។ ប្រសិនបើមានពេលនៅសល់នៅចុងម៉ោង៖ បន្ទាប់ពីគ្រប់គ្នាបានទទួលយោបល់ត្រលប់រួចហើយ អ្នកអាចពិភាក្សាថាតើពួកគេមានអារម្មណ៍បែបណាក្នុងការឱ្យយោបល់ត្រលប់ ហើយវាមានអារម្មណ៍បែបណាដែលធ្វើជាអ្នកទទួលយកយោបល់ត្រលប់។

ប្រភពរបស់លំហាត់នេះ៖ http://www.mentalhealthpromotion.net/resources/m-oon-jees.pdf.



# មេរៀនទី ៣៦ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ទី១១ ឬឆ្នាំទី ២

## សកម្មភាពសិស្សទី១ (រយៈពេល ១៥ នាទី)

ឱ្យសិស្សយកសៀវភៅកត់ត្រា និងកំណត់ហេតុសិក្សាមក ដើម្បីរំឭក និងសរសេរសង្ខេបនូវអ្វីដែលបានរៀនពេញមួយឆ្នាំសិក្សានេះ។

## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

ឱ្យសិស្សឈរជាពីរជួរ ហើយត្រូវរកមើលកន្លែងឈរដែលសក្តិសមនឹងរូបគេតាមលទ្ធផលនៃការសិក្សា។

### ជួរទី ១ (៥នាទី)

តើអ្នកពេញចិត្តនឹងលទ្ធផលសិក្សានៅថ្នាក់ទី ១១ កម្រិតណា?

មិនពេញចិត្តទាល់តែសោះ ⟷ ខ្ញុំពេញចិត្តលទ្ធផលរបស់ខ្ញុំ

### ជួរទី ២ (៥នាទី)

តើអ្នកបានប្រឹងប្រែងដោយខ្លួនឯងកម្រិតណា?

ខ្ញុំមិនបានប្រឹងប្រឹងនោះទេ ⟷ ខ្ញុំបានប្រឹងប្រឹងអស់លទ្ធភាពហើយ

## សកម្មភាពសិស្សទី៣ (រយៈពេល ១៥ នាទី)

បង្កើតការពិភាក្សាជាក្រុមអំពីប្រធានបទជាច្រើន ឧ. (សួរសំណួរដែលពាក់ព័ន្ធ ឬសំណួរដែលសិស្សចង់លើកឡើង)

- តើមានចំណុចល្អៗអ្វីខ្លះនៅក្នុងឆ្នាំសិក្សាទី២?
- តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះនៅក្នុងឆ្នាំសិក្សាទី២?
- តើអ្នកពុះពារ និងដោះស្រាយបញ្ហាប្រឈមដូចម្តេច?
- តើនរណាខ្លះដែលបានជួយអ្នកក្នុងការសិក្សាឆ្នាំទី២ ហើយអ្នកចង់ថ្លែងអំណរគុណគេ?

## សកម្មភាពសិស្សទី៤ (រយៈពេល ១០ នាទី)

សម្រាប់លំហាត់ចុងក្រោយ អ្នកអាចមានការពិភាក្សាជាទូទៅមួយអំពីការសិក្សានៅឆ្នាំសិក្សាទី២ ថាតើពួកគេយល់យ៉ាងណា និងមានការរំពឹងទុកអ្វីខ្លះ សម្រាប់ឆ្នាំចុងក្រោយនៃមធ្យមសិក្សាទុតិយភូមិ? អរគុណអ្នកគ្រប់គ្នា សម្រាប់ការខិតខំប្រឹងប្រែងកន្លងមក!



# ផ្នែកទី ៣
# ជំនាញក្នុងជីវិតការងារ (ថ្នាក់ទី ១២)

## វត្ថុបំណងសម្រាប់ឆ្នាំទី ៣៖

ក្នុងឆ្នាំសិក្សាទី ៣ (ថ្នាក់ទី ១២)នេះ សិស្សានុសិស្សនឹងត្រូវផ្តោតការយកចិត្តទុកដាក់លើ **ជំនាញសម្រាប់បំពេញការងារ** និង**ការត្រៀមលក្ខណៈសម្បត្តិចូលទីផ្សារការងារ**។

នៅក្នុងឆ្នាំសិក្សានេះ តម្រូវឱ្យបង្រៀនរយៈពេល ៣៦ ម៉ោង (៤៥ នាទី សម្រាប់ម៉ោងសិក្សា ១៥ នាទី សម្រាក)។ សិស្សានុសិស្ស នឹងត្រូវអនុវត្តគម្រោងសិក្សាចំនួន ២ ការសិក្សាលក្ខណៈជាក្លឹបមុខវិជ្ជា ព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគន៍ ដែលជាផ្នែកមួយសម្រួលដល់ការបង្រៀន មេរៀនប្រឹក្សាអាជីព។ ក្នុងម៉ោងសិក្សា សិស្សត្រូវមានសៀវភៅកត់ត្រា និងប៊ិកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

## ខ្លឹមសារមេរៀន ត្រូវបានបែងចែកដូចខាងក្រោម៖

| | |
|---|---|
| មេរៀនទីមេរៀនទី១៖ | មេរៀនតម្រង់ទិសសិស្សថ្នាក់ទី១២ សម្រាប់ឆ្នាំសិក្សាថ្មី |
| មេរៀនទី២ ដល់ទី១០៖ | ជំនាញផ្ទាល់ខ្លួន |
| មេរៀនទី១១៖ | សង្ខេបមេរៀនជំនាញគាំទ្រក្នុងជីវិតការងារ |
| មេរៀនទី១២ ដល់ ១៣៖ | រូបភាពទីផ្សារការងារក្នុងមូលដ្ឋាន |
| មេរៀនទី១៤ ដល់ ១៥៖ | តម្រូវការនិយោជក |
| មេរៀនទី១៦ ដល់ ៣២៖ | ការត្រៀមដើម្បីចាប់យកអាជីពការងារ |
| មេរៀនទី៣៣ ដល់ ៣៦៖ | ការឆ្លុះបញ្ចាំងការសិក្សារយៈពេល៣ឆ្នាំ |

## មេរៀនទី ១ ស្វាគមន៍មកកាន់ថ្នាក់ទី១២ ឬឆ្នាំទី ៣

វត្ថុបំណងនៃមេរៀនគឺៈ

- សិស្សគ្រប់គ្នាមានអារម្មណ៍ថាពួកគេត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅមកកាន់ថ្នាក់ថ្មី
- បង្កើនស្មារតីសាមគ្គីភាព។

អ្នកត្រូវរៀបចំបំណែករូបភាពសម្រាប់ផ្គុំចំនួន ៨-១២ ឈុត (១ ឈុតមាន ៥ បំណែក និងផ្គុំបានជារូបភាព ១)។

### សកម្មភាពសិស្សទី១ (រយៈពេល ១០-១៥ នាទី)

អ្នកអាចចាប់ផ្តើមសំណេះសំណាលជាមួយសិស្សអំពីវិស្សមកាលរបស់ពួកគេ ដែលទើបកន្លងផុតទៅថាតើ ពួកគេបានទៅកន្សាន្តនៅកន្លែងណាខ្លះជាមួយក្រុមគ្រួសារ។ បន្ទាប់មក ឱ្យពួកគេពិភាក្សាជារួមក្នុងថ្នាក់ ដើម្បីរំឭកពីអ្វីដែលពួកគេចងចាំពីមេរៀនប្រឹក្សាអាជីព កាលពីឆ្នាំសិក្សាមុន។ តើពួកគេមេរៀនណាខ្លះដែលគេពេញចិត្តជាងគេ...។

### សកម្មភាពសិស្សទី២ៈ ការផ្គុំរូប (រយៈពេល ៣០ នាទី)

ណែនាំសិស្សធ្វើការជាក្រុមដែលមានគ្នា ៥-៦ នាក់។ ផ្តល់ឱ្យក្រុមនីមួយៗនូវរូបភាពដែលត្រូវផ្គុំមួយឈុត (មាន ៥ បំណែក)។ ក្រុមនីមួយៗ ត្រូវចាត់តំណាងម្នាក់ឱ្យធ្វើជាអ្នកផ្គុំរូប (ចងក្រណាត់បិទភ្នែក) ហើយអ្នកផ្សេងទៀតក្នុងក្រុមជាមួយ ត្រូវប្រាប់ពីទម្រង់ ឬបំណែករូបភាពដែលត្រូវយកមកផ្គុំដល់គេ។ គោលបំណងសកម្មភាពនេះ គឺសិស្សត្រូវរៀនធ្វើការជាក្រុមដើម្បីឱ្យសម្រេចគោលដៅរួម។

ដកស្រង់ចេញពីៈ http://www.ryhmayttaminen.fi/? page_id=61

### សកម្មភាពសិស្សទី៣ (រយៈពេល ៥ នាទី)

ពេលនេះពន្យល់សិស្សដោយសង្ខេបអំពីប្រធានបទប្រឹក្សាអាជីព ដែលនឹងត្រូវរៀននៅថ្នាក់ទី១២។ ឱ្យសិស្សយកសៀវភៅមួយក្បាលសម្រាប់កត់ត្រាមេរៀន និងមួយក្បាលទៀតសម្រាប់ធ្វើសៀវភៅកំណត់ហេតុសិក្សា។ ពួកគេពិតជាអាចបន្តប្រើប្រាស់សៀវភៅពីឆ្នាំមុន និងប្រើសៀវភៅដដែលសម្រាប់កត់ត្រា និងធ្វើជាសៀវភៅកំណត់ហេតុសិក្សា ករណីប្រើមិនទាន់អស់។



# មេរៀនទី ២ ការសម្រេចចិត្ត

ការសម្រេចចិត្ត ជាផ្នែកមួយដ៏សំខាន់ក្នុងការបំពេញការងារ។ ខ្លឹមសារមេរៀនពាក់ព័ន្ធនឹងការសម្រេចចិត្តនេះ សិស្សនឹងត្រូវរៀន និងអនុវត្តសកម្មភាពការងាររយៈពេល ២ ខែស្មើនឹង ៩ មេរៀន។ វត្ថុបំណងនៃមេរៀនទាំង ៩ នេះគឺ៖

- បង្កើនចំណេះដឹង និងទេពកោសល្យសិស្សពាក់ព័ន្ធនឹងការធ្វើសេចក្ដីសម្រេចចិត្ត ដែលជាផ្នែកមួយនៃជំនាញក្នុងជីវិតការងារ។

## សកម្មភាពសិស្សទី១

សិស្សនឹងត្រូវទទួលបានការណែនាំថ្មីអំពីបច្ចេកទេស NAF (N = New ថ្មី, A = Appeal ទាក់ទាញ, F = Feasibility អាចធ្វើទៅបាន)។ NAF វាជាវិធីមួយនៅក្នុងការដាក់ពិន្ទុគំនិត ថាតើវានឹងអាចបន្ត ឬអនុវត្តបានឬទេ។ បច្ចេកទេស NAF ត្រូវបានរចនាឡើងដើម្បីវាស់វែងអារម្មណ៍អំពីគំនិតខុសៗគ្នា ហើយវាអាស្រ័យលើសភាវគតិ និងការវិនិច្ឆ័យរបស់សិស្ស។ សូមអ្នកត្រៀមកាត (ទទេ) សម្រាប់សិស្សធ្វើលំហាត់។

### *ជំហានទី ១ (រយៈពេល ១៥ នាទី)*

បែងចែកសិស្សជា ៤ ក្រុម។ ឱ្យក្រុមនីមួយៗពិភាក្សាឯកភាពគ្នាលើប្រធានបទរួមមួយ ដែលពួកគេត្រូវធ្វើសេចក្ដីសម្រេចចិត្ត។ ពេលនេះពួកគេត្រូវមានពេលវេលា ២-៣ នាទី ក្នុងការបំផុសគំនិត ហើយសរសេរនៅលើសន្លឹកកាតមួយ (កាត ១ សន្លឹក = គំនិត ១)។ ពួកគេត្រូវបង្កើតគំនិតឱ្យបានច្រើនតាមដែលអាចធ្វើបាន។ ឱ្យក្រុមមើលកាតដែលបានសរសេររួច។ លុបនូវអ្វីដែលត្រួតគ្នាចោល និងបញ្ចូលគំនិតប្រហាក់ប្រហែលគ្នាចូលគ្នាតែមួយ។

### *ជំហានទី ២ (រយៈពេល ១៥ នាទី)*

អ្នកត្រូវចាត់ឱ្យសិស្សម្នាក់នៅក្នុងក្រុម ធ្វើជាអ្នកសម្របសម្រួល។ សមាជិកក្រុមត្រូវតែពិចារណានូវគំនិតដែលពួកគេបានលើកឡើងក្នុងសន្លឹកកាតម្ដងមួយៗ។ អ្នកសម្របសម្រួលគួរតែអានគំនិតនីមួយៗទៅកាន់សមាជិកក្រុម។ បន្ទាប់មកក្រុមគួរតែបោះឆ្នោតលើគំនិតនោះថាតើ ថ្មី ទាក់ទាញ និងអាចធ្វើទៅបាន ដែរឬទេ។ សិស្សម្នាក់ៗត្រូវដាក់ពិន្ទុរៀងៗខ្លួនលើគំនិតដែលបានលើកឡើងនោះ ដែលវានឹងក្លាយជាសន្លឹកឆ្នោតរបស់គេ។ សិស្សម្នាក់ៗត្រូវពិចារណាសំណួរខាងក្រោម ជាមួយនឹងច្បាប់សម្រាប់ដាក់ពិន្ទុ៖

- ***ថ្មី៖*** តើគំនិតនេះថ្មីសម្រាប់អ្នកដែរឬទេ? ដាក់ពិន្ទុពី ១ ទៅ ១០។ សំណួរនេះសំដៅទៅលើភាពជាក់ស្ដែងទាំងស្រុង។ គំនិតអាចប្រហែលជាមិនមែនថ្មីសុទ្ធសាធសម្រាប់គ្រប់គ្នានោះទេ ប៉ុន្តែប្រសិនបើវាថ្មីសម្រាប់អ្នក អ្នកអាចឱ្យ ១០ ពិន្ទុបាន។ ប្រសិនបើវាមិនថ្មីសម្រាប់អ្នកទេ ឱ្យពិន្ទុ ១។
- ***ទាក់ទាញ៖*** តើគំនិតនេះមានភាពទាក់ទាញដល់អ្នកដែរឬទេ? ឱ្យពិន្ទុពី ១ (មិនទាក់ទាញ) ទៅ១០ (ទាក់ទាញខ្លាំង)។ សំណួរនេះពិតជាទាក់ទងនឹងអារម្មណ៍ច្រើន។
- ***អាចធ្វើទៅបាន៖*** គំនិតនេះអាចអនុវត្តបានដែរឬទេ?សំណួរនេះសំដៅទៅលើភាពជាក់ស្ដែងទាំងស្រុង ថាតើគំនិតនេះអាចធ្វើឲ្យកើតឡើងបានដែរឬទេ។ដាក់ពិន្ទុពី ១០ សម្រាប់គំនិតដែលអាចធ្វើទៅបាន និង ១សម្រាប់គំនិតដែលមិនអាចធ្វើបាន។

សិស្សម្នាក់ៗត្រូវតែសរសេរពិន្ទុទាំង ៣ ទៅលើកាតមួយ និងហុចទៅឱ្យអ្នកសម្របសម្រួល។ ប្រមូលសន្លឹកឆ្នោតសម្រាប់គំនិតនីមួយៗ និងដាក់វានៅក្បែរប្រធានបទនីមួយៗ។ បន្តរហូតទាល់តែគំនិតត្រូវបានយកមកពិចារណា ហើយដាក់ពិន្ទុ។

*ជំហានទី ៣ (រយៈពេល ១៥ នាទី)*

ដល់ពេលដែលត្រូវវាយតម្លៃលទ្ធផល។ សម្រាប់គំនិតនីមួយៗ ពិន្ទុត្រូវបានគណនាផ្អែកលើលក្ខណៈ៖ **ថ្មី ទាក់ទាញ** និង **អាចធ្វើទៅបាន**។ រួចឱ្យសិស្សចែករំលែកជាមួយក្រុម និងពិភាក្សា។ សូមពិចារណានូវការបកស្រាយដូចខាងក្រោម៖

- ប្រសិនបើគំនិតមិនថ្មីខ្លាំង មិនសូវទាក់ទាញ និងមិនអាចធ្វើទៅបាន ដូចនេះគំនិតនេះនឹងមិនទំនងជាពិបាកក្នុងការអនុវត្ត
- ប្រសិនបើគំនិតនេះថ្មីខ្លាំង ទាក់ទាញខ្លាំង ប៉ុន្តែមិនអាចធ្វើទៅបាន ដូចនេះគំនិតនេះសក្តិសមនឹងយកទៅពិភាក្សាបន្ថែមថាតើមានដំណោះស្រាយច្នៃប្រឌិតណាដែលអាចធ្វើឱ្យវាប្រសើរបាន
- ប្រសិនបើ ពិន្ទុទាក់ទាញជាមធ្យមទទួលបានច្រើនជាង ៥ វាសក្តិសមក្នុងការពិចារណាបំពេញបន្ថែមនូវដំណោះស្រាយដែលអាចបង្កើនភាពទាក់ទាញរបស់គំនិតនេះ។

ដូចនេះ វត្ថុបំណងគឺស្វែងរកគំនិតដែលថ្មី ហើយទាក់ទាញ និងកុំបារម្ភខ្លាំងពេកអំពីថាវាអាចធ្វើទៅបានឬអត់។ បន្តជាមួយនឹងគំនិតម្តងមួយរហូតទាល់តែគំនិតទាំងអស់ត្រូវបានពិភាក្សា។

**សកម្មភាពសិស្សទី២** (រយៈពេល ៥ នាទី)

អ្នកត្រូវបង្កើតការពិភាក្សាជាក្រុមអំពីបច្ចេកទេសនេះ។ ឱ្យក្រុមនីមួយៗពិភាក្សាអំពីគំនិតទាំងអស់ដែលបានរកឃើញ រួចបង្កើតចងក្រងនូវសកម្មភាព និងបូកសរុបគំនិតទាំងនោះ។ បន្តពិភាក្សាទៅលើប្រសិទ្ធភាពនៃបច្ចេកទេសនេះ។ តើអ្នកគិតបែបណាចំពោះការដាក់ពិន្ទុដោយផ្អែកលើលក្ខណៈ ថ្មី ទាក់ទាញ និងភាពអាចធ្វើទៅបាន? តើការដាក់ពិន្ទុដោយផ្អែកលើអារម្មណ៍ ជួយអ្នកឱ្យបានឃើញថាអ្នកចូលចិត្តគំនិតនោះបានប៉ុណ្ណា? តើអ្វីដែលជាចំណាប់អារម្មណ៍ខ្លាំងបំផុតដែលអ្នកមានចំពោះលំហាត់នេះ? (៥នាទី)

ប្រភព៖

http://www.skillsconverged.com/FreeTrainingMaterials/tabid/258/articleType/ArticleView/articleId/1034/categoryId/114/Decision-Making-The-NAF-Technique.aspx



# មេរៀនទី ៣ ការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព

វត្ថុបំណងនៃមេរៀននេះគឺ៖

- ឱ្យសិស្សមើលឃើញអំពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទង

## សកម្មភាពសិស្សទី១៖ ល្បែងបត់ក្រដាស (រយៈពេល ១៥ នាទី)

### ជំហានទី ១



ចែកក្រដាសឱ្យសិស្សម្នាក់មួយសន្លឹក។ អ្នកត្រូវប្រាប់សិស្សឱ្យបិទភ្នែក និងហាមសួរ រួចធ្វើការណែនាំពួកគេពីរបៀបបត់ក្រដាសបង្កើតជារាង អូរីហ្កាមី រួចហែកវា។ ណែនាំឱ្យបានច្រើនដង រហូតដល់សិស្សអ្នកមានទំនុកចិត្តថា ពួកគេអាចធ្វើវាបាន។ បន្ទាប់មកអនុញ្ញាតឱ្យពួកគេចាប់ផ្ដើមបត់ និងហែក រួចហើយឱ្យពួកគេលាក្រដាសនោះ រួចប្រៀបធៀបគ្នាថាវាមានរូបរាងបែបណាខ្លះ។

### ជំហានទី ២

ណែនាំឱ្យពួកគេពិភាក្សាគ្នាពីរូបរាងក្រដាសនោះ។ ប្រាប់សិស្សថាក្រដាសនីមួយៗមានរាងខុសៗគ្នា ទោះបីជាអ្នកផ្ដល់នូវការណែនាំដូចគ្នាក៏ដោយ។ តើវាមានន័យយ៉ាងដូចម្ដេច? សួរទៅកាន់ក្រុមថា លទ្ធផលអាចនឹងប្រសើរជាងនេះប្រសិនបើសិស្សបើកភ្នែកមើល ឬក៏ឱ្យសួរសំណួរ។

ការប្រាស្រ័យទាក់ទងគ្នា ដើម្បីទទួលបានព័ត៌មានច្បាស់លាស់ មិនមែនជាការងាយស្រួលនោះទេ។ យើងបកស្រាយព័ត៌មានដែលយើងទទួលបានខុសៗគ្នា។ អាស្រ័យហេតុនេះហើយបានជាវាមានសារៈសំខាន់នៅក្នុងការសួរសំណួរ និងបញ្ជាក់នូវការយល់របស់យើង ដើម្បីធានាថាសារដែលត្រូវបានផ្ដល់ទៅ (ប្រាស្រ័យទាក់ទង) មិនត្រូវបានខ្វះចន្លោះ។ នេះគឺជាសកម្មភាពដែលងាយស្រួល និងលឿនដែលបង្ហាញថា សេចក្ដីណែនាំមានការបកស្រាយខុសៗគ្នា ដោយមនុស្សខុសៗគ្នា និងរំលេចពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទងច្បាស់លាស់។ (រយៈពេល ១០នាទី)



## សកម្មភាពសិស្សទី២៖ សំណួរបិទ និងសំណួរបើក (រយៈពេល ២០ នាទី)

### *ជំហានទី ១*

បែងចែកសិស្សជា ៤-៥ ក្រុម។ សិស្សម្នាក់ក្នុងក្រុមនីមួយៗត្រូវចាកចេញពីបន្ទប់ រួចគិតមួយសន្ទុះអំពីសម្ភារៈសិក្សាដែលមាននៅក្នុងថ្នាក់រៀន (សម្ភារៈអ្វីក៏បាន ឱ្យតែគេអាចគិតឃើញដូចជា ប៊ិក សៀវភៅ កាបូបស្ពាយ...)។ នៅពេលដែលសិស្សម្នាក់នោះចូលមកកាន់ក្រុមវិញ សមាជិកក្រុមត្រូវសួរសំណួរបិទ (ជាសំណួរដែលអាចឆ្លើយបានថា «មែន» ឬ «មិនមែន» តែប៉ុណ្ណោះ) ដើម្បីព្យាយាមស្វែងយល់ថាវត្ថុនោះជាអ្វី។ នៅពេលដែលក្រុមណាមួយទាយត្រូវវត្ថុនោះ មានន័យថាក្រុមនោះឈ្នះជុំនេះ។ អាស្រ័យលើពេលវេលាដែលអ្នកមាន អ្នកអាចលេងបាន ២ជុំ។

### *ជំហានទី ២*

អ្នកត្រូវប្រាប់សិស្សក្នុងក្រុមទាំងអស់ថា ការពិតវាចំណាយពេលយូរ ដើម្បីទាយត្រូវថាវត្ថុនោះជាអ្វីនៅក្នុងជុំនីមួយៗ នៅពេលដែលយើងប្រើទម្រង់សំណួរបិទ។ ប្រសិនបើយើងគ្មានពេល ហើយត្រូវសួរតែមួយសំណួរដើម្បីទាយវត្ថុនោះ តើសំណួរនោះគួរតែជាអ្វី?

សំណួរគួរតែជា «តើវត្ថុនោះជាអ្វី?» ដែលគេហៅថាសំណួរបើក។

សំណួរបើកគឺជាមធ្យោបាយមួយដ៏ប្រពៃនៅក្នុងការសន្សំពេលវេលា ថាមពល និងជួយអ្នកក្នុងការទទួលបានព័ត៌មានដែលអ្នកត្រូវការលឿន។ ទោះជាយ៉ាងណាក៏ដោយ សំណួរបិទក៏អាចមានប្រយោជន៍ច្រើននៅពេលខ្លះ ក្នុងការបញ្ជាក់ការយល់ដឹងរបស់អ្នក ឬក្នុងការជួយអ្នកគ្រប់គ្រងការសន្ទនាជាមួយនឹងមនុស្សទូទៅដែលចូលចិត្តនិយាយច្រើន។ សកម្មភាពដ៏សាមញ្ញបែបនេះ គឺជាវិធីមួយដ៏រីករាយ ដើម្បីណែនាំ និងបង្ហាញនូវភាពខុសគ្នារវាងសំណួរបិទ និងសំណួរបើក។

## សកម្មភាពសិស្សទី៣ (រយៈពេល ១០ នាទី)

បង្កើតការពិភាក្សាដ៏លឿនមួយ អំពីអ្វីដែលពួកគេគិតថាល្អ និងមានប្រសិទ្ធភាពក្នុងការប្រាស្រ័យទាក់ទង។ អ្នកអាចសរសេរសំណើទៅលើក្តារខៀន ហើយពួកគេអាចសរសេរចូលទៅក្នុងសៀវភៅរបស់ពួកគេ។

ប្រភព៖ https://www.trainingcoursematerial.com/mini-course-material-packages



## មេរៀនទី ៤ ការដោះស្រាយបញ្ហា

វត្ថុបំណងនៃមេរៀននេះគឺ៖

- ឱ្យសិស្សសាកល្បងដោះស្រាយបញ្ហាមួយ ដែលភ្ជាប់ទៅនឹងជំនាញធ្វើការងារជាក្រុម

### សកម្មភាពសិស្ស៖ ល្បែងផ្គុំរូបភាព

អ្នកត្រូវជ្រើសរើសរូបភាព ឬរូបគំនូរដែលល្បីឈ្មោះមួយដែលមានព័ត៌មានពេញលេញ និងមិនត្រូវបង្ហាញរូបភាពនេះទៅកាន់សិស្សឡើយ។ អ្នកអាចកាត់រូបភាពនេះ ជាចំណែកដែលមានរាងការេតូចៗជាច្រើនឱ្យស្មើនឹងចំនួនសិស្សសម្រាប់សកម្មភាពនេះ។ ចែកបំណែករូបភាពឱ្យសិស្សម្នាក់មួយ ហើយណែនាំសិស្សឱ្យផ្គុំរូបនោះឡើងវិញឱ្យដូចទៅនឹងរូបភាពដើម ដែលមានទំហំធំជាង ៥ ដងនៃរូបភាពដើម។ អ្នកអាចចែកខ្មៅដៃ ប៊ិកហ្វឺត ក្រដាស និងបន្ទាត់ ដើម្បីឱ្យដំណើរការនេះប្រព្រឹត្តទៅដោយរលូន។ នៅពេលដែលសិស្សបញ្ចប់កិច្ចការធ្វើរូបឱ្យធំជាងមុន ៥ដងនេះរួច ឱ្យពួកគេផ្គុំបំណែករូបរបស់ពួកគេទៅក្នុងរូបភាពធំនោះនៅលើតុ។ សកម្មភាពដោះស្រាយបញ្ហានេះ នឹងបង្រៀនសិស្សពីរបៀបធ្វើការជាក្រុម ហើយវាបានបង្ហាញអំពីការបែងចែកការទទួលខុសត្រូវលើការងារ ដែលផ្តល់នូវការយល់ដឹងទៅកាន់សិស្សថា ការងាររបស់បុគ្គលម្នាក់ៗ រួមចំណែកបង្កើតបានជាលទ្ធផលរបស់ក្រុមទាំងមូល។

*ប្រភព៖* https://www.huddle.com/blog/team-building-activities/

*សូមមើលផងដែរនូវ៖* https://icebreakerideas.com/problem-solving-activities/



# មេរៀនទី ៥ ភាពជាអ្នកដឹកនាំ

វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សនឹងយល់ដឹងបន្ថែមអំពីការគ្រប់គ្រងខ្លួនឯង និងភាពជាអ្នកដឹកនាំ

## សកម្មភាពសិស្សទី១

ណែនាំឱ្យសិស្សគ្រប់គ្នាដាក់ពិន្ទុខ្លួនឯង ដោយប្រើប្រាស់សន្លឹកកិច្ចការខាងក្រោម ឬពួកគេអាចសរសេរសំណួរចូលក្នុងសៀវភៅ។

## សន្លឹកកិច្ចការ៖ បញ្ជីផ្ទៀងផ្ទាត់ការដឹកនាំខ្លួនឯង!

អ្នកអាចសាកល្បងប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់នេះ ដើម្បីធ្វើការប៉ាន់ប្រមាណនូវជំនាញភាពជាអ្នកដឹកនាំរបស់អ្នក៖

| បរិយាយ | ជាទូទៅ | ម្តងម្កាល | កម្រ/មិនដែល | ឧទាហរណ៍ជាក់ស្តែង |
|---|---|---|---|---|
| បង្កើតទស្សនៈវិស័យផ្ទាល់ខ្លួន៖<br>ខ្ញុំប៉ាន់ប្រមាណខ្លួនឯងដោយប្រើប្រាស់ ធាតុចូល/យោបល់ត្រលប់ពីអ្នកដទៃ លក្ខណៈវិនិច្ឆ័យខាងក្រៅ និងការសង្កេតផ្ទាល់ខ្លួនក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងបំពេញគោលដៅ។ | | | | |
| ខ្ញុំយល់ថា អត្តចរិត និងជម្រើសរបស់ខ្ញុំ អាចជួយ និងរារាំងការសម្រេចជោគជ័យ និងដំណើរការឆ្ពោះទៅរកគោលដៅរបស់ខ្ញុំ។ | | | | |
| ខ្ញុំប្រើប្រាស់យុទ្ធសាស្ត្រ ដើម្បីរំឭកខ្លួនឯងនូវចំណុចខ្លាំង វិធីរៀនសូត្រ និងរបៀបរៀនរបស់ខ្ញុំ។ | | | | |
| ខ្ញុំអាចបន្សាំ និងកែតម្រូវទៅលើវិធីរៀនសូត្រ និងរបៀបរៀនខុសៗគ្នា។ | | | | |
| ខ្ញុំស្វែងរកឱកាស ដើម្បីពុះពារទៅមុខដោយខ្លួនឯង។ | | | | |
| ខ្ញុំគិតអំពីភាពជោគជ័យ និងបរាជ័យរបស់ខ្ញុំ និងអ្វីដែលខ្ញុំបានរៀនអំពីខ្លួនឯង។ | | | | |
| ខ្ញុំប៉ាន់ប្រមាណនូវភាពភ័យខ្លាចបរាជ័យ កម្រិតសមត្ថភាព និងជម្រើសរបស់ខ្ញុំ | | | | |
| ការកំណត់គោលដៅ អាទិភាព ផែនការ៖ ខ្ញុំទទួលស្គាល់ និងចាប់យកការទទួលខុសត្រូវសម្រាប់ធ្វើផែនការ និងបញ្ចប់គម្រោង។ | | | | |

| | | | | |
|---|---|---|---|---|
| ខ្ញុំកំណត់អាទិភាព និងរៀបចំការងាររបស់ខ្ញុំដោយប្រើប្រាស់គំរូផែនការសកម្មភាព។ គំរូរបស់ខ្ញុំដាក់បញ្ចូល គោលដៅ និងជំហានក្នុងការឈានទៅដល់ និងដាក់នូវគោលដៅ និងអាទិភាពជាច្រើន។ | | | | |
| ខ្ញុំបង្កើត និងប្រើប្រាស់នូវប្រព័ន្ធដ៏មានប្រសិទ្ធភាពសម្រាប់ចាត់ចែងពេលវេលា និងសម្ភារៈ។ | | | | |
| ខ្ញុំរៀបរចនាសម្ព័ន្ធផែនការដែលដាក់វាយយ៉ាងច្បាស់នូវយុទ្ធសាស្ត្រ កត្តាពេលវេលា ធនធានដែលត្រូវការ និងឧបសគ្គជាទូទៅ | | | | |
| ការគ្រប់គ្រងខ្លួនឯង៖<br>ខ្ញុំប្រើប្រាស់បច្ចេកទេស និងឧបករណ៍គ្រប់គ្រងពេលវេលា ដូចជាសៀវភៅផែនការប្រចាំថ្ងៃ និងប្រតិទិន។ | | | | |
| ខ្ញុំធ្វើការជ្រើសរើសដោយផ្អែកលើព័ត៌មាន ឬទិន្នន័យ និងការយល់ដឹងអំពីការទទួលខុសត្រូវ ដូចជាហេតុ និងផល និងផលវិបាក។ | | | | |
| ខ្ញុំធ្វើផែនការ និងផែនការត្រៀមបង្ការ ដែលដោះស្រាយនូវបញ្ហាស្រួស និងជៀសវាងនូវការពន្យារពេល។ | | | | |
| ខ្ញុំកំណត់រកលំនាំជំរុញទឹកចិត្តផ្ទាល់ខ្លួន ធ្វើការងារដោយផ្អែកលើចំណុចខ្លាំង និងប្រើប្រាស់បច្ចេកទេសសម្រាប់ប្រភេទការងារណាដែលត្រូវការកែលំអឱ្យប្រសើរឡើង។ | | | | |
| ខ្ញុំពន្យល់កំហុសនោះថាជាឱកាសសម្រាប់រៀនសូត្រ និងចង្អុលបង្ហាញការរៀនសូត្រតាមរយៈកំហុសរបស់ខ្ញុំ។ | | | | |
| ខ្ញុំបង្កើត និងប្រើប្រាស់នូវភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯង និងជំនាញគ្រប់គ្រងខ្លួនឯង។ ឧ.ស្វែងរកដំណោះស្រាយបញ្ហាដោយខ្លួនឯង មុននឹងរកជំនួយ ហើយដឹងថាត្រូវរកជំនួយនៅពេលណា ដោយរបៀបណាដែលសមរម្យ។ | | | | |
| ខ្ញុំចង្អុលបង្ហាញ និងវាយតម្លៃទម្លាប់ការងារ និងអត្តចរិតខ្លួនឯង ហើយពិពណ៌នាពីចំណុចខ្លាំង និងចំណុចដែលត្រូវកែលំអដូចជា ការសហការ អត្តចរិតវិជ្ជមាន ការប៉ុនប៉ងធ្វើកិច្ចការឲ្យលើសពីស្តង់ដា និងបញ្ចប់កិច្ចការ។ | | | | |

*ប្រភព៖* https://www.oercommons.org/authoring/22763-self-direction-checklist-high-school/view

### សកម្មភាពសិស្សទី២

ឱ្យសិស្សធ្វើការជាក្រុមដែលមានគ្នា ៣ នាក់ ហើយពិភាក្សាអំពីលទ្ធផលរបស់ពួកគេទៅលើតេស្តខាងលើ និងចំណាប់អារម្មណ៍របស់ពួកគេចំពោះតេស្តនេះ។ ឱ្យពួកគេដាក់គោលដៅផ្ទាល់ខ្លួនផងដែរ៖ តើពួកគេនឹងធ្វើដូចម្តេចចំពោះជំនាញគ្រប់គ្រងខ្លួនឯងដែលពួកគេមិនបានពិន្ទុច្រើន? ឱ្យពួកគេសរសេរនូវគំនិតដែលមានចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។



## មេរៀនទី ៦ សុខុមាលភាព

វត្ថុបំណងនៃមេរៀននេះគឺៈ

- សិស្សយល់ពីភាពសំខាន់នៃការថែទាំសុខភាពផ្លូវចិត្ត និងរាងកាយរបស់គេ។

### សកម្មភាពសិស្ស

ផ្ដល់ការណែនាំខ្លីដល់សិស្សអំពីអត្ថន័យនៃទិដ្ឋភាពទាំង ៦ ខុសៗគ្នារបស់សុខុមាលភាពៈ

***ស្ថានភាពរូបរាងកាយៈ*** ដើម្បីថែរក្សាស្ថានភាពរាងកាយរបស់អ្នកឱ្យបានល្អប្រសើរ អ្នកត្រូវហាត់កីឡាបានគ្រប់គ្រាន់ បរិភោគអាហារឱ្យបានទៀងទាត់ សម្រាក-គេងឱ្យបានគ្រប់គ្រាន់ មិនប្រើប្រាស់សារធាតុស្រវឹងច្រើនពេក មិនជក់បារី ជាដើម។

***ស្ថានភាពស្មារតី និងខួរក្បាលៈ*** នៅពេលមនុស្សមានស្មារតី និងសុខភាពខួរក្បាលល្អ ពួកគេនឹងមានថាមពលរស់រវើក ងាយស្រួលក្នុងការរៀនអ្វីដែលថ្មី មានការចងចាំល្អ មានទេពកោសល្យសម្រាប់ការគិតត្រិះរិះពិចារណា និងមានភាពច្បាស់លាស់ អាចគិតពិចារណាបានល្អ អាចធ្វើឱ្យចិត្តស្ងប់ ងាយស្រួលក្នុងការសម្រេចចិត្ត មានតុល្យភាពក្នុងទំនាក់ទំនង និងការងារ មិនភ័យខ្លាចនឹងភាពបរាជ័យ និងអាចឆ្លុះបញ្ចាំងគំនិតបានស៊ីជម្រៅ។

***ស្ថានភាពសង្គម និងអារម្មណ៍ៈ*** មានន័យថា ចុះសម្រុងជាមួយអ្នកផ្សេងបានល្អ អាចទប់ទល់នឹងអារម្មណ៍អវិជ្ជមានខ្លួនឯងបាន មានមិត្តភក្តិដ៏គួរឱ្យទុកចិត្តដែលអាចនិយាយពីបញ្ហាសំខាន់ៗជាមួយបាន មានចំណង់ចំណូលចិត្តគួរឱ្យចាប់អារម្មណ៍ មានភាពរីករាយ យល់អំពីអារម្មណ៍របស់អ្នកដទៃ មានមិត្តភក្តិគ្រប់គ្រាន់ និងអាចស្ដាប់អារម្មណ៍ផ្ទាល់ខ្លួន។

***ស្ថានភាពគុណតម្លៃ និងផ្លូវចិត្តៈ***មានន័យថាមានតុល្យភាពជាមួយនឹងគុណតម្លៃខ្លួនឯង មានអារម្មណ៍ថាជីវិតពិតជាមានន័យ មានគោលដៅជីវិតច្បាស់លាស់ក្នុងជីវិត ដឹងថាអ្វីដែលជាគុណតម្លៃសំខាន់បំផុតរបស់មនុស្សម្នាក់ អាចរស់នៅប្រកបដោយសតិសម្បជញ្ញៈល្អ អាចអភិវឌ្ឍខ្លួនឯងជានិរន្តរ៍ សិក្សាអ្វីដែលថ្មី ស្រាវជ្រាវស្វែងរកការពិត មានចិត្តល្អ មានគោលដៅជីវិតជាក់លាក់។

***ស្ថានភាពការងារ និងវិជ្ជាជីវៈៈ*** មានន័យថា ការសិក្សាបានផ្ដល់នូវការពុះពារជាវិជ្ជមានដល់អ្នក។ អ្នកអាចរក្សាតុល្យភាពរវាងការសិក្សា ការងារ និងជីវិតរស់នៅបានល្អ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការពង្រឹងការសិក្សា និងអភិវឌ្ឍខ្លួនជាប្រចាំ មានគោលដៅច្បាស់លាស់នៅក្នុងការសិក្សា មានភាពចុះសម្រុងគ្នាបានល្អជាមួយមិត្តរួមថ្នាក់។

***ការអភិវឌ្ឍខ្លួនៈ*** មានន័យថា មានភាពងាយស្រួលក្នុងការរកឃើញអ្វីដែលជាគំនិតថ្មី និងដំណោះស្រាយផ្ទាល់ខ្លួនលើបញ្ហាប្រឈមអ្វីមួយ មើលឃើញបញ្ហាជាការប្រជែងចាប់យកឱកាសថ្មីមានគុណតម្លៃ និងការគិតត្រូវ មានភាពជឿជាក់លើខ្លួនឯងខ្ពស់ មានសមត្ថភាពក្នុងការវិនិច្ឆ័យវិភាគបញ្ហាដោយស៊ីជម្រៅជាលក្ខណៈប្រព័ន្ធ ដឹងអំពីចំណុចខ្សោយ និងចំណុចខ្លាំងរបស់ខ្លួនឯង។ (ប្រភពៈ Sydänmaalakka ២០១៣)

ពេលនេះឱ្យសិស្សប្រើប្រាស់សន្លឹកកិច្ចការ ឬគូររូបភាពចូលទៅក្នុងសៀវភៅរបស់ពួកគេ ដើម្បីធ្វើការវាយតម្លៃអំពីសុខុមាលភាពផ្ទាល់ខ្លួន។ ឱ្យពួកគេគូររូបភាពប្រហាក់ប្រហែលមួយទៀត ដោយដាក់ចូលនូវគោលដៅសម្រាប់អនាគត (ដាក់កាលបរិច្ឆេទច្បាស់លាស់) និងបង្កើតជាជំហាន និង

ផែនការដែលពួកគេត្រូវធ្វើ ដើម្បីសម្រេចបានគោលដៅទាំងនេះ។ ពួកគេគួរតែកត់ត្រារាល់ចំណុចទាំងនេះចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។

## សន្លឹកកិច្ចការ






# មេរៀនទី ៧ ការបង្កើតបណ្តាញ

វត្ថុបំណងនៃមេរៀននេះគឺៈ

- សិស្សយល់អំពីសារៈសំខាន់នៃការបង្កើតបណ្តាញនៅក្នុងការរស់នៅ និងនៅកន្លែងការងារ។

## សកម្មភាពសិស្សទី១

បំផុតឱ្យសិស្សពិភាក្សាបង្ហាញការយល់ឃើញរបស់ពួកគេអំពីពាក្យថា «បណ្តាញ» ។ អ្វីទៅជាការកសាងបណ្តាញ? តើការកសាងបណ្តាញសំខាន់យ៉ាងដូចម្តេចខ្លះសម្រាប់អ្នក?

## សកម្មភាពសិស្សទី២

សាកល្បងឱ្យសិស្សធ្វើផែនទីបណ្តាញរបស់ពួកគេ។ ឱ្យសិស្សបំពេញនៅក្នុងសន្លឹកកិច្ចការ ឬចម្លងសំណួរចូលក្នុងសៀវភៅ រួចហើយបំពេញចម្លើយ។

## សន្លឹកកិច្ចការ

១. ប្រសិនបើខ្ញុំត្រូវការអ្នកស្តាប់ដ៏ល្អម្នាក់ ខ្ញុំនឹងនិយាយជាមួយ ________________ (ដាក់ឈ្មោះបុគ្គលនោះ)។

២. ប្រសិនបើខ្ញុំត្រូវការយោបល់គ្រលប់បែបស្ថាបនាខ្ញុំនឹងពិគ្រោះជាមួយ _____________ ។

៣. នៅពេលដែលខ្ញុំមានអារម្មណ៍ថាឯកា ធុញថប់អារម្មណ៍ និងត្រូវការជំនួយ ខ្ញុំនឹងពិភាក្សាជាមួយ ________ ។

៤. នៅពេលដែលខ្ញុំត្រូវការឱ្យនរណាម្នាក់ប្រកួតប្រជែងនឹងខ្ញុំ ដើម្បីឱ្យខ្ញុំធ្វើការរឹតតែបានល្អ ខ្ញុំនឹងទៅរក ________ ។

៥. នៅពេលដែលខ្ញុំត្រូវការឱ្យនរណាម្នាក់ប្រាប់ថា ខ្ញុំជាអ្នកណា និងអ្វីដែលខ្ញុំធ្វើមានតម្លៃឬអត់ ខ្ញុំនឹងពិភាក្សាជាមួយ ________ ។

៦. នៅពេលដែលខ្ញុំព្យាយាមស្វែងរកទេពកោសល្យរបស់ខ្ញុំ និងព្យាយាមអភិវឌ្ឍជំនាញរបស់ខ្លួន ខ្ញុំនឹងស្វែងរកជំនួយពី________ ។

៧. នៅពេលដែលខ្ញុំចង់ចែករំលែកសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ ខ្ញុំនឹងទៅរក ________ ។

៨. ___________ជួយខ្ញុំក្នុងការបង្ហាញឱ្យឃើញនូវតម្លៃនៃភាពច្នៃប្រឌិតផ្ទាល់របស់ខ្ញុំ។

៩. ប្រសិនបើចាំបាច់នៅក្នុងការនិយាយអំពីការសិក្សារបស់ខ្ញុំ ខ្ញុំនឹងទៅរក ____________។

១០. ប្រសិនបើខ្ញុំចង់ពិភាក្សាពាក់ព័ន្ធបញ្ហាសីលធម៌ និងគុណតម្លៃរបស់ខ្ញុំក្នុងការសម្រេចចិត្ត ខ្ញុំនឹងទៅរក ___________ ។

១១. ប្រសិនបើមានការព្រួយបារម្ភខ្លាចមានកំហុសក្នុងការងារដែលខ្ញុំធ្វើកន្លងមកខ្ញុំនឹងទៅរក ___________ ។

១២. នៅពេលដែលខ្ញុំចង់អបអរឿងល្អៗនៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំចង់ធ្វើវាជាមួយ ________ ។

*ដកស្រង់ចេញពី Peavy ២០០១។*




**សកម្មភាពសិស្សទី៣** (លំហាត់បន្ថែមប្រសិនបើមានពេល)

ឱ្យសិស្សអានអត្ថបទខាងក្រោម ចែករំលែកគំនិតនៅក្នុងក្រុមតូច (ដោយ Ian James Wright) ៖

*«វាអាចពិបាកសម្រាប់នរណាម្នាក់ ដែលធ្វើការជាអ្នកទទួលបន្ទុកការងារប្រាស្រ័យទាក់ទង ឬទំនាក់ទំនងសាធារណៈ ប៉ុន្តែមិនពូកែនិយាយទាក់ទងគ្នា។ នៅពេលដែលពួកគេចាប់ផ្ដើមកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធ ពួកគេនៅតែមិនអាចធ្វើឱ្យគូសន្ទនាទទួលបាននូវអារម្មណ៍កក់ក្ដៅដូចអ្នកមានទេពកោសល្យពីធម្មជាតិ។*

*ប្រសិនបើអ្នកចូលរួម ព្រឹត្តការណ៍វិជ្ជាជីវៈណាមួយ អ្នកគួរតែចំណាយពេលឱ្យមានតម្លៃនៅទីនោះ ប្រៀបដូចជាជីវិតការងាររបស់អ្នកដូច្នោះដែរ។ ក្នុងន័យនេះ អ្នកត្រូវអនុវត្តតាមចំណុច ៤ ខាងក្រោម ដើម្បីជំរុញខ្លួនអ្នកឱ្យទទួលបានភាពជោគជ័យ៖*

***១. មកដោយមានគោលបំណងច្បាស់លាស់៖*** *ការចាប់ផ្ដើមជាមួយនឹងការចំណាយពេលវេលាស្គាល់មនុស្សដ៏គួរចាប់អារម្មណ៍ម្នាក់ វាប្រសើរជាងគ្រាន់តែណែនាំខ្លួនទៅកាន់មនុស្ស ១០ នាក់។*

***សកម្មភាព៖*** *ចូរឆ្លើយសំណួរទាំងនេះ៖ ១) តើអ្វីទៅជាចំណុចល្អបំផុតដែលអ្នកទទួលបានបន្ទាប់ពីបានចូលរួមក្នុងព្រឹត្តិការណ៍កសាងបណ្ដាញអ្វីមួយ? តើអ្វីជាគោលដៅដែលអ្នកអាចអនុវត្តបាន?*

***២. ការតាមដាន៖*** *អ្នកដែលបានប្រមូលនាមបណ្ណផ្សេងៗកន្លងមក ប៉ុន្តែមិនដែលតាមដាន និងទាក់ទងបន្តសូមលើកដៃឡើង...។ តើការកសាងបណ្ដាញបានធ្វើឱ្យអ្នកទទួលផលល្អឬទេ?*
***សកម្មភាព៖*** *ចាប់យកនាមបណ្ណមួយមក រួចពិនិត្យមើលអាសយដ្ឋានអ៊ីម៉ែលរបស់ម្នាក់នោះ រួចផ្ញើសារអេឡិចត្រូនិចធម្មតាហើយលឿនមួយ។ អ្នកអាចនឹងមានលទ្ធភាពក្នុងការចាប់ផ្ដើមកិច្ចសន្ទនា ប្រសិនបើភាគីម្ខាងទៀតចាប់អារម្មណ៍សាររបស់អ្នក។ នេះជាការចាប់ផ្ដើមសាមញ្ញបំផុតក្នុងការបង្កើតបណ្ដាញ។*

***៣. ការអនុវត្ត៖*** *ប្រសិនបើអ្នកជាមនុស្សមិនសូវចេះមាត់កច្រើន អ្នកត្រូវហ្វឹកហាត់នូវជំនាញកសាងបណ្ដាញ ដើម្បីចូលរួមក្នុងព្រឹត្តការណ៍ណាមួយដោយរលូន ក្នុងគោលដៅរាប់អានអ្នកដទៃ ឬបង្កើតមិត្តភាពថ្មី។ អ្វីៗទាំងអស់សុទ្ធតែអាចហ្វឹកហាត់បាន។ សូមបង្កើតការសន្ទនាជាមួយនឹងមនុស្សចំលែកម្នាក់នៅក្នុងសប្ដាហ៍នេះ។*

***សកម្មភាព៖*** *អ្នកអាចចាប់ផ្ដើមការសន្ទនាទៅកាន់មនុស្សមិនដែលស្គាល់គ្នាពីមុនមក ឬអ្នកដែលធ្វើការជាមួយគ្នាថ្មីថ្មោង។ ការសន្ទនាមិនចាំបាច់ទាល់តែប្រើពេលយូរ ស៊ីជម្រៅនោះទេ ប៉ុន្តែគឺជាអ្វីដែលអ្នកអាចទទួលបានអ្វីមួយគួរឱ្យចាប់អារម្មណ៍ ឬភ្ញាក់ផ្អើល។*

*៤. **ធ្វើខ្លួនអ្នកងាយឱ្យគេចូលជិតបាន៖** ចូរចងចាំថា មិនមែនមានតែអ្នកម្នាក់ទេដែលស្វែងរកការតភ្ជាប់ទំនាក់ទំនង។ ប្រសិនបើអ្នកមានការបើកផ្លូវសន្ទនា អ្នកផ្សេងអាចនឹងឈានជើងចូលមកនិយាយជាមួយអ្នក។*

***សកម្មភាព៖*** *ប្រសិនបើអ្នកចូលរួមស្ដាប់វាគ្មិន ដែលត្រូវមានវគ្គសំណួរ និងចម្លើយ អ្នកគួរព្រាងសំណួរដែលពាក់ព័ន្ធចំនួនបី ដើម្បីសួរ។ ពេលនេះ វាជាឱកាសអ្នកដែល អាចណែនាំខ្លួនទៅកាន់អ្នកចូលរួមបាន។*

ប្រភព៖http://www.prnewsonline.com/improve-networking-skills by Ian James Wright 2017.



# មេរៀនទី ៨ ការធ្វើការងារជាក្រុម

វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សបានយល់ និងរីករាយនឹងបទពិសោធន៍នៃការធ្វើការងារជាក្រុម
- រៀនក្នុងការវាយតម្លៃជំនាញក្នុងការធ្វើការងារជាក្រុមរបស់ពួកគេផ្ទាល់។

## សកម្មភាពសិស្សទី១

*ជំហានទី ១* (រយៈពេល ២៥ នាទី)

សិស្សនឹងបង្កើតជាអត្ថបទកាសែតជាមួយគ្នា។ ឱ្យសិស្សយកអត្ថបទកាសែតមកពីផ្ទះរៀងៗខ្លួន។ បែងចែកសិស្សជា ៤-៥ ក្រុមដែលមានគ្នា ៣-៦ នាក់ រួចចែកភារកិច្ចខុសៗគ្នាទៅតាមផ្នែកនៃអត្ថបទកាសែត (ឧ.សេដ្ឋកិច្ច អន្តរជាតិ នយោបាយ វប្បធម៌ កីឡា)។ ពេលនេះ ក្រុមនីមួយៗមានអត្ថបទកាសែតចំនួន ២ ទំព័រដែលត្រូវបំពេញ (ផ្ទាំងក្រដាសធំមួយ)។ ពួកគេអាចកាត់ចេញ រួចបិទនូវព័ត៌មានមិនថាថ្មី ឬចាស់ ឬសរសេរព័ត៌មានថ្មី និងគូររូបភាពទៅក្នុងផ្ទាំងក្រដាស។ សម្ភារៈដែលត្រូវការគឺ ផ្ទាំងក្រដាស ប៊ិកហ្វឺត កាវ ស្កុត កន្ត្រៃ និងកាសែត។

*ជំហានទី ២* (រយៈពេល ១០ នាទី)

ឱ្យពួកគេបិទផ្ទាំងក្រដាស (មួយផ្ទាំង) នៅលើជញ្ជាំង។ មានន័យថា ពួកគេត្រូវពិភាក្សាក្នុងក្រុមពីការកំណត់មាតិកាក្នុងអត្ថបទកាសែតរបស់ខ្លួន។

## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

បង្កើតការពិភាក្សាជាក្រុមអំពីអ្វីដែលពួកគេបានរៀន៖

- តើក្រុមរបស់អ្នកសម្រេចយកចំណងជើងអ្វី?
- តើសមាជិកក្រុមគ្រប់គ្នាយល់ស្របចំពោះចំណងជើងនេះដែរឬទេ? ប្រសិនបើមិនយល់ស្រប តើអ្នកត្រូវសម្របសម្រួលគ្នាដូចម្តេច?
- តើនរណាជា «អ្នកកែសម្រួលអត្ថបទ»? តើតួនាទីគាត់/នាងជាអ្វី?
- តើសមាជិកផ្សេងនៅក្នុងក្រុមស្តាប់យោបល់របស់អ្នកទេ? តើអ្នកគ្រប់គ្នាបានចូលរួមដៃឬទេ?
- យ៉ាងហោចណាស់ពួកគេបានរៀនអំពី ការកំណត់គោលដៅច្បាស់លាស់ ការគិតបែបច្នៃប្រឌិត ការសហការ និងការប្រាស្រ័យទាក់ទង។



ដកស្រង់ពីៈ - http://www.ventureteambuilding.co.uk/all-the-news-team-building-activity/

- http://www.ventureteambuilding.co.uk/team-building-activities/

# មេរៀនទី ៩ ការទទួលខុសត្រូវ

វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សយល់អំពីភាពខុសគ្នារវាង អាកប្បកិរិយាទទួលខុសត្រូវ និងមិនទទួលខុសត្រូវ នៅក្នុងជីវិតការងារ សិក្សា និងជីវិតរស់នៅប្រចាំថ្ងៃ។

## សកម្មភាពសិស្សទី១ (រយៈពេល ១៥ នាទី)

ឱ្យសិស្សធ្វើការជាក្រុមដែលមានគ្នា ៤ នាក់ជាមួយនឹងសន្លឹកកិច្ចការ ឬឱ្យពួកគេសរសេរលំហាត់ចូលទៅក្នុងសៀវភៅ។

### សន្លឹកកិច្ចការ

| តើអ្វីខ្លះជាសញ្ញាមិនទទួលខុសត្រូវ (នៅសាលា ឬនៅកន្លែងធ្វើការ)? សរសេរខាងក្រោម៖ | តើវាមានអ្វីកើតឡើងប្រសិនបើបន្ទាប់ពីធ្វើសកម្មភាពបែបនេះ? សរសេរខាងក្រោម៖ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

## សកម្មភាពសិស្សទី២ (រយៈពេល ១៥ នាទី)

ឱ្យសិស្សធ្វើការជាក្រុមដែលមានគ្នា ៤ នាក់ជាមួយនឹងសន្លឹកកិច្ចការ ឬឱ្យពួកគេសរសេរលំហាត់ចូលទៅក្នុងសៀវភៅ។

### សន្លឹកកិច្ចការ

| តើអ្វីខ្លះជាសញ្ញាទទួលខុសត្រូវ (នៅសាលា ឬនៅកន្លែងធ្វើការ)? សរសេរខាងក្រោម៖ | តើវាមានអ្វីកើតឡើងប្រសិនបើបន្ទាប់ពីធ្វើសកម្មភាពបែបនេះ? សរសេរខាងក្រោម៖ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

### សកម្មភាពសិស្សទី៣ (រយៈពេល ១៥ នាទី)

ឱ្យក្រុមនីមួយៗបង្ហាញម្តងមួយក្រុមៗនូវសកម្មភាពទាំងពីរ (សញ្ញា –ផលវិបាក) និងធ្វើបែបនេះរហូតទាល់តែគ្រប់ទិដ្ឋភាពទាំងអស់ត្រូវបានគ្របដណ្តប់។

### សម្រាប់អ្នកប្រឹក្សាយោបល់៖

ប្រសិនបើសិស្សពិបាកក្នុងការរកឧទាហរណ៍ អ្នកអាចជួយពួកគេ៖ សញ្ញានៃការមិនទទួលខុសត្រូវគឺ ឧ. ខ្វះចំណាប់អារម្មណ៍ក្នុងការងារ និងការសិក្សា ហើយនៅក្នុងក្រុម អ្នកបន្ទោសអ្នកដទៃចំពោះកំហុស និងភាពបរាជ័យ មិនគោរពពេលកំណត់ គេចវេសពីការងារ - គម្រោងដែលត្រូវប្រឈម និងរអ៊ូរទាំអំពីការឱ្យតម្លៃមិនស្មើភាពគ្នាពីសំណាក់ប្រធានក្រុម គេចវេសការផ្តួចផ្តើម និងពឹងផ្អែកលើអ្នកដទៃ សម្រាប់ការងារផ្សេងៗ ខ្វះការជឿជាក់លើសមាជិកក្រុម និងអ្នកដឹកនាំ រកលេសជារឿយៗ ពួកគេតែងតែនិយាយ «វាមិនមែនជាកំហុសខ្ញុំទេ» ឬ «វាមិនយុត្តិធម៌នោះទេ»។ សញ្ញានៃការទទួលខុសត្រូវគឺ ឧ. ធ្វើនូវអ្វីដែលអ្នកយល់ព្រមក្នុងការធ្វើ ឆ្លើយតបតាមរយៈសកម្មភាពរបស់អ្នក យកចិត្តទុកដាក់លើបញ្ហាខ្លួនឯង ធ្វើខ្លួនគួរឱ្យជឿទុកចិត្ត ប្រើប្រាស់ការកាត់ក្តីដែលល្អ មិនទុកការងារចោល គោរពអ្នកដទៃ គោរពពេលវេលាកំណត់ គោរពកិច្ចព្រមព្រៀងរួម គិតគូរពីទ្រព្យសម្បត្តិរួមជាដើម។

*ដកស្រង់ចេញពី៖* https://www.slideshare.net/oyasjohn/helping-people-take-responsibility
http://www.goodcharacter.com/terms.shtml



# មេរៀនទី ១០ ក្រមសីលធម៌ការងារ

វត្ថុបំណងនៃមេរៀននេះគឺៈ

- សិស្សយល់អំពីអត្ថន័យនៃសីលធម៌នៅក្នុងការបំពេញការងារ។

## សកម្មភាពសិស្សទី១

សិស្សត្រូវស្រាវជ្រាវពីប្រភពអ៊ិនធឺណិតនូវក្រមសីលធម៌វិជ្ជាជីវៈ នៅកន្លែងការងារណាមួយ។ ជាជម្រើស ពួកគេអាចសម្ភាសអ្នកដែលធ្វើការនៅក្នុងអាជីពវិជ្ជាជីវៈនោះ ឬសុំជំនួយពីគ្រូ។ វិជ្ជាជីវៈមួយចំនួន មានក្រមសីលធម៌ផ្ទាល់របស់គេ ដែលអាចងាយស្រួលរកបាននៅតាមអ៊ិនធឺណិត (ឧ. សីលធម៌ក្នុងវិស័យថែទាំសុខភាព ឬសម្រាប់គិលានុបដ្ឋាយិកា/វេជ្ជបណ្ឌិត) ប៉ុន្តែការងារខ្លះ សីលធម៌វិជ្ជាជីវៈមិនសូវមានភាពច្បាស់លាស់នោះទេ។ ក្រមសីលធម៌មួយចំនួនគឺ ពិតជាច្បាស់លាស់ខ្លាំងណាស់ (ដូចជាមិនត្រូវលួចរបស់ថៅហ្វាយ...) ហើយត្រូវបានបុគ្គលិកអាចយល់ជាទូទៅ។ សិស្សគួរតែស្រាវជ្រាវផ្តោតទៅលើតែវិជ្ជាជីវៈណាដែលគេប៉ងចង់ដឹង និងចង់ធ្វើតែប៉ុណ្ណោះ។

ប្រសិនបើមិនអាចរកឃើញអ្វីនោះ ពួកគេគួរតែព្យាយាមប្រើប្រាស់ការគិតពិចារណាផ្ទាល់ខ្លួនក្នុងការចែងគោលការណ៍នៃក្រមសីលធម៌ និងសុជីវធម៌នៅក្នុងការងារទៅអនាគតរបស់ពួកគេ។ ឱ្យសិស្ស សរសេរលទ្ធផលចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់ពួកគេ។ ប្រសិនបើមានសិស្សណាដែលប៉ងចង់ធ្វើការនៅក្នុងវិជ្ជាជីវៈដូចគ្នា ពួកគេអាចធ្វើការជាមួយគ្នាជាគូ ឬជាក្រុម។

## សកម្មភាពសិស្សទី២

ឱ្យសិស្ស ឬក្រុមបង្កើតខិតបណ្ណមួយទំព័រ ឬក្រមសីលធម៌ៈ តើអ្វីជាក្រមសីលធម៌របស់ការងារ ឬវិជ្ជាជីវៈនេះ? ពួកគេក៏អាចគូរ ឬបិទរូបភាពចូលទៅក្នុងខិតបណ្ណ ដើម្បីធ្វើឱ្យវាកាន់តែទាក់ទាញ។ ដាក់ខិតបណ្ណទៅលើជញ្ជាំង ដូចនេះសិស្សគ្រប់គ្នាអាចអានវាបាន។ នៅចុងបញ្ចប់ ពួកគេអាចបិទខិត បណ្ណទាំងនោះចូលទៅក្នុងកំណត់ហេតុសិក្សារបស់ពួកគេ។




## សម្រាប់អ្នកប្រឹក្សាយោបល់

ចរិតលក្ខណៈរបស់ក្រមសីលធម៌ទូទៅរបស់និយោជិតម្នាក់នៅក្នុងអាជីពវិជ្ជាជីវៈគឺៈ

- សេចក្តីប្រកាសអំពីសីលធម៌ដែលទាក់ទងនឹងនិយោជិត (ឧ. គួរឱ្យជឿទុកចិត្តបាន គណនេយ្យភាព ស្មោះត្រង់ យុត្តិធម៌ ថ្លៃថ្នូរ មានការផ្តួចផ្តើមដោយខ្លួនឯងជាដើម។)
- អត្តចរិតរបស់និយោជិតសម្រាប់ការងារក្នុងសហគមន៍របស់គេ (ឧ. អត្តចរិតល្អ និងគោរពពេលវេលា និងការណែនាំការងារ ចរចារដោយស្មើភាព យុត្តិធម៌ ការផ្សះផ្សាលទ្ធភាពសហការ មានហេតុផល សុវត្ថិភាពវិជ្ជាជីវៈ សុខមាលភាពនៅកន្លែងធ្វើការ។)
- សិទ្ធិអតិថិជន និងគោលការណ៍អនុវត្តល្អទូទៅ (ឧ. ភាពសម្ងាត់របស់វិជ្ជាជីវៈ រក្សាការសម្ងាត់ និងឯកជនភាព បទប្បញ្ញត្តិការពារអតិថិជន អតិថិជន អ្នកជំងឺ និងសុវត្ថិភាពផលិតផល ការអនុវត្តនូវគុណតម្លៃរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធទៅនឹងអតិថិជន។
- ក្រមសីលធម៌វិជ្ជាជីវៈ (ឧ.ការអនុវត្តវិជ្ជាជីវៈល្អនៅក្នុងវិស័យនីមួយៗ ក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងវិជ្ជាជីវៈរបស់អ្នក គុណតម្លៃនៃការងាររបស់អ្នក។)

# មេរៀនទី ១១  ជំនាញក្នុងការបំពេញការងារ

ក្នុងមេរៀននេះ យើងនឹងសង្ខេបឡើងវិញនូវប្រធានបទធំៗចំនួនពីរនៅក្នុងឆមាសនេះ (ជំនាញក្នុងការបំពេញការងារ និងការងារគម្រោង)។ អ្នកនឹងត្រូវណែនាំសិស្សឱ្យមានការប្រជុំក្លឹបមុខវិជ្ជា ដូចនេះសិស្សអាចធ្វើការដោយឯករាជ្យ និងដោយសេរីនៅក្នុងថ្នាក់រៀន ដោយពួកគេអាចចាប់ដៃគូ ឬធ្វើការជាក្រុមតូចៗ។ អ្នកក៏អាចលើកទឹកចិត្តពួកគេឱ្យជួយគ្នាទៅវិញទៅមក។ តួនាទីរបស់គ្រូ/អ្នកប្រឹក្សាយោបល់គឺ ផ្តល់នូវជំនួយនៅពេលដែលត្រូវការ ប៉ុន្តែត្រូវផ្តល់ជាការណែនាំ និងគាំទ្រជាជាង «បង្រៀន»។ សិស្សអាចបញ្ចប់ភារកិច្ចរបស់គេក្នុងមេរៀនមុន ប្រសិនបើពួកគេមិនទាន់បានបញ្ចប់ ដោយសារតែអវត្តមាន ឬឈឺ។

## សកម្មភាពសិស្ស

ឱ្យសិស្សបូកសរុបដោយខ្លួនឯងនូវមេរៀនមុនទាំង ៩ ស្តីពីជំនាញក្នុងការបំពេញការងារដែលពួកគេបានរៀន។ ពួកគេអាចសរសេរ គូរ បន្ថែមរូបថត បន្ថែមកាតប៉ុស្តាល់ អត្ថបទខ្លីដកស្រង់ចេញពីកាសែត រូបភាពពីទស្សនាវដ្តី។ល។ ពួកគេ ត្រូវតែព្យាយាមយល់នូវជំនាញទាំងនោះឱ្យស៊ីជម្រៅ និងធ្វើឱ្យជំនាញទាំងនោះក្លាយជាទេពកោសល្យ និងបំណិនជីវិតផ្ទាល់ខ្លួន។ ដូចនេះ កំណត់ហេតុសិក្សារបស់ពួកគេ គួរតែរៀបរាប់អំពីរបៀបដែលគេយល់អំពីជំនាញទាំងនោះ និងអត្ថន័យសម្រាប់ខ្លួនឯង មិនត្រូវចម្លងនូវអ្វីដែលអ្នកបានបង្រៀនដូចជាមនុស្សយន្តនោះទេ។ អ្នកនឹងត្រូវចំណាយពេលពេញមួយ មេរៀនសម្រាប់លំហាត់នេះ។

ភារកិច្ចរបស់អ្នកគឺរក្សានូវភាពរីករាយ និងច្នៃប្រឌិត ប៉ុន្តែបង្កនូវបរិយាកាសដែលទន់ភ្លន់ អ្នកអាចចាក់សំឡេងតន្ត្រីស្រទន់ ដើម្បីជំរុញការងាររបស់សិស្ស រួចដើរជុំវិញ និងជួយសិស្សដែលមិនសូវច្បាស់ថាត្រូវធ្វើអ្វី ដើម្បីជួយឱ្យគេឆ្លុះបញ្ចាំងនូវគំនិតទាំងនោះ។












# មេរៀនទី ១២ ទីផ្សារការងារក្នុងមូលដ្ឋាន ១

មេរៀននេះ យើងត្រលប់ទៅកាន់ការងារគម្រោងទី១ និងប្រធានបទដ៏ធំមួយទៀតក្នុងថ្នាក់ទី ១២ គឺការស្វែងរកការងារ។ វត្ថុបំណងនៃការងារគម្រោងគឺ៖

- ផ្តល់ព័ត៌មានដល់សិស្ស អំពីប្រភេទការងារដែលពួកគេអាចដាក់ពាក្យបាននៅពេលនេះ ឬពេលក្រោយ
- ឱ្យសិស្សអនុវត្តបន្ថែមអំពីការធ្វើការការងារគម្រោងជាក្រុម

## សកម្មភាពសិស្សទី១

### *ជំហានទី ១*

បំផុសគំនិត!

ឱ្យសិស្សធ្វើការជាក្រុមដែលមានគ្នា ៥ នាក់។ ឱ្យសិស្សកាត់ក្រដាសដែលមានទំហំមធ្យមជារាង រង្វង់។ បន្ទាប់មក ឱ្យពួកគេរាយឈ្មោះក្រុមហ៊ុន សហគ្រាសសាធារណៈ និងសាជីវកម្ម អង្គការសង្គមស៊ីវិល សហគ្រាសខ្នាតតូច ឬមធ្យម ដែលកំពុងមានប្រតិបត្តិការនៅក្នុងតំបន់ ដាក់ក្នុងរង្វង់ (រង្វង់មួយ ឈ្មោះមួយ)។ ពួកគេ អាចសរសេរឈ្មោះស្ថាប័នទាំងនោះកាន់តែច្រើន កាន់តែល្អ។



*ជំហានទី ២*

ពេលនេ ឱ្យសិស្សរៀបចំរង្វង់របស់ពួកគេដាក់នៅលើផ្ទាំងក្រដាសធំបិទនៅលើជញ្ជាំងទៅតាមវិស័យនីមួយៗ (ឧ. ការងារថែរក្សាសុខភាពដាក់នៅលើផ្ទាំងក្រដាសធំមួយ និងសហគ្រាសជួសជុលរថយន្ត ដាក់នៅលើផ្ទាំងក្រដាសមួយទៀត)។ ប្រើប្រាស់ផ្ទាំងក្រដាសតាមចំនួនដែលត្រូវការ។




*ជំហានទី ៣*

ពេលនេះឱ្យសិស្សចូលជាក្រុមទៅតាមចំនួនផ្ទាំងក្រដាសធំដែលមានតាមវិស័យការងារនីមួយៗដើម្បីអង្កេត។

**សកម្មភាពសិស្សទី២**

ពេលនេះ សិស្សត្រូវធ្វើការងារគម្រោងសម្រាប់មេរៀនបន្ទាប់។ ចែកឱ្យក្រុមនីមួយៗនូវផ្ទាំងក្រដាសធំ ដែលពួកគេត្រូវធ្វើការសិក្សាឱ្យបានស៊ីជម្រៅ។ ពួកគេត្រូវស្រាវជ្រាវរកក្រុមហ៊ុនផ្សេងៗទៀត ដើម្បីដាក់បញ្ចូលក្នុងវិស័យដែលក្រុមគេទទួលបន្ទុក។ ពួកគេអាចប្រើប្រាស់ការស្រាវជ្រាវតាមអ៊ិនធឺណិត កាតាឡុក ឬសៀវភៅពណ៌លឿង (yellow pages) និងសួរគេឯង។ វត្ថុបំណងគឺ ដើម្បីមានបញ្ជីឈ្មោះក្រុមហ៊ុនមួយដែលគ្រប់ជ្រុងជ្រោយតាមដែលអាចធ្វើបាន។ ពួកគេនឹងត្រូវបិទរង្វង់បន្ថែមទៅលើផ្ទាំងក្រដាស ទៅតាមចំនួនឈ្មោះក្រុមហ៊ុនដែលពួកគេអាចរកបន្ថែមបាន។

# មេរៀនទី ១៣ ទីផ្សារការងារក្នុងមូលដ្ឋាន ២

## សកម្មភាពសិស្សទី១ (រយៈពេល ២៥ នាទី)

ឱ្យក្រុមនីមួយៗ (ពីមេរៀនមុន) បង្ហាញលទ្ធផលនៃការស្រាវជ្រាវព័ត៌មានរបស់ពួកគេ។ ដាក់ក្រដាសផ្ទាំងធំទៅលើជញ្ជាំងវិញ ដោយទុកឱ្យមានចន្លោះសម្រាប់បំពេញបន្ថែម។ ក្រុមនីមួយៗ នឹងបង្ហាញនូវក្រុមហ៊ុនថ្មីណាដែលពួកគេបានរកឃើញកំពុងប្រតិបត្តិនៅក្នុងវិស័យជាក់លាក់។ អ្នកផ្សេង (និងអ្នក) អាចនឹងបន្ថែមនូវក្រុមហ៊ុន ឬសហគ្រាសអ្វីដែលក្រុមមិនបានដាក់ ហើយអ្នកដឹង។




## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

ពេលនេះ ឱ្យសិស្សដែលចាប់អារម្មណ៍លើប្រភេទការងារជាក់លាក់ក្នុងវិស័យដូចគ្នា ចូលក្នុងក្រុមជាមួយគ្នាទៅតាមផ្ទាំងក្រដាសធំនីមួយៗ។ អ្នកអាចដកផ្ទាំងក្រដាសស្តីពីវិស័យការងារដែលមិនមានសិស្សចាប់អារម្មណ៍ចេញ។ ឱ្យសិស្សពិភាក្សាអំពីលទ្ធផលនៃការស្រាវជ្រាវព័ត៌មានរបស់ពួកគេ។ តើមានក្រុមហ៊ុនប្រភេទអ្វីខ្លះ? តើអ្នកមានចម្ងល់អ្វីសម្រាប់សួររកព័ត៌មានរបស់ក្រុមហ៊ុនទាំងនោះទេ?

## សកម្មភាពសិស្ស ៣ (រយៈពេល ១០ នាទី)

ឱ្យសិស្សចម្លងបញ្ជីឈ្មោះក្រុមហ៊ុនដែលពួកគេចាប់អារម្មណ៍ចូលក្នុងសៀវភៅ។ ពួកគេនឹងបន្តក្នុងការបកស្រាយវានៅពេលក្រោយ។

## មេរៀនទី ១៤ តើនិយោជកចង់បានអ្វី? ១

**សកម្មភាពសិស្សទី១** (រយៈពេល ៣៥ នាទី)

ឱ្យសិស្សចូលក្រុមដដែលដូចទៅនឹងមេរៀនមុន។ ដូចនេះ ពួកគេមានក្រុមដែលមានសមាជិកក្រុមចាប់អារម្មណ៍ក្នុងវិស័យការងារដូចគ្នា។ ពេលនេះ ពួកគេមានគំនិតល្អៗអំពីក្រុមហ៊ុនដែលកំពុងប្រតិបត្តិក្នុងវិស័យនោះ។ ឱ្យពួកគេបំផុសគំនិតអំពីអ្វីដែលនិយោជករំពឹងពីអ្នកដែលស្វែងរកការងារក្នុងវិស័យដែលគេចាប់អារម្មណ៍នោះ ដោយស្រមៃថា ពួកគេគឺជានិយោជកដែលត្រូវការជួលបុគ្គលិក។ តើគុណសម្បត្តិបែបណាដែលពួកគេស្វែងរកពីបុគ្គលិកដែលពួកគេចង់ជួល? បន្ទាប់មក សួរទៅកាន់ក្រុមឱ្យសរសេរនូវគុណសម្បត្តិដែលពួកគេនឹកឃើញថានឹងត្រូវការ។

ឱ្យក្រុមនីមួយៗបង្ហាញនូវលក្ខខណ្ឌតម្រូវការទៅកាន់ក្រុមធំទាំងមូល ហើយប្រសិនបើចាំបាច់ ក្រុមនីមួយៗអាចបញ្ចប់ការបកស្រាយរបស់ពួកគេជាមួយនឹងគំនិតដែលពួកគេឮពីក្រុមផ្សេង។

**សកម្មភាពសិស្សទី២** (រយៈពេល ២០ នាទី)

ឱ្យសិស្សរៀបចំបញ្ជីលក្ខខណ្ឌតម្រូវការរបស់ពួកគេតាមលំដាប់លំដោយ។ ក្នុងមេរៀនខាងមុខ ពួកគេត្រូវសម្ភាសនិយោជិតម្នាក់ដែលចង់បម្រើការក្នុងវិស័យការងារនោះ។ សំណួរតែមួយគត់របស់ពួកគេគឺៈ តើគុណសម្បត្តិបែបណាដែលអ្នករំពឹងថានឹងទទួលបានពីបុគ្គលិកដែលអ្នកត្រូវជួលសម្រាប់ក្រុមហ៊ុន/សហគ្រាសរបស់អ្នក? ពេលនេះ ពួកគេគួរតែសម្រេចថា ក្នុងចំណោមសមាជិកក្រុម តើនរណាដែលនឹងត្រូវឆ្លើយសម្ភាសនេះ? នៅក្នុងការសម្ភាស ពួកគេត្រូវតែកត់ត្រាអំពីចម្លើយទាំងនោះ។



# មេរៀនទី ១៥   តើនិយោជកចង់បានអ្វី? ២

## សកម្មភាពសិស្សទី១

ឱ្យសិស្សចូលក្នុងក្រុមការងារគម្រោងរបស់ពួកគេ ហើយបង្ហាញលទ្ធផលនៃការសម្ភាស។ តើនិយោជិកបានឆ្លើយអ្វីខ្លះ? តើព័ត៌មានរបស់គេស្រដៀងគ្នាទៅនឹងសិស្សផ្សេងដែរឬទេ? តើមានចំណុចដែលភ្ញាក់ផ្អើលដែរឬទេ? ឱ្យសិស្សបញ្ចូលព័ត៌មានដែលស្រដៀងទៅនឹងសន្លឹកកិច្ចការ។

## សន្លឹកកិច្ចការ

ឱ្យសិស្សរៀបរាប់ចម្លើយរបស់និយោជកនៅផ្នែកខាងឆ្វេង និងការវាយតម្លៃខ្លួនឯង ហើយប្រៀបធៀបទេពកោសល្យ ជំនាញ និងអាកប្បកិរិយា របស់ពួកគេទៅនឹងតម្រូវការរបស់និយោជកទាំងនោះ។

| គុណភាពដែលនិយោជកចង់ឱ្យនិយោជិតមានៈ | តើខ្ញុំអាចឆ្លើយតបទៅនឹងការរំពឹងទុកទាំងនោះបានដោយរបៀបណា? |
|---|---|
| រៀបរាប់ចម្លើយដែលគេទទួលបានពីការសម្ភាស<br>✓<br>✓<br>✓<br>✓ | <br>✓<br>✓<br>✓<br>✓ |

## សកម្មភាពសិស្សទី២

ពេលនេះពួកគេដឹងពីការរំពឹងទុករបស់និយោជក ក្នុងវិស័យជាក់លាក់ណាមួយ។ ពេលនេះឱ្យពួកគេបំពេញក្នុងសន្លឹកកិច្ចការ ដោយមិនបញ្ជាក់ពីវិស័យជាក់លាក់ ឬសាខាណាមួយនៃឧស្សាហកម្ម។



## សន្លឹកកិច្ចការ

តើនិយោជកត្រូវការអ្វី? តើខ្ញុំអាចឆ្លើយតបទៅនឹងការរំពឹងទុកទាំងនោះបានដោយរបៀបណា?

| គុណសម្បត្តិកំពូលសម្រាប់និយោជិត៖ | តើខ្ញុំអាចឆ្លើយតបទៅនឹងការរំពឹងទុកទាំងនោះបានដោយរបៀបណា? |
|---|---|
| **១) ភាពវៃឆ្លាត៖**<br>ភាពវៃឆ្លាតក្នុងន័យនេះមានន័យថា សមត្ថភាពក្នុងការធ្វើផែនការ រៀបចំ ចាត់អាទិភាព ដោះស្រាយបញ្ហា និងធ្វើការងារឱ្យរួចរាល់។ ភាពវៃឆ្លាតសំដៅទៅលើកម្រិតនៃសុភនិច្ឆ័យ និងសមត្ថភាពអនុវត្តរបស់អ្នកក្នុងការដោះស្រាយបញ្ហាប្រឈមនឹងការងារប្រចាំថ្ងៃ។ គន្លឹះនៅក្នុងការបកស្រាយភាពវៃឆ្លាតរបស់អ្នក គឺអ្នកត្រូវសួរសំណួរបែបឆ្លាតវៃ។ ចំណុចសំខាន់មួយនៃភាពវៃឆ្លាត គឺភាពចង់ដឹងចង់ឮ។ ពេលដែលអ្នកសួរសំណួរល្អៗកាន់តែច្រើន ហើយស្តាប់ចម្លើយ អ្នកនឹងសម្តែងចេញនូវភាពវៃឆ្លាត។ | |
| **២) សមត្ថភាពក្នុងភាពជាអ្នកដឹកនាំ៖**<br>ភាពជាអ្នកដឹកនាំគឺជាឆន្ទៈ និងចេតនាក្នុងការទទួលខុសត្រូវសម្រាប់លទ្ធផល។ វាគឺជាសមត្ថភាពនៅក្នុងការទទួលយកការងារស្ម័គ្រចិត្តសម្រាប់ភារកិច្ច និងទទួលយកគណនេយ្យភាពសម្រាប់សម្រេចបាននូវលទ្ធផលដែលទាមទារ ចេញពីភារកិច្ចទាំងនោះ។ សញ្ញាណនៃអ្នកដឹកនាំគឺថា គាត់ឬនាងមិនយកលេសរួចខ្លួន។ អ្នកត្រូវមានឆន្ទៈខ្ពស់ ក្នុងនាមជាអ្នកដឹកនាំនៅក្នុងស្ថាប័នដោយការទទួលខុសត្រូវ ដើម្បីសម្រេចគោលដៅរបស់ក្រុមហ៊ុន។ បន្ទាប់មក ប្តេជ្ញាចិត្តក្នុងការអនុវត្តឱ្យដល់កម្រិតខ្ពស់។ | |
| **៣) សុចរិតភាព៖**<br>វាប្រហែលជាសមត្ថភាពតែមួយគត់ ដែលសំខាន់បំផុតសម្រាប់ភាពជោគជ័យរយៈពេលវែងនៅក្នុងជីវិត និងការងារ។ សុចរិតភាព ចាប់ផ្តើមដោយការស្មោះត្រង់ចំពោះខ្លួនឯង។ មានន័យថាអ្នកពិតជាស្មោះត្រង់ចំពោះខ្លួនឯង និងនៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ។ អ្នកស្ម័គ្រចិត្តក្នុងការសារភាពនូវចំណុចខ្លាំង និងបញ្ហាប្រឈម។ អ្នកស្ម័គ្រចិត្តក្នុងការសារភាពនូវចំណុចដែលអ្នកបានធ្វើខុសកាលពីអតីត។ ជាពិសេសអ្នកបានបង្ហាញនូវភាពស្មោះត្រង់។ អ្នកមិនដែលនិយាយអ្វីអវិជ្ជមានអំពីនិយោជិតពីមុនរបស់អ្នក ឬអ្នកដែលធ្លាប់ធ្វើការជាមួយ។ ទោះបីជាអ្នកត្រូវបានគេបណ្តេញចេញពីការងារក៏ដោយ មិនត្រូវនិយាយអ្វីដែលអវិជ្ជមាន ឬរិះគន់។ | |
| **៤) គួរជាទីចូលចិត្ត៖**<br>និយោជកចូលចិត្តអ្នកដែលមានភាពកក់ក្តៅ រួសរាយ ងាយស្រួល និងសហការជាមួយអ្នកដទៃ។ និយោជក គឺកំពុងស្វែងរកមនុស្សដែលអាចចូលរួមជាក្រុម និងជាផ្នែកមួយនៃគ្រួសារការងារ។ ស្ត្រី និងបុរសដែលមានបុគ្គលិកលក្ខណៈល្អ គឺមានប្រជាប្រិយភាព និងមានប្រសិទ្ធភាពការងារច្រើននូវរាល់អ្វីដែលពួកគេធ្វើ។ ការងារជាក្រុម គឺជាគន្លឹះនៃភាពជោគជ័យរបស់អាជីវកម្ម។ | |
| **៥) សមត្ថភាព៖**<br>យើងបាននិយាយអំពីចំណុចនេះពីខាងដើម។ សមត្ថភាព គឺពិតជាសំខាន់ខ្លាំងណាស់សម្រាប់ភាពជោគជ័យរបស់អ្នក។ វាគឺជាមូលដ្ឋានគ្រឹះនៃអ្វីៗគ្រប់យ៉ាងដែលកើតមានចំពោះអ្នកនៅក្នុងអាជីពការងារ។ សមត្ថភាព គឺជាលទ្ធភាពដែលអាចធ្វើ | |

| | |
|---|---|
| ការងារសម្រេចបាន។ វាគឺជាលទ្ធភាពក្នុងការចាត់អាទិភាព បែងចែកភារកិច្ចមិនពាក់ព័ន្ធចេញពីភារកិច្ចដែលពាក់ព័ន្ធ រួចផ្តោតលើកិច្ចការតែមួយរហូតទាល់តែចប់។ | |
| **៦) ភាពក្លាហាន៖**<br>ភាពក្លាហានមានន័យថា ជាការប្តេជ្ញាក្នុងការទទួលយកការពុះពារ។ ការប្តេជ្ញាក្នុងការចាប់យកការងារធំ ឬក៏ការងារថ្មីដែលមានភាពមិនប្រាកដប្រជា និងភាពបរាជ័យខ្ពស់។ ភាពក្លាហាន ក៏មានន័យថាជាការប្តេជ្ញាក្នុងការនិយាយនូវអ្វីដែលអ្នកបានគិត និងមានអារម្មណ៍នៅក្នុងស្ថានភាពលំបាកណាមួយ។ និយោជក កោតសរសើរបុរស ឬស្ត្រីណាដែលមិនខ្លាចក្នុងការនិយាយពីការគិតរបស់ខ្លួន។ អ្នកបានបង្ហាញនៅក្នុងពេលសម្ភាសការងារ នៅពេលដែលអ្នកសួរសំណួរត្រង់ៗអំពីក្រុមហ៊ុន តួនាទី និងអនាគតដែលអ្នកអាចនឹងមានជាមួយនឹងស្ថាប័ន។ | |
| **៧) កម្លាំងចិត្តខាងក្នុង៖**<br>កម្លាំងចិត្តខាងក្នុង មានន័យថាអ្នកមានការតាំងចិត្ត និងលទ្ធភាពក្នុងការស៊ូទ្រាំនៅក្នុងទុក្ខលំបាក។ កម្លាំងចិត្តខាងក្នុង មានន័យថាអ្នកមានគុណភាពក្នុងការព្យាយាមនៅពេលដែលមានរឿងរ៉ាវពិបាក។ អ្នកបង្ហាញពីកម្លាំងចិត្តខាងក្នុងតាមរយៈការរក្សាភាពស្ងប់ស្ងាត់ និងស្ងប់អារម្មណ៍ពេលសម្ភាស។ ប្រសិនបើអ្នករក្សាភាពស្ងប់ស្ងាត់នៅក្នុងស្ថានភាពវិបត្តិដែលកើតឡើងនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន។ | |

ចំណុចខាងលើទាំងអស់នេះ គឺជាបុគ្គលិកលក្ខណៈរបស់អ្នក ដែលរាល់សមត្ថភាពវិជ្ជមានរបស់អ្នកនឹងមានឥទ្ធិពលទៅលើថាតើអ្នកអាចទទួលបានការងារដែលអ្នកចង់បានឬអត់។ ការងាររបស់អ្នកនៅពេលនេះ គឺបន្តធ្វើការទៅលើបុគ្គលិកលក្ខណៈរបស់អ្នក ដោយអនុវត្តនូវអត្តចរិតគុណសម្បត្តិកំពូលនៅគ្រប់កាលៈទេសៈ។

# មេរៀនទី ១៦   ការវិភាគព័ត៌មានអំពីការងារ

វត្ថុបំណងនៃមេរៀននេះគឺ៖

- រៀនវិភាគការផ្សព្វផ្សាយព័ត៌មានអំពីការងារ។

អ្នកត្រូវកាត់យកផ្នែកផ្សព្វផ្សាយព័ត៌មានអំពីការងារចេញពីកាសែតណាមួយ និងយកវាមកជាមួយអ្នកពេលមករៀន។ អ្នកអាចឱ្យសិស្សយកការផ្សព្វផ្សាយព័ត៌មានអំពីការងារដែលពួកគេចាប់អារម្មណ៍មកជាមួយ។

## សកម្មភាពសិស្ស (រយៈពេល ៤៥ នាទី)

ឱ្យសិស្សចូលជាក្រុមដែលមានគ្នា ៤-៥ នាក់។ ពេលនេះ ពួកគេត្រូវជ្រើសរើសការផ្សព្វផ្សាយព័ត៌មានអំពីការងារចំនួន ២ ដែលពួកគេចង់វិភាគកាន់តែច្បាស់។ ឱ្យសិស្សយកចិត្តទុកដាក់ទៅលើចំណងជើងតម្រូវការការងារដែលជាក់លាក់ ឬស្រដៀងគ្នានឹងកិច្ចការដែលពួកគេបានធ្វើក្នុង *លំហាត់តើនិយោជកចង់បានអ្វី។* តើអ្វីដែលជាតម្រូវការពិតប្រាកដសម្រាប់ការងារ? ឱ្យពួកគេបិទការផ្សព្វផ្សាយព័ត៌មានអំពីការងារទៅលើក្រដាស ហើយសរសេរតម្រូវការដែលពួកគេបានបង្កើតឡើងនៅជុំវិញនោះ។ ពួកគេគួរតែមានពេលវិភាគយ៉ាងហោចណាស់ការផ្សព្វផ្សាយព័ត៌មានអំពីការងារចំនួន ២ ឬច្រើនជាងនេះ អាស្រ័យលើពេលវេលាជាក់ស្តែង។ អ្នកគួរតែដើរជុំវិញក្រុម និងធានាថាពួកគេបានវិភាគយ៉ាងស៊ីជម្រៅ ដោយផ្អែកលើអ្វីដែលពួកគេបានរៀនពីវគ្គមុន មិនមែនគ្រាន់តែវិភាគរាក់ៗ លឿនរហ័សពេកនោះទេ។ រក្សាទុកការផ្សព្វផ្សាយព័ត៌មានអំពីការងារសម្រាប់មេរៀនទី ២២។



## មេរៀនទី ១៧ ជម្រើសការងាររបស់ខ្ញុំ

### សកម្មភាពសិស្សទី១

សិស្សនឹងបូកសរុបព័ត៌មានដែលប្រមូលបានជុំវិញអាជីពការងារដែលពួកគេបានជ្រើសរើសពីពេលមុន គិតផងដែរអំពីសមត្ថភាពរបស់ពួកគេនៅក្នុងវិស័យការងារ៖ ថាតើពួកគេអាចឆ្លើយតបនូវការរំពឹងទុករបស់ការងារដែលពួកគេបានជ្រើសរើសដោយរបៀបណា។ ពួកគេអាចប្រើប្រាស់មេរៀនមុនៗ សម្រាប់ធ្វើលំហាត់នេះ។ ប្រសិនបើមានពេល ពួកគេអាចចែករំលែកផែនការរបស់គេជាមួយដៃគូបាន។ អ្នកអាចប្រើប្រាស់សន្លឹកកិច្ចការ ឬឱ្យពួកគេចម្លងចូលសៀវភៅរបស់ពួកគេ។

**សន្លឹកកិច្ចការ**

| | ជម្រើសការងារ ១ | ជម្រើសការងារ ២ |
|---|---|---|
| តួនាទី និងភារកិច្ចចម្បងៗ៖ | | |
| ការអប់រំ តម្រូវការផ្លូវការជទៃទៀត៖ | | |
| ជំនាញផ្ទាល់ខ្លួនដែលមាន (ជំនាញសង្គម ជំនាញភាសា ឬផ្សេងទៀត)៖ | | |
| បទពិសោធន៍ការងារដែលត្រូវការ៖ | | |
| ឱកាសការងារទៅពេលអនាគតនៅសាខា៖ | | |
| ប្រាក់ខែ៖ | | |
| ម៉ោងធ្វើការ៖ | | |
| និយោជកដែលអាចមាននៅក្នុងបណ្ដាញ ឬការភ្ជាប់ទំនាក់ទំនងរបស់ខ្ញុំ | | |
| តើនិយោជកត្រូវការអ្វី? | | |
| តើខ្ញុំអាចឆ្លើយតបទៅនឹងតម្រូវការទាំងនោះបានដោយរបៀបណា? | | |
| | | |
| ការវាយតម្លៃប្រៀបធៀបនៃជម្រើសទាំង២របស់ខ្ញុំ៖ | | |

### សកម្មភាពសិស្សទី២

ឱ្យសិស្សសរសេរចូលក្នុងកំណត់ហេតុសិក្សារបស់ពួកគេនូវអ្វីដែលគេបានរៀនក្នុងការងារគម្រោង។ តើជំនាញធ្វើការងារជាក្រុមប្រភេទណាដែលគេបានរៀន? តើពួកគេបានរៀនអ្វីពីគ្នាទៅវិញទៅមក? តើពួកគេអាចធ្វើឱ្យប្រសើរឡើងនូវជំនាញក្នុងការងារគម្រោងដោយរបៀបណា? តើពួកគេមានមោទនភាពទៅលើអ្វី?



# មេរៀនទី ១៨ ក្លឹបមុខវិជ្ជា

ពេលនេះ ជាពេលបញ្ចប់ឆមាស សិស្សនឹងរៀបចំបង្កើតក្លឹបមុខវិជ្ជា។ ឱ្យសិស្សម្នាក់ដឹកនាំការអនុវត្តក្នុងថ្នាក់រៀន ឬណែនាំឱ្យសិស្សគ្រប់គ្នាធ្វើកិច្ចការតាមដែលគេចង់ធ្វើ អាចជាលក្ខណៈបុគ្គលជាគូ ឬជាក្រុមតូចៗ និងលើកទឹកចិត្តពួកគេឱ្យជួយគ្នាទៅវិញទៅមក។ ភារកិច្ចរបស់អ្នកគឺ បង្កើតបរិយាកាសរីករាយ មានភាពច្នៃប្រឌិត និងអាចចាក់តន្ត្រីស្រទន់ ដើម្បីជំរុញការងារសិស្ស។ អ្នកត្រូវដើរពិនិត្យការងារសិស្ស និងជួយសិស្សនៅពេលពួកគេត្រូវការជំនួយ។

## សកម្មភាពសិស្ស៖ បង្កើតគំនូរជីវចលរួមគ្នា

បែងចែកសិស្សជា ៥ ក្រុម ហើយចែកក្រដាសផ្ទាំងធំមួយក្រុម ១ សន្លឹក។ អ្នកគួរតែគូររូបប្រអប់ធំចំនួន ៥ ទៅលើក្រដាសទុកជាមុន។ អ្នកអាចចែកក្រដាសចំនួន ៥ សន្លឹកដែលមានបង់លំដាប់លេខរៀងឱ្យសិស្សក្នុងក្រុមនីមួយៗ ដោយក្រដាសនីមួយៗគឺត្រូវមានទំហំប៉ុននឹងប្រអប់គំនូរជីវចលមួយ។ វត្ថុបំណងគឺ បង្កើតគំនូរជីវចលក្នុងប្រអប់ចំនួន ៥ ពាក់ព័ន្ធការស្វែងរកការងារ។



ក្រុមនីមួយៗ មានរយៈពេល ៥ នាទី ដើម្បីគូររូបនៅលើក្រដាសសន្លឹកទី១ ដោយផ្ដើមឡើងនូវសាច់រឿងខាងដើមដូចៗគ្នា។ បន្ទាប់មក ពួកគេត្រូវបន្តគូរសាច់រឿងនៅលើក្រដាសសន្លឹកទី២ និងសន្លឹកបន្តបន្ទាប់រៀងៗក្រុម ដោយប្រើពេល ៥ នាទីសម្រាប់ការគូរលើសន្លឹកនីមួយៗ។ សាច់រឿងត្រូវតែចាប់ផ្ដើមនៅសន្លឹកទី១ (ផ្ដើមរឿងលើប្រធានបទតែមួយ) និងបញ្ចប់នៅសន្លឹកទី៥។ នៅពេលគូរចប់ ក្រុមនីមួយៗនឹងមានសាច់រឿងគំនូរជីវចលរបស់ខ្លួនចំនួន ៥ សន្លឹក រួចយកវាទៅបិទភ្ជាប់នឹងប្រអប់ដែលបានបែងចែកសម្រាប់ក្រុមនីមួយៗនៅលើផ្ទាំងក្រដាសធំ។

សិស្សអាចប្រើការស្រមើស្រមៃរបស់ពួកគេ អំពីសាច់រឿងបន្តពីក្រដាសទី១បានដោយសេរី។ សាច់រឿងគំនូរជីវចលនេះ មិនមានភាពខុស ឬត្រូវនោះទេ។ ក្រុមនីមួយៗត្រូវឡើងបង្ហាញអំពីសាច់រឿងរបស់ពួកគេទៅវិញទៅមករហូតទាល់តែចប់។

# មេរៀនទី ១៩ ជំនាញក្នុងការស្វែងរកការងារ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ស្គាល់អំពីជំនាញស្វែងរកការងារដោយខ្លួនឯង។

## សកម្មភាពសិស្សទី១ (រយៈពេល ១៥ នាទី)

ឱ្យសិស្សបំពេញតារាងខាងក្រោម អំពីជំនាញស្វែងរកការងាររបស់ពួកគេ និងត្រៀមរួចរាល់សម្រាប់ការស្វែងរកការងារ។

## សន្លឹកកិច្ចការ

សូមធ្វើការវាយតម្លៃជំនាញស្វែងរកការងាររបស់អ្នក! អានល្បះខាងក្រោម ហើយគូសសញ្ញាជ្រើសរើស ប្រសិនបើត្រូវនឹងអ្នក «មែន» ឬ «មិនមែន»។

| | មែន | មិនមែន |
|---|---|---|
| ខ្ញុំដឹងអ្វីជាផលិតភាពផ្ទាល់ខ្លួន (សមត្ថភាព) ដែលនិយោជកចង់បាន | | |
| ខ្ញុំដឹងអំពីលទ្ធភាពការងារដែលមានទាំងអស់ | | |
| ខ្ញុំដឹងពីប្រភេទការងារអ្វីដែលខ្ញុំកំពុងស្វែងរក | | |
| ខ្ញុំដឹងអំពីសមត្ថភាពរបស់ខ្ញុំ | | |
| ខ្ញុំដឹងអំពីរបៀបដាក់ពាក្យរកការងារ | | |
| ខ្ញុំបានសរសេរពាក្យការងារ និងជីវប្រវត្តិរួចរាល់ហើយ | | |
| ខ្ញុំបានចូលសម្ភាសការងារកាលពី ៣ ខែមុន | | |
| ខ្ញុំមានផែនការសម្រាប់ស្វែងរកការងារ | | |
| ខ្ញុំដឹងពីរបៀបពិព័ណ៌នាអំពីសមត្ថភាពរបស់ខ្ញុំនៅក្នុងពាក្យការងារ និងពេលសម្ភាស | | |
| ខ្ញុំដឹងពីបញ្ហាប្រឈមដែលខ្ញុំមាន ក្នុងការស្វែងរកការងារ | | |
| ពិន្ទុ (មានចម្លើយ «មែន» និង «មិនមែន» ប៉ុន្មានដែលអ្នកទទួលបាន? ) | | |

## សកម្មភាពសិស្សទី២ (រយៈពេល ១០ នាទី)

សួរសិស្សថា តើពួកគេយល់ឃើញបែបណាអំពីលទ្ធផលខាងលើនេះ? តើអ្នកមានចំណុចខ្វះខាតលើជំនាញអ្វីខ្លះពាក់ព័ន្ធនឹងការស្វែងការងារក្នុងមូលដ្ឋាន? ឱ្យសិស្សធ្វើការវាយតម្លៃពីលទ្ធផលរបស់ពួកគេក្នុងតារាងខាងលើ។

## សកម្មភាពសិស្សទី៣ (រយៈពេល ១០ នាទី)

ពិព័ណ៌នាអំពីខ្លួនឯង! សិស្សបានដាក់បញ្ចូលរួចហើយនូវចំណុចខ្លាំង និងជំនាញរបស់ពួកគេ។ សម្រាប់ការស្វែងរកការងារ ពួកគេត្រូវការពិពណ៌នាអំពីខ្លួនឯងនៅក្នុងពាក្យស្វែងរកការងារ និងពេលសម្ភាស។ ឱ្យសិស្សមើលតារាងខាងក្រោម និងជ្រើសរើសនូវពាក្យ ឬកន្សោមពាក្យទាំងអស់ដែលត្រូវនឹងពួកគេ។

| | | |
|---|---|---|
| ការស្រមើស្រមៃដ៏សម្បូរបែប<br>អ្នកសម្រេចជោគជ័យ | ប្រសិទ្ធភាព<br>ស្វាហាប់ | អ្នកសម្ដែង<br>ផ្ទាល់ខ្លួន |

| | | |
|---|---|---|
| សកម្ម | មានគំនិតច្រើន/សហគ្រាស | បញ្ចុះបញ្ចូល |
| សម្របបាន | ដាក់លាក់ | រីករាយ |
| មហិច្ឆតា | រំភើប | សុភាពរាបសារ |
| វែកញែក | បត់បែន | ដែលអាចនឹងធ្វើទៅបាន |
| ត្រចះត្រចង់ | រួសរាយ | ច្បាស់លាស់ |
| មានសមត្ថភាព | មានប្រយោជន៍ | មោទនភាព |
| ដោយយកចិត្តទុកដាក់ | ស្មោះត្រង់ | ស្ងប់ស្ងាត់ |
| អ្នកពុះពារ | ដែលកំប្លុកកំប្លែង | ប្រាកដនិយម |
| មានមន្តស្នេហ៍ | ដែលជំរុញចិត្ត | មានហេតុផល |
| ក្លៀវក្លា | សភាវគតិ | សម្រួលអារម្មណ៍ |
| ច្បាស់លាស់ | ឈ្លាសវៃ | គួរឱ្យជឿជាក់បាន |
| មនសិកា | ច្នៃប្រឌិត | សំណើសុំ |
| ត្រួតត្រា | មានចំណេះដឹង | ឆ្លើយតប |
| ការបង្កើតថ្មី | អ្នកមានភាពទទួលខុសត្រូវ | សុវត្ថិភាព |
| ការផ្តល់សិទ្ធិ | សមហេតុសមផល | ដែលជឿជាក់លើសមត្ថភាព |
| ថ្លៃថ្នូរ | ភក្តីភាព | ខ្លួនឯង |
| វីរៈភាព | អ្នកសុទិដ្ឋិនិយម | មនោសញ្ចេតនា |
| ការទូត | អ្នករៀបចំ | ធ្ងន់ធ្ងរ |
| មានការវិនិច្ឆ័យល្អ | សណ្តានដើម | ដោយស្មោះ |
| មិនសម្ងៃង | ស្វែងរកសុក្រឹតភាព | រួសរាយ |
| អធិបតេយ្យភាព | ដែលជាប្រព័ន្ធ | ដោយផ្ទាល់មាត់ |
| ស្ថិរភាព | ដែលប៉ិនប្រសប់ | រួសរវើក |
| ខ្លាំងក្លា | ទ្រឹស្តីនិយម | យុវភាព |
| ដែលចិត្តដាច់ | ហ្មត់ចត់ | |
| អ្នកស្នងតំណែង | ដែលចេះគិតដល់អ្នកដទៃ | |

## សកម្មភាពសិស្សទី៨ (រយៈពេល ១០ នាទី)

សួរសិស្សបន្ថែមប្រសិនបើមានពាក្យ ឬកន្សោមពាក្យដែលមិនទាន់មានដាក់នៅក្នុងតារាងខាងលើនេះ រួចបំពេញបន្ថែម។ ឱ្យសិស្សជ្រើសរើសពាក្យ ឬកន្សោមពាក្យណាដែលត្រូវនឹងបុគ្គលិកលក្ខណៈរបស់គេ។ អ្នកអាចប្រើប្រាស់ពេលក្នុងការបង្កើតពាក្យ ឬកន្សោមពាក្យណាដែលថ្មី វិជ្ជមាន និងទាក់ទាញចំណាប់អារម្មណ៍។ សិស្សអាចសរសេរពាក្យ ឬកន្សោមពាក្យទាំងអស់នេះ ដែលពិពណ៌នាអំពីពួកគេផ្ទាល់ចូលក្នុងសៀវភៅ។



## មេរៀនទី ២០ ការវាយតម្លៃខ្លួនឯង

វត្ថុបំណងរបស់មេរៀននេះគឺ៖

- សិស្សនឹងរៀនវាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងរបស់ពួកគេក្នុងការបំពេញការងារ

### សកម្មភាពសិស្សទី១

ឱ្យសិស្សធ្វើលំហាត់ស្តីពីការវិភាគ (SWOT) នៅក្នុងក្រុមរបស់គេ៖

- ដាក់ពាក្យថា «SWOT» នៅគ្រប់ជ្រុងនៃថ្នាក់រៀន។ បន្ថែមក្រដាសនៃសមាសភាគ SWOT មួយនៅក្នុងជ្រុងនីមួយៗ។ (ណែនាំឱ្យសិស្សធ្វើកិច្ចការនេះមុននឹងចាប់ផ្តើមមេរៀន)
- ពន្យល់ពីចំណុចខ្លាំង (វិជ្ជមាន) និងចំណុចខ្សោយ (អវិជ្ជមាន) គឺជាអ្វីដែលអ្នកមាន
- ការគំរាមកំហែង និងឱកាស៖ ទាក់ទងនឹងឱកាស អ្នកត្រូវមើលនូវអ្វីដែលអ្នកអាចធ្វើបានតាមសមត្ថភាពរបស់ខ្លួន ដើម្បីធ្វើឱ្យស្ថានភាពអ្នកប្រសើរឡើង។
- ដោយដើរមើលតាមជ្រុងនីមួយៗនៃថ្នាក់រៀន អ្នកអាចចាប់ផ្តើមបង្ហាញឧទាហរណ៍ផ្ទាល់ខ្លួនពីការវិភាគ SWOT របស់អ្នក (មិនចាំបាច់លម្អិតពេកទេ)។ ឧទាហរណ៍ងាយៗអាចសម្រាប់អ្នកក្នុងការវិភាគនេះមានដូចជា «ខ្ញុំមានជំនាញទំនាក់ទំនងល្អ ដែលអាចជួយឱ្យខ្ញុំ ងាយស្រួលក្នុងការធ្វើការជាមួយមនុស្សទូទៅ»។ ការធ្វើដូចនេះ គឺជាការលើកទឹកចិត្តសិស្សឱ្យមានលទ្ធភាពអាចសរសេរចំណុចខ្លាំង និងបញ្ហាប្រឈមរបស់គេចូល។ អ្នកត្រូវសង្កត់ធ្ងន់ថា ការស្គាល់ខ្លួនឯងគឺជាគន្លឹះក្នុងការដណ្តើមភាពជោគជ័យ។
- ចែកសិស្សជាក្រុម (មានគ្នាពី ៤-៥ នាក់) អាស្រ័យលើចំនួនសិស្សជាក់ស្តែង។
- ក្រុមនីមួយៗមានអ្នកកត់ត្រាម្នាក់ មានហ្វឺតមួយដើម និងក្រដាសផ្ទាំងមួយ។ ក្រុមត្រូវដើរមើលជ្រុងបន្ទប់រៀននីមួយៗ ហើយសមាជិកម្នាក់ៗត្រូវនិយាយពី «SWOT» របស់គេ។ អ្នកកត់ត្រា ត្រូវសរសេរនូវ SWOT ដែលបានលើកឡើង (មិនបាច់កត់ឈ្មោះទេ) និងបិទក្រដាសពណ៌ស្អិតនៅលើជញ្ជាំង។ ក្រុមនីមួយៗមានពេល ១០-១៥ នាទី។

សរសេរដាក់តាមជ្រុងម្ខាងៗនៃបន្ទប់នូវពាក្យមួយដែលជាផ្នែកមួយនៃ SWOT។






## សកម្មភាពសិស្សទី២

លំហាត់នៅផ្ទះ! ឱ្យសិស្សគ្រប់រូបបំពេញនៅក្នុងតារាងវាយតម្លៃជាលក្ខណៈបុគ្គលរបស់ពួកគេចូលទៅក្នុងសៀវភៅ ឬកំណត់ហេតុសិក្សារបស់គេ។

| **ចំណុចខ្លាំងរបស់ខ្ញុំ** | **បញ្ហាប្រឈមរបស់ខ្ញុំ** |
|---|---|
| **ឱកាសរបស់ខ្ញុំ** | **បញ្ហាប្រឈមរបស់ខ្ញុំ<br>(ឧបសគ្គ ឬការគំរាមកំហែង)** |

# មេរៀនទី ២១ ការស្វែងរកការងារ និងបង្កើតបណ្តាញ

វត្ថុបំណងនៃប្រធានបទនេះគឺៈ

- ចង្អុលបង្ហាញអំពីចំណុចសំខាន់នៃការស្វែងរកការងារ និងការបង្កើតបណ្តាញដល់សិស្ស។

## សកម្មភាពសិស្សទី១

ឱ្យសិស្សធ្វើការជាដៃគូ ឬជាក្រុមតូច។ ចែកសន្លឹកកិច្ចការឱ្យសិស្សគ្រប់គ្នា ឬឱ្យសិស្សចម្លងខ្លឹមសារចូលក្នុងសៀវភៅរបស់ពួកគេ។ ពេលនេះ ឱ្យពួកគេបំផុសគំនិតជាមួយគ្នាទៅលើផែនការមួយសម្រាប់ពួកគេទាំងពីរ ឬសរសេរក្នុងកូឡោនទី១ៈ

តើគេអាចដាក់ពាក្យស្វែងរកការងារធ្វើនៅកន្លែងណា? តាមរយៈសំណួរនេះ បំផុតឱ្យពួកគេចាប់ផ្តើមនឹកគិតពីការរកបណ្តាញ និងការភ្ជាប់ទំនាក់ទំនងកាន់តែធំទូលាយ កាន់តែល្អ ទៅកាន់អ្នកដែលគេស្គាល់ហើយគិតថាអាចពឹងពាក់លើការងារនេះបាន។

## សកម្មភាពសិស្សទី២

ឱ្យសិស្សបំពេញសន្លឹកកិច្ចការនៅផ្ទះ ហើយត្រូវធ្វើដូចពួកជាគេកំពុងស្វែងរកការងារ។

## សន្លឹកកិច្ចការ

ផែនការ ឬកំណត់ហេតុស្វែងរកការងារ។ សូមបំពេញផែនការរបស់អ្នក និងលេខទំនាក់ទំនងដែលអ្នកបានធ្វើ ឬមានផែនការក្នុងការៈ

| ឈ្មោះកន្លែង ស្ថាប័ន និង អាសយដ្ឋាន | ភារកិច្ចដែលដាក់ពាក្យស្នើសុំបម្រើការងារ | បានជួប ឬផ្ញើពាក្យរួច (ថ្ងៃខែ) | អ្នកទំនាក់ទំនង លេខទូរស័ព្ទ ឬអាសយដ្ឋាន | ថ្ងៃខែសម្ភាស ម៉ោងនិងទីកន្លែង | លទ្ធផល |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |



## មេរៀនទី ២២ ពាក្យស្នើសុំចូលបម្រើការងារ

វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យសិស្សយល់ដឹង និងស្គាល់គំរូពាក្យស្នើសុំចូលបម្រើការងារផ្លូវការ។

### សកម្មភាពសិស្ស

ណែនាំសិស្សអំពីគំរូពាក្យស្នើសុំចូលបម្រើការងារ។ ដូចនេះ ពួកគេនឹងយល់នូវអ្វីដែលជាមាតិកា និងគម្រោងរបស់ពាក្យស្នើសុំចូលបម្រើការងារ។

ឱ្យពួកគេប្រើប្រាស់គំរូខាងក្រោម សរសេរនូវពាក្យស្នើសុំចូលបម្រើការងារជាលក្ខណៈបុគ្គលចូលទៅក្នុងសៀវភៅរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក។ ដើម្បីសរសេរពាក្យនេះបាន ពួកគេត្រូវតែយល់ពីព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងដំណឹងជ្រើសរើសបុគ្គលិក និងសរសេរវាឱ្យមានភាពទាក់ទាញ។ ប្រើប្រាស់ទម្រង់ស្តង់ដាមូលដ្ឋានសម្រាប់សរសេរសំបុត្រផ្លូវការ។



**ពាក្យសុំចូលបម្រើការងារ**

នាមត្រកូល នាមខ្លួនៈ
អាសយដ្ឋានៈ
លេខទូរសព្ទៈ

កាលបរិច្ឆេទៈ ថ្ងៃទី ខែ ឆ្នាំ២០១៨

ឈ្មោះក្រុមហ៊ុនៈ
អាសយដ្ឋានៈ
លេខទូរសព្ទៈ

ព័ត៌មានយោង (ឧទាហរណ៍ ការផ្សាយពាណិជ្ជកម្មតាមកាសែត ឬអ៊ីនធឺណិត និងកាលបរិច្ឆេទផ្សព្វផ្សាយ)
**ចំណងជើង** (ឧទាហរណ៍ មុខតំណែងស្នើសុំ)

***ចូលតួសេចក្ដី!***
ព្យាយាមទាក់ទាញចំណាប់អារម្មណ៍របស់និយោជក។ ពិពណ៌នាសមត្ថភាពរបស់អ្នក ដែលអាចឆ្លើយតបនឹងតម្រូវការការងារ និងបង្ហាញកម្រិតអប់រំ/វគ្គបណ្ដុះបណ្ដាលដែលអ្នកឆ្លងកាត់ ដើម្បីឱ្យនិយោជកពិនិត្យ មើលថាអ្នកត្រូវនឹងតម្រូវការរបស់គេឬអត់។ ពិពណ៌នានៅទីនេះ ហេតុអ្វីបានជាអ្នកគឺជានិយោជិតដែលល្អបំផុតសម្រាប់ការងារនេះ។

***សមត្ថភាព!***
ពិពណ៌នាទីនេះនូវសមត្ថភាពជាក់លាក់របស់អ្នក សម្រាប់ការងារដែលអ្នកបានដាក់ពាក្យស្នើសុំ (ពី១-២ ចំណុច)។ ស្វែងរក លក្ខណៈវិនិច្ឆ័យនៅក្នុងការផ្សាយពាណិជ្ជកម្មអំពីការងារ និងពិពណ៌នាសមត្ថភាពរបស់អ្នកក្នុងអត្ថន័យដ៏ច្បាស់លាស់ហើយគ្រប់គ្រាន់។

***ជំនាញ និងបុគ្គលិកលក្ខណៈ!***
អ្នកអាចពិពណ៌នាជំនាញ ចំណុចខ្លាំង និងបុគ្គលិកលក្ខណៈរបស់អ្នកដែលជួយឱ្យទទួលបានជោគជ័យនៅក្នុងការងារ។ បន្ថែមលើនេះ អ្នកអាចពិពណ៌នាជំនាញភាសា និងចំណេះដឹងផ្នែក IT របស់អ្នក និងចំណុចខ្លាំងផ្សេងៗទៀត។

***សេចក្ដីបញ្ចប់!***
អ្នកអាចបញ្ជាក់បន្ថែមនូវចំណង់ចំណូលចិត្តរបស់អ្នកក្នុងការងារ និងការសម្ភាសផ្ទាល់។

ហត្ថលេខា

ឈ្មោះសរសេរជាអក្សរធំ

ភ្ជាប់មកជាមួយ CV

# មេរៀនទី ២៣ ការរៀបចំឯកសារប្រវត្តិរូបសង្ខេប

វត្ថុបំណងនៃមេរៀននេះគឺៈ

- ជួយឱ្យសិស្សយល់ដឹង និងស្គាល់គំរូប្រវត្តិរូបសង្ខេបស្នើសុំចូលបម្រើការងារផ្លូវការ

## សកម្មភាពសិស្ស

អ្នកត្រូវណែនាំសិស្សអំពីគំរូប្រវត្តិរូបសង្ខេបស្នើសុំចូលបម្រើការងារ ឱ្យពួកគេយល់នូវខ្លឹមសារ និងមាតិកាដែលត្រូវសរសេរ។ ប្រវត្តិរូបសង្ខេបនេះ ជាឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យស្នើសុំចូលបម្រើការងារ (មេរៀនខាងលើ)។ ដោយប្រើប្រាស់គំរូខាងក្រោម សិស្សត្រូវរៀនសរសេរប្រវត្តិរូបសង្ខេបរបស់ខ្លួន ក្នុងបំណងស្នើសុំចូលបម្រើការងារនៅក្នុងស្ថាប័នណាមួយដែលគេពេញចិត្ត។ ការសរសេរនេះ ត្រូវប្រើប្រាស់ទម្រង់ស្តង់ដាជាមូលដ្ឋានមួយច្បាស់លាស់។



# ប្រវត្តិរូបសង្ខេប

| បិទរូបថត |
|---|

**ព័ត៌មានផ្ទាល់ខ្លួន**

| | |
|---|---|
| ឈ្មោះ | |
| ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត | |
| ជនជាតិ | |
| ស្ថានភាពគ្រួសារ | |
| លេខទូរសព្ទ | |

**ព័ត៌មានវិជ្ជាជីវៈ**

| |
|---|
| សរសេរការពិពណ៌នាខ្លីមួយអំពី ទេព្យកោសល្យ និងចំណុចខ្លាំងរបស់អ្នក។ |

**ប្រវត្តិការអប់រំ**

| ឆ្នាំ | ស្ថាប័ន | សញ្ញាបត្រ |
|---|---|---|
| | | |
| | | |
| | | |

**បទពិសោធន៍ការងារ**

| ឆ្នាំ | និយោជក | តួនាទី |
|---|---|---|
| | | |
| | | |
| | | |

**ជំនាញផ្សេងទៀត** (ចំណាប់ចំណូលចិត្ត ការងារស្ម័គ្រចិត្ត ជំនាញ IT)

| | |
|---|---|
| **ជំនាញភាសា** | |
| **ជំនាញIT** | |
| **ការងារស្ម័គ្រចិត្ត** | |

**អ្នកផ្តល់ព័ត៌មានធានា**

| |
|---|
| ១. (ឈ្មោះ តួនាទី និងព័ត៌មានទំនាក់ទំនង) |
| ២. |
| ៣. |

## មេរៀនទី ២៤ ការហៅទូរសព្ទទៅនិយោជក និងការសម្ភាសការងារ

វត្ថុបំណងនៃមេរៀនេះគឺៈ

- សិស្សនឹងយល់ដឹងពីវិធីសាស្ត្រហៅទូរសព្ទ និងការសម្ភាសការងារជាមួយនិយោជក។

### សកម្មភាពសិស្សទី១ៈ ការហៅទូរសព្ទ

ផ្តល់នូវការណែនាំទៅលើប្រធានបទ ជាមួយនឹងដំបូន្មានខាងក្រោម។ សិស្សអាចនឹងត្រូវហៅទូរសព្ទ ជាច្រើនដងនៅពេលស្វែងរកការងារធ្វើ ឬដើម្បីបង្កើតឱ្យមានការណាត់ជួប។ បន្ទាប់ពីដាក់ពាក្យរួចហើយ ពួកគេគួរតែហៅទូរសព្ទទៅកាន់និយោជកក្នុងហេតុផលបីយ៉ាងដើម្បីធានាថាៈ

- និយោជកទទួលបានពាក្យស្នើសុំចូលបម្រើការងាររបស់អ្នក
- អ្នកមានចំណាប់អារម្មណ៍ខ្លាំងចំពោះការងារនេះ
- អ្នកទទួលបានការអញ្ជើញទៅវគ្គសម្ភាសការងារ

អ្នកគួរតែមានក្រដាស និងប៊ិកសម្រាប់កត់ត្រា ពាក្យការងារ និង CV នៅពេលដែលទូរសព្ទទៅគេ ដូចនេះអ្នកអាចធ្វើការផ្ទៀងផ្ទាត់រួចជាស្រេចនូវព័ត៌មានដែលអ្នកបានផ្ញើចេញ។

១. ធ្វើការហៅទូរសព្ទ នៅពេលដែលអ្នកគិតថាជាពេលវេលាល្អបំផុតសម្រាប់អ្នកទទួល។

២. ត្រូវធានាថា អ្នកនិយាយទៅកាន់មនុស្សដែលត្រឹមត្រូវ ហើយត្រូវរៀបចំសម្រាប់រងចាំ ឬ/និងពន្យល់រឿងរ៉ាវរបស់អ្នកទៅកាន់ពួកគេ។

៣. នៅពេលដែលអ្នកនិយាយទៅកាន់អ្នកដែលទទួលខុសត្រូវក្នុងការទទួលពាក្យការងារៈ

ក. ជំរាបសួរគាត់ដោយសុភាពរាបសារ

ខ. សួរទៅកាន់គាត់ថាបានទទួលពាក្យការងាររបស់អ្នកដែរឬទេ

គ. លើកឡើងពីសមត្ថភាពមួយ ឬពីររបស់អ្នក

ឃ. ត្រូវរៀមឱ្យរួចរាល់ក្នុងការសួរអំពីពាក្យការងារ ឬ CV ដែលអ្នកបានផ្ញើ

ង. សួរថាតើអ្នកទៅធ្វើបទសម្ភាសបានដែរឬទេ (សុំដោយទន់ភ្លន់)

ច. ប្រសិនបើអ្នកទទួលបានលិខិតអញ្ជើញទៅសម្ភាស សរសេរថ្ងៃខែ ម៉ោង អាសយដ្ឋាន និងឈ្មោះរបស់អ្នកដែលអ្នកត្រូវជួប។

ឆ. ពេលរៀបដាក់ទូរសព្ទចុះ ត្រូវអរគុណគេដោយសុភាពរាបសារ។

ឱ្យសិស្សធ្វើការជាគូ ហើយអនុវត្តការហៅទូរសព្ទសាកល្បង (ម្នាក់ជាអ្នកស្វែងរកការងារធ្វើ ម្នាក់ជាតំណាងនិយោជក)។ បន្ទាប់មកដូរតួនាទីគ្នា។ (១០នាទី)

### សកម្មភាពសិស្សទី២ៈ ការសម្ភាសការងារ

ឱ្យសិស្សត្រៀមខ្លួនដើម្បីភាពជោគជ័យក្នុងការសម្ភាសការងារ។ ប្រាប់ពួកគេ អំពីភាពសំខាន់ក្នុងការបង្ហាញជំនាញរបស់ខ្លួនដោយសង្ខេបខ្លី។ ណែនាំសិស្សរបស់អ្នកនូវប្រធានបទ និងចែករំលែកនូវគំនិតអំពីមាតិកា និងសំណួរដែលតែងតែសួរញឹកញាប់ក្នុងកិច្ចសម្ភាសការងារ។

ប្រើប្រាស់ការសម្តែងសាច់រឿង ក្នុងការឱ្យជាឧទាហរណ៍នៃការសម្ភាសការងារដ៏ល្អ និងមិនល្អ។ បន្ទាប់ពីការសម្តែងការសម្ភាស ពិភាក្សាជាមួយក្រុមរបស់អ្នក ថាតើមួយណាដែលល្អ ហើយហេតុអ្វី? ឱ្យអ្នកចូលរួមសាកល្បងសម្តែងទាំងការសម្ភាសល្អ និងមិនល្អជាគូ ហើយឱ្យពួកគេយល់ពី

ភាពខុសគ្នា។ ប្រើប្រាស់ការលេងសើចដែលបង្កបរិយាកាសរីករាយ! ជាជម្រើស ឱ្យសិស្សធ្វើការសម្ភាសការងារជាដៃគូ។

### សកម្មភាពសិស្សទី៣៖ លំហាត់នៅផ្ទះ

ឱ្យសិស្សបំពេញចម្លើយផ្ទាល់ខ្លួន ទៅនឹងសំណួរដែលត្រូវបានសួរជាញឹកញាប់នៅពេលសម្ភាសការងារ ដែលមានជាគំរូក្នុងសន្លឹកកិច្ចការ។

### សម្រាប់ការណែនាំ៖

## ការរៀបចំខ្លួនមុនពេលសម្ភាស

- ស្វែងរកព័ត៌មានអំពីនិយោជកទុកជាមុន។ តើពួកគេចាប់ផ្ដើមដំណើរការស្ថាប័នគេដោយរបៀបណា? ពួកគេធ្វើអ្វីខ្លះ? ហើយសម្រេចបានសមិទ្ធផលអ្វីខ្លះ?
- រំលឹកការចងចាំរបស់អ្នកអំពីការងារដែលអ្នកបានដាក់ពាក្យ និងអ្វីខ្លះដែលបានរៀបរាប់នៅក្នុងការផ្សាយព័ត៌មាន។
- រំលឹកខ្លួនអ្នកនូវជំនាញរបស់អ្នកដោយមើលប្រវត្តិរូបសង្ខេបឡើងវិញ។ ត្រូវត្រៀមសម្រាប់ពន្យល់អំពីគោលបំណង និងហេតុផលសម្រាប់ការផ្លាស់ប្ដូរការងារ ភាពខ្វះចន្លោះនៅក្នុងប្រវត្តិរូបសង្ខេប និងជម្រើសសម្រាប់ជីវិតរបស់អ្នក។
- គិតអំពីសំណួរដែលអ្នកអាចសួរទៅនិយោជកពាក់ព័ន្ធនឹងការងារ អំឡុងពេលសម្ភាស។
- ត្រូវត្រៀមចម្លើយសម្រាប់សំណួរដែលមិនបានត្រៀមទុកផងដែរ។ ការសម្ភាស អាចនឹងតម្រូវឱ្យលើកឧទាហរណ៍សាកល្បង តេស្តរកម្រិតភាសារបស់អ្នកដោយផ្លាស់ប្ដូរភាសាពេលសម្ភាស។
- នាំយកនូវលិខិតបញ្ជាក់ការងារចាស់ និងសញ្ញាបត្រមកជាមួយអ្នកប្រសិនបើមាន។
- ត្រៀមសម្រាប់ឆ្លើយតបថាហេតុអ្វីបានជាអ្នកសក្ដិសមសម្រាប់ការងារនេះ។
- ស្វែងយល់ពីចម្ងាយចរក្នុងការធ្វើដំណើរពីផ្ទះរបស់អ្នកទៅកាន់កន្លែងសម្ភាសការងារ។
- ជ្រើសរើសសំលៀកបំពាក់ឱ្យសក្ដិសមទៅនឹងការសម្ភាសការងារ។
- យកមកតាមខ្លួននូវឈ្មោះ និងលេខទូរសព្ទនិយោជកដែលអ្នកនឹងត្រូវទៅជួប។

## អំឡុងពេលសម្ភាស

គោលបំណងនៃបទសម្ភាស គឺដើម្បីស្វែងរកថាតើអ្នកសក្ដិសម និងមានការជំរុញទឹកចិត្តបែបណាសម្រាប់ការងារ។ អ្នកត្រូវមកដល់កន្លែងសម្ភាសឱ្យទាន់ពេល៖

- មកទាន់ពេលមានន័យថា មកដល់ ១៥ នាទីមុនម៉ោងសម្ភាស។
- ការសម្ភាសការងារនឹងធ្វើឱ្យអ្នកមានអារម្មណ៍រំភើប។ អ្នកត្រូវរកវិធីសម្រាកអារម្មណ៍មុននឹងសម្ភាស ដើម្បីឱ្យអារម្មណ៍ស្ងប់អាចឆ្លើយសំណួរពេលសម្ភាសបានល្អ។
- ការបង្ហាញចំណាប់អារម្មណ៍វិជ្ជមានរបស់អ្នក ពិតជាសំខាន់ខ្លាំងណាស់។ ចាប់ដៃ សម្លឹងមើលភ្នែកអ្នកសម្ភាស។
- រៀបចំឥរិយាបថអង្គុយឱ្យសុភាពរាបសារ បិទទូរសព្ទ ហាមទំពាស្ករកៅស៊ូ។
- ឆ្លើយសំណួរដោយសុភាព និងសង្ខេប។ យកចិត្តទុកដាក់លើកាយវិការ ទឹកមុខ និងរបៀបនិយាយរបស់អ្នក។

- ប្រសិនបើអ្នកត្រូវបានសម្ភាសដោយក្រុមគណៈកម្មការ អ្នកត្រូវបង្ហាញនូវការយកចិត្តទុកដាក់ក្នុងការឆ្លើយសំណួររបស់សមាជិកម្នាក់ៗឱ្យស្មើៗគ្នា។
- ត្រូវសកម្ម ហើយសួរសំណួរអំពីការងារ ឬក្រុមហ៊ុននោះ។ ចុងបញ្ចប់ត្រូវអរគុណនិយោជកសម្រាប់ឱកាសក្នុងការបង្ហាញខ្លួន ហើយត្រូវសួរថាពេលណាទើបដឹងលទ្ធផល និងដឹងដោយរបៀបណា។

### បន្ទាប់ពីការសម្ភាសរួច

- បើពេលវេលាអំណោយផល អ្នកគួរសួរពីចំណុចខ្វះខាត ហើយព្យាយាមអភិវឌ្ឍខ្លួនអ្នក។

### សន្លឹកកិច្ចការ ប្រភេទសំណួរ

សំណួរមួយចំនួនដែលនឹងកើតឡើងពេលសម្ភាស ត្រូវបានរៀបរាប់ខាងក្រោម។ អ្នកគួរតែហ្វឹកហ្វាត់ឆ្លើយទៅនឹងសំណួរទាំងនេះ។

| សំណួរៈ | ចម្លើយរបស់ខ្ញុំៈ(ប្រើប្រាស់ក្រដាសបន្ថែមបាន) |
|---|---|
| ១.រៀបរាប់ពីរបីពាក្យដែលពិព័ណ៌នាអំពីខ្លួនអ្នក។<br>២.ចូរពិព័ណ៌នាអំពីការងារបច្ចុប្បន្នឬការងារចុងក្រោយ។<br>៣.ហេតុអ្វីបានជាអ្នកដាក់ពាក្យធ្វើការងារនេះ?<br>៤.ហេតុអ្វីបានជាអ្នកចង់ផ្លាស់ប្ដូរការងារ?<br>៥.តើអ្វីទៅជាគោលដៅអនាគតរបស់អ្នក?<br>៦.តើអ្នកជាសហការី ឬជាអ្នកគ្រប់គ្រងប្រភេទណា?<br>៧.តើអ្វីសំខាន់បំផុតដែលអ្នកបានរៀនពីការងារពីមុនរបស់អ្នក?<br>៨.តើការងារក្នុងសុបិនអ្នកជាអ្វី?<br>៩.តើអ្នកមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ?<br>១០.តើចំណុខ្លាំងរបស់អ្នកអាចជួយឱ្យអ្នកជោគជ័យក្នុងការងារដោយរបៀបណា? តើអ្នកបានធ្វើអ្វី ឬមានបំណងចង់ធ្វើឱ្យប្រសើរឡើងនូវចំណុចខ្សោយរបស់អ្នកទេ?<br>១១.តើអ្វីជំរុញឱ្យអ្នកក្លាយជានិយោជិតម្នាក់?<br>១២.តើសហគមន៍ការងារបែបណាដែលអ្នកមានអារម្មណ៍ថាដូចជាផ្ទះរបស់អ្នក?<br>១៣.ក្នុងគំនិតរបស់អ្នក តើអ្វីទៅជាកន្លែងការងារល្អ?<br>១៤.តើអ្នកចង់ធ្វើការម្នាក់ឯង ឬក៏ការងារជាក្រុម?<br>១៥.ហេតុអ្វីបានជាអ្នកដាក់ពាក្យមកធ្វើការ ដែលមិនត្រូវនឹងបទពិសោធន៍ការងារ និងការអប់រំរបស់អ្នក?<br>១៦.តើអ្នកអាចធ្វើការក្រោមសម្ពាធបានល្អបែបណាទៅ? សូមឱ្យឧទាហរណ៍ជាក់ស្ដែង។<br>១៧.តើអ្នកបានត្រៀមសម្រាប់ការធ្វើដំណើរទៅធ្វើការហើយឬនៅ?<br>១៨.តើអ្នកបានត្រៀមសម្រាប់ម៉ោងធ្វើការដែលបត់បែន | |

| | |
|---|---|
| ហើយឬនៅ?<br>១៩.តើអ្នកបានរៀនអ្វីខ្លះពីការងារពីមុនរបស់អ្នក?<br>២០.តើភាពជោគជ័យអ្វីដែលអ្នកមានមោទនភាពបំផុត?<br>២១.ហេតុអ្វីបានជាយើងត្រូវជ្រើសរើសយកអ្នកក្នុង ចំណោមបេក្ខជនដទៃទៀត?<br>២២. តើអ្នកមានចង់ដឹងអ្វីអំពីពួកយើងទេ?<br>២៣. តើនរណាអាចធ្វើជាអ្នកផ្តល់ព័ត៌មានអំពីអ្នក?<br>២៤.ប្រសិនបើយើងហៅទូរសព្ទទៅអ្នកផ្តល់ព័ត៌មានអំពីអ្នក តើពួកគេនឹងប្រាប់យើងអ្វីខ្លះអំពីអ្នក? | |



# មេរៀនទី ២៥ សហគ្រិនភាព

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយឱ្យសិស្សចាប់ផ្ដើមគិតពីសហគ្រិនភាព ដោយប្រើបច្ចេកវិទ្យាព័ត៌មានវិទ្យា។

## សកម្មភាពសិស្សទី១

អ្នកអាចបញ្ចូលប្រធានបទដោយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា។ ឱ្យសិស្សប្រើប្រាស់ប្រភពអ៊ិនធឺណិតតាមរយៈតំណ https://www.psychometrictest.org.uk/entrepreneur-test/ រួចហើយធ្វើតេស្តអំពី ការត្រៀមខ្លួនជាស្រេចក្នុងសហគ្រិនភាព។ នេះគឺជាគំរូគេហទំព័រដែលពន្យល់ទៅលើតេស្ត និងលទ្ធផលដែលសិស្សត្រូវទទួលបាន។ ឱ្យសិស្សកត់ត្រាពិន្ទុរបស់ពួកគេចូលក្នុងសៀវភៅ ឬកំណត់ហេតុសិក្សា។

«សហគ្រិនដែលជោគជ័យ គឺទទួលបានពិន្ទុខ្ពស់ក្នុងចំណុចជាច្រើន ឬក៏គ្រប់ចំណុចសម្រាប់វាស់វែងទាំងនេះ។ សហគ្រិនដែលមិនជោគជ័យ ឬអ្នកដែលមិនសក្ដិសមនឹងសហគ្រិនភាព អាចនឹងបានពិន្ទុទាបទៅលើចំណុចសម្រាប់វាស់វែងទាំងនេះ។»

### *ខិតខំដើម្បីទទួលបានសមិទ្ធផល*

ខិតខំដើម្បីទទួលបានសមិទ្ធផល គឺជាការជំរុញទឹកចិត្តខាងក្នុងរបស់មនុស្សក្នុងការទទួលបានលទ្ធផលលេចធ្លោ ហើយមានទំនោរធ្វើការប្រឹងប្រែងខ្លាំងដើម្បីសម្រេចគោលដៅ។ ពិន្ទុ ៣៦ បង្ហាញនូវកម្រិតខ្ពស់គួរសមសម្រាប់ការជំរុញទឹកចិត្តខាងក្នុងដើម្បីបានជោគជ័យ។ អ្នកអាចនឹងផ្ដោតលើគោលដៅ ហើយសម្រេចលទ្ធផលលេចធ្លោជាងអ្នកដទៃ។ អ្នកនឹងអាចដាក់ការងាររបស់អ្នកក្នុងអាទិភាពខ្ពស់ជាងអាទិភាពផ្ទាល់ខ្លួន ប៉ុន្តែអ្នកក៏ត្រូវគិតពីការរក្សាតុល្យភាពរវាងការងារ និងជីវិតផងដែរ។ អ្នកទំនងជាមនុស្សដែលសុខចិត្តធ្វើដំណើររាប់គីឡូម៉ែត ឬដាក់ការប្រឹងប្រែងបន្ថែមដើម្បីទទួលបានលទ្ធផលខ្ពស់។ ថ្វីដ្បិតតែ អ្នកជាមនុស្សដែលជំរុញទៅរកការជោគជ័យក៏ដោយ ពេលខ្លះអ្នកអាចមានអារម្មណ៍ថានឹងប្រឹងប្រែងកាន់តែខ្លាំងដើម្បីសម្រេចបានលទ្ធផលធំជាងមុនទៅទៀត។

### *ភាពឧស្សាហ៍*

ភាពឧស្សាហ៍ គឺជាកម្រិតតស៊ូ អត់ធន់និងស្រ្ដេស និងវិន័យផ្ទាល់ខ្លួនរបស់មនុស្ស។ ពិន្ទុ ៣៦ បង្ហាញនូវកម្រិតខ្ពស់គួរសម សម្រាប់ភាពឧស្សាហ៍។ អ្នកអាចធ្វើការបានយ៉ាងល្អនៅក្នុងពេលមានស្រ្ដេស ឬស្ថានភាពប្រឈមខ្លាំង ប៉ុន្តែពេលខ្លះក៏ត្រូវការដកថយមួយរយៈដើម្បីប្រតិបត្តិការបានល្អដែរ។ អ្នកអាចនឹងមានគុណសម្បត្តិនៅក្នុងបរិយាកាសការងារដែលមានសម្ពាធខ្លាំងបើប្រៀបធៀបនឹងអ្នកដទៃជាច្រើនទៀត។ អ្នកអាចនឹងធ្វើការលើសម៉ោង ឬជាទូទៅទទួលយកការទទួលខុសត្រូវបន្ថែម។ អ្នកមិនងាយបង្អែរបង្អង់ការងារ ឬបែកអារម្មណ៍ធ្វើការជាងមនុស្សភាគច្រើន។

### *សេចក្ដីស្រឡាញ់*

សេចក្ដីស្រឡាញ់សំដៅលើការធ្វើសេចក្ដីសម្រេចចិត្តដោយផ្អែកលើភាពរំជួលចិត្ត ភាពស្មុះស្មារ ភាពរំជួលអារម្មណ៍របស់បុគ្គលម្នាក់។ ពិន្ទុ ៣៩ បង្ហាញនូវកម្រិតខ្ពស់គួរសម សម្រាប់សេចក្ដីស្រឡាញ់។ អ្នកប្រើប្រាស់កត្តាស្មារតី ជាកត្តាជំរុញការអនុវត្តច្រើនជាងមនុស្សភាគច្រើន។ អ្នកបង្ហាញការស្មុះស្មារក្នុងការងាររបស់អ្នកជាងអ្នកដទៃ។ នៅពេលដែលធ្វើការសម្រេចចិត្ត អ្នកទំនងជាប្រើប្រាស់អព្ភន្តរញាណ និងភាពឈ្លាសវៃខាងស្មារតីក្នុងការសម្រេចចិត្តចុងក្រោយ។ ការបំផុស

ទឹកចិត្ត ការជំរុញទឹកចិត្ត និងភាពឈ្លាសវៃខាងស្មារតីគឺត្រូវបានមើលឃើញថាជាកត្តាសំខាន់នៅក្នុងការសម្របសម្រួលការអនុវត្តការងាររបស់អ្នក និងសម្រាប់ជំរុញអ្នកដទៃផងដែរ។

### *ការត្រួតត្រា*

ការត្រួតត្រា គឺទាក់ទងនឹងទ្រឹស្តីបុគ្គលិកលក្ខណៈបែបផ្លូវចិត្ត «ទីតាំងនៃការត្រួតត្រា» ជាអ្វីដែលមនុស្សម្នាក់ជឿជាក់ថាគេអាចគ្រប់គ្រងស្ថានការណ៍ដែលប៉ះពាល់ទៅដល់គេ។ ពិន្ទុ ៣៨ បង្ហាញនូវកម្រិតខ្ពស់គួរសម ដែលអាចគ្រប់គ្រងត្រួតត្រាបាន។ អ្នកមានភាពជឿជាក់នៅពេលដែលត្រូវគ្រប់គ្រងស្ថានការណ៍។ នៅពេលលទ្ធផលវិជ្ជមានកើតឡើង អ្នកតែងសរសើរខ្លួនឯង ប៉ុន្តែនៅពេលលទ្ធផលអវិជ្ជមានកើតឡើង អ្នកភាគច្រើនបន្ទោសកត្តាខាងក្រៅ ឧ. សំណាង ឱកាស...។

### *ការច្នៃប្រឌិត*

ភាពច្នៃប្រឌិត គឺជាការប្រើប្រាស់ភាពស្រមើស្រមៃក្នុងការបង្កើត និងអនុវត្តគំនិតដើម និងគំនិតផ្តួចផ្តើម។ ពិន្ទុ ៣២ បង្ហាញនូវកម្រិតខ្ពស់គួរសម នៃភាពច្នៃប្រឌិត។ អ្នកបង្ហាញនូវចំណាប់ចំណូលចិត្តសម្រាប់ការបង្កើតគំនិតថ្មី និងដោះស្រាយបញ្ហាដែលស្មុគស្មាញ។ នៅពេលដែលលើកឡើងពីបញ្ហា អ្នកតែងតែផ្តោតស៊ីជម្រៅទៅដល់ឫសគល់នៃបញ្ហា ជាជាងមើលស្រាលៗជុំវិញបញ្ហា។ អ្នកភាគច្រើនប្រើប្រាស់ការគិតដែលជាក់លាក់ និងបន្ត ជាជាងការគិតបែបចាស់គំរិល និងបុរាណនៅពេលដែលធ្វើការសម្រេចចិត្ត។

ប្រភព៖ https://www.psychometrictest.org.uk/entrepreneur-test/

https://www.bdc.ca/en/articles-tools/entrepreneur-toolkit/business-assessments/pages/self-assessment-test-your-entrepreneurial-potential.aspx? page=1

### សកម្មភាពសិស្សទី២

បង្កើតការពិភាក្សានៅក្នុងក្រុម៖ ប្រសិនបើអ្នកចង់ក្លាយជាសហគ្រិន តើតេស្តខាងលើនេះបានពន្យល់អ្នកច្បាស់លាស់ឬទេ? តើចំណុចទាំងអស់នេះ មួយណាសំខាន់ជាងគេ? តើអ្នកចង់បន្ថែមចំណុចសំខាន់អ្វីទៀតឬទេ?



# មេរៀនទី ២៦ ការរៀបចំផែនការ

យើងបានឈានមកដល់ ការងារគម្រោងចុងក្រោយក្នុងថ្នាក់ទី ១២ នៃមធ្យមសិក្សាទុតិយភូមិ។ ការងារគម្រោងនេះនឹងមាននៅក្នុងមេរៀនចំនួន ៥ ខាងមុខទៀត។ វត្ថុបំណងនៃមេរៀនទាំងនេះគឺៈ

- ប្រមូលព័ត៌មានដែលគ្របដណ្តប់លើទិដ្ឋភាពផ្សេងៗពាក់ព័ន្ធនឹងទីផ្សារការងារ

## សម្រាប់អ្នកប្រឹក្សាយោបល់ៈ

អ្នកត្រូវរៀបចំមេរៀននេះ ដោយការស្រាវជ្រាវទិដ្ឋភាពផ្សេងៗពាក់ព័ន្ធក្រមសីលធម៌ និងបទប្បញ្ញត្តិពាក់ព័ន្ធការងារៈ



- កិច្ចសន្យាការងារ
- ប្រាក់ខែ និងម៉ោងការងារ ពេលឈប់សម្រាក
- សិទ្ធិ និងភារកិច្ចរបស់កម្មករនិយោជិត
- សិទ្ធិ និងភារកិច្ចរបស់និយោជក
- សុវត្ថិភាព និងការថែទាំសុខភាពវិជ្ជាជីវៈ
- សហជីព
- កិច្ចសន្យាការងារ វិញ្ញាបនបត្រការងារ
- សមភាពក្នុងជីវិតការងារ
- ធានារ៉ាប់រងសុខភាព
- ច្បាប់ដែលអនុវត្តចំពោះសហគ្រិន
- ។ល។

អ្នកត្រូវផ្តល់យោបល់ ដល់សិស្សនូវប្រភពព័ត៌មានណាខ្លះដែលចាំបាច់សម្រាប់ការស្រាវជ្រាវរបស់ពួកគេ។ សិស្សអាចនឹងស្រាវជ្រាវព័ត៌មានចេញពីអ៊ិនធឺណិត ឬប្រភពផ្សេងទៀត។ បន្ទាប់មករៀបចំទុកជាមុនថា តើត្រូវរៀបចំបែងចែកក្រុមសិស្សបែបណា។ ដោយសារតែអ្នកស្គាល់សិស្សរបស់អ្នកស្រាប់ អ្នកគួរតែបង្កើតក្រុមដែលមានការយល់ដឹងប្រហាក់ប្រហែលគ្នា ហើយសិស្សណាខ្លះដែលត្រូវការជំនួយបន្ថែមពីអ្នក និងត្រូវផ្តល់ប្រធានបទដល់ពួកគេចាប់ផ្តើមការងារ។ រៀបចំសិស្សជា ៦ ក្រុម និងបែងចែកប្រធានបទទៅឱ្យពួកគេ (ក្រុមនីមួយៗនឹងមាន ២-៣ ប្រធានបទ)។ ដោយសារតែនេះមិនមែនជាភារកិច្ចដែលងាយស្រួល ដូចនេះត្រូវរៀបចំផែនការរបស់អ្នកដោយប្រុងប្រយ័ត្នទុកជាមុន ដើម្បីឱ្យពួកគេមានការទទួលខុសត្រូវល្អ និងទទួលបានជោគជ័យ!

## សកម្មភាពសិស្ស

ណែនាំសិស្សអំពីប្រធានបទ និងវត្ថុបំណងនៃការងារគម្រោង។ បែងចែកពួកគេជាក្រុមដូចដែលអ្នកបានរៀបចំទុកជាមុន និងចែកប្រធានបទទៅកាន់ក្រុមនីមួយៗ។ ពេលនេះពួកគេអាចរៀបចំផែនការក្នុងការចាប់ផ្តើមដំណើរការ និងត្រូវស្វែងរកព័ត៌មានពីកន្លែងណា។ ពួកគេបង្កើតតារាងកាលវិភាគ (ជាផ្នែកមួយនៃលំហាត់នៅផ្ទះ) និងប្រហែលជាចែកភារកិច្ចគ្នានៅក្នុងក្រុម។ នៅចុងបញ្ចប់នៃមេរៀន ពួកគេដឹងថាគេនឹងត្រូវធ្វើអ្វី ហើយនៅពេលណា(មុនពេលមេរៀនបន្ទាប់)។

# មេរៀនទី ២៧ ការពន្យល់បកស្រាយ

## សកម្មភាពសិស្សទី១

មេរៀននេះគឺសម្រាប់ឱ្យសិស្សអនុវត្តការងារគម្រោង។ បន្ទាប់ពីបានទទួលប្រធានបទស្រាវជ្រាវពីមេរៀនមុន សមាជិកក្រុមម្នាក់ៗនឹងតម្រូវឱ្យដាក់ព័ត៌មានដែលពួកគេប្រមូលបានយកមកបញ្ចូលគ្នា ដោយរៀបតាមមាតិកាជាលំដាប់លំដោយ។ ភារកិច្ចរបស់អ្នក គឺរង់ចាំផ្តល់ជំនួយតាមដែលសិស្សត្រូវការ ប៉ុន្តែអ្នកត្រូវប្រាកដថា ពួកគេគឺជាអ្នកទទួលខុសត្រូវផ្ទាល់លើការងារនេះ។

## សកម្មភាពសិស្សទី២

នៅចុងបញ្ចប់មេរៀន បន្ទាប់ពីសិស្សដាក់ព័ត៌មានរបស់ពួកគេបញ្ចូលគ្នារួចហើយ ឱ្យតំណាងក្រុមនីមួយៗឡើងធ្វើបទបង្ហាញបន្តិច អំពីរបៀបដែលពួកគេបានដំណើរការការងារជាក្រុមរបស់ខ្លួន ថាតើពួកគេប្រមូលព័ត៌មានដោយរបៀបណាកន្លងមក ហើយពួកគេបានជួបផលលំបាកអ្វីខ្លះ? (ក្រុមផ្សេងអាចឱ្យដំបូន្មានល្អៗ ក្នុងករណីមានផលលំបាកត្រង់ចំណុចណា)។



# មេរៀនទី ២៨  ការរៀបចំត្រៀមធ្វើបទបង្ហាញ

## សកម្មភាពសិស្ស

នៅក្នុងមេរៀននេះ ក្រុមនឹងរៀបចំសម្រាប់ធ្វើបទបង្ហាញ។ ពួកគេធ្វើការក្នុងក្រុមម្តងទៀត ដើម្បីរៀបចំបទបង្ហាញរបស់ពួកគេ។ ឱ្យពួកគេរៀបចំផ្ទាំងក្រដាសធំ ជាមួយនឹងមាតិកានៃមេរៀន ស្នូល គំរូកាសែត រូបថត រូបគំនូរ កាតប៉ុស្តាល់ជាដើម។ អ្នកអាចដើរមើលតាមក្រុម និងផ្តល់ជំនួយ ដល់សិស្សដែលជួបប្រទះផលវិបាក ឬពួកគេមិនអាចស្វែងរកព័ត៌មានអំពីអ្វីមួយបាន។ការងាររបស់ អ្នកគឺសម្របសម្រួលឱ្យមានបរិយាកាសស្ងប់ស្ងាត់ និងរីករាយ ដូចនេះពួកគេអាចធ្វើការដោយផ្តោតអារម្មណ៍ និងបានលឿន។

ផ្ទាំងក្រដាសគ្រាន់តែជាផ្នែកមួយនៃបទបង្ហាញ។ អ្នកអាចលើកទឹកចិត្តពួកគេឱ្យរៀបចំសម្តែងតួអំពីប្រធានបទរបស់ពួកគេ។ ពួកគេអាចប្រើតន្ត្រី ឬអ្វីដែលមានភាពច្នៃប្រឌិតដែលពួកគេចង់បង្រៀនអំពីប្រធានបទទៅកាន់ក្រុមដទៃទៀត។ ពួកគេគួរតែរៀបចំប្រធានបទតាមលំដាប់លំដោយ និងយកចិត្តទុកដាក់ ធ្វើយ៉ាងណាច្នៃឱ្យផ្ទាំងក្រដាសមានភាពទាក់ទាញ។ រយៈពេលសម្រាប់បទបង្ហាញនីមួយៗដែលពួកគេបានរៀបចំគឺ ២០ នាទី។

ឱ្យពីរក្រុមដំបូង ត្រៀមឱ្យបានរួចរាល់សម្រាប់ពេលបន្ទាប់។



# មេរៀនទី ២៩ ការធ្វើបទបង្ហាញ ១

## សកម្មភាពសិស្សទី១

ពេលនេះក្រុមទី ១ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមានដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។

## សកម្មភាពសិស្សទី២

ពេលនេះក្រុមទី ២ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមានដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។ ឱ្យសិស្សទុកដាក់ផ្ទាំងក្រដាសទាំងអស់ទុកប្រើនៅពេលក្រោយ។ ឱ្យសិស្សក្រុមទី ៣ និងទី ៤ត្រៀមសម្រាប់វគ្គបន្ទាប់។



# មេរៀនទី ៣០  ការធ្វើបទបង្ហាញ ២

## សកម្មភាពសិស្សទី១

ពេលនេះក្រុមទី ៣ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមានដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។

## សកម្មភាពសិស្សទី២

ពេលនេះក្រុមទី ៤ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមានដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។ ឱ្យសិស្សទុកដាក់ផ្ទាំងក្រដាសទាំងអស់ទុកប្រើនៅពេលក្រោយ។ ឱ្យសិស្សក្រុមទី ៥ និងទី ៦ ត្រៀមសម្រាប់វគ្គបន្ទាប់។



# មេរៀនទី ៣១ ការធ្វើបទបង្ហាញ ៣

## សកម្មភាពសិស្សទី១

ពេលនេះក្រុមទី ៥ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមាន ដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។

## សកម្មភាពសិស្សទី២

ពេលនេះក្រុមទី ៦ នឹងបង្ហាញអំពីគម្រោងរបស់ពួកគេ។ បទបង្ហាញ ២០ នាទី និងក្រុមពិភាក្សា ៥ នាទី (ក្រុមផ្សេងនឹងសួរសំណួរ ឬផ្តល់យោបល់ត្រលប់ និងកត់ត្រាចូលក្នុងសៀវភៅ/កំណត់ហេតុសិក្សារបស់គេ)។ អ្នកគួរតែយកចិត្តទុកដាក់ទៅលើកំហុសដែលអាចនឹងកើតមាន ដើម្បីកែសម្រួលវា។ ដូចនេះសិស្សនឹងមិនមានព័ត៌មានដែលយល់ច្រលំ។ អ្នកផ្សេងគួរតែកត់ត្រាចូលនូវអ្វីដែលបាននិយាយពីប្រធានបទនេះ។ ឱ្យសិស្សទុកដាក់ផ្ទាំងក្រដាសទាំងអស់ទុកប្រើនៅពេលក្រោយ។



# មេរៀនទី ៣២ ការសន្ទេបខ្លឹមសារ

## សកម្មភាពសិស្សទី១

បំផុសសិស្សឱ្យមានការពិភាក្សាក្នុងចំណោមក្រុមទាំងមូល៖

- តើពួកគេគិតថាការងារគម្រោងរបស់គេបានដំណើរការដោយរបៀបណា?
- តើអ្វីដែលពួកគេមានមោទនភាព?
- តើអ្វីដែលគេអាចធ្វើខុសពីលើកមុន?
- តើពួកគេជួបប្រទះផលវិបាកអ្វីខ្លះ?
- តើជំនួយអ្វីខ្លះដែលគេទទួលបាន?
- តើពួកគេបានរៀនអ្វីអំពីការធ្វើការងារគម្រោង និងការទទួលខុសត្រូវ?
- តើពួកគេវាយតម្លៃ ប៉ាន់ប្រមាណ ឬដាក់ពិន្ទុទៅលើការអនុវត្តរបស់ពួកគេក្នុងការងារគម្រោងដោយរបៀបណា?



## សកម្មភាពសិស្សទី២

ឱ្យពួកគេសរសេរចូលក្នុងសៀវភៅកំណត់ហេតុសិក្សារបស់ពួកគេ អំពីចំណាប់អារម្មណ៍សរុបលើការងារគម្រោង។

## សកម្មភាពសិស្សទី៣

ឱ្យសិស្សបិទផ្ទាំងព័ត៌មានគម្រោងលើជញ្ជាំងបន្ទប់អគារ ឬតាមផ្លូវដើរក្នុងសាលា ក្នុងលក្ខណៈជាការតាំងពិព័រណ៍។ ដូចនេះ សិស្សដទៃទៀតដែលនៅក្នុងសាលាក៏អាចមើលឃើញអំពីការងារដ៏ល្អដែលពួកគេបានធ្វើ។ ពួកគេ អាចឈរតាមផ្ទាំងព័ត៌មានគម្រោងរបស់ពួកគេ សម្រាប់ពន្យល់ព័ត៌មានគម្រោងទៅកាន់ «សិស្សដទៃទៀតដែលជាទស្សនិកជន»។



## មេរៀនទី ៣៣ ការអប់រំបន្ត

មេរៀននេះស្រដៀងទៅនឹងខ្លឹមសារមេរៀនក្នុងថ្នាក់ទី១១ (មេរៀនទី២៦)។ វត្ថុបំណងនៃមេរៀននេះគឺ៖

- សិស្សនឹងទទួលបានព័ត៌មានបន្ថែមពីប្រព័ន្ធអប់រំបន្តនៅកម្ពុជា
- សិស្សនឹងទទួលបានព័ត៌មានបន្ថែមពីការអប់រំបន្តដែលអាចមាននៅក្នុងអាជីពការងារដែលពួកគេបានជ្រើសរើស។

### សកម្មភាពសិស្ស

អ្នកបានរៀនមេរៀននេះម្តងរួចទៅហើយកាលពីថ្នាក់ទី១១ ពាក់ព័ន្ធនឹងការអប់រំបន្ត។ ការជ្រើសរើសអាជីពការងាររបស់សិស្ស តែងមានការប្រែប្រួល។ ពេលនេះ ពួកគេគួរតែធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីការអប់រំ និងការបណ្តុះបណ្តាលបន្ត ដែលត្រូវការនៅក្នុងអាជីពបណ្តោះអាសន្ននាពេលអនាគតរបស់ពួកគេឡើងវិញ។ អ្នកត្រូវផ្តល់ការគាំទ្រដល់ពួកគេក្នុងការរៀបចំផែនការនៃការអប់រំ។ វាជាការណ៍សំខាន់ក្នុងការលើកទឹកចិត្តសិស្សឱ្យប្រើប្រាស់ប្រភពព័ត៌មានផ្សេងៗគ្នា ដើម្បីប្រមូលព័ត៌មាន។ ការអានកាតាឡុក ប្រើប្រាស់អ៊ិនធឺណិត និងជួបជាមួយអ្នកប្រឹក្សាអាជីព ឪពុកម្តាយ ឬមនុស្សពេញវ័យដទៃទៀត គឺជាវិធីសាស្ត្រដែលគួរតែផ្តល់ដំបូន្មានដល់សិស្ស។ មធ្យោបាយមួយទៀតក្នុងការទទួលបានព័ត៌មានភ្លាមៗគឺ ការសម្ភាសនរណាម្នាក់ដែលកំពុងសិក្សាក្នុងជំនាញជាក់លាក់នោះ។

នៅពេលដែលសិស្សបានប្រមូលព័ត៌មានទាំងអស់នៅលើតារាងហើយ ពួកគេអាចចងក្រងព័ត៌មានដែលពាក់ព័ន្ធទៅនឹងការព្រាងផែនការអប់រំ និងជម្រើសអាជីព ហើយធ្វើការប្រៀបធៀបរវាងអាជីពទាំងនោះ។ ពួកគេក៏អាចបូកសរុបបច្ចុប្បន្នភាពនៃការសិក្សាបន្ថែម និងអាជីពការងាររបស់ពួកគេ។

### សន្លឹកកិច្ចការ

ឱ្យពួកគេបំពេញនូវបច្ចុប្បន្នភាពព័ត៌មាននៅក្នុងតារាងខាងក្រោម៖

| | អាជីព ក | អាជីព ខ | អាជីព គ |
|---|---|---|---|
| អាជីពដែលខ្ញុំចាប់អារម្មណ៍ | | | |
| ខ្ញុំចាប់អារម្មណ៍នឹងអាជីពនេះដោយសារតែ... | | | |
| តើការអប់រំ និងការបណ្តុះបណ្តាលប្រភេទណាដែលត្រូវការនៅក្នុងអាជីពការងារ/ជំនាញនេះ? | | | |
| តើវិស័យអ្វីដែលអ្នកអាចមានជំនាញក្នុងការអប់រំ ឬ កម្មវិធីបណ្តុះបណ្តាលនេះ? | | | |

| | | | |
|---|---|---|---|
| តើភារកិច្ចប្រភេទណាដែលអ្នកអាចធ្វើបាន បន្ទាប់ពីការអប់រំ ឬការបណ្តុះបណ្តាលនេះរួច? | | | |
| តើស្ថាប័នណាដែលផ្តល់ការអប់រំ ឬការបណ្តុះបណ្តាលនេះរួច? តើមួយណាដែលនៅជិតផ្ទះអ្នក? | | | |
| តើតម្រូវការអ្វីខ្លះសម្រាប់ការចូលសិក្សាការអប់រំ ឬការបណ្តុះបណ្តាលនេះ? | | | |
| តើការអប់រំ ឬកម្មវិធីបណ្តុះបណ្តាលនេះមានរយៈពេលប៉ុន្មាន? | | | |
| រាយបញ្ជីការងារ និងមុខរបរអាជីពដែលការអប់រំនេះ នឹងផ្តល់ជំនាញ និងចំណេះដឹងសម្រាប់ការងារនោះ។ | | | |



# មេរៀនទី ៣៤ សង្ខេបមេរៀនមគ្គុទ្ទេសក៍ និងប្រឹក្សាអាជីព

វត្ថុបំណងនៃមេរៀន ២ បន្ទាប់ទៀតគឺ៖

- ដើម្បីប្តូកសរុបការងាររយៈពេល ៣ ឆ្នាំ នៅលើកំណត់ហេតុសិក្សាក្នុងលក្ខណៈបែបសិល្បៈច្នៃប្រឌិត។

## សកម្មភាពសិស្ស

ឱ្យសិស្សមើលកំណត់ហេតុសិក្សារបស់ពួកគេទាំងអស់គ្នាជាគូ ឬក្នុងក្រុមតូចដែលមានគ្នា ៣ នាក់។ ឱ្យពួកគេសរសេរកំណាព្យ ឬប្រលោមលោកខ្លីខ្លី ឬចំណាប់អារម្មណ៍រួម ចេញពីអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សារៀងៗខ្លួន (ប្រហែល ២ ទំព័រ)។ ជាជម្រើស ពួកគេអាចគូររូបគំនូរជីវចលនៃរាល់ហេតុការណ៍ដែលបានកើតឡើងនាពេល ៣ ឆ្នាំនៃមធ្យមសិក្សាទុតិយភូមិរបស់ពួកគេ និងអាចបង្កើតជាការសំដែងផងដែរ។



## មេរៀនទី ៣៥  ភ្លឺបមុខវិជ្ជា

ពេលនេះដល់ពេលការបង្ហាញ គំនូរជីវចល ឬកំណាព្យ ឬរឿងប្រលោមលោកខ្លី ឬអត្ថបទចំណាប់អារម្មណ៍របស់សិស្ស។

### សកម្មភាពសិស្ស

ចែកសិស្សជា ២ ឬ ៣ ក្រុមធំ ហើយឱ្យពួកគេបង្ហាញការងារសិល្បៈ ដោយផ្អែកលើកំណត់ហេតុសិក្សាទៅកាន់គ្នាទៅវិញទៅមក។ អ្នកអាចឱ្យពួកគេ ធ្វើកិច្ចការដោយស្ងៀមស្ងាត់ ពិភាក្សាដោយសេរីអំពីការងាររបស់ពួកគេជាដើម។ អ្នកគ្រាន់តែធានាថាសិស្សគ្រប់គ្នា អាចបង្ហាញកិច្ចការរបស់គេទៅកាន់មិត្តភក្តិ។



# មេរៀនទី ៣៦ លាហើយមធ្យមសិក្សាទុតិយភូមិ

វត្ថុបំណងនៃមេរៀននេះគឺ៖

- ជួយសិស្សចាកចេញដោយទុកការសិក្សានៅមធ្យមសិក្សាទុតិយភូមិ

សកម្មភាពសិស្ស (រយៈពេល ២០ នាទី)

អ្នកត្រូវបំផុសសិស្ស ដើម្បីរំឭកការចងចាំសកម្មភាពក្នុងឆ្នាំសិក្សាកន្លងទៅ និងសកម្មភាពការងារជាក្រុម ឬសកម្មភាពខុសឆ្គងអំឡុងពេលធ្វើការងារជាក្រុម។ល។ អ្នកអាចប្រមូលរូបថត ឬរូបភាពដែលបានថតដោយសិស្ស ឬមើលរូបភាពទាំងនោះនៅលើទូរសព្ទ ដើម្បីដាក់បង្ហាញជាជំនួយដល់ការរំឭកពីសកម្មភាពកន្លងមក។ ធ្វើការពិភាក្សាដោយសេរី រយៈពេល ២០នាទី។

ឱ្យសិស្សអង្គុយជារង្វង់ ហើយធ្វើបែបនេះចំនួន ៤ ដង៖

ទី១៖ សិស្សគ្រប់គ្នាត្រូវនិយាយម្នាក់ម្តងៗ ដើម្បីរំលេចឡើងនូវបទពិសោធន៍ដ៏មានអត្ថន័យសម្រាប់រូបគេ។

ទី២៖ សិស្សគ្រប់គ្នាត្រូវនិយាយម្នាក់ម្តង ដើម្បីរំលេចនូវអ្វីដែលគេមានមោទនភាពបំផុតចំពោះការសម្រេចបានជោគជ័យរបស់គេ។

ទី៣៖ សិស្សគ្រប់គ្នាត្រូវនិយាយម្នាក់ម្តងនូវរឿងមួយដែលគេចង់នាំយកទៅជាមួយ ពីថ្នាក់មធ្យមសិក្សាទុតិយភូមិ ទៅកាន់ការសិក្សាបន្ត ឬការងារពេលអនាគត។

ទី៤៖ សិស្សគ្រប់គ្នាត្រូវនិយាយម្នាក់ម្តងនូវការរំពឹងទុកសម្រាប់អនាគតរបស់ពួកគេ។

ពេលនេះ សិស្សគ្រប់គ្នាត្រូវបែរមុខទៅខាងស្តាំដៃ រួចលើកដៃស្តាំរបស់គេអង្អែលស្មាមិត្តដែលនៅពីខាងមុខថ្មមៗ ហើយនិយាយអរគុណគាត់សម្រាប់កិច្ចការដ៏ប្រសើរបំផុត និងសុំទោសនូវរាល់កំហុសឆ្គងទាំងឡាយដែលយើងបានធ្វើក្នុងមធ្យមសិក្សាទុតិយភូមិនេះ!





# ផ្នែកទី ៤
# ឧបសម្ព័ន្ធសម្រាប់អ្នកផ្តល់ប្រឹក្សាអាជីព

## ១. វិធីសាស្ត្រផ្សេងៗនៃការផ្តល់ប្រឹក្សាអាជីព

មានរបៀបនៃការផ្តល់ប្រឹក្សាយោបល់ជាច្រើន ដែលគេបានធ្វើចំណាត់ថ្នាក់តាមមធ្យោបាយខុសៗគ្នា។ អ្នកនឹងបានដឹងដោយសង្ខេបអំពីការចាត់ចំណាត់ថ្នាក់របស់ Heikkilä-Laakso-Heikkilä (ឆ្នាំ១៩៩៧) សំដៅទៅលើវិធីសាស្ត្រផ្សេងៗដែលបានប្រើក្នុងការផ្តល់ប្រឹក្សាយោបល់ចំពោះបុគ្គលណាមួយក្នុងលក្ខណៈទល់មុខមួយទល់នឹងមួយ។ ជាទូទៅ អន្តរកម្មធម្មជាតិរបស់មនុស្សមិនមែនប្រព្រឹត្តទៅស្របនឹងរបៀបជាក់លាក់ណាមួយនោះទេ ប៉ុន្តែបើអ្នកមានភាពស៊ាំទៅនឹងរបៀបផ្តល់ប្រឹក្សាយោបល់ផ្សេងៗគ្នា វាអាចជួយអ្នកឱ្យយល់ដឹង និងអាចធ្វើអន្តរកម្មទៅបានដោយរលូន។

### វិធីសាស្ត្របែបផ្តាច់ការ៖ (Definite style)

របៀបផ្តល់ប្រឹក្សាយោបល់បែបត្រួតត្រាគេ ហាក់ដូចជាបានប្រើប្រាស់ច្រើនបំផុតនៅក្នុងការបង្រៀន និងការណែនាំ។ ដើម្បីប្រើរបៀបផ្តល់ប្រឹក្សាយោបល់នេះ អ្នកផ្តល់ប្រឹក្សាយោបល់ដើរតួនាទីជាអ្នកជំនាញចំពោះអ្វីដែលគេត្រូវបង្ហាត់បង្ហាញដោយផ្ទាល់ដល់សិស្សានុសិស្សដូចជា ការដាក់កិច្ចការផ្សេងៗឱ្យសិស្សធ្វើជាដើម។ អ្នកគ្រប់គ្រងការផ្តល់ប្រឹក្សាយោបល់ ជាអ្នកកំណត់នូវបញ្ហា និងផ្តល់នូវដំណោះស្រាយពិតប្រាកដមួយ ប៉ុន្តែអ្នកដែលទទួលការប្រឹក្សាយោបល់មិនមែនជាផ្នែកមួយនៅក្នុងដំណើរការនៃការដោះស្រាយបញ្ហានោះទេ។ ផ្ទុយទៅវិញពួកគេគឺជាអ្នកស្តាប់ដំបូន្មាន និងការណែនាំ។ នៅពេលដែលប្រើរបៀបផ្តល់ប្រឹក្សាយោបល់នេះ ដំណោះស្រាយគឺមានភាពច្បាស់លាស់ ហើយលឿន។

យ៉ាងណាមិញ វាអាចទៅរួចដែលថាអ្នកដែលទទួលបានការប្រឹក្សាយោបល់មិនបានយល់ ឬមិនជ្រាបច្បាស់ចំពោះការសម្រេចចិត្តរបស់អ្នកផ្តល់ប្រឹក្សាយោបល់។ ដូច្នេះ វាមិនមានភាពផ្លាស់ប្តូរក្នុងការរៀនសូត្រនោះទេ។ នៅពេលដែលអ្នកធ្វើការណែនាំអ្វីមួយដោយប្រញាប់ប្រញាល់ ហើយយល់ថាការណែនាំនោះវាច្បាស់លាស់នៅក្នុងគំនិតអ្នក ដោយសារតែអ្នកគិតខ្លួនឯងថាអ្វីៗទាំងអស់ដែលអ្នកគិតគឺមានភាពត្រឹមត្រូវហើយ នោះអ្នកងាយស្រួលក្នុងការកត់សម្គាល់ «ខ្ញុំបាននិយាយយ៉ាងតិចប្រាំដងហើយ ប៉ុន្តែអ្នកមិនធ្វើតាម...»។ ដោយឡែកវាគឺជាការល្អក្នុងការចងចាំថា មានមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលអាចនឹងទទួលយកភាសាធ្ងន់ៗ តាមរយៈការស្តាប់ឮ។ ប្រសិនបើអ្នកផ្តល់ប្រឹក្សាយោបល់អាចផ្តល់នូវដំបូន្មានល្អៗដែលគេចង់បាន ហើយព្យាយាមពន្យល់ និងចង្អុលបង្ហាញក្នុងបរិបទច្បាស់លាស់ នោះការជឿជាក់របស់អ្នកទទួលបានការប្រឹក្សាយោបល់នឹងមិនត្រូវបានកាត់បន្ថយឡើយ។ ប្រសិនបើស្ថានភាពកើតឡើងដដែលៗហើយអ្វីៗដោះស្រាយមិនចេញ អ្នកគ្រប់គ្រងការផ្តល់ប្រឹក្សាយោបល់គួរឈប់គ្រប់គ្រងស្ថានការណ៍តាមរបៀបរបស់ខ្លួនឯងដោយសួរខ្លួនឯងថា តើខ្ញុំប្រើប្រាស់របៀបត្រួតត្រាពេកទេឬ? តើខ្ញុំធ្លាប់បានស្តាប់អ្នកដែលទទួលការប្រឹក្សាយោបល់ដែរឬទេ? ហេតុអ្វីមិនមានអ្វីផ្សេងបន្តទៅមុខទៀត? តើអ្នកយកចិត្តទុកដាក់ថាបញ្ហានៅកន្លែងណាដែរឬទេ? ហេតុអ្វីបានជាអ្នកតែងតែធ្វើរឿងនេះមុនគេ។ល។

ទោះបីជាយ៉ាងណា ការប្រើប្រាស់របៀបត្រួតត្រាគេបែបនេះ អាចប្រើបាននៅពេលដែលអ្នកទទួលការប្រឹក្សាយោបល់មិនអាចធ្វើសកម្មភាពអ្វី កំពុងជាប់គាំង ឬស្ថិតក្នុងវិបត្តិ ព្រមទាំងមិនអាច

ទៅធ្វើការងារអ្វីបានជាបណ្តោះអាសន្ន។ ពេលខ្លះ ការប្រឹក្សាយោបល់បែបនេះត្រូវបានគេប្រើប្រាស់ក្នុងស្ថានភាពដែលចាំបាច់ក្នុងការធ្វើសកម្មភាពជាបន្ទាន់ ឱ្យលឿន និងមិនមានពេលឱ្យអ្នកទទួលការប្រឹក្សាយោបល់គិតគូរអំពីដំណោះស្រាយ។ រឿងនេះ អាចធ្វើទៅបានលុះត្រាតែអ្នកប្រឹក្សាយោបល់ពិតជាមានដំណោះស្រាយជាមុនរួចទៅហើយ។

### វិធីសាស្ត្របែបជំរុញទឹកចិត្ត (Catalyst style)

ការជំរុញទឹកចិត្តមានន័យថា ជាការពន្លឿនប្រតិកម្មដោយមិនចាំបាច់នៅក្នុងស្ថានភាពនោះ។ អ្នកផ្តល់ប្រឹក្សាយោបល់ ជំរុញដំណើរការនៃការណែនាំឱ្យផ្តោតលើការគិត និងការរៀនសូត្រ។ នេះអាចជាការចែករំលែកព័ត៌មាន ហើយជួយធ្វើឱ្យសិស្សភ្លឺច្បាស់ ឬធ្វើឱ្យពួកគេកាន់តែមានភាពសកម្មឡើង។ ការប្រើប្រាស់របៀបជំរុញទឹកចិត្ត ពាក់ពន្ធ័ទៅនឹងសំណួរបើក និងការលើកទឹកចិត្តដែលមានទិសដៅផ្តល់ការណែនាំឱ្យសិស្សរៀនរកដំណោះស្រាយដោយខ្លួនឯង។ អ្នកដែលទទួលការប្រឹក្សាយោបល់ គឺត្រូវបានបណ្តុះបណ្តាល ដើម្បីគ្រប់គ្រងការកំណត់បញ្ហា និងដំណោះស្រាយដោយឯករាជ្យ។ ឧទាហរណ៍ បញ្ហាផ្សេងៗពាក់ព័ន្ធនឹងការកំណត់បញ្ហាគឺ «និយាយពាក្យដែលចង់និយាយ តើអ្នកចង់ឱ្យអ្វីៗទៅជាយ៉ាងណា? តើអ្នកមានអារម្មណ៍ថា ស្ថានភាពវាមានការវិវត្តយ៉ាងណាហើយ? »។ ឧទាហរណ៍ សំណួរផ្សេងៗទៀតដែលអាចនាំទៅដល់ការសម្រេចចិត្តបាន អាចជាអ្វីបន្តបន្ទាប់? តើអ្វីជាគុណសម្បត្តិ និងគុណវិបត្តិ? អ្វីដែលអាចជាដំណោះស្រាយល្អ...?

ហានិភ័យផ្សេងៗនៃការប្រើប្រាស់របៀបជំរុញទឹកចិត្ត គឺជាការបិទបាំងនូវបញ្ហាខាងក្នុង និងបង្ហាញត្រឹមបញ្ហាសើៗ។ ការបិទបាំងអ្វីដែលលាក់ទុកក្នុងចិត្ត អាចជាចំណុចខុសឆ្គងក្នុងការប្រាប់នូវអ្វីដែលបានកើតឡើង៖ «តើអ្នកធ្លាប់ធ្វើរឿងនេះដែរឬទេ? ឬតើវាអាចជាគំនិតដ៏ល្អមួយទេ ប្រសិនជា...» (អាន៖ តើនេះ!)។ ជាការគួរឱ្យភ្ញាក់ផ្អើលដែលថា វាមានផលអាក្រក់នៅពេលដែលអ្នកផ្តល់ប្រឹក្សាយោបល់មិនអាចចែករំលែកទស្សនៈផ្ទាល់ខ្លួនរបស់គាត់ ក៏ប៉ុន្តែការសម្រេចចិត្តនៅតែស្ថិតក្នុងស្ថានភាពតូចចង្អៀត។

ការប្រើប្រាស់របៀបជំរុញទឹកចិត្ត សមស្របជាពិសេសនៅក្នុងស្ថានភាពដែលអ្នកទទួលការប្រឹក្សាយោបល់ត្រូវការព័ត៌មានបន្ថែម ឬព្យាយាមយល់ពីវាដែលជាញឹកញយកើតឡើងនៅក្នុងដំណើរការនៃការរៀនសូត្រពីការងារ។ របៀបមួយនេះ គឺមានភាពអព្យាក្រិត្យ និងមានប្រយោជន៍នៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការប្រឹក្សាយោបល់ ដោយសារវាជួយឱ្យសិស្សមានស្វ័យភាពក្នុងដំណើរការនៃការគិតដែលវាជាទុនសម្រាប់ការរៀនសូត្រ។

### វិធីសាស្ត្របែបប្រឈមមុខដាក់គ្នា (Confronting style)

ការប្រឈមមុខដាក់គ្នាមានន័យថា គឺជាការបង្កើតឱ្យមានភាគីម្ខាងៗដែលចង្អុលបង្ហាញពីការប្រជែងគ្នាពីអ្វីមួយ។ ការងាររបស់អ្នកផ្តល់ប្រឹក្សាយោបល់គឺ ការចង្អុលបង្ហាញពីភាពផ្ទុយគ្នាផ្សេងៗនៅក្នុងការគិតរឿងរ៉ាវផ្សេងៗ និងសកម្មភាពរបស់សិស្ស។ មូលដ្ឋានគ្រឹះនៃរបៀបមួយនេះគឺដើម្បីជួយដល់សិស្សឱ្យក្លាយទៅជាអ្នកយល់ដឹងពីភាពផ្ទុយគ្នាផ្សេងៗទៅនឹងគំនិតរបស់ពួកគេ។ ជម្លោះគួរតែមានភាពច្បាស់លាស់ មានគោលបំណងត្រឹមត្រូវ និងមិនគួរដាក់បញ្ចូលនូវភាសាមានលក្ខណៈរិះគន់ ឬខ្វះសីលធម៌នោះទេ។

ការធ្វើឱ្យមានការមិនឯកភាពគ្នាបែបនេះនៅក្នុងការនិយាយ ឬក្នុងការធ្វើសកម្មភាពណាមួយរបស់អ្នកដែលទទួលការប្រឹក្សាយោបល់ អាចធ្វើឱ្យការណែនាំមានភាពគួរឱ្យភ្ញាក់ផ្អើល និងមានហានិភ័យទៅវិញ ដោយសារតែយើងមិនអាចដឹងបានថា តើសិស្សនឹងមានប្រតិកម្មតបយ៉ាងណានៅពេលដែលពួកគេបានដឹងថា អ្វីដែលពួកគេបានធ្វើ ឬគិតមានភាពផ្ទុយពីគេទៅវិញ។ ជាលទ្ធផល វាអាចមានប្រតិកម្មតបដែលមានការភ្ញាក់ផ្អើល និងជម្លោះកើតឡើង។ នៅពេលបង្កើតស្ថានភាពប្រឈមគ្នា វាទាមទារឱ្យមានបរិយាកាសចិត្តសាស្ត្រដែលមានសុវត្ថិភាព ទើបអាចធ្វើទៅបាន។

អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន ថាតើការបង្កើតឱ្យមានភាពផ្ទុយគ្នា មានសារៈសំខាន់ឬយ៉ាងណា។ ភាពយល់ច្រឡំអាចកើតឡើងបាន។ ទោះជាយ៉ាងណាក៏ដោយ កាតព្វកិច្ចរបស់អ្នកផ្តល់ប្រឹក្សាយោបល់ដែលមានសមត្ថភាព គឺចង្អុលបង្ហាញជម្លោះនៅពេលដែលមានការរារាំងណាមួយទៅលើភាពរីកចម្រើននៃដំណើរការសិក្សា។ អ្នកផ្តល់ប្រឹក្សាយោបល់ក៏ចៀសមិនផុតពីកិច្ចការដែលមិនចង់ធ្វើបែបនេះដែរ ប្រសិនបើមានបញ្ហាអ្វីមួយកើតឡើង ឬក៏ពិបាកដោះស្រាយ។ ប៉ុន្តែ បើសិនពួកគេមិនយកចិត្តទុកដាក់ចំពោះរឿងដែលមិនសប្បាយចិត្តនេះ ការងារនេះនឹងមានដំណើរការទៅមុខទៀត។ តួនាទីនៃរបៀបប្រឈមមុខដាក់គ្នានេះ គឺចង់ឱ្យកើតមានឡើងនៅដំណាក់កាលពាក់កណ្តាល ឬចុងបញ្ចប់នៃដំណើរការប្រឹក្សាយោបល់។ វិធីមួយនេះ កម្រនឹងទទួលបានផ្លែផ្កានៅក្នុងការណែនាំនៅក្នុងជំនួបលើកទីមួយ ដោយសារតែការកសាងនូវបរិយាកាសដែលមានលក្ខណៈអាថ៌កំបាំង មិនបើកចំហ និងមិនស្មោះត្រង់ និងមិនងាយជោគជ័យនោះទេ។

### វិធីសាស្ត្របែបស្រុះស្រួលគ្នា (Approving style)

នៅពេលប្រើរបៀបដែលមានលក្ខណៈទន់ភ្លន់ អ្នកដែលទទួលការប្រឹក្សាយោបល់ចូលចិត្តចូលរួម។ នៅចំណុចចាប់ផ្តើម ចំណុចនានាត្រូវបានយកមកពិចារណាដោយគិតពីទស្សនៈរបស់អ្នកដែលទទួលការប្រឹក្សាយោបល់។ សិស្សចង់ប្រាប់អំពីស្ថានភាពផ្ទាល់ខ្លួនដែលពួកគេជួបប្រទះ ហើយអ្នកផ្តល់ប្រឹក្សាយោបល់ចាំស្តាប់ដោយយកចិត្តទុកដាក់ បង្ហាញពីការគាំទ្រ និងយល់ចិត្ត លើកទឹកចិត្ត ឬបញ្ជាក់បន្ថែមដោយមានអព្យាក្រិតភាពក្នុងការនិយាយ។ អ្នកផ្តល់ប្រឹក្សាយោបល់មិនត្រូវបញ្ជាក់លម្អិត ផ្តល់នូវយោបល់ផ្សេងៗ ប្រឈមមុខដាក់គ្នា ឬសំដែងចេញមតិយោបល់របស់ខ្លួននោះទេ។ ការងាររបស់អ្នក គឺត្រូវបង្កើតនូវបរិយកាសដែលមានលក្ខណៈចិត្តសាស្ត្រអាចទុកចិត្តបានមួយ ដែលធ្វើឱ្យសិស្សអាចមានសេរីភាពក្នុងការដោះស្រាយបញ្ហារបស់ខ្លួន។ គេបានសន្មតថាអ្នកត្រូវតែទទួលបានការណែនាំដោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីដំណើរការកិច្ចការរបស់អ្នកក្នុងការស្វែងរកដំណោះស្រាយ។ ការប្រើប្រាស់របៀបមួយនេះ គឺទាក់ទងជាពិសេសទៅនឹងការងារខាងវិធីព្យាបាលរោគ។ ប៉ុន្តែ វាក៏មានស្ថានភាពជាក់លាក់មួយចំនួននៅក្នុងសាលារៀនផងដែរដែលត្រូវការរបៀបមួយនេះ។ នៅពេលដែលមានការផ្លាស់ប្តូរណាមួយដោយមិនបានព្រៀងទុកបានកើតឡើងនៅក្នុងជីវិតរបស់សិស្ស អ្នកផ្តល់ដំបូន្មានដែលជាអ្នកចាស់ទុំជាង អាចនៅចាំស្តាប់សិន ហើយផ្តល់ដំបូន្មានខ្លះជាមួយនឹងការជួយចែករំលែក និងការយល់ចិត្ត។ ហានិភ័យនៃរបៀបប្រឹក្សាដោយភាពអត់ធ្មត់ គឺការឡើងសម្ពាធដែលជាហេតុនាំឱ្យការដោះស្រាយបញ្ហាមានការវិវត្តទៅមុខយឺតៗ។ វាអាចពិបាកផងដែរសម្រាប់អ្នកផ្តល់ប្រឹក្សាយោបល់ ដើម្បីរក្សានូវរបៀបដែលល្អឥតខ្ចោះអាចទទួលយកបាន និងមានអព្យាក្រិតភាព។ របៀបមួយនេះ គឺមានសារៈប្រយោជន៍នៅពេលណាដែលសិស្សមានសម្ពាធផ្លូវចិត្តខ្លាំង ហើយមិនអាចធ្វើឱ្យមានភាពធូរស្បើយបាន របៀត

ដល់អារម្មណ៍ពួកគេអាចទទួលយកបាន។ អារម្មណ៍ និងផ្លូវចិត្តទាំងឡាយ គឺជាអ្នកបង្កើតនូវតថភាពជាក់ស្តែង ជាពិសេសអារម្មណ៍ដែលទទួលយកអ្វីដែលមិនចង់បាន។ នៅក្នុងដំណើរការដ៏វែងឆ្ងាយនៃការផ្តល់ការប្រឹក្សាយោបល់ មានការរៀនសូត្រយ៉ាងទូលំទូលាយ ឬមានបញ្ហានានាទាក់ទងនឹងជីវិតអាចកើតឡើងដែលអាចធ្វើឱ្យយើងទទួលបាននូវបទពិសោធន៍នៃការរំជួលចិត្តដែលខ្លាំងក្លាណាមួយ។

### ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ (Use of Styles)

នៅពេលដែលគោលបំណងនៃការរៀនសូត្រកាន់តែច្បាស់លាស់ នោះការប្រើប្រាស់របៀបប្រឹក្សាយោបល់បែបផ្តាច់ការ កាន់តែអាចសម្រេចបាននូវគោលបំណងក្នុងពេលវេលាមួយដែលបានកំណត់។ ចំពោះរបៀបនៃការជំរុញទឹកចិត្ត គឺជាវិធីល្អបំផុតសម្រាប់ស្ថានភាពដែលសិស្សានុសិស្សត្រូវមានការគិតអំពីអ្វីមួយចេញពីជ្រុងខុសៗគ្នា ធ្វើការសិក្សា និងធ្វើការសន្និដ្ឋានអំពីកិច្ចការដែលបានដាក់ឱ្យធ្វើ។ ចំណែករបៀបនៃការស្រុះស្រួលគ្នា សមស្របក្នុងការជួយគាំទ្រការគ្រប់គ្រងជីវិតខ្លួនឯង ឬការឆ្លុះបញ្ចាំងពីភាពរីកចម្រើនរបស់ខ្លួនឯង។ របៀបនៃការប្រឈមមុខដាក់គ្នា គឺសមស្របក្នុងការប្រើប្រាស់ចំពោះការផ្តល់យោបល់ជាលក្ខណៈបុគ្គល ដើម្បីផ្តាច់មនោសញ្ចេតនា ឬបង្កើតឱ្យមានភាពមិនរលូនកើតឡើងក្នុងកំឡុងពេលសន្ទនាគ្នា។

## ២. ទ្រឹស្តីនៃការប្រឹក្សាអាជីព

នៅក្នុងផ្នែកនេះ អ្នកនឹងយល់ដឹងនូវខ្លឹមសារសង្ខេបអំពីទ្រឹស្តីសាមញ្ញបំផុតចំនួនបួនក្នុងការងារណែនាំ និងការប្រឹក្សាយោបល់។

**ការប្រឹក្សាអាជីពដោយផ្តោតលើដំណោះស្រាយ** គឺជាការស្វែងរកដំណោះស្រាយវិជ្ជមានចំពោះបញ្ហា ឬការប្រឈមផ្សេងៗ។ ចំណុចគន្លឹះនៃទិសដៅដែលចង្អុលបង្ហាញនេះ គឺទាក់ទងទៅនឹងគោលដៅ និងការសម្រេចបាននូវគោលដៅ។ អ្នកផ្តល់ប្រឹក្សាយោបល់ ត្រូវបង្កើនការស្វែងយល់អំពីស្ថានភាពកើតឡើងថ្មីៗ និងចេះរៀបចំគោលដៅផ្សេងៗដើម្បីបង្កើតនូវផែនការសកម្មភាព។ ផែនការសកម្មភាព គឺត្រូវតែច្បាស់លាស់ និងត្រូវបានពិនិត្យពីភាពរីកចម្រើនរបស់វា។ វិធីសាស្ត្រផ្សេងៗ ជាឧទាហរណ៍រួមមាន ការបង្កើតជំហានទីមួយៗ និងការវាស់វែងពីទំហំនៃការរីកចម្រើន។ គោលគំនិតនេះក៏មានន័យថា អ្នកដែលទទួលការប្រឹក្សាយោបល់ បានព្យាយាមអះអាងពីអ្វីដែលអាចធ្វើទៅបាន អ្វីដែលងាយស្រួល និងមានភាពវិជ្ជមាន។ បន្ទាប់ពីនេះ ការងារប្រឹក្សាយោបល់ក៏អាចធ្វើទៅបានជាមួយនឹងការវិវត្តនៃបញ្ហាប្រឈមផ្សេងៗ។ មធ្យោបាយនៃការធ្វើការងារនេះគឺយល់ចិត្តអតិថិជនជាធំ ដើម្បីសម្រេចគោលដៅ គិតគូរពីអនាគត ចេះប្រើប្រាស់ធនធាន បង្កើតឱ្យមានវឌ្ឍនភាព ភាពវិជ្ជមាន និងគំនិតច្នៃប្រឌិត។ ការប្រឹក្សាយោបល់ដោយផ្តោតលើដំណោះស្រាយក៏អាចមានទំនាក់ទំនងទៅនឹងវិធីសាស្ត្រដទៃផ្សេងៗទៀតផងដែរ។

**ការប្រឹក្សាអាជីពបែបត្រិះរិះពិចារណា** គឺផ្អែកលើការប្រើការគិត និងភាពសមហេតុផលក្នុងស្ថានភាពនៃការធ្វើការសម្រេចចិត្ត។ មគ្គុទ្ទេសក៍បែបនេះ គឺមានសារៈសំខាន់ណាស់ ដើម្បីជួយដល់អ្នកដែលទទួលការប្រឹក្សាយោបល់ឱ្យដឹងពីជម្រើសដែលពួកគេមាន និងភាពសមស្របសម្រាប់ពួកគេនៅក្នុងការជ្រើសរើសការសម្រេចចិត្ត និងការដោះស្រាយបញ្ហា។ វាជាចំណុចសំខាន់ក្នុងការដាស់តឿនដល់អ្នកទទួលការប្រឹក្សាយោបល់ចំពោះការគិតផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជាការពង្រីក

បង្រួម ឬផ្តល់តម្លៃដល់ជម្រើសផ្សេងៗគ្នា។ នៅក្នុងការអនុវត្តនេះ មានន័យថាពួកគេអាចការបង្កើន ចំណេះដឹងខ្លួនឯងតាមរយៈការធ្វើតេស្តផ្សេងៗ និងការស្វែងរកព័ត៌មានពីប្រភពផ្សេងៗ។ ទន្ទឹមនឹង នេះ ការប្រឹក្សាយោបល់ដោយការត្រិះរិះ មានគោលបំណងបង្ហាញពីដំណើរការនៃការសម្រេចចិត្ត ប្រកបដោយភាពជឿជាក់ និងពិតប្រាកដ។ តួនាទីរបស់អ្នកប្រឹក្សាយោបល់ គឺស្វែងរកប្រភព ព័ត៌មាន និងមធ្យោបាយនានា ដើម្បីបង្កើនការយល់ដឹងខ្លួនឯង។ ជម្រើស ឬដំណោះស្រាយកើត ឡើងដោយ សារការបង្កើនចំណេះដឹង (ចំណេះដឹង និងជម្រើសផ្ទាល់ខ្លួន) និងការស្វែងយល់។ មគ្គុទ្ទេសក៍បែបត្រិះរិះ អាចធ្វើឡើងតាមរយៈការធ្វើតេស្តដោយប្រើកុំព្យូទ័រ ការប្រមូលយកព័ត៌មាន នានា ការចងក្រង ភាពរីកចម្រើននៃកម្រងសំណួរ បង្កើតជម្រើស និងតម្លៃរបស់របស់វា ការបង្កើត ផែនការសកម្មភាព និងការតាមដាន។

**ការប្រឹក្សាអាជីពបែបថាមពលសង្គម** គឺជាវិធីសាស្ត្របែបស្ថាបនា។ យោងតាមចំណុច នេះ គោលបំណងនៃការណែនាំគឺដើម្បីគាំទ្រ និងលើកទឹកចិត្តដល់អ្នកដែលទទួលការប្រឹក្សា យោបល់ក្នុងការយល់ និងដោះស្រាយស្ថានភាព និងបញ្ហាផ្សេងៗនៅក្នុងជីវិតផ្ទាល់ខ្លួន។ ចំណុច នេះ ផ្តោតសំខាន់ទៅលើបរិស្ថានដែលពាក់ព័ន្ធទាំងមូល ក៏ដូចជាសកម្មភាពជាក់លាក់របស់បុគ្គល ម្នាក់ៗ។សកម្មភាពនៃការផ្តល់ប្រឹក្សាយោបល់ គឺជាចំណុចសំខាន់ និងមានបំណងដើម្បីផ្តល់នូវក្តី សង្ឃឹម ការលើកទឹកចិត្ត និងការជួយដល់អ្នកទទួលការប្រឹក្សាយោបល់។ ក្នុងការងារនេះ វាក៏ត្រូវ ការការគិតពីធនធាន និងមានគោលបំណងពង្រឹងភាពខ្លាំងរបស់ខ្លួន។ គោលដៅនៃអ្វីដែលគេហៅ ថាការបញ្ចូលចំណេះដឹងខាងស្មារតី គឺជាការផ្តោតសំខាន់លើឱកាសផ្សេងៗ គ្មានក្បួនខ្នាត ឬ អំណាចនៃការគ្រប់គ្រងណាមួយឡើយ។ វិធីសាស្ត្រនេះ មានគោលបំណងបែងចែករវាងស្ថានភាព ដែលមានស្រាប់ និងជម្រើសគោលនយោបាយដោយប្រើប្រាស់ប្រភេទផ្សេងៗនៃផែនទី ឬរូបភាព ដែលអាចមើលឃើញនឹងភ្នែក។ ការប្រឹក្សាយោបល់បែបថាមពលសង្គម មានយកចិត្តទុកដាក់ ចំពោះជីវិតនៃការរស់នៅរបស់បុគ្គលម្នាក់ៗ។ អ្វីដែលមានពីមុន និងបច្ចុប្បន្ន អាចកត់ត្រាដើម្បី បង្កើតបានការសម្រេចចិត្តថ្មីៗ ក្នុងន័យកសាងអនាគត។ អ្វីដែលសំខាន់ក្នុងការប្រឹក្សាយោបល់នេះ គឺដើម្បីដឹកនាំជីវិតបុគ្គលណាមួយ និងពង្រឹងសិទ្ធិអំណាចក្នុងការសម្រេចចិត្តខ្លួនឯង។ ឧទាហរណ៍ មគ្គុទ្ទេសក៍បែបថាមពលសង្គម រួមបញ្ចូលទាំង មើលឃើញជីវិត ដឹងពីដំណើរជីវិត រឿងរ៉ាវផ្សេងៗ បណ្តាញ ប្រអប់ទំនាក់ទំនង ការផ្លាស់ប្តូរទស្សនៈវិស័យ និងវដ្តនៃការផ្តល់សិទ្ធិអំណាច។ វិធីសាស្ត្រ នៃមគ្គុទ្ទេសក៍បែបសង្គមមានដូចជា ការចុះទៅឃើញពីជិវិតពិត ខ្សែជីវិតពិត រឿងរ៉ាវ បណ្តាញ ការ ទំនាក់ទំនង ការផ្លាស់ប្តូរទស្សនៈ និងការដោះស្រាយបញ្ហាជីវិត នៅក្នុងសង្គម។

**ការផ្តល់ប្រឹក្សាអាជីពបែបថាមពលផ្លូវចិត្ត** សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃទំនាក់ទំនង បើកចំហ និងសម្ងាត់នៅក្នុងការប្រឹក្សាយោបល់។ យោងតាមទ្រឹស្តីនេះ ការគាំទ្រត្រូវបានធ្វើឡើង នៅក្នុងទំនាក់ទំនងដឹកនាំដែលអ្នកទទួលការប្រឹក្សាយោបល់ អាចឆ្លុះបញ្ចាំងដោយខ្លួនឯង និង អនាគតរបស់ខ្លួន។ ការងាររបស់អ្នកផ្តល់ប្រឹក្សាយោបល់ គឺបង្កើតលក្ខខណ្ឌវិជ្ជមាន និងក្លាយជាអ្នក សម្របសម្រួលដែលអាចគ្រប់គ្រងខ្លួនឯងបាន។ ការស្តាប់ ការស្វែងយល់ និងការឆ្លុះបញ្ចាំង គឺជា ឧបករណ៍របស់អ្នកប្រឹក្សាយោបល់ ក្នុងការប្រាស្រ័យទាក់ទង។ គោលបំណងនៃមគ្គុទ្ទេសន៍នេះ គឺ ដើម្បីធ្វើឱ្យអាចមើលឃើញពីកត្តាមានឥទ្ធិពលចំពោះការសម្រេចចិត្តដែលបានធ្វើឡើងដោយមិន ច្បាស់លាស់។ វាអាចជាការចាំបាច់ណាស់ ក្នុងការដែលត្រូវបង្ហាញឱ្យដឹងថា ការសម្រេចចិត្តដែល បានធ្វើរួចហើយមានបញ្ហានៅកន្លែងណា ហើយគួរដោះស្រាយរបៀបណា។ ការវិភាគទំនាក់ទំនង

នៃការប្រឹក្សាយោបល់ គឺមានសារៈសំខាន់។ វាចាំបាច់ណាស់ក្នុងការគិតអំពីរបៀបនៃទំនាក់ទំនង ដែលគេបានអនុវត្ត និងអ្វីដែលគេកំពុងបានធ្វើ។ វិធីសាស្ត្រនៃមគ្គុទ្ទេសក៍បែបថាមពលផ្លូវចិត្តរួមមាន window of Johari ដែលជាវិធីសាស្ត្រដែលមានរូបភាព ពិសេសការពិភាក្សា។

ជម្រើសក្នុងការអនុវត្តទ្រឹស្តីវាអាស្រ័យទៅលើលើចំណាប់ចំណូលចិត្ត និងសមត្ថភាពផ្ទាល់របស់អ្នកប្រឹក្សាយោបល់ ប៉ុន្តែវាក៏ជាតម្រូវការរបស់អ្នកដែលទទួលការប្រឹក្សាយោបល់ផងដែរ។ វិធីសាស្ត្រមួយចំនួនអាចមានភាពសមស្របទៅនឹងប្រភេទនៃការគ្រប់គ្រងស្ថានភាពណាមួយ ជាងវិធីសាស្ត្រផ្សេងទៀត។ ផ្ទុយទៅវិញទ្រឹស្តីទាំងអស់សុទ្ធតែអាចនាំឱ្យមានលទ្ធផលល្អសម្រាប់ការប្រឹក្សាយោបល់។

(សូមមើល Corey ឆ្នាំ 2017)



### ៣. ទស្សនាទាន ( Concepts )

**ការប៉ាន់ប្រមាណ** គឺជាដំណើរការនៃការវាយតម្លៃចំណេះដឹង របៀបធ្វើ ជំនាញវិជ្ជាជីវៈ និង/ឬ សមត្ថភាពរបស់បុគ្គលម្នាក់ធៀបទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានកំណត់ជាមុន (ការរំពឹងទុកចំពោះការរៀនសូត្រ)។ ជាទូទៅ ការវាយតម្លៃត្រូវបានធ្វើឡើងដោយមានការផ្ទៀងផ្ទាត់ និងការបញ្ជាក់ត្រឹមត្រូវ។ បើតាមឯកសារយោង ការវាយតម្លៃជាទូទៅសំដៅទៅលើការវាយតម្លៃបុគ្គលម្នាក់ៗដែលការវាយតម្លៃនេះបានប្រើជាញឹកញាប់ ដើម្បីពិពណ៌នាអំពីការវាយតម្លៃការអប់រំ និងវិធីបណ្តុះបណ្តាល ឬអ្នកផ្តល់សេវា។ (Cedefop)

**ការប្រឹក្សាយោបល់អំពីអាជីព** សំដៅលើដំណើរការនៃបុគ្គល ឬក្រុមដែលសង្កត់ធ្ងន់ទៅលើការយល់ដឹង និងការស្វែងយល់ដោយខ្លួនឯង ហើយជួយសម្របសម្រួលមនុស្សចេះអភិវឌ្ឍជីវិតរបស់ខ្លួនឱ្យមានន័យ ជួយមនុស្សឱ្យមានលទ្ធភាពអាចតម្រង់ទិសដៅការងារដែលត្រឹមត្រូវ ដើម្បីជាមូលដ្ឋានក្នុងការរៀនសូត្រ ការធ្វើការងារ និងការធ្វើការសម្រេចចិត្តនានា ក៏ដូចជាការគ្រប់គ្រង ការឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិស្ថានការងារ និងបរិស្ថានរៀនសូត្រនៅក្នុងដំណើរជីវិតប្រចាំថ្ងៃ។ (IAEVG)

**ការបញ្ជាក់** គឺជាដំណើរការនៃការចេញវិញ្ញាបនបត្រ វិញ្ញាបនបត្រ ឬប័ណ្ណដែលបញ្ជាក់ពីសំណុំនៃលទ្ធផលសិក្សា (ចំណេះដឹង ចំណេះធ្វើ ជំនាញ និង/ឬ គុណវុឌ្ឍិ) ដែលទទួលបានដោយបុគ្គលម្នាក់ ហើយត្រូវបានវាយតម្លៃ និងបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ចធៀបទៅនឹងបទដ្ឋានស្តង់ដាជាក់លាក់ណាមួយដែលបានកំណត់ជាមុន។ (Cedefop)

**សមត្ថភាព** គឺជាភាពដែលអាចប្រើប្រាស់បាននូវចំណេះដឹង ជំនាញ និងលក្ខណៈផ្ទាល់ខ្លួនសង្គម និង/ឬសមត្ថភាពនៅក្នុងការងារ ឬការសិក្សា ក៏ដូចជានៅក្នុងការអភិវឌ្ឍអាជីព និងការអភិវឌ្ឍខ្លួនឯង ឬលទ្ធភាពក្នុងការអនុវត្តតួនាទីភារកិច្ចឱ្យបានគ្រប់ជ្រុងជ្រោយស្ថិតក្នុងបរិបទដែលបានកំណត់ (ការអប់រំ ការងារ ការអភិវឌ្ឍអាជីព និងការអភិវឌ្ឍខ្លួនឯង)។ សមត្ថភាពត្រូវបានពិពណ៌នាថាជាការទទួលខុសត្រូវ និងមានស្វ័យភាព។ (Cedefop)

**ការបន្តការអប់រំ និងការបណ្តុះបណ្តាល** ជាការបន្តការសិក្សាបន្ថែម បន្ទាប់ពីទទួលបានការអប់រំ និងការបណ្តុះបណ្តាលដំបូង ឬបន្ទាប់ពីចូលប្រឡូកនៅក្នុងជីវិតការងារ។ ការអប់រំ ឬបណ្តុះបណ្តាលបន្តនេះ មានទិសដៅជួយដល់បុគ្គលណាម្នាក់ក្នុងការធ្វើឱ្យប្រសើរឡើង ឬបង្កើនចំណេះដឹង និងជំនាញរបស់ពួកគេ ក្នុងការទទួលបានជំនាញថ្មីៗដើម្បីវឌ្ឍនៈភាពការងារ ឬថែរក្សាអាជីព ឬក្នុងការបន្តការអភិវឌ្ឍអាជីព និង/ឬការអភិវឌ្ឍខ្លួនឯង។ (Cedefop)

**ការផ្តល់ប្រឹក្សាយោបល់** រួមមានការជួយបុគ្គលណាម្នាក់ឱ្យរកឃើញ បញ្ជាក់ វាយតម្លៃ និងស្វែងយល់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីស្គាល់ពីភាពខ្លាំង និងខ្សោយ។ ការប្រឹក្សាយោបល់ ក៏ជាផ្នែកមួយនៃការជំរុញលើកទឹកចិត្ត និងទិសដៅជីវិត/ការងាររបស់ពួកគេ ដើម្បីស្វែងរកជម្រើស និងការអនុវត្តដែលអាចធ្វើទៅបានយ៉ាងប្រសើរ។ វាគឺជាដំណើរការរួមមួយដែលមានបំណងបង្កើនការយល់ដឹងដោយខ្លួនឯង កំណត់នូវតម្រូវការ និងទិសដៅ គោលចំណង ព្រមទាំងបង្កើត និងអនុវត្តផែនការសកម្មភាព ដើម្បីសម្រេចគោលដៅដែលចង់បាននោះ។ ការផ្តល់ប្រឹក្សាយោបល់ គឺជាសកម្មភាពដែលកើតចេញពីបំណងរបស់អ្នកប្រឹក្សាយោបល់ និងអ្នកទទួលការប្រឹក្សា

យោបល់ដែលជាទូទៅពាក់ព័ន្ធទៅនឹងទំនាក់ទំនងជាមួយនឹងការប្រាស្រ័យទាក់ទងជាទៀងទាត់។ (IAEVG)

**កម្មវិធីសិក្សា** គឺជាការជ្រើសរើស និងការរៀបចំនូវបទពិសោធន៍សិក្សាសម្រាប់សិស្ស ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ។ វារួមបញ្ចូលចំណេះដឹង គុណតម្លៃ អាកប្បកិរិយា និងជំនាញដែលគួរត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ និងស្របតាមលំដាប់លំដោយទៅតាមតម្រូវការការសិក្សា និងការអភិវឌ្ឍទៅតាមវ័យ និងដំណាក់កាលអប់រំខុសៗគ្នា។ សិស្សម្នាក់ៗ គួរត្រូវបានបែងចែករវាងកម្មវិធីសិក្សា (ជាធម្មតាកម្មវិធីសិក្សា មានជាលាយលក្ខណ៍អក្សរ និងផ្លូវការ) ដែលបានអនុវត្តនៅក្នុងថ្នាក់រៀន។ ជាទូទៅ កម្មវិធីសិក្សាត្រូវបានដំណើរការតាមរយៈឯកសារជាក់ស្តែងដូចជា ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល និងសម្ភារៈឧបទេ្ទសផ្សេងៗទៀត ដោយរាប់បញ្ចូលទាំងគោលបំណងនៃការអប់រំ វត្ថុបំណងនៃការសិក្សា និងលទ្ធផលរំពឹងទុក (សមត្ថភាពសិស្ស) មាតិកា និងវិធីសាស្រ្តសិក្សាដែលរួមបញ្ចូលទាំងសកម្មភាពរបស់សិស្ស និងយុទ្ធសាស្រ្តសម្រាប់វិភាគ និងវាយតម្លៃ។ (INEE)

**ការវាយតម្លៃ** គឺជាការត្រួតពិនិត្យ ឬសិក្សាប្រៀបធៀបលទ្ធផលនៃការអនុវត្តសកម្មភាពជាក់ស្តែង ទៅនឹងផែនការយុទ្ធសាស្រ្តដែលបានឯកភាពគ្នា ដើម្បីរកឱ្យឃើញចំណុចខ្លាំង ចំណុចខ្សោយរបស់សិស្ស។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ សិស្សនឹងមើលឃើញពីចំណុចដែលត្រូវកែលម្អដើម្បីមានលទ្ធភាពអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យកាន់តែរីកចម្រើន។ (INEE)

**មតិយោបល់ត្រឡប់** គឺការបញ្ជូនការរកឃើញដែលបង្កើតឡើងតាមរយៈដំណើរការវាយតម្លៃទៅភាគីដែលមានទំនាក់ទំនង និងមានប្រយោជន៍ ដើម្បីសម្រួលដល់ការរៀនសូត្រ។ ទាំងនេះ អាចពាក់ព័ន្ធនឹងការប្រមូល និងផ្សព្វផ្សាយរបកគំហើញ សេចក្តីសន្និដ្ឋាន អនុសាសន៍ និងមេរៀនពីបទពិសោធន៍ផ្សេងៗ។ (INEE)

**អ្នកប្រឹក្សាយោបល់** ត្រូវបានគេស្នើឱ្យធ្វើការជាមួយក្រុមប្រឹក្សាភិបាលសាលារៀនបឋមសិក្សា ឬមធ្យមសិក្សា។ សកម្មភាពសំខាន់ៗរួមមាន ការផ្តល់ប្រឹក្សាដល់សិស្សអំពីបញ្ហាផ្ទាល់ខ្លួន និងបញ្ហាទាក់ទងនឹងការសិក្សា។ ការសង្កត់ធ្ងន់ចម្បង គឺការផ្តល់ជ្រើសរើសការអប់រំ និងការបណ្តុះបណ្តាលក្រោយមធ្យមសិក្សា ដោយមិនសូវផ្តោតលើបញ្ហាដែលទាក់ទងទៅនឹងការងារពីសាលាទេ។ អ្នកប្រឹក្សាយោបល់ រៀបចំសម្របសម្រួលសេវាកម្មប្រឹក្សាយោបល់ សេវាកម្មព័ត៌មានស្តីពីអាជីព និងជួយបញ្ជូនទៅសេវាកម្មជំនាញខាងក្រៅបើសិស្សត្រូវការ។ គាត់អាចគ្រប់គ្រង និងបកស្រាយឧបករណ៍វាយតម្លៃអាជីពដែលមានលក្ខណៈស្តង់ដា រួមទាំងការធ្វើតេស្តសមត្ថភាព និងចំណាប់អារម្មណ៍របស់សិស្ស។ (IAEVG)

**ការអប់រំបរិយាបន្ន** ធានានូវវត្តមាន ការចូលរួម និងសមិទ្ធផលរបស់បុគ្គលគ្រប់រូបក្នុងឱកាសសិក្សា។ វាពាក់ព័ន្ធនឹងការធានាថាគោលនយោបាយអប់រំ ការអនុវត្តផ្ទាល់ និងគ្រឹះស្ថានអប់រំ ឆ្លើយតបទៅនឹងភាពចម្រុះនៃបុគ្គលគ្រប់រូបនៅក្នុងបរិបទមួយ។ ការមិនបានទទួលការអប់រំ អាចបណ្តាលមកពីការរើសអើង ការខ្វះការគាំទ្រ ដើម្បីលុបបំបាត់ឧបសគ្គ ឬការប្រើប្រាស់ភាសា មាតិកា ឬវិធីសាស្រ្តបង្រៀនដែលមិនផ្តល់អត្ថប្រយោជន៍ដល់អ្នករៀនទាំងអស់គ្នា។ មនុស្សភាគច្រើនដែលមានពិការភាពផ្លូវកាយ ផ្លូវចិត្ត ខួរក្បាល និងបញ្ញា ជារឿយៗត្រូវបានគេផាត់ចេញពីការអប់រំ។ ក្រុមងាយរងគ្រោះ មិនត្រូវបានគេយកចិត្តទុកដាក់។ បុគ្គលខ្លះដែលពីមុនអាចចូលរៀនបាន អាចត្រូវបានគេ

ផាត់ចេញដោយសារតែកត្តាសង្គម កាលៈទេសៈ វប្បធម៌ រូបសម្បត្តិ ឬហេដ្ឋារចនាសម្ព័ន្ធ។ ការអប់រំបរិយាប័ន្នមានន័យថា ជាការធានាថាឧបសគ្គក្នុងការចូលរួម និងការរៀនសូត្រត្រូវបានដោះស្រាយ ហើយវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សាគឺអាចចូលទៅដល់ និងសមស្របសម្រាប់សិស្សពិការ។ បុគ្គលទាំងអស់ត្រូវបានស្វាគមន៍ និងគាំទ្រ ដើម្បីធ្វើឱ្យមានវឌ្ឍនភាព ហើយម្យ៉ាងវិញទៀត តម្រូវការបុគ្គលរបស់ពួកគេត្រូវបានដោះស្រាយ។ (INEE)

**អ្នករៀនសូត្រ** មនុស្សទាំងអស់រួមទាំងកុមារ យុវជន និងមនុស្សពេញវ័យដែលចូលរួមក្នុងកម្មវិធីអប់រំ គឺជាអ្នករៀនសូត្រ ដោយរួមបញ្ចូលទាំងនិស្សិត សិស្សានុសិស្សក្នុងកម្មវិធីអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ អ្នកទទួលបានការអប់រំក្រៅប្រព័ន្ធ (ថ្នាក់អក្ខរកម្ម បំណិនជីវិតក្នុងសហគមន៍) និងអ្នករៀនបន្តពីមិត្តភក្តិជាដើម។ (INEE)

**ការរៀនសូត្រ** គឺជាការទទួលបាន ឬការកែប្រែនៃព័ត៌មាន ចំណេះដឹង ការយល់ដឹង អាកប្បកិរិយា តម្លៃ ជំនាញ សមត្ថភាព ឬឥរិយាបទ តាមរយៈបទពិសោធន៍ ការអនុវត្ត ការសិក្សា ឬការបង្រៀន។ (INEE)

**លក្ខខណ្ឌនៃការសិក្សា** គឺជាកត្តាទាំងឡាយដែលហួសពីឥទ្ធិពលនៃការច្នៃប្រឌិតដែលមានឥទ្ធិពលលើផលប៉ះពាល់នៃវិធីបង្រៀន។ លក្ខខណ្ឌអាចរួមបញ្ចូលលក្ខណៈនៃអ្វីដែលកំពុងរៀន (មាតិកា) អ្នកសិក្សា បរិយាកាសរៀនសូត្រ និងឧបសគ្គនៃការអភិវឌ្ឍការបង្រៀន ឧទាហរណ៍ ពេលវេលា និងថវិកាជាដើម។ (INEE)

**ភាពលំបាកនៃការរៀនសូត្រ** ត្រូវបានបកស្រាយដោយមានន័យថា មានអ្វីមួយធ្វើឱ្យអន់ថយផ្នែកបញ្ញា (ខ្សោយផ្នែកណាមួយនៃសរីរៈខួរក្បាល)។ ទោះជាយ៉ាងនេះក្ដី មិនមែនមនុស្សគ្រប់រូបដែលជួបប្រទះការលំបាកក្នុងការរៀនមានបញ្ហាបញ្ញា ខួរក្បាល ឬពិការរាងកាយនោះទេ។ ស្ថិតនៅក្នុងចំណុចណាមួយនៃជីវិតរបស់ពួកគេ មនុស្សគ្រប់គ្នាអាចមានបទពិសោធន៍រយៈពេលយូរ ឬរយៈពេលខ្លីនៃការលំបាកក្នុងការរៀនសូត្រ។ (INEE)

**បរិយាកាសនៃការសិក្សា** សំដៅទៅដល់ទីតាំងរូបវន្ត បរិបទ និងវប្បធម៌ផ្សេងៗដែលសិស្សានុសិស្សរៀនដូចជា បរិយាកាសខាងក្រៅគេហដ្ឋាន មណ្ឌលថែទាំកុមារ សាលាមត្តេយ្យ រចនាសម្ព័ន្ធសំណង់បណ្ដោះអាសន្ន និងសាលារៀន។ ដើម្បីឱ្យបរិកាយាកាសនៃការសិក្សារបស់សិស្សមានដំណើរការទៅបានដោយរលូន គ្រូអាចរៀបចំទីកន្លែងបង្រៀន ឬថ្នាក់រៀន ឱ្យមានលក្ខណៈអំណោយផលដល់ការរៀនសូត្រ។ ឧទាហរណ៍ដូចជា ការរៀបចំថ្នាក់រៀនឱ្យពាក់ព័ន្ធទៅនឹងប្រព័ន្ធអេកូធម្មជាតិ រៀបចំតុជាក្រុមដោយវិធីជាក់លាក់ តុបតែងជញ្ជាំងដោយប្រើសម្ភារៈសិក្សា ឬប្រើបច្ចេកវិទ្យាសំឡេង មើលឃើញរូបភាពជាលក្ខណៈឌីជីថល។ គោលនយោបាយសាលារៀន រចនាសម្ព័ន្ធអភិបាលកិច្ច និងលក្ខណៈពិសេសផ្សេងទៀត អាចត្រូវបានចាត់ទុកថាជាធាតុផ្សំនៃបរិយាកាសសិក្សា។

**វត្ថុបំណងនៃការរៀនសូត្រ** បានបង្ហាញយ៉ាងច្បាស់អំពីសមិទ្ធផលដែលរំពឹងទុករបស់អ្នកសិក្សានៅចុងបញ្ចប់នៃវគ្គសិក្សា ឬកម្មវិធី ដែលអាចរួមបញ្ចូល ចំណេះដឹង ឥរិយាបថ និងជំនាញ។ (INEE)

**លទ្ធផលសិក្សា** សំណុំចំណេះដឹង ជំនាញ និង/ឬសមត្ថភាពដែលបុគ្គលម្នាក់ៗទទួលបាន និង/ឬអាចពន្យល់បង្ហាញបានច្បាស់ បន្ទាប់ពីបញ្ចប់ដំណើរការសិក្សាជាផ្លូវការ ឬមិនផ្លូវការ ត្រូវបានបញ្ចប់។ (Cedefop)

**ការរៀនសូត្រពេញមួយជីវិត** គ្រប់សកម្មភាពរៀនសូត្រទាំងអស់ដែលត្រូវបានអនុវត្តពេញមួយជីវិត។ ការណ៍នេះ នាំឱ្យមានការលើកកម្ពស់ចំណេះដឹង របៀបធ្វើ ជំនាញវិជ្ជាជីវៈ សមត្ថភាព និង/ឬគុណសម្បត្តិសម្រាប់ហេតុផលផ្ទាល់ខ្លួន សង្គម និង/ឬវិជ្ជាជីវៈ។ (Cedefop)

**ការអប់រំក្រៅប្រព័ន្ធ** សកម្មភាពនៃការអប់រំមិនផ្លូវការ ឬការអប់រំក្រៅប្រព័ន្ធ កើតឡើងទាំងក្នុង និងក្រៅគ្រឹះស្ថានអប់រំ ដើម្បីបំពេញបំណងដល់មនុស្សគ្រប់វ័យ។ អ្នកទទួលបានការអប់រំក្រៅព្រព័ន្ធនាំ មិនមែនសុទ្ធតែត្រូវទទួលបានវិញ្ញាបនបត្របញ្ជាក់នោះទេ។ កម្មវិធីផ្សេងៗនៃការអប់រំក្រៅផ្លូវការមានលក្ខណៈខុសគ្នា ភាពបត់បែន និងសមត្ថភាពក្នុងការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងតម្រូវការអប់រំថ្មីរបស់កុមារ ឬមនុស្សពេញវ័យ។ ជារឿយៗ កម្មវិធីទាំងនោះត្រូវបានរចនាឡើងសម្រាប់ក្រុមអ្នកសិក្សាជាក់លាក់ដូចជា អ្នកដែលមានអាយុចាស់ពេក អ្នកដែលមិនបានចូលរៀនសាលាផ្លូវការ ឬមនុស្សពេញវ័យ។ កម្មវិធីសិក្សាអាចផ្អែកលើការអប់រំផ្លូវការ ឬវិធីថ្មីៗ។ ការអប់រំក្រៅប្រព័ន្ធអាចនាំឱ្យមានការចូលរួមក្នុងកម្មវិធីអប់រំជាផ្លូវការយឺត។ ជួនកាល កម្មវិធីនេះត្រូវបានហៅថា «ឱកាសនៃការអប់រំលើកទី២»។

**ការរៀនសូត្រដោយមានការចូលរួម** គឺជាវិធីសាស្ត្រក្នុងការបង្រៀន និងរៀនដែលផ្តោតលើអ្នកសិក្សា។ វាលើកទឹកចិត្តដល់ការរៀនសូត្រដោយ ការធ្វើ ប្រើក្រុមតូចៗ សម្ភារៈជាក់លាក់ សំណួរបើកចំហ និងការបង្រៀនពីមិត្តភក្តិ។ ជាឧទាហរណ៍ អ្នកសិក្សាប្រើសកម្មភាពអនុវត្តជាក់ស្តែងដើម្បីយល់អំពីបញ្ញត្តិគណិតវិទ្យា ឬធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហា ហើយសួរ និងឆ្លើយសំណួរ។ ការរៀនសូត្រដោយការចូលរួម គឺផ្ទុយគ្នាជាមួយវិធីសាស្ត្រដែលផ្តោតលើគ្រូបង្រៀនដែលត្រូវបានកំណត់ដោយអ្នកសិក្សា ដែលអង្គុយនៅតុដោយឆ្លើយសំណួរបិទ ហើយចម្លងពីក្តារខៀន។ ការរៀនសូត្រដោយការចូលរួមក៏អាចត្រូវបានប្រើជាមួយគ្រូ និងការអប់រំអាជ្ញាធរផងដែរ ដើម្បីជួយពួកគេវិភាគពីតម្រូវការរបស់ពួកគេ កំណត់ដំណោះស្រាយ និងអភិវឌ្ឍ និងអនុវត្តផែនការសកម្មភាព។ នៅក្នុងបរិបទទាំងនេះ វាអាចរួមបញ្ចូលទាំងការចូលរួមពីសហគមន៍ ការសម្របសម្រួល និងការវិភាគ។ (INEE)

**គរុកោសល្យ** សំដៅទៅលើយុទ្ធសាស្ត្រ ឬរបៀបនៃការបង្រៀន និងដំណើរការរៀនសូត្រពោលគឺជាការសិក្សាដើម្បីក្លាយខ្លួនជាគ្រូបង្រៀនពេញលក្ខណៈ។ គរុកោសល្យ គឺជាអ្វីដែលអាចដែលបង្ហាញពីទ្រឹស្តីអប់រំ គុណតម្លៃ ភស្តុតាងផ្សេងៗ ប្រើប្រាស់ក្នុងពេលបង្រៀន។ ឧទាហរណ៍គរុកោសល្យដែលងាយស្រួលសម្រាប់កុមារ គឺការប្រើកម្មវិធីសិក្សាផ្អែកលើរូបភាព ឬអ្វីដែលអាចមើលឃើញ ស្តាប់ឮផ្ទាល់។ល។ ដើម្បីឱ្យពួកគេចាប់ផ្តើមទទួលបានចំណេះដឹងជាមូលដ្ឋានរបស់ខ្លួនមុននឹងឈានដល់ដំណាក់កាលមួយទៀត។ (INEE)

**ការគាំទ្រខាងចិត្តសាស្ត្រសង្គម** សំដៅលើដំណើរការ និងសកម្មភាពដែលលើកកម្ពស់សុខមាលភាពរួមគ្នារបស់មនុស្សនៅក្នុងសង្គមរបស់ពួកគេ។ វារួមបញ្ចូលទាំងការគាំទ្រដែលផ្តល់ដោយក្រុមគ្រួសារ និងមិត្តភក្តិ។ ឧទាហរណ៍នៃការគាំទ្រពីគ្រួសារ និងសហគមន៍រួមមាន កិច្ចខិតខំប្រឹង

ប្រែងដើម្បីបង្រួបបង្រួមកុមារដែលបែកចេញពីគ្នា និងការរៀបចំការអប់រំនៅក្នុងស្ថានភាពអាសន្ន។ (INEE)

**គុណវុឌ្ឍិ (Qualification)** គុណវុឌ្ឍិជាផ្លូវការ គឺជាលទ្ធផលសម្រេចបានជាផ្លូវការ (មានដូចជា វិញ្ញាបនបត្រ សញ្ញាបត្រ ឬឈ្មោះវិញ្ញាបនបត្រផ្សេងទៀត) តាមរយៈការវាយតម្លៃ និងការផ្ទៀងផ្ទាត់ ដែលធ្វើឡើងនៅពេលដែលបុគ្គលមានសមត្ថកិច្ចចង់ចេញបទដ្ឋាន ឬកម្មសិទ្ធិចាំបាច់ណាមួយអំពី លទ្ធផលនៃការសិក្សារបស់បុគ្គលណាម្នាក់ក្នុងការឈានចូលទៅក្នុងវិស័យអាជីព។ (Cedefop)

**គុណភាពអប់រំ** គឺជាការដែលមនុស្សទាំងឡាយមានលទ្ធភាពចំណាយ និងទទួលបានការ អប់រំ ព្រមទាំងមិនមានការប្រកាន់ភេទ ហើយអាចឆ្លើយតបទៅនឹងតម្រូវការនៃមជ្ឈដ្ឋានផ្សេងៗគ្នា បាន។ គុណភាពអប់រំ រួមមាន៖ (១) បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងលក្ខណៈបរិយាបន្ន (២) គ្រូបង្រៀនដែលមានសមត្ថភាព និងទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវ ដោយមានចំណេះដឹង លើមុខវិជ្ជា ដែលខ្លួនបង្រៀន និងគរុកោសល្យ។ (៣) កម្មវិធីសិក្សាមានលក្ខណៈសមស្របទៅនឹង បរិបទជាក់លាក់ដែលងាយយល់ និងទទួល យកបាននៅក្នុងវប្បធម៌ (៤) សម្ភារសិក្សាពាក់ព័ន្ធមាន គ្រប់គ្រាន់សម្រាប់បង្រៀន និងរៀន (៥) វិធីសាស្ត្របង្រៀន និងដំណើរការរៀន មានការចូលរួមពី សិស្សដោយមានការគោរពពីភាពថ្លៃថ្នូរបស់គ្នាទៅវិញទៅមក (៦) ថ្នាក់រៀនមានទំហំសមរម្យ និង មានចំនួនផលធៀបសិស្ស ជាមួយគ្រូសមាមាត្រគ្នា និង (៧) ការផ្ដោតសំខាន់ទៅលើភាពរីករាយ ការលេង លេងកីឡា និងសកម្មភាពរៀនសប្បាយៗបន្ថែមពីលើការរៀនអក្សរសិល្ប៍ លេខនព្វន្ត និងបំណិនជីវិត។ (INEE)

**ជំនាញ** គឺជាលទ្ធភាពក្នុងការអនុវត្តចំណេះដឹង និងដឹងពីរបៀបក្នុងការបំពេញភារកិច្ច និង ដោះស្រាយបញ្ហា។ នៅក្នុងបរិបទ ក្របខណ្ឌគុណវុឌ្ឍិនៃប្រទេសប៉ែកអឺរ៉ុប ជំនាញបកប្រែថា បញ្ញា (ដោយមានការប្រើប្រាស់ភាពសមហេតុផល វិចារណញ្ញាណ និងការគិតដែលមានភាពច្នៃប្រឌិត) ឬបទពិសោធន៍ (ដោយមានការធ្វើដោយស្ទាត់ជំនាញ និងការប្រើប្រាស់វិធីសាស្ត្រ សម្ភារៈ ឧបករណ៍ និងរបស់របរផ្សេងៗ)។ (Cedefop)

**តម្រូវការការអប់រំពិសេស** កុមារត្រូវការការអប់រំពិសេស ប្រសិនបើពួកគេមានពិការភាព មាន ការលំបាកក្នុងការរៀន ឬស្ថិតក្នុងស្ថានភាពដែលត្រូវការការអប់រំពិសេសសម្រាប់ពួកគេ។ (INEE)

**ការអប់រំសម្រាប់តម្រូវការពិសេស** ត្រូវបានរៀបចំឡើងដើម្បីជួយសម្រួលដល់ការរៀនសូត្រ របស់បុគ្គលដែលត្រូវការជំនួយបន្ថែមសម្រាប់ហេតុផលផ្សេងៗ និង/ឬវិធីសាស្ត្រគរុកោសល្យដែល មានលក្ខណៈប្រែប្រួល ដើម្បីចូលរួមបំពេញតាមគោលបំណងនៃការរៀននៅក្នុងកម្មវិធីអប់រំ។ សិស្សដែលត្រូវការការអប់រំពិសេស អាចអនុវត្តតាមកម្មវិធីសិក្សាដែលមានលក្ខណៈស្រដៀងគ្នា ឬ តម្រូវការប្រែប្រួល ហើយតម្រូវការរបស់ពួកគេត្រូវបានគាំទ្រតាមរយៈយុទ្ធសាស្ត្របង្រៀនជាក់លាក់ និង/ឬធនធានជាក់លាក់ដូចជា បុគ្គលិកហ្វឹកហាត់ សំភារៈ ឬកន្លែងពិសេសៗជាដើម។ កម្មវិធីទាំង នេះ អាចត្រូវបានផ្ដល់ជូនសម្រាប់សិស្សម្នាក់ៗនៅក្នុងកម្មវិធីអប់រំដែលមានស្រាប់រួចហើយ ឬត្រូវ បានផ្ដល់ជូនជាថ្នាក់ដាច់ដោយឡែកពីគ្នានៅក្នុងស្ថាប័នអប់រំដែលមានលក្ខណៈដូចគ្នា ឬដាច់ដោយ ឡែកពីគ្នា។ (INEE)

**ការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល** គឺជាពាក្យមានន័យដូចចំពោះយុទ្ធសាស្ត្រអប់រំជាច្រើនដែលត្រូវបានគេស្គាល់ជាទូទៅថា ការរៀនខ្លួនឯង។ ការសម្រេចចិត្តខាងផ្នែកអប់រំ ត្រូវបានធ្វើឡើងដោយពិចារណាអំពីអ្វីដែលសិស្សត្រូវដឹង ឬវិធីណាដែលមានប្រសិទ្ធភាពបំផុតក្នុងការសម្របសម្រួលការរៀនសូត្រសម្រាប់សិស្សម្នាក់ៗ ឬក្រុមសិស្សនិស្សិតណាមួយ។ ជាធម្មតា ការសិក្សារៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌល សំដៅលើជម្រើសដែលបានស្នើឡើងទៅនឹងវិធីសាស្ត្រដែលមានស្រាប់ ឬច្រើនជាងវិធីសាស្ត្រតាមបែបប្រពៃណី ដើម្បីផ្តល់ការបង្រៀនដែលអ្នកអប់រំមួយចំនួនចាត់ទុកថាជាការផ្តោតលើគ្រូ ឬសាលារៀន។ *(INEE)*

ប្រភពនៃទស្សនាទាន

INEE

http://toolkit.ineesite.org/term-bank/en

Cedefop

http://www.cedefop.europa.eu/en/publications-and-resources/publications/4126

IAEVG http://iaevg.net/?page_id=70&menuid=49&smenuid=5&tpage=1&t1=275&t2=289&t3=290&t4=291&t5=Lexique&t6=Glossary&t7=Glosario&t8=Glossar&t9=--

## ៤. ក្របខណ្ឌកម្មវិធីសិក្សា និងលទ្ធផលរំពឹងទុក

ទាញយកក្របខណ្ឌកម្មវិធីសិក្សា ២០១៥ នៅទីនេះ?

ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ចំណេះទូទៅ និងអប់រំបច្ចេកទេស (ក្រសួងអប់រំយុវជន និងកីឡា ២០១៥)៖

| លទ្ធផលរំពឹងទុក | មធ្យមសិក្សាទុតិយភូមិ |
|---|---|
| **វិជ្ជាសម្បទា** | មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែក អក្សរសាស្ត្រខ្មែរ និងវិទ្យាសាស្ត្រសង្គម គណិតវិទ្យា សុខភាពកាយ សម្បទា និងសីលធម៌ |
| | ស្ទាបនាចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT) និងភាសាបរទេស។ |
| **បំណិនសម្បទា** | ស្ទាបនាជំនាញមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)។ |
| | ស្ទាបនាជំនាញមូលដ្ឋានគ្រឹះរឹងមាំផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ។ |
| | មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT)។ |
| | មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហាទាំងក្នុងការសិក្សា និងក្នុងសង្គម។ |
| | មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយទាំងក្នុងការសិក្សា និងក្នុងសង្គម។ |
| | មានបំណិនក្នុងការបង្ការ និងថែទាំសុខភាពបឋម។ |
| | បង្កើត និងប្រើប្រាស់ចំណេះដឹង មានជំនាញ និងសីលធម៌ក្នុងការការពារអំពើល្អ។ |
| **ចរិយាសម្បទា** | ស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត។ |
| | ស្គាល់ និងឱ្យតម្លៃសណ្តានចិត្តមេត្តា និងករុណាចំពោះគ្រួសារ មិត្តភក្តិនិងអ្នកដទៃ។ |
| | អភិរក្ស និងអភិវឌ្ឍវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់សិល្បៈជាតិ តំបន់ និងអន្តរជាតិ។ |
| | ស្រឡាញ់ និងផ្តល់តម្លៃដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ |
| | ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ។ |
| | មានទម្លាប់ និងអនុវត្តការរស់នៅប្រកបដោយសុខភាព តាមរយៈការធ្វើពលកម្ម និងហាត់កីឡា។ |
| | ទទួលខុសត្រូវចំពោះទង្វើរបស់ឯង និងរបស់ក្រុម ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។ |

# ៥. ការប្រឹក្សាទល់មុខ



គ្រូគង្វាលព្រំដែន: អែខឃី ម៉ាន់ស្រ្តឹម
កក្កដា ២០១៨

## ក. ការស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន




ការផ្តល់ប្រឹក្សាទល់មុខ គឺជាការលើកយកបញ្ហារបស់សិស្ស ស្វែងយល់ និងពិភាក្សារិះរកដំណោះស្រាយ។ ក្នុងនាមជាគ្រូប្រឹក្សាយោបល់អ្នកត្រូវកសាងទំនាក់ទំនង ប្រកបដោយ ទំនុកចិត្ត និងភាពស្និទ្ធស្នាល ដើម្បីទទួលបានព័ត៌មានជាក់លាក់ពីសិស្ស ធ្វើជាមូលដ្ឋានក្នុងការផ្តល់ប្រឹក្សា ស្ថិតក្នុងស្មារតីវិជ្ជាជីវៈ។ អ្នកត្រូវផ្តល់ពេលវេលាសមស្របដល់សិស្ស ដើម្បីឱ្យពួកគេអាចនិយាយនូវអ្វីដែលជាបញ្ហាប្រឈមផ្ទាល់ខ្លួន ហើយអ្នកអាច ប្រើសំណួរបំផុសនានា នៅអំឡុងពេលផ្តល់ប្រឹក្សាទល់មុខជាមួយសិស្សតាមស្ថានភាពជាក់ស្តែង។ ការងារសំខាន់របស់អ្នក គឺត្រូវស្តាប់ដោយយកចិត្តទុកដាក់នូវការពណ៌នារបស់សិស្ស។ គ្រូប្រឹក្សាក៏ត្រូវយល់ដឹងពីសាវតារបស់ខ្លួន ថាតើ គុណតម្លៃ ការគិត ជំនឿ ឧត្តមគតិ មានផលប៉ះពាល់ដល់ស្ថានភាពរបស់សិស្សដែរឬទេ។

ក្នុងនាមគ្រូប្រឹក្សាអាជីព អ្នកគួរជួយ និងផ្តល់ការគាំទ្រដល់សិស្ស ក្នុងការពន្យល់មធ្យោបាយនៃការគិត អារម្មណ៍ គុណតម្លៃ ឧត្តមគតិ និងសេចក្តីប្រាថ្នា។ បន្ថែមលើនេះ គ្រូប្រឹក្សាអាចជួយសិស្សឱ្យស្វែងយល់ពីខ្លួនឯង ឆ្លុះបញ្ចាំងពីខ្សែជីវិត ជំនាញ ភាពខ្លាំង ក្តីសុបិន គោលដៅ និងបញ្ហាប្រឈមរបស់គេ ដើម្បីជួយឱ្យសិស្សស្វែងរកមាគ៌ានៃជីវិតដ៏សម្បូរបែប។

## ខ. តើសិស្សកំពុងទៅទីណា ហើយអ្វីជាទិសដៅរបស់ពួកគេ?




តើសិស្សចង់សម្រេចគោលដៅអ្វី?

គ្រូប្រឹក្សាអាជីព ត្រូវជួយសិស្សឱ្យចេះរៀបចំគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ ហើយគោលដៅនោះ គួរតែជាអ្វីដែលអាចវាស់វែងបាន អាចទទួលយកបាន។ វាជាត្រីវិស័យជួយដល់សិស្ស ក្នុងការដឹកនាំជីវិតសិក្សារបស់ពួកគេទទួលបានជោគជ័យ។ នៅពេលដែលសិស្សដឹងថា ពួកគេត្រូវធ្វើដំណើរទៅណាហើយ ពួកគេនឹងប្រើថាមពលរបស់គេដើម្បីសម្រេចគោលដៅនោះ។

## គ. តើអ្នកមានជម្រើសបែបណាខ្លះ?



គ្រូប្រឹក្សា គួរជួយសិស្សឱ្យមើលឃើញនូវភាពដែលនឹងកើតឡើង និងស្វែងរកជម្រើសឱ្យបានច្រើន ទៅតាមលទ្ធភាពដែលអាចធ្វើបាន។ តាមរយៈការសួរសំណួរបើក និងសំណួរបញ្ជាក់បន្ថែម គ្រូប្រឹក្សានឹងអាចជួយសិស្សឱ្យមើលឃើញនូវស្ថានការថ្មី និងខុសប្លែកគ្នា និងក្នុងពេលជាមួយគ្នានេះជួយសិស្សឱ្យស្វែងរកជម្រើសបន្ថែម។ ក្នុងនាមជាគ្រូប្រឹក្សាអាជីព អ្នកអាចផ្តល់ដំបូន្មានអំពីគំនិតខុសប្លែកគ្នា ប៉ុន្តែសិស្សគួរតែជាអ្នកធ្វើការសម្រេចចិត្តផ្អែកលើគំនិតដែលគេបានជ្រើសយក។ សិស្សគួរធ្វើការប្រៀបធៀបជម្រើស ដែលនឹងកើតមាននាពេលខាងមុខ ហើយការពិភាក្សាជាក្រុមដែលមានសមាជិកពី ៣ ទៅ ៤ នាក់ ក៏អាចជួយសិស្សឱ្យស្វែងរកលទ្ធភាព និងជម្រើសបន្ថែមទៀតបានដែរ។

## ឃ. តើត្រូវធ្វើសកម្មភាពអ្វីខ្លះ?

### តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីឆាប់បានសម្រេចគោលដៅ?

### ចូរផ្តល់ការគាំទ្រដល់សកម្មភាព!




ការប្រឹក្សាទល់មុខ គួរតែផ្តល់ឱ្យសិស្សនូវលទ្ធផលអ្វីមួយ។ យើងកំពុងស្វែងរកការផ្លាស់ប្តូរដល់សិស្ស វាអាចជារបៀបនៃការមើលឃើញខ្លួនឯង ឬការគិតអ្វីមួយ ដើម្បីផ្លាស់ប្តូរទម្លាប់ ឬឥរិយាបថ។ យើងអាចផ្តល់ការគាំទ្រ ដើម្បីឱ្យសិស្សជឿជាក់ខ្លួនឯង ស្វែងរកព័ត៌មាន ក្រឡេកមើលខ្សែជីវិតរបស់គេ តាមរយៈទស្សនៈ និងជម្រើសផ្សេងៗ។ យើងអាចជួយពួកគេឱ្យស្វែងយល់នូវឱកាស ហើយធ្វើការជ្រើសរើស ដើម្បីធ្វើឱ្យស្ថានភាពរបស់ពួកគេកាន់តែប្រសើរឡើង ធ្វើឱ្យសិស្សសកម្ម និងមានទំនួលខុសត្រូវលើជីវិតរបស់គេ។

ក្នុងចំណោមជម្រើស និងគំនិតទាំងអស់ សិស្សនឹងធ្វើការសម្រេចចិត្តលើសកម្មភាពដែលគេត្រូវធ្វើ ហើយទទួលខុសត្រូវលើសកម្មភាពទាំងនោះ។ គ្រូប្រឹក្សាអាជីពអាចជួយឱ្យសិស្សរកឃើញ បញ្ជាក់ពីជម្រើស និងផ្តល់ការគាំទ្រក្នុងការស្វែងរកដំណោះស្រាយ ដែលអាចទៅរួច គួរឱ្យទុកចិត្ត និងទទួលយកបាន។ សកម្មភាពរបស់សិស្ស នឹងផ្តល់លទ្ធផលថ្មីដែលអាចឆាប់សម្រេចគោលដៅ។ គ្រប់ជំហានតូចៗគឺសុទ្ធតែមានតម្លៃ ចូរផ្តល់ការគាំទ្រដល់សកម្មភាពរបស់សិស្ស។

## ង. ចូរគាំទ្រសិស្សដោយការតាមដាន




គ្រូប្រឹក្សាអាជីព អាចគាំទ្រសិស្សដោយការតាមដានសកម្មភាពរបស់ពួកគេ។ តើប្អូនសុខសប្បាយជាទេ? តើគ្រូអាចជួយអ្វីខ្លះដល់ប្អូន? តើប្អូនចង់សួរអ្វីខ្លះ?

ជារឿងចាំបាច់សម្រាប់គ្រូប្រឹក្សា ក្នុងការកាត់ត្រាព័ត៌មានរបស់សិស្ស ដើម្បីឱ្យសិស្សពិនិត្យមើលថាតើគេបានធ្វើការសម្រេចចិត្តបែបណាចំពោះសកម្មភាព។

### តើអ្នកផ្តល់ព័ត៌មាន និងផ្សព្វផ្សាយការងារគ្រូប្រឹក្សា និងការប្រឹក្សាទល់មុខដោយរបៀបណា? តើអ្វីជាពាក្យស្លោករបស់អ្នក?

ដើម្បីទទួលបានភាពជោគជ័យលើការងារ គ្រូប្រឹក្សាអាជីពត្រូវមានការគាំទ្រពីនាយកសាលា លោកគ្រូអ្នកគ្រូ និងអាណាព្យាបាល។ ការផ្តល់ប្រឹក្សាគឺ មិនមែនគ្រាន់តែនិយាយអំពីបញ្ហាប្រឈមរបស់សិស្សនោះទេ ហើយក៏មិនមែនមានន័យថា គ្រូប្រឹក្សាត្រូវតែផ្តល់សេវានេះដល់សិស្សគ្រប់រូបដែរ តែវាជាសេវាដែលសិស្សអាចឆ្លុះបញ្ចាំងអំពីជីវិត និងអនាគតរបស់ពួកគេបាន។ គោលដៅដ៏ចម្បងរបស់មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា គឺជាការគាំទ្រ និងជួយសិស្សឱ្យស្វែងរកផ្លូវដ៏ប្រសើរបំផុតសម្រាប់ជីវិតពួកគេ។ ទោះជាអ្នកគិតថា សិស្សមិនមានបញ្ហាប្រឈមក៏ដោយ ក៏ពួកគេមានសំណួរ និងបញ្ហាប្រឈមដែរ។

ការគាំទ្រ គឺមានន័យថា សិស្សត្រូវតែយល់នូវគុណតម្លៃនៃការងារដែលគ្រូប្រឹក្សាកំពុងធ្វើ។ សិស្សត្រូវតែយល់នូវអត្ថប្រយោជន៍សម្រាប់សាលារៀន ជីវិតប្រចាំថ្ងៃរបស់ពួកគេ និងមុខវិជ្ជាផ្សេងៗ។ សិស្សត្រូវតែដឹងអំពីរឿងទាំងអស់នេះ ព្រមទាំងការងារដែលគ្រូប្រឹក្សាធ្វើនៅសាលារៀន។ តើមានបន្ទប់ពិសេសសម្រាប់ការប្រឹក្សាទល់មុខដែរឬទេ? តើគ្រូប្រឹក្សារៀបចំកាលវិភាគ និងផ្តោតការយកចិត្តទុកដាក់លើថ្នាក់ទីប៉ុន្មាន? តើការប្រឹក្សាទល់មុខប្រើរយៈពេលប៉ុន្មាន? គ្រូប្រឹក្សាអាជីពត្រូវចងចាំផងដែរថា បើនាយកមិនគាំទ្រទេ ពួកគេអាចទទួលការគាំទ្រពីគ្រូប្រឹក្សាអាជីពដូចគ្នា ចំពោះចំណាប់អារម្មណ៍សិស្ស និងបទពិសោធន៍ដែលបានពីការប្រឹក្សាទល់មុខ។

សិស្សត្រូវទទួលព័ត៌មានអំពីការប្រឹក្សាទល់មុខ តើវាមានន័យដូចម្តេច? នរណាទទួលសេវានេះ? តើយើងពិភាក្សាអំពីអ្វី? តើប្រើរយៈពេលប៉ុន្មាន? តើត្រូវធ្វើជាលក្ខណៈបុគ្គល ឬជាក្រុមតូច? រឿងដែលសំខាន់ត្រូវប្រាប់សិស្សអំពីការរក្សាព័ត៌មានសម្ងាត់សម្រាប់ពួកគេ។ សិស្សដែលបានទទួលសេវាប្រឹក្សាទល់មុខហើយ អាចដើរតួជាអ្នកផ្សព្វផ្សាយ និងចែករំលែកចំណាប់អារម្មណ៍ និងការឆ្លុះបញ្ចាំង។

តើធ្វើដូចម្តេច ដើម្បីឱ្យសេវាប្រឹក្សាទល់មុខ មានការចាប់អារម្មណ៍ ហើយមានសិស្សមកទទួល និងផ្តល់ការគាំទ្រដល់សេវានេះ? តើពាក្យស្លោកបែបណាដែលគ្រូប្រឹក្សានឹងប្រើនៅក្នុងសាលារៀន




### ទីកន្លែង

គ្រូប្រឹក្សាអាជីពត្រូវការកន្លែងសម្រាប់ការផ្តល់ប្រឹក្សាទល់មុខ។ ទីកន្លែងអាចជាកៅអីវែង ឬកន្លែងដែលអាចរក្សាភាពសម្ងាត់ដល់សិស្សបាន។ ជួនកាលស្ថានភាពរបស់សិស្ស និងសំណួររបស់គ្រូអាចធ្វើឱ្យសិស្សមានអារម្មណ៍មិនស្រួល និងអាចធ្វើឱ្យសិស្សយំ។ សូម

ចងចាំថា នេះជាការពិភាក្សារវាងគ្រូប្រឹក្សា និងសិស្ស។ បើមិនចាំបាច់ទេ មិនត្រូវឱ្យគ្រូដទៃចូលរួមក្នុងការពិភាក្សានេះឡើយ។

## កាលវិភាគ

គួរតែមានផែនការ និងកាលវិភាគសម្រាប់ការផ្តល់សេវាប្រឹក្សាទល់មុខ។ បើសិនអ្នកជាគ្រូប្រឹក្សាពេញម៉ោង អ្នកត្រូវនៅប្រចាំការ ៤ ម៉ោងក្នុង ១ ថ្ងៃ។ សម្រាប់គ្រូប្រឹក្សាក្រៅម៉ោង អ្នកត្រូវនៅប្រចាំការ ២ ម៉ោងក្នុង ១ ថ្ងៃ។ គ្រូប្រឹក្សាអាជីពអាចរៀបចំផែនការសម្រាប់សេវានេះ ទៅតាមចំនួនសិស្ស និងស្ថានភាពរបស់ពួកគេ។ តើអ្នកអាចជួបសិស្សទាំងអស់គ្នា ក្នុងអំឡុងពេល ១ ឆ្នាំសិក្សា ឬអ្នកផ្តោតលើថ្នាក់មួយចំនួន? តើអ្នកនឹងជួបសិស្សជាក្រុមតូចៗ ឬជាលក្ខណៈបុគ្គល? តើអ្នកនឹងផ្តល់សេវានេះនៅទីណា? តើអ្នកនឹងផ្តល់ពេលវេលាប៉ុន្មានដល់សិស្ស និងណាត់សិស្សមកទទួលសេវានេះដោយរបៀបណា?

| កាលបរិច្ឆេទ | ពេលវេលា | ឈ្មោះ |
|---|---|---|
| 11.7 | 8.00 am | អែងឃី |
| | 8.30 am | វណ្ណឌី |
| | 9.00 am | សុភា |
| | 9.30 am | អែងឃី វណ្ណឌី សុភា |

សូមប្រាប់នាយក និងគ្រូផ្សេងទៀតអំពីផែនការ និងកាលវិភាគរបស់អ្នក ដើម្បីឱ្យគ្រូទាំងនោះយល់ថា សិស្សនឹងទទួលបានមេរៀននៅពេលពួកគេមកជួបជាមួយអ្នក។ តើគ្រូប្រឹក្សាអាជីពអាចចែករំលែក និងគាំទ្រក្រុមការងារដូចម្តេច?

## គុណតម្លៃ




នៅពេលផ្តល់ព័ត៌មាន និងផ្តល់ការប្រឹក្សាទល់មុខ គ្រូប្រឹក្សា គប្បីចងចាំថានេះជាគុណតម្លៃសម្រាប់សិស្ស សាលារៀន គ្រូមុខវិជ្ជា និងសម្រាប់អ្នកជាគ្រូប្រឹក្សាដែរ។ សូមយកចិត្តទុកដាក់ចំពោះពេលវេលា ដែលអ្នកបានចំណាយជាមួយសិស្ស ដោយផ្តោតអារម្មណ៍លើរឿងវិជ្ជមានក្នុងជីវិតរបស់សិស្ស (៧០% គឺល្អ) ឱ្យបានច្រើនជាងបញ្ហាប្រឈម (៣០% គឺមិនល្អ)។ ចូរប្រើពាក្យ *បញ្ហាប្រឈម* ជំនួសពាក្យ *បញ្ហា*។ ចូរគិតថា កំហុស ឬសកម្មភាព ជាជម្រើសល្អ ដែលយើងអាចរៀនសូត្រពីវាបាន។

## តួនាទី

អ្នកផ្តល់ប្រឹក្សា ក៏មានតួនាទីជាគ្រូបង្រៀនដែរ។ ជំនាញដ៏សំខាន់របស់អ្នកផ្តល់ប្រឹក្សា គឺផ្តោតលើបច្ចុប្បន្នកាល និងការស្តាប់ដោយប្រុងប្រយ័ត្ន។ ជួបជាមួយសិស្ស ដើម្បីឱ្យដឹងថា ពួកគេដើរដល់ណាហើយក្នុងជីវិត។ បង្កើតសំណួរឱ្យបានច្រើន ហើយផ្តល់ដំបូន្មាន។ កសាងទំនាក់ទំនងដែលអាចជួយឱ្យសិស្សមានអារម្មណ៍ថាអ្វីៗគឺដើម្បីជីវិតគេ។

ចូរស្តាប់សាច់រឿងដែលគេនិយាយប្រាប់អ្នក និងរំលឹកពួកគេដល់ការប្រាស្រ័យទាក់ទងដោយមិនប្រើភាសានិយាយ អត្ថន័យបង្កប់ និងភាសាកាយវិការ។ គ្រូប្រឹក្សាគួរគិតអំពីកន្លែងដែលត្រូវអង្គុយ និងប្រើភ្នែកក្នុងការទាក់ទងជាមួយសិស្ស។ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ចូរផ្តោតលើគោលដៅ ហើយបើកចិត្តឱ្យទូលាយ និងការរក្សាភាពសម្ងាត់វិជ្ជាជីវៈ។

## ការសួរសំណួរ ជួយសិស្សឱ្យស្វែងរកជម្រើស




បើអ្នកមិនដឹងថាត្រូវចាប់ផ្តើមនៅទីណា ចូរឱ្យសិស្សនិយាយអំពីជីវិតរបស់គេ។ អ្នកក៏អាចសួរសំណួរ «តើប្អូនសុខសប្បាយជាទេ?» ឬ «តើប្អូនមានបញ្ហាប្រឈមអ្វីដែលឬទេ សម្រាប់ការសិក្សា ឬជីវិតផ្ទាល់ខ្លួន?» អ្នកនឹងអាចបង្កើតសំណួរផ្សេងទៀតបានជាបន្តបន្ទាប់ តាមអ្វីដែលសិស្សឆ្លើយមកកាន់អ្នក។

| | | |
|---|---|---|
| សុខភាព | គ្រួសារ | មិត្តភ័ក្តិ |
| សាលារៀន ការសិក្សា | សេដ្ឋកិច្ច | ចំណាប់អារម្មណ៍ |

គោលបំណងគឺ ផ្តល់ឱកាសដល់សិស្ស ដើម្បីនិយាយ និងគិតឱ្យបានច្រើន។ គាំទ្រសិស្សក្នុងការនិយាយអំពី អារម្មណ៍ខាងក្នុង ការគិត សេចក្តីប្រាថ្នា ក្តីសុបិន ភាពខ្លាំង ការភ័យខ្លាច និងបញ្ហាប្រឈមរបស់គេ។ ចូរកុំខ្លាចនឹងភាពស្ងៀមស្ងាត់ ផ្តល់ពេលឱ្យសិស្សគិត ចៀសវាង ការវិនិច្ឆ័យ និងការដាក់សម្ពាធ។ ក្នុងនាមអ្នកផ្តល់ប្រឹក្សា អ្នកអាចបង្ហាញពីការយល់ចិត្ត និងភាពស្និទ្ធស្នាល។

## ប្រភេទផ្សេងៗនៃសំណួរ

- **សំណួរបិទ៖** ចម្លើយតែមួយ បាទ/ចាស

  តើមែនទេ? តើវាឬ? តើវាអាច? តើវានឹងអាច? តើអ្នកចង់? តើអ្នកគិតថា?

  <u>សិស្សមិនចាំបាច់គិត</u> – អ្នកនឹងមិនអាចទទួលបានព័ត៌មានច្រើនទេ

- **សំណួរបើក៖** ទទួលបានព័ត៌មាន ភាពច្បាស់លាស់ និងសហការ
  របៀបណា អ្វី ពេលណា ឯណា អ្វីទៀត?
  សិស្សត្រូវគិតសម្រាប់ខ្លួនឯង – អ្នកនឹងទទួលបានព័ត៌មានច្រើន




- **សំណួរបញ្ជាក់៖** តើខ្ញុំយល់ត្រូវទេថាអ្នក......?
  តើវាពិតជាមានន័យដូចម្ដេចសម្រាប់អ្នក?
  អ្នកចង់មានន័យថា...
  សិស្សត្រូវគិតសម្រាប់ខ្លួនឯង – អ្នកនឹងទទួលបានព័ត៌មានច្រើន!
- **សំណួរផ្ដើម៖** តើអ្នកមានជម្រើសអ្វីខ្លះ? តើអ្នកអាចធ្វើអ្វីបាន? តើអ្នកអាចប្ដូរទម្លាប់របស់អ្នកដូចម្ដេច? ខ្ញុំចង់ដឹងគំនិតរបស់អ្នក? តើអ្នកអាចប្រាប់អ្វីបានទៀតអំពីវា?
  សិស្សត្រូវគិតសម្រាប់ខ្លួនឯង – អ្នកនឹងទទួលបានព័ត៌មានច្រើន
  បញ្ចប់ដោយសំណួរ: តើអ្នកមានសំណួរ ឬចង់និយាយអ្វីទៀតទេ?

## ៦. ឧបករណ៍សម្រាប់ការប្រឹក្សាទល់មុខ ( Iina Pälväjärvi ( ina.palvajarvi@gmail.com ) )

**ឈ្មោះ...................... ថ្នាក់.................... សាលា..................**

**ចូរគូសរង្វង់ជុំវិញលេខដែលបញ្ជាក់ពីជម្រើសដ៏សក្តិសមបំផុតសម្រាប់ប្អូន:**

1.មិនដែល...សោះ 2.ជូនកាល 3.ជាញឹកញាប់ 4.តែងតែ

| **១. ជីវិតប្រចាំថ្ងៃ** | | | | |
|---|---|---|---|---|
| ១.១ ខ្ញុំ..ពេញចិត្តនឹងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ... | 1 | 2 | 3 | 4 |
| *អ្វីដែលខ្ញុំយល់ថាពិបាក នៅពេលនេះគឺ* | | | | |
| ១.២. ការបរិភោគឱ្យបានទៀងទាត់ | 1 | 2 | 3 | 4 |
| ១.៣. ការណាត់ជួបដែលបានព្រមព្រៀងគ្នា និងការរៀបចំកាលវិភាគ | 1 | 2 | 3 | 4 |
| ១.៤. ការចូលគេងឱ្យទាន់ពេលវេលា | 1 | 2 | 3 | 4 |
| ១.៥. ការភ្ញាក់ពីដំណេក ដើម្បីទៅរៀន | 1 | 2 | 3 | 4 |
| ១.៦. ការថែរក្សា ឬទុកដាក់របស់របរ ដូចជាសៀវភៅមេរៀនជាដើម... | 1 | 2 | 3 | 4 |
| *តើប្រយោគខាងក្រោមនេះ ពិពណ៌នាអំពីប្អូនត្រូវបានកម្រិតណា?* | | | | |
| ១.៧. ខ្ញុំយល់ថា កន្លែងថ្មីធ្វើឱ្យមានភាពតានតឹង | 1 | 2 | 3 | 4 |
| ១.៨. ខ្ញុំយល់ថា ស្ថានភាពថ្មីធ្វើឱ្យមានភាពតានតឹង | 1 | 2 | 3 | 4 |
| ១.៩. ខ្ញុំមានការព្រួយបារម្ភអំពីការញៀនថ្នាំ (គ្រឿងស្រវឹង ថ្នាំ ។ល។) | 1 | 2 | 3 | 4 |
| ១.១០. ខ្ញុំមានការព្រួយបារម្ភអំពី ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ | 1 | 2 | 3 | 4 |
| ១.១១. ខ្ញុំមានការព្រួយបារម្ភអំពីសុខភាព | 1 | 2 | 3 | 4 |
| *តើប្អូនពេញចិត្តនឹង..................របស់ប្អូនទេ?* | | | | |

| | | | | |
|---|---|---|---|---|
| ១.១២. ... មិត្តភាព... | 1 | 2 | 3 | 4 |
| ១.១៣. ...ទំនាក់ទំនងជាមួយក្រុមគ្រួសារ... | 1 | 2 | 3 | 4 |
| *ខ្ញុំយល់ថា...* | | | | |
| ១.១៤. ...ការនិយាយទៅកាន់មនុស្សជារឿងលំបាក | 1 | 2 | 3 | 4 |
| ១.១៥. ...ការបង្កើតមិត្តថ្មីជារឿងលំបាក | 1 | 2 | 3 | 4 |
| ១.១៦. ...ការរក្សាទំនាក់ទំនងជាមួយអ្នកដទៃជារឿងលំបាក | 1 | 2 | 3 | 4 |
| ១.១៧. ...ការជួបជាមួយមនុស្សថ្មី មានភាពតានតឹង | 1 | 2 | 3 | 4 |
| *ពេលនេះ ខ្ញុំគិត / មានអារម្មណ៍ថា...* | | | | |
| ១.១៨. គ្រួសារ និងមិត្តភក្តិរបស់ខ្ញុំ... មិនចាប់អារម្មណ៍លើព័ត៌មានរបស់ខ្ញុំទេ | 1 | 2 | 3 | 4 |
| ១.១៩. ខ្ញុំមិនដឹងទៅពឹងអ្នកណាឱ្យជួយទេ | 1 | 2 | 3 | 4 |
| ១.២០. គ្មានមនុស្សណាចូលចិត្តខ្ញុំទេ | 1 | 2 | 3 | 4 |
| ១.២១. ខ្ញុំឯកាខ្លាំងណាស់ | 1 | 2 | 3 | 4 |
| ១.២២. ភាពលំបាកនៅផ្ទះ ( ឪពុកម្ដាយ អ្នកថែរក្សា បងប្អូន) រំខានការសិក្សារបស់ខ្ញុំ | 1 | 2 | 3 | 4 |
| ១.២៣. ភាពលំបាកក្នុងការទាក់ទង (មិត្តភក្តិ ទំនាក់ទំនងផ្ទាល់ខ្លួន) រំខានការសិក្សារបស់ខ្ញុំ | 1 | 2 | 3 | 4 |
| ១.២៤. ការសម្លុត រំខានការសិក្សារបស់ខ្ញុំ | 1 | 2 | 3 | 4 |
| **២. អារម្មណ៍** | | | | |
| ២.១ ខ្ញុំកើតទុក្ខ | 1 | 2 | 3 | 4 |
| ២.២. ខ្ញុំមិនសប្បាយ និងសៅហ្មងក្នុងចិត្តជាខ្លាំង | 1 | 2 | 3 | 4 |

| | | | | |
|---|---|---|---|---|
| ២.៣. ខ្ញុំមិនស្ងប់ចិត្ត (វសាប់វសល់) ដោយគ្មានហេតុផល | 1 | 2 | 3 | 4 |
| ២.៤ ខ្ញុំអន្ទះសារ | 1 | 2 | 3 | 4 |
| ២.៥. ខ្ញុំគ្មានសង្ឃឹមនឹងអនាគតទេ | 1 | 2 | 3 | 4 |
| **៣. ការសិក្សា** | | | | |
| ៣.១. ខ្ញុំពេញចិត្តនឹងការសិក្សារបស់ខ្ញុំ | 1 | 2 | 3 | 4 |
| ៣.២. ការចាប់ផ្តើមកិច្ចការពិតជាពិបាកសម្រាប់ខ្ញុំ | 1 | 2 | 3 | 4 |
| ៣.៣. បើសិនជាមានរឿងអ្វីពិបាកពេកសម្រាប់ខ្ញុំ ខ្ញុំធ្វើអ្វីផ្សេងជំនួសវិញ | 1 | 2 | 3 | 4 |
| ៣.៤. ខ្ញុំពិបាកសុំជំនួយពីគ្រូរបស់ខ្ញុំ | 1 | 2 | 3 | 4 |
| ៣.៥. ខ្ញុំមិនយល់ការណែនាំរបស់គ្រូទេ | 1 | 2 | 3 | 4 |
| ៣.៦. ខ្ញុំពិបាកផ្តោតអារម្មណ៍លើពាក្យពេចន៍របស់គ្រូ | 1 | 2 | 3 | 4 |
| ៣.៧. ខ្ញុំពិបាកអង្គុយស្ងៀមក្នុងថ្នាក់រៀន | 1 | 2 | 3 | 4 |
| ៣.៨. ខ្ញុំពិបាកធ្វើការងារជាក្រុម | 1 | 2 | 3 | 4 |
| *ខ្ញុំយល់ព្រមថា...* | | | | |
| ៣.៩. ការសិក្សាមានសារៈសំខាន់សម្រាប់ខ្ញុំ | 1 | 2 | 3 | 4 |
| ៣.១០. ខ្ញុំរំភើបនឹងការសិក្សារបស់ខ្ញុំ | 1 | 2 | 3 | 4 |
| ៣.១១. ខ្ញុំសម្រេចបាននូវគោលដៅក្នុងជីវិតដោយសារការសិក្សា | 1 | 2 | 3 | 4 |
| ៣.១២. ខ្ញុំនឹងត្រូវការអ្វីដែលខ្ញុំបានរៀនសូត្រទៅបម្រើការងារ និងជីវិតរបស់ខ្ញុំ | 1 | 2 | 3 | 4 |
| **៤. ការគ្រប់គ្រងជីវភាពទូទៅរបស់ប្អូន** | | | | |
| ៤.១.ខ្ញុំពេញចិត្តនឹងការគ្រប់គ្រងជីវិតរបស់ខ្ញុំ | 1 | 2 | 3 | 4 |

| | | | | |
|---|---|---|---|---|
| ៤.២. ខ្ញុំអាចធ្វើឱ្យមានភាពជោគជ័យដោយខ្លួនឯងបាន | 1 | 2 | 3 | 4 |
| ៤.៣. ខ្ញុំអាចគ្រប់គ្រងភាពលំបាកច្រើនយ៉ាងបាន | 1 | 2 | 3 | 4 |
| ៤.៤. ជីវិតរបស់ខ្ញុំមានគោលដៅច្បាស់លាស់ | 1 | 2 | 3 | 4 |
| **៥. ខ្លួនឯង** | | | | |
| ៥.១. ខ្ញុំពេញចិត្តនឹងខ្លួនឯង | 1 | 2 | 3 | 4 |
| ៥.២. ខ្ញុំសម្រេចបាននូវរឿងសំខាន់ៗក្នុងជីវិត | 1 | 2 | 3 | 4 |
| ៥.៣. ខ្ញុំមានគុណសម្បត្តិល្អៗជាច្រើន | 1 | 2 | 3 | 4 |
| ៥.៤. ខ្ញុំមានតម្លៃ | 1 | 2 | 3 | 4 |
| *ចំពោះការជ្រើសយកជម្រើសទាំងនេះ ខ្ញុំមានអារម្មណ៍ថា....* | | | | |
| ៥.៥. មានភាពងាយស្រួល | 1 | 2 | 3 | 4 |
| ៥.៦. មានភាពលំបាកខ្លាំងណាស់ | 1 | 2 | 3 | 4 |
| ៥.៧. វាច្រើនពេកសម្រាប់ខ្ញុំ | 1 | 2 | 3 | 4 |

សូមអរគុណចំពោះជម្រើសរបស់ប្អូន!

## ៧. មគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន

### ចូរផ្ដល់ពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យសិស្សស្គាល់ខ្លួនឯងកាន់តែច្បាស់

ចូរធ្វើឱ្យការងារនៃមគ្គុទ្ទេសក៍ក្នុងថ្នាក់របស់អ្នកប្រសើរឡើង។ នេះជាមុខវិជ្ជាដែលមិនមានពិន្ទុ និងការដាក់សម្ពាធលើការសិក្សាទេ។ ប្រើវិធីដែលសិស្សអាចធ្វើការងារជាក្រុមតូច ដើម្បីឱ្យពួកគេអាចបណ្ដុះសមត្ថភាពក្នុងការនិយាយអំពីខ្លួនឯង។ ចូរផ្ដល់ការគាំទ្រដល់ពួកគេក្នុងការប្រឈមនឹងស្ថានភាព និងប្រាប់សមាជិកក្រុមផ្សេងទៀតអំពីអារម្មណ៍ ក្ដីសុបិន សេចក្ដីប្រាថ្នា ភាពខ្លាំង និងបញ្ហាប្រឈម។ ប្រាប់សិស្សឱ្យដឹងផង អំពីរបៀបនៃការប្រើប្រាស់ភាពខ្លាំងរបស់គេ ក្នុងជីវិតប្រចាំថ្ងៃ ការសិក្សា ជម្រើសអាជីព និងជីវិតការងារ។ ជួយសមាជិកឱ្យបង្កើតសំណួរ ដើម្បីសួរគ្នា ហើយឆ្លុះបញ្ចាំងពីស្ថានភាពផ្ទាល់ខ្លួនរបស់គេ។ វិធីនេះក៏អាចជួយសិស្សឱ្យបានត្រៀម ដើម្បីជជែកជាមួយអ្នកនៅពេលមានការប្រឹក្សាទល់មុខ។

អ្នកក៏អាចប្រើឧបករណ៍ផ្សេងទៀត ដើម្បីប្រមូលទិន្នន័យអំពីប្រភេទសំណួរទាក់ទងនឹងក្ដីបារម្ភនាពេលអនាគតរបស់សិស្ស និងប្រភេទនៃព័ត៌មានដែលសិស្សចង់បាន។ អ្នកអាចប្រើកម្រងសំណួរ ឬប្រាប់សិស្សឱ្យប្រគល់សំណួរដល់អ្នក។ បើសិនជាអ្នកដឹងពីតម្រូវការរបស់សិស្ស អ្នកអាចផ្ដល់ព័ត៌មានទូទៅនៅក្នុងថ្នាក់រៀន។ នេះជាវិធីសន្សំពេលវេលាសម្រាប់ការប្រឹក្សាទល់មុខ។ អ្នកអាចបន្តការសួរ ថាតើសិស្សនឹងប្រើសំណួរដែលប្រគល់ឱ្យនោះដោយរបៀបណា។ អ្នកក៏អាចណាត់ឱ្យសិស្សមកជួបប្រឹក្សាទល់មុខជាក្រុមដែលមានសមាជិក ៣ ទៅ ៤ នាក់បានដែរ។ ពេលនោះសេវាប្រឹក្សាទល់មុខនេះ មានលក្ខណៈក្រៅផ្លូវការបន្តិច មិនមែនលក្ខណៈបុគ្គលឡើយ ប៉ុន្តែអ្នកអាចគាំទ្រសិស្ស ក្នុងការបញ្ចេញគំនិត និងដំណោះស្រាយ ដើម្បីឱ្យពួកគេអាចធ្វើសកម្មភាពនៅពេលសមស្របណាមួយ។

## សន្លឹកកិច្ចការសម្រាប់ការប្រឹក្សាទល់មុខ

ឈ្មោះ:______________________ កាលបរិច្ឆេទ______________________

ថ្នាក់______________________ គ្រូប្រឹក្សាអាជីព ______________________

| រឿងល្អៗក្នុងជីវិតរបស់ខ្ញុំ | បញ្ហាប្រឈមក្នុងជីវិតរបស់ខ្ញុំ |
|---|---|
| រឿងល្អៗក្នុងការសិក្សារបស់ខ្ញុំ | បញ្ហាប្រឈមក្នុងការសិក្សារបស់ខ្ញុំ |

គោលបំណងក្នុងការសិក្សារបស់ខ្ញុំមាន:

______________________________________________________________

______________________________________________________________

______________________________________________________________

ខ្ញុំត្រូវការជំនួយទាក់ទងរឿងនេះ

______________________________________________________________

______________________________________________________________

______________________________________________________________

ខ្ញុំមានសំណួរអំពីការសិក្សា និងអនាគតរបស់ខ្ញុំ:

______________________________________________________________

______________________________________________________________

______________________________________________________________



| ភាពខ្លាំងរបស់ខ្ញុំ | នេះជាអ្វីដែលខ្ញុំអាចធ្វើបាន |
|---|---|
| 1.<br><br>2.<br><br>3.<br><br>4.<br><br>5. | |

# សៀវភៅកត់ត្រា

នៅក្នុងការងារប្រឹក្សាទល់មុខ គ្រូត្រូវប្រើសៀវភៅសម្រាប់កត់ត្រា។ គ្រូប្រឹក្សាគួរធ្វើការកត់ត្រាព័ត៌មានរបស់សិស្សគ្រប់រូប។ កំណត់ត្រាដ៏សំខាន់បំផុតគឺ គោលដៅ និងសកម្មភាពដែលសិស្សសម្រេចចិត្តធ្វើ។ គ្រូប្រឹក្សាត្រូវការកំណត់ត្រា ដើម្បីធ្វើការតាមដានសិស្ស នៅពេលជួបសិស្សលើកក្រោយទៀត។ ជួនកាល គ្រូប្រឹក្សាត្រូវការកំណត់ត្រានេះ នៅពេលជួបជាមួយគ្រូផ្សេងទៀត ឬអាណាព្យាបាលសិស្ស។ ចូរចងចាំនូវភាពសម្ងាត់នៃជីវិតផ្ទាល់ខ្លួនរបស់សិស្ស។ ការណែនាំដ៏ល្អគឺត្រូវសួរសិស្សថាតើពួកគេអនុញ្ញាតឱ្យអ្នកនិយាយអំពីរឿងរ៉ាវ ដែលពួកគេបានប្រាប់អ្នកដែរឬទេ។

## ការសិក្សាផ្សារភ្ជាប់ជាមួយការអនុវត្តន៍ __ ការឆ្លុះបញ្ចាំងអំពីខ្លួនឯង

> We do not learn from experience... we learn from reflecting on experience.
>
> - John Dewey

អ្នកត្រូវការរៀនសូត្រអំពីការងារនេះ ដោយការអនុវត្ត (25% - 75%)។ ចូរបន្តការពង្រឹងសមត្ថភាពរបស់អ្នក។ បទពិសោធន៍ដែលគ្មានការឆ្លុះបញ្ចាំងគឺ មិនមែនជាបទពិសោធន៍ទេ។ សំណួរដែលអ្នកអាចសួរខ្លួនឯងបានគឺ៖ តើអ្នកបានរៀនសូត្រអ្វីខ្លះពេលនេះ? តើអ្នកមានអារម្មណ៍ដូចម្តេច? តើមានអ្វីដែលល្អ? តើខ្ញុំអាចធ្វើអ្វីបានប្រសើរជាងនេះ? តើខ្ញុំបានទទួលដំបូន្មានច្រើនទេ ឬខ្ញុំបានបង្កើតសំណួរទេ? តើខ្ញុំអ្នកបានស្តាប់សិស្សទេ? តើព័ត៌មានអ្វីខ្លះដែលខ្ញុំទទួលបាន? តើខ្ញុំបានបង្កើតសំណួរ ដែលផ្តល់ការគាំទ្រដល់សិស្ស ដើម្បីរកឃើញនូវជម្រើស ព្រមទាំងដំណោះស្រាយដែរទេ?

តើខ្ញុំត្រូវការជំនួយ និងការគាំទ្រពីអ្នកផ្សេងដែរឬទេ? នរណាអាចជួយខ្ញុំបាន? តើមាននរណាអាចផ្តល់ដំបូន្មានដល់ខ្ញុំបានទេ? តើខ្ញុំគួរថតវីឌីអូអំពីការប្រឹក្សាទល់មុខរបស់ខ្ញុំ នៅពេលក្រោយបានទេ? ក្រោយពីអ្នកបានឆ្លុះបញ្ចាំងអំពីជំនាញនៃការផ្តល់ប្រឹក្សា ការងារ និងអានឯកសារនេះ ដល់ពេលដែលអ្នករៀបចំផែនការសកម្មភាពហើយ។ អ្នកនឹងធ្វើអ្វី? តើអ្នកត្រូវដើរតាមជំហានណាខ្លះ ដើម្បីឱ្យការងាររបស់អ្នក មានភាពរីកចម្រើន?

1. ____________________________________________________________
2. ____________________________________________________________
3. ____________________________________________________________
4. ____________________________________________________________
5. ____________________________________________________________
6. ____________________________________________________________

**សូមសំណាងល្អចូរមានដល់ការងារដ៏មានតម្លៃរបស់អ្នក!**
**អ្នកមិនអាចជួយមនុស្សគ្រប់រូបបានទេ ប៉ុន្តែអ្នកអាចជួយមនុស្សម្នាក់ ឬសិស្សមួយចំនួនបាន ជារៀងរាល់ថ្ងៃ!**

## ៨. កម្មវិធីជួបជុំមាតាបិតា




### ហេតុអ្វីបានជាការអញ្ជើញមាតាបិតាមកសាលារៀនមានសារៈសំខាន់ ?
### ដើម្បីលើកទឹកចិត្ត និងផ្តល់ការគាំទ្រដល់សិស្ស និងទប់ស្កាត់ការបោះបង់

**បញ្ហាប្រឈម**

*មាតាបិតាមិនគាំទ្រការសិក្សារបស់សិស្ស។ មាតាបិតាមិនសូវមានចំណាប់អារម្មណ៍លើការសិក្សារបស់កូន ដោយសារតែស្ថានភាពរស់នៅលំបាក។ គ្មានការចូលរួមពីមាតាបិតា ដោយពួកគាត់គិតថានេះ ជាការងាររបស់គ្រូប្រឹក្សានៅសាលារៀន។ ឪពុកម្តាយមានការយល់ដឹងតិចតួចអំពីការងារប្រឹក្សាអាជីពនៅតាមសាលារៀន ពិសេសជម្រើសនៃការអប់រំបន្តរបស់កូនៗពួកគាត់ និងស្ថានភាពព័ត៌មានទីផ្សារការងារ។*

*មាតាបិតាសិស្សក៏ត្រូវគេយល់ឃើញថា ជាអ្នកមានភារៈកិច្ចក្នុងរឿងនេះដែរ។ ដើម្បីបង្កើនប្រាក់ចំណូលដល់ក្រុមគ្រួសារ ឪពុកម្តាយជាញឹកញាប់មិនឱ្យកូនមកបង្ហាញមុខក្នុងថ្នាក់រៀន ហើយឈប់ឱ្យទៅរៀន ដើម្បីជួយធ្វើស្រែ ឃ្វាលគោ ឬធ្វើទេសន្តរប្រវេសន៍ទៅប្រទេសផ្សេងៗ ឬធ្វើការក្នុងរោងចក្រនៅប្រទេសកម្ពុជា។*

*ការអញ្ជើញមាតាបិតាឱ្យចូលរួមប្រជុំ ចែករំលែកព័ត៌មាន និងតស៊ូមតិជាមួយគ្នា នឹងទទួលបាននូវការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីធានាថាមាតាបិតាពិតជាមានការគាំទ្រដល់កូនក្នុងការបន្តការសិក្សា។*

*បើសិនមាតាបិតាមានទំនុកចិត្ត និងការយល់ដឹងអំពីការអប់រំ ពួកគាត់នឹងបញ្ជូនកូនមកសាលារៀន ផ្តល់ការលើកទឹកចិត្ត និងគាំទ្រកូនៗបានល្អជាងមុន។ នៅពេលមាតាបិតាគាំទ្រលោកគ្រូអ្នកគ្រូ កម្លាំងចិត្ត*



*និងលទ្ធផលសិក្សារបស់សិស្សប្រាកដជាប្រសើរឡើង។ តាមរយៈការជួបជុំជាមួយមាតាបិតា និងការផលិតសម្ភារៈព័ត៌មាន យើងក៏អាចបង្កើនសមត្ថភាពយល់ដឹងរបស់មាតិបិតាដើម្បីគាំទ្រកូនៗក្នុងការជ្រើសផ្លូវសិក្សា និងអាជីពរបស់ពួកគេដែរ។ នៅពេលមាតាបិតាយល់ដឹងនូវសារៈសំខាន់នៃការអប់រំ ការបោះបង់ការសិក្សារបស់សិស្ស នឹងមានការថយចុះ។*

*ក្នុងនាមគ្រូប្រឹក្សាអាជីព អ្នកប្រហែលជាអាចធ្វើកិច្ចព្រមព្រៀងរវាងផ្ទះ និងសាលារៀនបានដែរ។ នេះជាការបង្ហាញពីក្ដីរំពឹងទុករបស់កូន មាតាបិតា និងរបៀបនៃការរិះរកវិធីសាស្ត្របង្រៀន និងការរៀនសូត្រ។ ដូចនេះ ការជួបជុំជាមួយមាតាបិតា ជាព្រឹត្តិការណ៍ដ៏ល្អក្នុងការជជែកអំពីរឿងហ្នឹង។*

# តើអត្ថប្រយោជន៍នៃការជួបជុំមាតាបិតាមានអ្វីខ្លះ?

## ទស្សនៈរបស់មាតាបិតា

- ✓ អ្នកអាចមើលឃើញសាលា បន្ទប់រៀន និងបរិវេណសាលារៀន
- ✓ អ្នកអាចទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងការអប់រំ និងទីផ្សារការងារ
- ✓ អ្នកអាចពិភាក្សាអំពីអ្វីដែលកូនកំពុងធ្វើនៅក្នុងសាលារៀន
- ✓ អ្នកអាចចូលរួមបានល្អក្នុងការរៀនសូត្ររបស់កូន
- ✓ អ្នកអាចគាំទ្រកូនបានល្អជាងមុន
- ✓ អ្នកអាចសួរសំណួរ និងចែករំលែកព័ត៌មានអំពីកូន សាលារៀននឹងផ្តល់តម្លៃដល់ទស្សនៈរបស់អ្នក
- ✓ អ្នកអាចជ្រើសយកយោបល់ជាក់ស្តែងអំពីរបៀបដែលអ្នកអាចជួយកូននៅផ្ទះបាន
- ✓ អ្នកអាចបង្ហាញកូនថា អ្នកមានចំណាប់អារម្មណ៍លើការសិក្សារបស់កូន

## ទស្សនៈរបស់សិស្ស

- ✓ ឪពុកម្តាយរបស់ខ្ញុំ មានចំណាប់អារម្មណ៍លើការសិក្សារបស់ខ្ញុំ
- ✓ ពួកគាត់យល់ពីស្ថានភាពរបស់ខ្ញុំ
- ✓ ពួកគាត់អាចគាំទ្រខ្ញុំ ក្នុងការសិក្សា និងជម្រើសអាជីពរបស់ខ្ញុំ
- ✓ ការគាំទ្ររបស់ពួកគាត់ផ្តល់កម្លាំងចិត្ត ហើយលទ្ធផលសិក្សារបស់ខ្ញុំកាន់តែប្រសើរ
- ✓ យើងអាចជជែកអំពីការសិក្សានៅផ្ទះបាន
- ✓ ពួកគាត់ដឹងពីបញ្ហាប្រឈមរបស់ខ្ញុំ

## ទស្សនៈរបស់សាលា

- ✓ អាចជួប និងស្គាល់មាតាបិតា
- ✓ អាចទទួលបានព័ត៌មានច្រើនអំពីសិស្ស
- ✓ អាចចែករំលែកព័ត៌មានអំពីលទ្ធភាពនៃការអប់រំបន្ត និងទីផ្សារការងារ
- ✓ អាចសុំការគាំទ្រពីឪពុកម្តាយ

**«កិច្ចសហការណ៍រវាងមាតាបិតា និងគ្រូ នាំមកនូវភាពប្រសើរបំផុតដល់កូន»**

## ការស្គាល់អ្នកចូលរួមកម្មវិធី

មាតាបិតាទាំងអស់ចង់បានភាពប្រសើរបំផុតសម្រាប់កូន។ ពួកគាត់ចង់ទទួលអារម្មណ៍ថា គេកំពុងមានការយកចិត្តទុកដាក់ខ្ពស់ចំពោះកូន ហើយថាអ្នកដឹងនូវរឿងរ៉ាវ ចូលចិត្តពួកគេ និងដឹងនូវអ្វីដែលអ្នកកំពុងនិយាយ!

### *មាតាបិតាអាចមានសំណួរដូចជា៖*

- ○ តើកូនរបស់ខ្ញុំពូកែខាងអ្វី?
- ○ តើកូនរបស់ខ្ញុំត្រូវការជំនួយអ្វី?
- ○ តើយើងអាចជួយកូននៅផ្ទះដោយរបៀបណា?
- ○ តើកូនខ្ញុំអាចធ្វើអ្វីបាន ដើម្បីជួយខ្លួនឯង?
- ○ តើពួកគេកំពុងរៀនអ្វី ហើយត្រូវការកម្រិតយល់ដឹងបែបណាចំពោះរឿងហ្នឹង?

- ○ តើកូនរបស់ខ្ញុំចូលចំណោមគេចុះទេ?
- ○ តើកូនរបស់ខ្ញុំសួរសំណួរ ឬចូលរួមការពិភាក្សាក្នុងថ្នាក់ដែរឬទេ?

មាតាបិតាចង់ដឹងថា តើការរៀនសូត្ររបស់កូនដូចម្តេចដែរ មិនមែនចង់ដឹងអំពីអ្វីដែលមាននៅក្នុងកម្មវិធីសិក្សាឡើយ។ ចូរចៀសវាងការនិយាយច្រើន បញ្ហាតែងកើតមានជាធម្មតា ប៉ុន្តែវាមិនមែនជារឿងចម្បងទេ ដូចនេះចូររក្សាបរិយាកាសវិជ្ជមាន។ ចូរយកចិត្តទុកដាក់ខ្ពស់ចំពោះមាតាបិតាសិស្ស ស្តាប់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលពួកគាត់និយាយ តាមដាននូវទុក្ខកង្វល់ដែលពួកគាត់មាន ចូរធ្វើតាមការសន្យារបស់អ្នក។ បើមានពេលសមរម្យណាមួយ ចូរប្រាប់សិស្សដែលមានបញ្ហាសំខាន់ៗឱ្យមកជជែកជាមួយក្រុមការងារដែលមានបទពិសោធន៍ច្រើនជាងអ្នក។

## កាលបរិច្ឆេទ និងពេលវេលា

ការជួបជុំមាតាបិតា គួរតែជាផ្នែកនៃផែនការសកម្មភាពប្រចាំឆ្នាំ សម្រាប់សាលារៀនរបស់អ្នក។ គោលបំណងគឺ ត្រូវជួបជាមួយមាតាបិតាយ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយឆ្នាំសិក្សា។ ព័ត៌មានត្រឡប់បានពីការជួបជុំបង្ហាញថា មាតាបិតាចង់ឃើញកម្មវិធីជួបជុំច្រើនជាងម្តងក្នុងមួយឆ្នាំសិក្សា។ អ្នកក៏អាចជួបជាមួយមាតាបិតាជាក្រុមតូចបានដែរ ឧទាហរណ៍ជួបជាមួយមាតាបិតារបស់សិស្សមួយថ្នាក់ម្តង។

នៅពេលអ្នកមានកាលបរិច្ឆេទសម្រាប់ការជួបជុំ ចូរមកឱ្យទាន់ពេលវេលាដែលបានកំណត់ក្នុងលិខិតអញ្ជើញរបស់មាតាបិតា។ ព័ត៌មានគួរនិយាយអំពីរបៀបវារៈ និងប្រធានបទសំខាន់ៗសម្រាប់ព្រឹត្តិការណ៍ និងផ្តល់ព័ត៌មានទាក់ទងនឹងអ្នកដែលត្រូវចូលរួម ដែលមកពីសាលារៀន និងសហគមន៍ផ្សេងៗ។ ការស្នើឱ្យមាតាបិតារៀបចំសំណួរសម្រាប់សួរនៅពេលពួកគាត់ចូលរួមក្នុងកម្មវិធីជួបជុំ ជាគំនិតមួយដ៏ល្អ។

## របៀបវារៈ និងប្រធានបទ

ជាការល្អ គឺពិភាក្សាជាមួយមិត្តរួមការងារនូវប្រភេទព័ត៌មានដែលអ្នកចង់ផ្តល់ឱ្យមាតាបិតាសិស្ស។ មតិសំណេះសំណាលរបស់នាយកសាលា តែងមានតម្លៃសម្រាប់កម្មវិធីនេះ។ តើខ្លួនអ្នកផ្ទាល់អាចផ្តល់ព័ត៌មាន ឬត្រូវការជំនួយពីខាងក្រៅសាលាដែរ ឬទេ? តើអ្នកអាចសហការជាមួយមជ្ឈមណ្ឌលការងារ ឬវិស័យឯកជនឬទេ? តើមានពេលវេលាគ្រប់គ្រាន់សម្រាប់ការសាកសួរ និងការជួបជុំជាមួយមាតាបិតាដែរទេ?

## ប្រធានបទល្អៗមាន៖

- ✓ តើមាតាបិតាលើកទឹកចិត្ត និងគាំទ្រកូនដោយរបៀបណា?
- ✓ តើមាតាបិតាអាចរៀបចំពេលវេលា និងកាលវិភាគ ដើម្បីឱ្យមានពេលសម្រាប់ធ្វើកិច្ចការផ្ទះ និងការងារដែលត្រូវធ្វើនៅផ្ទះទេ?
- ✓ ចូរប្រាប់មាតាបិតាពីតម្លៃនៃការអប់រំដ៏ល្អថា ជាការវិនិយោគសម្រាប់អនាគតរបស់កូន
- ✓ ការអប់រំដ៏ល្អផ្តល់នូវឱកាសការងារ
- ✓ តើប្រភេទនៃការអប់រំ មុខរបរបែបណាដែលត្រូវការនាពេលអនាគត?
- ✓ តើទីផ្សារការងារក្នុងតំបន់មានលក្ខណៈដូចម្តេច?


សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍
ភាសាបរទេស
ពលរដ្ឋ
ពេញលេញ

EMPOWERING PEOPLE THROUGH PEACE, QUALITY EDUCATION AND LIVELIHOODS.

FCA Finn Church Aid

actalliance